ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី២៤ ខែកក្កដា លេខ ៧

ព.ស. ២៤៩៥ – គ.ស. ១៩៥២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — *ទំព័រ*


ពន្លឺអាស៊ីទ្វីប (ត—ចប់) .......... លោកវ៉ាយ - ប៊ុក .......... ៤៨៣

បញ្ញាវុឌ្ឍិកថា .................. ព្រះមហា សុខ — វន់ ........ ៤៨៨

អត្តានុទិដ្ឋិ (ត—ចប់)............. ឧកញ៉ា សំ - ស៊ុន ........ ៥០១


*ផ្នែកអក្សរសាស្ត្រ*


ការបណ្ដុះនិស្ស័យ (តមក)........ ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម ... ៥០៩

រឿងសាមកុក (តមក)........... ឧកញ៉ា ទួ - កន .......... ៥១៩

រឿងអាក្យថ្លែងរឿងម្ភៃប្រាំ (តមក).... លោក វ៉ាយ - ប៊ុក.......... ៥៣១

រឿងស្នេហាជាតិ (តមក).......... លោក គង់ - លឹម.......... ៥៣៧

រឿងប៉ូលនឹងវីរ៉ស៊ីនី (តមក)......... លោក ដេង - ជ្រីវ ........ ៥៤៥


*កំណត់នីងប្រវត្តិការណ៍*


ពិធីបើកសាលាធម្មវិន័យ នៅវត្តរាជបូរណ៌

ខែត្រសៀមរាប.................. ព្រះអាចារ្យ ស៊ុន — ស៊ាន .... ៥៥៥

បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក). ក្រសួងធម្មការ .........., ៥៥៨



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៨៣រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES


### PARTIE RELIGIEUSE

| | | Pages |
|---|---|---|
| La lumière de l'Asie (suite et fin) | *M. Ray-Buc* . . . . . . . . . . | 483 |
| Pannavuddhikathâ . . . . . . . . . . . . | *Vén. Sok-Vonn* . . . . . . . . . . | 488 |
| Attânuditthikathâ (suite et fin). . . | *Oknha Sam-Sun* . . . . . . . . | 501 |

### PARTIE LITTERAIRE

| | | |
|---|---|---|
| Education morale (suite). . . . . . . . | *Vén. Pœung - Pam* . . . . . . . | 509 |
| Histoire de SAMKOK (suite) . . . . | *Oknha Nou - Kan* . . . . . . . | 519 |
| Les vingt cinq récits du Mauvais Génie (suite) . . . . . . . . . . . . . . . . . | *M. Ray-Buc* . . . . . . . . . . | 531 |
| L'Amour de la Patrie (suite) . . . . | *M. Kong-Lim* . . . . . . . . . . | 537 |
| Paul & Virginie (suite) . . . . . . . . | *M. Phéng-Chrieu* . . . . . . . . | 545 |

### NOTES ET CHRONIQUES

| | | |
|---|---|---|
| Cérémonies religieuses de l'ouverture de l'École de Dhammavinaya à Vat Reach-Bor Siemreap . . . . . | *Vén. Sun-Sean*. . . . . . . . . | 555 |
| Nomination des nouveaux Chauadhikar (suite) . . . . . . . . . . . . . | *Ministère des Cultes* . . . . . . . . . | 558 |


Prix d'abonnement annuel comprenant (12 numéros:) 183$00

ពន្លឺអាស៊ីទ្វីប

វគ្គទី ៨

*លោក ស៊ែរ-អេតវីន អារណូលត៍ តែង*

# លោករ៉ាយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ ប្រែរៀបរៀង

(តចប់)

---

*មានមួយថ្ងៃ ពេលបុព្វណ្ហសម័យ តថាគតបានទៅឃើញនាយត្រកូល (គ្រួសារ) ឈ្មោះសិង្គាលៈ កំពុងងូតទឹក ហើយសំដែងគារវភាពចំពោះផែនដី មេឃនឹងទិសទាំងបួន ហើយយកដៃបាចនូវអង្ករក្រហមស ៗ តថាគតសួរថា ម្នាលមាណព! អ្នកឱនក្បាលធ្វើអ្វី? ៗ សិង្គាលៈក្រាបទូលថា ខ្ញុំព្រះអង្គដែលធ្វើយ៉ាងនេះ គឺធ្វើតាមប្រពៃណីនៃបិតាដែលបានបង្ហាត់បង្រៀនខ្ញុំព្រះអង្គថា ក្នុងពេលជិតព្រះអរុណរះ មុននឹងចាប់ផ្ដើមការបំពេញកិច្ចទាំងពួងត្រូវដេញសេចក្ដីឧបទ្រពចេញ ដែលមកពីមេឃផែនដីដែលនៅក្រោមបាតជើងយើង ព្រមទាំងរាំយោបក់បោកគ្រប់ទិសានុទិស ៗ តថាគតតបថា កុំឲ្យរាយគ្រាប់អង្ករពាសពេញ តែត្រូវយកចិន្ដានឹងសកម្មភាព ព្រហ្មវិហារផ្សាយទៅអ្នកទាំងអស់គ្នា ទៅបិតាមាតា ដោយក្រឡេកទៅទិសខាងកើត ដែលជាបុព្វហេតុនៃស្នេហ, ទៅគ្រូបាធ្យាយដោយក្រឡេកទៅទិសខាងត្បូង ដែលជាបុព្វហេតុនៃសិរីវត្ថុដ៏ឧត្ដម, ទៅភរិយានឹងបុត្រាបុត្រី ដោយក្រឡេកទៅទិសខាងលិច*

ដែលមានមេឃប្រកបដោយពណ៌សំបុរខ្ចី ហើយដែលជាទិសព្រះសុរិយាអស្តង្គត, ទៅពួកមិត្តញាតិសាលោហិត អ្នកជិតខាងនឹងមនុស្សទាំងអស់ ដោយក្រឡេកទៅទិសខាងជើង, ទៅសាមញ្ញសត្វដោយឱនក្បាលទៅកាន់ដី, ទៅពួកសទ្ធបុគ្គល ទេវតានឹងពួកបេតបុគ្គល ដោយក្រឡេកទៅរកមេឃ, ដោយហេតុនេះហើយ បានជាអពមង្គលទាំងឡាយបៀសចេញឆ្ងាយ ហើយអ្នកឯងឈ្មោះថាគោរពទិសសំខាន់ទាំងប្រាំមួយ ។

ចំណែកខាងពួកគ្រងចីពរលឿង ដូចជាសត្វឥន្ទ្រីយ ក្រាក់ពីព្រលឹមឡើង ហើយចាកចេញដោយស្អប់ខ្ពើមពន់ពេក ពីជ្រោះទាបនៃជីវភាពទៅកាន់ព្រះសុរិយាខ្ពស់ ចំពោះពួកនេះដែលព្រះអង្គបានទេសនានូវបទបញ្ញត្តិទាំង ១០ ប្រការ (សីល ១០) ។ ព្រះសម្មាសម្ពុទ្ធមានបន្ទូលថា តាមស្រាវជ្រាវនូវទ្វារបីនឹងចិន្តាបីយ៉ាង ស្ថានភាពចិត្តប្រាំមួយៗយ៉ាង អានុភាពប្រាំៗយ៉ាង ទ្វារធំប្រាំបីនៃវិសុទ្ធិ, សភាពប្រាជ្ញា, ឥទ្ធិ, ឧបេក្ខា, សមាធិ សំខាន់ប្រាំយ៉ាង ដែលជាអាហារមានឱជារសជាងទឹកអម្រឹត ចំពោះពួកសទ្ធបុគ្គល, ឈាននឹងរត្នបីយ៉ាង ។ ព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មានតទៅទៀតចំពោះពួកនេះ តើនឹងសង់គេហដ្ឋានបែបយ៉ាងណា ត្រូវរស់នៅយ៉ាងណា ដោយសេរី, ឆ្ងាយពីអន្ទាក់តណ្ហានឹងគ្រឿងអាមិស ត្រូវបរិភោគបាយទឹកនឹងត្រូវពាក់នូវ ស្បង់ ចីពរ សង្ឃាដី ទាំងចីពណ៌លឿងដេរភ្ជាប់គ្នា, ស្នាក់នៅទទេ, អុតត្រខុត ១ បាត្រ ១ តម្រងទឹក ១ ។

ព្រះអង្គទ្រង់បានស្ថាបនានូវព្រះសង្ឃឲ្យមានសភាពមួនមាំ, គណៈប្រសើរ ដែលគ្រងស្បង់លឿង ដែលស្ថិតនៅលុះសព្វថ្ងៃ ដើម្បីនឹងស្រោចស្រង់សត្វលោក ។

ព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាពល់ក្រតី អំពីធម៌ច្រើនបែបច្រើនយ៉ាង ហើយពួកអ្នកស្ដាប់ គ្មានអ្នកណាត្អូញត្អែរថាធុញយេកសោះ ព្រោះអ្នកណាបានស្ដាប់ព្រះសម្មាសម្ពុទ្ធហើយ តែងមានចិត្តជ្រះថ្លាសប្បាយពន់ពេក កាលណាព្រះអង្គទេសនាចប់ ព្រះវរបិតាទ្រង់ក្រោកពីរាជបល្ល័ង្ក មានព្រះបាទាទទេ ឱនព្រះសិរសាទៅចំព្រះភក្ត្រព្រះរាជបុត្រ ថើបនូវជាយចីពរ ហើយមានបន្ទូលថា "ចូរកូនទទួលបិតាឲ្យនៅជាមួយផង" ។ ឯព្រះនាងយសោធរា ឥឡូវនេះមានព្រះហឫទ័យរីករាយសប្បាយពន់ពេក មានបន្ទូលថា "ឱព្រះអង្គ! សូមទ្រង់ព្រះរាជទានឲ្យទៅរាហុលកុមារនូវព្រះកេរ្តិ៍គឺព្រះពុទ្ធឱស្ឋដ៏ប្រសើរ" ។ មហាបុរសទាំងបីអង្គ គឺព្រះសម្មា-សម្ពុទ្ធ, ព្រះបិតា, ព្រះនាងពិម្ពា ទ្រង់បានស្ដេចចូលទៅកាន់ផ្លូវអដ្ឋង្គិកមគ្គហើយ ។

នៅទីនេះ ចប់សេចក្ដីពណ៌នាអំពីព្រះសម្មាសម្ពុទ្ធជាបរមគ្រូដែលខ្ញុំពេញចិត្តពន់ពេក ព្រោះព្រះអង្គមានព្រះហឫទ័យអាសូរចំពោះយើង ។ អំពីព្រះពុទ្ធប្រវត្តិ នឹងមគ្គទៅកាន់សន្តិភាព ខ្ញុំដឹងតិច ខ្ញុំក៏ពណ៌នាតិចដែរ ។ ក្នុង ៤៥ វស្សា ព្រះអង្គទ្រង់បានទេសនាពន្យល់នូវវិសុទ្ធិមគ្គ ចំពោះ

ប្រទេសជាច្រើន ដោយភាសាជាច្រើនយ៉ាង ទ្រង់បានព្រះរាជទានចំពោះ ទ្វីបអាស៊ីទាំងមូល នូវប្រទីបនេះ ដែលមានរស្មីភ្លឺចាំងចែងជានិរន្តរ៍ ដែលបានផ្សាយចេញទូទៅពិភពលោក ដោយកំសួលអានុភាពអស្ចារ្យ ។ ទាំងអស់នេះគេបានចារឹកទុកនៅក្នុងគម្ពីរ ព្រមទាំងទីកន្លែងដែលព្រះអង្គស្ដេចទៅទេសនាតាមនិគមជនបទផ្សេងៗ ហើយមានព្រះអធិរាជទ្រង់បានចាត់ឲ្យឆ្លាក់ព្រះពុទ្ធោវាទ នៅលើថ្មនិងគុហា[១] ។ រួចដល់ពេលវេលាព្រះសម្មាសម្ពុទ្ធទ្រង់ចូលកាន់ព្រះបរិនិព្វាន ដូចជាមនុស្សសាមញ្ញម្នាក់នៅកណ្ដាលចំណោមមនុស្សទាំងអស់ ដោយព្រះអង្គបានបំពេញពុទ្ធកិច្ចជាអវសាន ហើយមានមនុស្សជាច្រើនសែននាក់ បានដើរតាមមគ្គដែលព្រះអង្គបានត្រាយទុក ឲ្យប្រតិបត្តិតាម ដើម្បីទឹងទៅកាន់ស្ថានបរមនិព្វាន ។

ឱព្រះសម្មាសម្ពុទ្ធជាទីគោរពនៃសត្វទាំងឡាយ ! ព្រះអង្គជានិយ្យានិកបុរស ប្រកបដោយព្រះពលញ្ញាណដ៏អស្ចារ្យ, សូមទ្រង់អភ័យទោសចំពោះខ្ញុំព្រះអង្គ ដែលបានសរសេរតែងរឿងធ្វើឲ្យអ្នកឯទៀតដែលមិនបានដឹងនូវអានុភាពរបស់ព្រះអង្គ ឲ្យបានដឹងសព្វគ្រប់ ព្រោះខ្ញុំព្រះអង្គជាអ្នកមានប្រាជ្ញាតិច មិនអាចរាប់នូវព្រះករុណារបស់ព្រះអង្គចំពោះសព្វសត្វទាំងឡាយ ។ ឱព្រះអង្គដែលស្រឡាញ់យើង

---

១ សិលាចារឹកព្រះបាទអសោក ដែលគេបានជួបជាច្រើននៅប្រទេសឥណ្ឌាខាងជើង ។

ទាំងអស់គ្នា! ទ្រង់ជាព្រះរៀមច្បង, ព្រះមគ្គុទ្ទេសក៍ ព្រះប្រទីបនៃធម៌ទាំងឡាយ ខ្ញុំព្រះអង្គសូមជ្រកកោនក្នុងព្រះបរមនាមរបស់ព្រះអង្គហើយនៅក្នុងព្រះអង្គ ខ្ញុំព្រះអង្គសូមជ្រកកោនចំពោះព្រះពុទ្ធបញ្ញត្តិដែលសំដែងអំពីធម៌ល្អៗ. ខ្ញុំព្រះអង្គសូមជ្រកកោនចំពោះព្រះវិធាន (ព្រះវិន័យ) ។ ឱម ទឹកសន្សើមដែលមានរស្មីភ្លឺចាំងចែងទៅលើស្រទាប់បុប្ផាបទុម, រះឡើងព្រះសុរិយាជាធំសូមបើកសន្ទឹកខ្ញុំ ហើយនាំខ្ញុំទំលាក់ទៅទ័ងរលកសាគររបស់ព្រះអង្គ ។ ឱម មុនីបទ្មេ, ឱម បុត្តណ្ហសម័យ បញ្ចេញអានុភាពអើយ, ទឹកសន្សើមហូរចូលបាត់ សូតហួតហែង ទៅក្នុងសមុទ្រភ្លឺចាំងជាអស្ចារ្យ ។

ចប់ ពន្លឺអាស៊ីទ្វីប

ខ្លៅលើកខ្លួនជាចេះ

ខ្លៅប្រៀនរៀនចេះបន្តិចបន្តួច សំគាល់ខ្លួនថាស្រួចចេះមិនទាល់
មិនដឹងពុទ្ធវចនៈនៅសល់ ដូចកល់កង្កែបបែបកំឡៅ ។
នៅក្នុងអណ្ដូងអណ្ដៅទាល់ មិនដែលទៅស្គាល់សមុទ្រជ្រៅ
សំគាល់អណ្ដូងដែលខ្លួននៅ ថាធំថាជ្រៅលើសនានា ។

# បញ្ញាវុឌ្ឍិកថា

## ព្រះមហា សុខ-វ៉ន់ វត្តឧណ្ណាលោម ក្រុងភ្នំពេញ

ទេសនាផាក់វិទ្យុឃោសនសព្ទ នៃប្រទេសកម្ពុជា កាលពីថ្ងៃ ៨ កើត ខែអស្សុជ
ឆ្នាំជូតសំរិទ្ធិស័ក ព.ស. ២៤៩១ (១១-១០-៤៨)

---

## នមត្ថុ រតនត្តយស្ស

*សូមនមស្ការ (ដោយគោរព) ចំពោះព្រះរតនត្រ័យ គឺៈ ព្រះពុទ្ធ, ព្រះធម៌ នឹង ព្រះសង្ឃ ។*

*សាធុជន បពិត្រអស់លោកអ្នកសប្បុរសទាំងឡាយ! ឥឡូវនេះ អាត្មាភាព សូមសំដែងអំពីធម៌ជាគ្រឿងចំរើននៃប្រាជ្ញា ហៅថា បញ្ញា-វុឌ្ឍិកថា ដូចសេចក្ដីតទៅនេះ ។*

*ធម្មតាមនុស្សដែលកើតមកក្នុងពិភពលោកទាំងមូល សុទ្ធសឹងតែជាអ្នកមានបំណងចង់បានប្រាជ្ញាគ្រប់គ្នាទាំងអស់, កុំថាឡើយដល់មនុស្សដែលមានគុណសម្បត្តិ សមត្ថភាពបរិបូណ៌ពេញលេញ សូម្បីតែមនុស្សដែលខ្សត់ខ្សោយថោកទាបក៏ដោយ សុទ្ធតែមានបំណងដូចៗគ្នា តែបំណងនោះជួនកាលក៏សម្រេច ជួនកាលក៏មិនសម្រេច ព្រោះមនុស្សខ្លះចង់បានហើយ ខំខ្នះខ្នែងស្វែងរកពូជប្រាជ្ញាឲ្យកើតឡើង មនុស្សខ្លះចង់បានណាស់ដែរ ប៉ុន្តែខ្ជិលច្រអូសមិនខំស្វែងរក ទោះបីអ្នកដែលខំស្វែងរក ជួនកាលជួបប្រទះ ជួនកាលក៏មិនជួបប្រទះ, ឯអ្នកដែលជួបប្រទះ*

នោះសោត ខ្លះក៏បានសព្វគ្រប់ ខ្លះក៏ខ្វះមិនគ្រប់គ្រាន់, បើអ្នកណាចង់បានប្រាជ្ញាហើយខំស្វែងរកហេតុជាគ្រឿងឲ្យកើតឡើង បានជួបប្រទះសព្វគ្រប់ទាំងអស់ អ្នកនោះទើបមានប្រាជ្ញាសមដូចប្រាថ្នា ។ ចំណែកអ្នកដែលខ្ជិលច្រអូសមិនខំស្វែងរក ឬខំស្វែងរកដែរ តែមិនជួបប្រទះនោះ បើទុកជាជួបប្រទះខ្លះក៏នៅតែខ្វះមិនគ្រប់គ្រាន់. ប្រាជ្ញាក៏មិនអាចកើតឡើងបាន ។

ឯគុណធម៌គឺប្រាជ្ញានេះ, បណ្ដាមនុស្សដែលកើតមកក្នុងលោកនេះ, ទោះបីមនុស្សណាក៏ដោយ គួរតែត្រូវការចង់បាន ព្រោះជាធម្មជាតិដ៏វិសេសសំខាន់ ជាពន្លឺសម្រាប់ផ្ទុះបំភ្លឺឲ្យស្គាល់គុណទោស ត្រូវខុសល្អអាក្រក់ សព្វទៅ ទាំងផ្លូវលោកទាំងផ្លូវធម៌ រកពន្លឺដទៃមកផ្ទឹមឲ្យត្រឹមស្មើនឹងពន្លឺគឺប្រាជ្ញានេះគ្មាន សមនឹងពុទ្ធភាសិតថា: បញ្ញាយ បភា សព្វាហិ បភាហិ វិរោចតិ "ពន្លឺនៃប្រាជ្ញារុងរឿងជាងពន្លឺទាំងពួង" ។

មនុស្សអ្នកមានប្រាជ្ញា ឈ្មោះថាជាអ្នកធ្វើសេចក្ដីចង្អៀតចង្អល់ចិត្តគ្រប់យ៉ាង ឲ្យធូរទូលាយបាន, ឈ្មោះថាមានគ្រឿងភ្លឺសម្រាប់កំចាត់មោហៈអវិជ្ជាបាន, ដូចបុគ្គលមានប្រទីបសម្រាប់ផ្ទុះក្នុងទីងងឹត; ឈ្មោះថាមានសម្បត្តិ សមនឹងចិត្តដូចបុគ្គលមានរបស់ថ្លៃថ្លា មានពេជ្រជាដើម; ឈ្មោះថាមានគ្រឿងរក្សាការពារខ្លួន ដូចបុគ្គលមានកេរ្ដិ៍សម្បាច់ សម្រាប់ទំនុកបំរុងខ្លួន ឬមានអាវុធដ៏វិសេស សម្រាប់ការពារអន្តរាយ, ឈ្មោះថា

មានគ្រឿងដម្រះចិត្តឲ្យស្អាត ។ មានប្រាជ្ញាហើយឈ្មោះថាបានសុខស្រួល សមនឹងពុទ្ធភាសិតថា: សុខោ បញ្ញាបដិលាភោ "ការបានចំពោះនូវប្រាជ្ញានាំឲ្យបានសុខ" ។

បញ្ញានេះឯងតែងឈ្នះសត្រូវដែលខ្លាំងពូកែ ។ ខ្លះជាសត្វខ្លាំងពូកែមានសន្ទុះរហ័សដូចព្រញ ក្រចកនិងចង្កូមមុតដូចកាំបិតកោរ តែគង់ចាញ់មនុស្សដែលគ្មានអ្វីជាគ្រឿងពូកែ មានតែប្រាជ្ញាប៉ុណ្ណោះ អាចសម្លាប់ឬចាប់ដាក់ទ្រុងបាន, ទោះធំសម្បើមដូចដំរីក្តី ទោះមានពិសដូចពស់វែកក្តី ទោះកាចអាក្រក់កាប់មិនមុតដូចពួកចោរខ្លះក្តី ក៏ស៊ូនឹងអ្នកមានប្រាជ្ញាមិនបាន មានប្រាជ្ញាហាក់ដូចជាមានស្លាបហើរបាន ។

មានពុទ្ធភាសិតមួយកន្លែងទៀតថា: នត្ថិ បញ្ញា អឈាយិនោ "ប្រាជ្ញាមិនដែលមានដល់បុគ្គលដែលឥតពិនិត្យពិច័យទេ" ដូចជាពួកចាបខ្វាចទីងមោងគ្រាន់តែឃើញរូបកងស្រដៀងនឹងមនុស្សប៉ុណ្ណោះ ក៏ស្ទុះផ្អើលខានស៊ីស្រូវមិនគិតត្រិះរិះរកហេតុឲ្យឃើញថា: រូបកងកាយដូចជាមនុស្សនោះ តើជាអ្វី? ដូចមនុស្សទាំងអស់ ឬមានខុសត្រង់ណាដែរ? ពិនិត្យតែប៉ុណ្ណោះសិន ក៏គង់ឃើញផ្ទាំងកំបែកលាបកំបោរដែលដោតលើឈើឆ្កាងត្រដាងដោយអាវរហែកមួយពុំខាន ។

ប្រាជ្ញានេះមិនងាយនឹងកើតឡើងឯងៗ បានទេ លុះតែមានគ្រឿងប្រែកបផ្សំផងទើបកើតឡើងបាន, ដូចមានពុទ្ធភាសិតក្នុងធម្មបទ ខុទ្ទក-

និកាយថា យោគា វេ ជាយតេ ភូរិ អយោគា ភូរិ សង្ខយោ "ប្រាជ្ញានេះឯងតែងកើតមកអំពីការប្រកបផ្សំ ប្រាជ្ញាទាំងអស់ទៅក៏ព្រោះគ្មានគ្រឿងប្រកបផ្សំ" ឯគ្រឿងប្រកបផ្សំឲ្យកើតប្រាជ្ញានោះមាន ៤ យ៉ាង គឺ:

១ — សប្បុរិសូបសំសេវ សេពគប់នឹងសប្បុរសគឺលោកអ្នកប្រព្រឹត្តល្អ ដោយកាយ វាចា ចិត្ត ។

២ — សទ្ធម្មស្សវន ស្តាប់ព្រះសទ្ធម្មដែលជាពាក្យដំបូន្មានប្រៀនប្រដៅ របស់លោកដោយគោរព ។

៣ — យោនិសោមនសិការ ត្រិះរិះឲ្យស្គាល់ល្អឬអាក្រក់ កំណត់ទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ។

៤ — ធម្មានុធម្មប្បដិបត្តិ ប្រព្រឹត្តធម៌សមគួរដល់ធម៌ដែលបានត្រិះរិះឃើញហើយ ។

ការដែលបានសេពគប់នឹងសប្បុរស តែងមានគុណានិសង្សយ៉ាងវិសេសក្រៃពេកណាស់ ព្រោះសប្បុរសនោះ លោកប៉ុនប្រសប់ណែនាំប្រៀនប្រដៅជន ដែលសេពគប់នឹងលោក ឲ្យមានស្មារតីនឹករឭកដល់ធម៌ ដែលខ្លួនគួរប្រព្រឹត្តនឹងមិនគួរប្រព្រឹត្តផង ឲ្យមានស្មារតី ចេះពិចារណាស្គាល់បាបបុណ្យគុណទោស មានប្រយោជន៍នឹងឥតប្រយោជន៍ផង កាលបើបុគ្គលណាមួយ បានចូលទៅសេពគប់នឹងលោក ហើយ

តាំងចិត្តស្ដាប់ដោយគោរព គឺក្នុងខណៈដែលកំពុងស្ដាប់ មិនបណ្ដោយចិត្តរវើរវាយ ទៅក្នុងអារម្មណ៍ផ្សេងៗ ផ្គងចិត្តឲ្យត្រេចទៅតាមខ្សែសេចក្ដីនៃពាក្យប្រៀនប្រដៅនោះៗ លុះស្ដាប់បានចាំស្ទាត់ហើយ ក៏ធ្វើទុកក្នុងចិត្តដោយយោបល់ ពិចារណាឲ្យស្គាល់ន័យ និងលក្ខណៈធម៌នោះៗ ហើយស្ទង់មើលថា ធម៌នេះគួរប្រតិបត្តិយ៉ាងណា ទើបនឹងសម្រេចផលដល់អ្នកប្រតិបត្តិ កាលបើបានដឹងច្បាស់ហើយ ក៏ជ្រើសរើសទូទាត់ប្រតិបត្តិឲ្យសមគួរតាមកាលៈទេសៈ និងភូមិឋានរបស់ខ្លួន មិនប្រតិបត្តិឲ្យខុសគំរិតធម៌ឡើយ, ដំណាពីនោះមកនឹងបានជួបប្រទះនឹងផលានិសង្សនៃសេចក្ដីប្រតិបត្តិនោះៗ ដោយគ្រប់មិនខ្វះខាត ។ យ៉ាងនេះទើបប្រាជ្ញាកើតឡើង ព្រមទាំងចំរើនឡើងបាន ។

ឯធម៌ជាគ្រឿងប្រកបផ្សំ ឲ្យកើតប្រាជ្ញាទី ១ គឺ:

សប្បុរិសូបសំសេវ "ការសេពគប់នឹងសប្បុរស" នោះ សេចក្ដីថា: បណ្ដាមនុស្សដែលកើតមកក្នុងលោក ទុកជាមានកំឡាំងកាយ កំឡាំងចិត្ត នឹងកំឡាំងប្រាជ្ញា ជាជំនួយជួយរកចិញ្ចឹមជីវិតមកអំពីដើមខ្លះ ក៏ពិតមែន, តែនឹងធ្វើការងារនោះៗ ឲ្យសម្រេច ដោយងាយហើយស្រួលបួលមិនខុសមិនខ្វះខាត ឬប្រព្រឹត្តខ្លួនតាំងនៅក្នុងសេចក្ដីល្អប្រពៃ ដែលជាហេតុបានសេចក្ដីសុខចំរើននោះ ក៏ត្រូវអាស្រ័យសេចក្ដីឆ្លៀវឆ្លាសវាងវៃស្ទាត់ជំនាញ នឹងជាមនុស្សចេះសង្កេតរកហេតុផល ព្រមទាំងបានប្រទះឃើញបែបផែន

នឹងប្រពៃណីដែលល្អៗ មកអំពីដើម ទើបការងារទាំងនោះបានសម្រេច ដោយស្រួលបួលឆាប់រហ័សរួសរាន់ទាន់ចិត្តប្រាថ្នា ។

ក៏សេចក្ដីចម្រើនផ្សាយវៃស្មាត់ជំនាញក្នុងការងារ ព្រមទាំងកិរិយាមារយាទត្រឹមត្រូវល្អ នឹងប្រាជ្ញាជាគ្រឿងសង្កេតរកហេតុផល ដែលនឹងកើតឡើងបាននោះ ក៏មកតែអំពីចូលទៅជិតស្និទ្ធស្នាលនឹងសប្បុរសតែម្យ៉ាងប៉ុណ្ណោះ មិនកើតមកពីហេតុដទៃឡើយ ។

ឯជនដែលបានឈ្មោះថាសប្បុរសនោះ នឹងបានកំណត់តាមជាតិត្រកូល ឬយសស័ក្តិទ្រព្យសម្បត្តិ ក៏ទេដែរ គឺកំណត់យកតែគុណធម៌ដែលមាននៅក្នុងសន្ដានចិត្តរបស់ជននោះប៉ុណ្ណោះ ទុកជាស្ត្រីឬបុរសគ្រហស្ថឬបព្វជិតក៏ដោយ ឲ្យតែប្រព្រឹត្តត្រឹមត្រូវល្អតាមលក្ខណៈរបស់សប្បុរស មានសទ្ធានឹងសីលជាដើមហើយ ក៏លោកឲ្យឈ្មោះថាសប្បុរសទាំងអស់; បុគ្គលដែលបានឈ្មោះថាសប្បុរសនេះឯង នឹងត្រាច់ទៅក្នុងស្រុកទេសណាៗ មិនសូវជួបប្រទះនឹងសេចក្ដីអន្តរាយទេ អាចធ្វើខ្លួនឲ្យជាទីស្រឡាញ់របស់ជនទាំងឡាយ ដែលនៅក្នុងស្រុកទេសនោះៗបាន ។ ម្យ៉ាងទៀតគុណសម្បត្តិរបស់សប្បុរសជារបស់មានដម្លៃថ្លៃថ្លាណាស់ មិនវិនាសអន្តរាយដោយហេតុផ្សេងៗ មិនចាស់គ្រាំគ្រាដូចវត្ថុដទៃឡើយ អាស្រ័យហេតុនេះហើយ បានជាមានពុទ្ធភាសិត ពោលសរសើរសប្បុរសថា ៖

ន បុប្ផគន្ធោ បដិវាតមេតិ  ន ចន្ទនំ តគ្គរមល្លិកា វា
សតញ្ច គន្ធោ បដិវាតមេតិ សព្វា ទិសា សប្បុរិសោ បវាយតិ

“ក្លិនផ្កាឈើក្នុងលោកទាំងអស់ មិនដែលផ្ទុំច្រាសខ្យល់បានទេ ទុកជាក្លិននៃខ្លឹមច័ន្ទន៍ ក្រស្នា ម្លិះ ក៏ផ្ទុំក្រអូបច្រាសខ្យល់មិនបាន មានតែក្លិនរបស់សប្បុរសទើបផ្ទុំក្រអូបឈ្ងួយឈ្ងប់ច្រាសខ្យល់បាន” ។

កាលបើយើងបានដឹងច្បាស់យ៉ាងនេះហើយ បើមានប្រាថ្នានឹងសេពគប់ រាប់រកយកបុគ្គលណាមួយជាមិត្រសម្លាញ់ គួរពិចារណាជ្រើសរើសសង្កេតមើលឲ្យច្បាស់លាស់ជាមុនសិន ថានេះជាសប្បុរស នេះជាអសប្បុរស បើឃើញសប្បុរសហើយ គប្បីសេពគប់រាប់រកចុះ ប្រាថ្នានឹងចំរើនដល់យើងពុំខាន ។

អធិប្បាយសុភាសិតមកប៉ុណ្ណេះ ដើម្បីសេចក្ដីឲ្យឃើញថា ការដែលចូលទៅសេពគប់នឹងសប្បុរស តែងមានកេរ្ដិ៍ឈ្មោះល្អ ព្រោះក្លិនរបស់សប្បុរសនោះឯង រមែងផ្សព្វផ្សាយទៅដល់អ្នកដែលអង្គុយស្និទ្ធស្នាល ចំណែកខាងការសេពគប់នឹងអសប្បុរសវិញ តែងមានកេរ្ដិ៍ឈ្មោះអាក្រក់ផ្សាយទៅដល់អ្នកដទៃ បើទុកណាជាខ្លួនមិនធ្លាប់អាក្រក់មកអំពីដើមក៏ដោយ ឲ្យតែចូលទៅអង្គុយជិតស្និទ្ធស្នាល ជាមួយអសប្បុរសនោះញយៗ ក៏គង់នឹងមានកេរ្ដិ៍ឈ្មោះអាក្រក់ ពុំខាន ។

ហេតុនេះសាធុជនគួរនាំគ្នាគប់រកសប្បុរស ហើយប្រឹងស្តាប់ពាក្យប្រដៅរបស់លោក រំពឹងតាមឲ្យឃើញប្រាកដ នឹងប្រតិបត្តិឲ្យសមគួរដល់ធម៌នោះៗចុះ ព្រោះការគប់រកសប្បុរសនេះ ជាគុណជាតិនាំឲ្យចំរើនប្រាជ្ញាដោយពិត ។

ទី២— សទ្ធម្មស្សវន "ការស្តាប់ព្រះសទ្ធម្មដែលជាពាក្យប្រដៅរបស់សប្បុរសដោយគោរព" នោះ សេចក្តីថា: ចេតនាណាដែលអាចហាមឃាត់សេចក្តីពយមាយចិត្ត ឬកំចាត់បង់នូវសេចក្តីរើរាយចិត្ត ឲ្យឆ្ងាយចាកសន្តានបាន ហើយតាំងចិត្តឲ្យនឹងប្រឹងផ្ចៀងត្រចៀកចាំស្តាប់ពាក្យដម្បូន្មានប្រៀនប្រដៅដែលត្រឹមត្រូវប្រពៃ ចេតនានោះឈ្មោះថា សទ្ធម្មស្សវនៈ គឺកុសលចេតនាដែលជាហេតុឲ្យបុគ្គលតាំងចិត្តស្តាប់ធម៌ កាលបើឃើញមានអធ្យាស្រ័យយ៉ាងល្អបរិសុទ្ធឥតសៅហ្មង បានឃើញគុណានិសង្សនៃការស្តាប់ធម៌ហើយ គិតពិចារណាថា ឱ! អាត្មាអញគួរតែស្តាប់ធម៌ដោយគោរព ហើយប្រតិបត្តិកាយ វាចា ចិត្ត ឲ្យត្រឹមត្រូវល្អ តាមធម៌ដែលអាត្មាអញបានស្តាប់នោះចុះ ក្រែងលោបានសម្រេចគុណវិសេសណាមួយ ជាលោកិយ ឬលោកុត្តរ តាមសមគួរដល់ឧបនិស្ស័យរបស់អាត្មាអញដែលបានកសាងមកអំពីដើមក្តី ឬបុគ្គលណាមានគំនិតប្រកបដោយមេត្តាដល់អ្នកដទៃ ហើយរំពឹងគិតថា ឱ! អាត្មាអញត្រូវតែស្តាប់ធម៌ឲ្យចាំបានច្រើន ជាពហុស្សូតឡើង នឹងសំដែងប្រាប់អ្នកដទៃ

ដោយសេចក្ដីអនុគ្រោះឲ្យគេបានធ្វើការកុសល ត្រាន់ជាផលប្រយោជន៍របស់គេ ដោយសារអាត្មាអញផងដូច្នេះក្ដី ។ បើមានអធ្យាស្រ័យបរិសុទ្ធឥតសៅហ្មងមិនប៉ងប្រាថ្នាអាមិសបូជាទេ ហើយស្ដាប់ធម៌, កុសលចេតនានោះបានឈ្មោះថាសទ្ធម្មស្សវនៈ ។ សូម្បីតាំងចិត្តស្ដាប់វិជ្ជាដទៃៗ ដែលជាវិជ្ជាឥតទោស ក៏លោកសង្គ្រោះចូលក្នុងធម្មស្សវនៈដែរ ។

ឯការស្ដាប់ធម៌នេះ កើតមកអំពីបច្ច័យគឺ សទ្ធា សេចក្ដីជឿចំពោះអ្នកសំដែង ឬចំពោះធម៌តែម្យ៉ាង, បើប្រាសចាកសទ្ធាហើយ ស្ដាប់មិនចូលចិត្តទេ ឬមិនស្ដាប់សោះតែម្ដងក៏សឹងមាន កុំថាំបាច់និយាយដល់ធម៌ដែលល្អប្រពៃនោះឡើយ សូម្បីស្ដាប់វិជ្ជាចំណេះជាគ្រឿងរកស៊ីចិញ្ចឹមជីវិត មានស្ដាប់អំពីផ្លូវជំនួញជួញប្រែជាដើម ដែលជាវិជ្ជាឥតទោសក្នុងផ្លូវលោក ក៏ត្រូវតែអាស្រ័យសេចក្ដីជឿចំពោះអ្នកប្រដៅ ឬចំពោះវិជ្ជានោះជាមុនសិន, បើមិនមានការជឿជាឫសគល់ទេ ក៏មិនបានគុណប្រយោជន៍ឡើយ ។

គួរយើងកុំប្រហែសធ្វេសក្នុងការស្ដាប់ធម៌ គួរតែមានសេចក្ដីអើពើធ្វើសេចក្ដីក្លាហានក្នុងការស្ដាប់ធម៌ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សំដែងថាៈ ជាគ្រឿងប្រកបផ្សំឲ្យកើតប្រាជ្ញាប្រការទី ២ ៕

ទី ៣— យោនិសោមនសិការៈ "ធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ" នោះ បានដល់សេចក្ដីត្រិះរិះពិចារណា ឲ្យស្គាល់ហេតុផលល្អ

អាស្រ័យដោយយោបល់ដ៏ប្រពៃគឺឲ្យត្រឹមត្រូវតាមគន្លងធម៌ ។ កិច្ចការទាំងពួងដែលធ្វើរួច ហើយក្តី កំពុងធ្វើក្តី ឬប្រុងនឹងធ្វើទៅទៀតក្តី ក៏គួរតែមានយោនិសោមនសិការៈ គឺយកចិត្តទុកដាក់ក្នុងកិច្ចការគ្រប់ជំពូក ទើបកិច្ចការនោះៗបានសម្រេចដោយល្អ មិនមានទោស ទាំងលោកអ្នកបេះដឹងក៏តិះដៀលមិនបានឡើយ ។ ធម្មតាអ្នកធ្វើការងារអ្វីៗ បើមិនមានយោនិសោមនសិការៈ ជួយទប់ទល់ផងទេ ការងារនោះៗនឹងខុស ឬខូចខាតពុំលែងឡើយ, ដ្បិតមនុស្សយើងកាលណាបើជួបប្រទះឃើញអ្វី ឬបានរៀនវិជ្ជាណាមួយ បើមិនអាស្រ័យសេចក្តីធ្វើទុកក្នុងចិត្តដោយយោបល់ គឺថាមិនគិតថៃថ្នូនមើលឲ្យឃើញ ហេតុផលក្នុងវត្ថុវិជ្ជានោះៗឲ្យគ្រប់សព្វទេ សេចក្តីឈ្លាសវាងវៃជំនាញទៅក្នុងកិច្ចការនោះៗមិនបានកើតឡើង ។ ឯយោនិសោមនសិការៈនេះ សុំសេចក្តីទូលាយបានទាំងផ្លូវលោកនិងផ្លូវធម៌ ដូចយើងបានសិក្សាវិជ្ជាណាមួយក្នុងផ្លូវលោក មានរៀនជួសជុលរបស់អ្វីមួយដែលបាក់បែកទ្រុឌទ្រោមជាដើម និងការរៀនអក្សរលេខនព្វន្តគណិតជាដើមក្តី ក្នុងផ្លូវធម៌មានរៀនបរិយត្តិធម៌ជាដើមក្តី, កាលបើចូលទៅរៀនក្នុងសំណាក់អាចារ្យហើយ ក៏ត្រូវតែប្រើគំនិតពិនិត្យមើលឲ្យចូលចិត្តតាមពាក្យប្រដៅរបស់គ្រូ ត្រូវយកគ្រូដែលជាអ្នកប្រដៅជាគោលជាមេគំនិត ហើយពិនិត្យតាមពាក្យដែលគ្រូប្រដៅនោះ ។ បើធ្វើដូច្នោះហើយមិនយូរប៉ុន្មាន ប្រាជ្ញាក៏នឹងកើតមានឡើងដល់យើងមិនខានឡើយ ។

ហេតុនេះ គួរតែយើងបង្កើតឲ្យមានយោនិសោមនសិការៈក្នុងទីតាំង ពួង ព្រោះយោនិសោមនសិការៈនេះ ព្រះបរមសម្ពុទ្ធវិសុទ្ធគុណអនន្តញាណជាម្ចាស់ទ្រង់ចាត់ជាធម៌សំខាន់ម្យ៉ាង ខាងឯធ្វើឲ្យចំរើនប្រាជ្ញា ដោយបការទី ៣ ដូចពណ៌នាមកនេះ ។

ទី ៤— ធម្មានុធម្មប្បដិបត្តិ "សេចក្តីប្រតិបត្តិធម៌សមគួរដល់ធម៌ដែលត្រិះរិះឃើញហើយ" នោះ គុណធម៌នេះជាធម៌ជាប់តមក ពីយោ-និសោមនសិការៈ ព្រោះការដែលបុគ្គលប្រព្រឹត្តធម៌ដ៏សមគួរដល់ធម៌នោះ លុះតែមានយោនិសោមនសិការៈត្រិះរិះឲ្យស្គាល់ហេតុផលរបស់ធម៌នោះៗ ដោយយោបល់ដ៏ប្រពៃជាមុនសិន ទើបប្រតិបត្តិឲ្យសមគួរដល់ធម៌នោះបាន ធម្មានុធម្មប្បដិបត្តិនេះ ព្រះសម្ពុទ្ធជាម្ចាស់ត្រាស់ហៅថា ធម៌ជាគ្រឿងប្រកបផ្សំឲ្យកើតប្រាជ្ញាម្យ៉ាង ។ កាលបើបុគ្គលបានប្រតិបត្តិឲ្យត្រឹមត្រូវតាមលំអានរបស់ធម៌ហើយ រមែងបានជួបប្រទះ នឹងសេចក្តីសុខចំរើន សមគួរតាមសេចក្តីប្រតិបត្តិរបស់ខ្លួនមិនខានឡើយ ។

ចំណែកបុគ្គលខ្លះដែលប្រព្រឹត្តធម៌នឹងគេដែរ តែមិនបានជួបប្រទះនឹងសេចក្តីសុខចំរើន ដោយបរិបូណ៌នោះ ពីព្រោះប្រតិបត្តិមិនឲ្យសមគួរដល់ធម៌ ដែលខ្លួនត្រិះរិះឲ្យឃើញនោះឯង មនុស្សខ្លះប្រឹងតែប្រតិបត្តិទៅឲ្យច្រើនជាងការបេះដឹង សេចក្តីចូលចិត្តរបស់ខ្លួនក៏មាន ព្រោះហេតុតឹងហួស ធូរហួសយ៉ាងនេះ បានជាមិនបានជួបប្រទះនឹងសេចក្តី

សុខចំរើនដែលជាផលនៃការប្រតិបត្តិនោះៗ ដោយគ្រប់គ្រាន់ឡើយ ។ ព្រោះហេតុនេះ អស់លោកអ្នកទាំងឡាយ ដែលមានសេចក្ដីប៉ុនប៉ង ចង់បានប្រាជ្ញាគួរតែប្រតិបត្តិធម៌ ឲ្យសមគួរតាមធម៌ ដែលហៅថា ធម្មានុធម្មប្បដិបត្តិនេះ ដោយប្រញាប់ចុះ ដ្បិតមានគាថាសំស្ក្រឹតមួយកន្លែងសំដែងថា:

អជរាមរវត្ប្រាជ្ញោ វិទ្យា មត៌្ថំ ច ចិន្តយេត៑
គ្ឫហីត ឥវ កេសេសុ ម្ឫត្យុនា ធម៌មាចរេត៑

អ្នកប្រាជ្ញដែលមានបញ្ញា រមែងគិតនូវវិជ្ជាផង នូវប្រយោជន៍ផង ដូចជាអ្នកមិនមានជរា គឺសេចក្ដីចាស់គ្រាំគ្រាទាំងមរណៈ គឺសេចក្ដីស្លាប់ ថែមទាំងប្រព្រឹត្តធម៌ ដ៏សមគួរដល់ធម៌ យ៉ាងខ្ជាប់ខ្ជួនមិនឲ្យកំរើក ដូចបុគ្គលដែលសេចក្ដីស្លាប់ចាប់បានត្រង់សក់ទាំងឡាយ ។

រោគា ចេវន្តរាយា ច ឧប្បន្នា ចេ ឧបទ្ទវា
ធម្មទេសនានុភាវេន វិនស្សន្តុ អសេសតោ

ដោយអានុភាពនៃធម្មទេសនានេះ ប្រសិនបើមានរោគចង្រៃ ឧបទ្រពអន្តរាយណាមួយកើតឡើង សូមឲ្យវិនាសបាត់ទៅ កុំឲ្យមានសេសសល់ឡើយ ។

កម្ពោជិកា សាសនិកា សមគ្គា សុខី អនីឃាប ភវន្តុ និច្ចំ
កម្ពោជិភូតា បិហយន្តុ វឌ្ឍិ សជាតិកានំ ករោន្តុ អត្ថំ

ខេមរជាតិទាំងឡាយ ចូរជាអ្នកកាប់កានព្រះពុទ្ធសាសនាផង ចូរព្រមព្រៀងគ្នាផង ចូរមានសេចក្ដីសុខផង មានអាយុវែងផង អស់កាលជានិច្ច ជនទាំងឡាយដែលបានកើតក្នុងកម្ពុជរដ្ឋហើយ ចូរស្រឡាញ់ប្រទេសជាតិមាតុភូមិរបស់ខ្លួនផង ចូរធ្វើប្រយោជន៍ដល់ជនអ្នករួមជាតិទាំងឡាយផង សព្វៗ កាលទៅហោង ។

ចប់ធម៌ទេសនា ដោយសង្ខេប តាមសមគួរដល់កាលវេលា ឯវំ ។

---

រោគអ្វីមិនស្មើនឹងរោគឃ្លាន ទានអ្វីមិនស្មើទានធម៌ទេសនា
មានអ្វីមិនស្មើមានបញ្ញា ជាអ្វីមិនស្មើចិត្តជាបុណ្យ ។
រហ័សអ្វីមិនស្មើចិត្តដែលនឹក មុតអ្វីមិនស្មើទឹកដោរជន
ធ្ងន់អ្វីមិនស្មើព្រះគុណធ្ងន់ ធន់អ្វីមិនស្មើនឹងប្រពន្ធប្រើ ។

# អត្តានុទិដ្ឋិ

## អ្នកឧកញ៉ាឥស្សរវង្សា សំ-ស៊ុន

ជាអ្នកប្រែរៀបរៀង

(ត-ចប់)

---

មួយទៀត អ្នកធម៌ជាអ្នកចូលចិត្តក្នុងរឿងអនត្តា រមែងអានដល់លោកអារក: សាស្ដាចារ្យ ព្រោះលោកមានភូមិធម៌ខ្ពស់ សូម្បីដូច្នោះ លោកនេះក៏ឃើញថា អនត្តាគ្មាន ។ មានរឿងពោលក្នុងគម្ពីរថា ក្នុងអតីតកាលកន្លងទៅហើយ ជាកាលយូរឆ្ងាយ មុនព្រះពុទ្ធជាម្ចាស់របស់យើងកើតឡើងក្នុងលោក មានគណាចារ្យ អ្នកមានឈ្មោះសំឡេងឧត្តុង្គឧត្តមម្នាក់នាមថា អារក: សាស្ដាចារ្យ អធ្យាស្រ័យបង្អោនទៅក្នុងសេចក្ដីស្ងប់ ទ្រទ្រង់ភូមិធម៌ក្នុងថ្នាក់នោះ ប្រដៅប្រដុំជនដើម្បីសេចក្ដីស្ងប់ លទ្ធិប្រហាលគ្នានឹងពុទ្ធសាសនា, មហាជនសរសើរថា លោកជាអ្នកមានកិលេសស្រាលស្ដើង ឃើញ អនិច្ចំ ទុក្ខំ គឺសេចក្ដីមិនទៀងជាទុក្ខនៃសង្ខារធម៌ តែលោកឥតបានឃើញសង្ខារធម៌ថាជាអនត្តាផងឡើយ ។ ចុះហេតុអ្វីហ្ន៎: លោកអារក សាស្ដាចារ្យទើបមិនឃើញសង្ខារធម៌ថាជាអនត្តាធម៌? សេចក្ដីចូលចិត្តថា ព្រោះលោកនេះនៅមិនទាន់ជួបឃើញអត្តាយ៉ាងដទៃក្រៅពី ខន្ធ ៥, កាលបើដូច្នោះ នឹងឲ្យលោកឃើញខន្ធ ៥ ជាអនត្តានោះមិនបាន ប្រែថា អសង្ខតធាតុរបស់លោកនៅមិនទាន់បាន

សេចក្ដីបរិសុទ្ធ ជាវិភគធម៌ ឬនិព្វានដែលជាអត្តា (ខ្លួនប្រាណ) ពិតប្រាកដ ដ៏ជាហេតុឲ្យបដិសេធខន្ធ ៥ ថាជាអនត្តាបានទេ ។ ការណ៍ដែលលោកមិនបានជួបឃើញអត្តាគឺព្រះនិព្វាននោះ ក៏ព្រោះមិនបានខប្រដិបត្តិដែលត្រឹមត្រូវគឺអរិយមគ្គ ៨ ប្រការ, ឯអរិយមគ្គមានចំពោះក្នុងព្រះពុទ្ធសាសនា នឹងព្រះបច្ចេកពោធិប៉ុណ្ណោះ, លទ្ធិខាងក្រៅព្រះពុទ្ធ-សាសនាមិនមានអរិយមគ្គ ដែលនឹងឲ្យកើតផលគឺព្រះនិព្វានបានឡើយ, ព្រោះដូច្នោះក្នុងលោក ក្រៅអំពីព្រះពុទ្ធសាសនាហើយក៏មិនមានអ្នកឯណាស្គាល់អនត្តាធម៌ទេ ។ បំណែកសេចក្ដីប្រែប្រួលក្នុងសង្ខារធម៌ដែលហៅថា អនិច្ចំក្ដី សេចក្ដីវិបត្តិទំលាយបែករលាយនៃសង្ខារធម៌ដែលហៅថាទុក្ខំនោះក្ដី មិនចំពោះតែលោកអារកៈសាស្ដាចារ្យម្នាក់ឯង ដែលជាអ្នកមានឈ្មោះសម្ដេចគុត្តមដូច្នោះប៉ុណ្ណោះទេ ដែលមើលឃើញ សូម្បីមនុស្សសាមញ្ញក៏ឃើញបាន ព្រោះប្រាកដដល់ភ្នែកគ្រប់គ្នា មនុស្សកើតមកហើយចម្រើនឡើងជាកម្លោះក្រមុំ ហើយក៏ស្លាប់គរលើផែនដីទៅវិញ គេសឹងតែឃើញដោយភ្នែកហើយ តើនឹងមិនប្រើគំនិតគ្រប់គ្នាទេឬ? គង់ត្រូវប្រើគំនិតជាចំនួនច្រើនគ្នា ព្រោះដូច្នោះ លោកអារកៈសាស្ដាចារ្យមិនមែនឃើញប្លែកអ្វីអំពីពួកយើងឡើយ ។

នឹងរកផ្លូវបដិសេធថាព្រះនិព្វានជាអនត្តា ឬជាអត្តា (ខ្លួនប្រាណ) មិនមានក្នុងទីទាំងពួងនោះពុំបានឡើយ រឿងដែលគួរនឹងយកចិត្តទុកដាក់

សម្រាប់វិនិច្ឆ័យមានទៀតៈច្រើនប្រការ នឹងនាំមកឲ្យឃើញទៀត ។ កាលព្រះអង្គជិតនឹងស្ដេចរំលត់ខន្ធបរិនិព្វាន លោកពោលក្នុងមហាបរិនិព្វានសូត្រថា គ្រាមួយព្រះអង្គទ្រង់ព្រះប្រឈួនធ្ងន់ដោយអំណាចព្រះរោគផង ព្រះជរាភាពផងប្រកបគ្នា ទើបទ្រង់ប្រើអនិមិត្តចេតោសមាធិវិហារ ប្រែថា "សេចក្ដីតាំងខ្ជាប់នៃចិត្ត ដោយមិនបានប្រកាន់អ្វីៗទុកជានិមិត្តដែលសំគាល់" គឺទ្រង់ធ្វើព្រះហឫទ័យព្រងើយខ្ជាប់ដោយសភាពធម្មតានៃចិត្តឯង មិនប្រកាន់អារម្មណ៍អ្វីៗ ទុកឲ្យជាតីរ សល់នៅតែសង្ខតធាតុដែលបរិសុទ្ធម៉ត់ចត់ជានិព្វាន (ឈានទី ៤) សម្រាប់រម្ងាប់ទុក្ខវេទនា, កាលបានទ្រង់ធ្វើដូច្នេះ ទុក្ខវេទនាក៏ស្ងប់រម្ងាប់ទៅ ៗ ចំណែកព្រះអានន្ទម្ចាស់ជាពុទ្ធុបដ្ឋាកក៏តាំងតែគ្រាំចិត្តគិតវិតក្កថា "ព្រះអាពាធរបស់សម្ដេចព្រះពុទ្ធអង្គនឹងមិនត្រឡប់សះស្បើយ" ម្ល៉ោះហើយក៏ទៅគាល់ទូលសួរព្រះអាការពេកញយៗ ។ ក្នុងគ្រាមួយ ព្រះអង្គទ្រង់ត្រាស់តបនឹងព្រះអានន្ទត្ថេរថា "ម្នាលអានន្ទ! កាលតថាគតប្រើអនិមិត្តចេតោសមាធិវិហារ ទុក្ខវេទនាក៏បានស្ងប់ អាពាធនោះក៏ស្រាលទៅ រាប់ថាមិនសូវជាអ្វីណាស់ក្នុងការឈឺចាប់របស់តថាគត" ហើយក៏ត្រាស់តទៅថា

តស្មា តិហានន្ទ អត្តទីបា វិហរថ អត្តសរណា អនញ្ញសរណា

ជាដើម សេចក្ដីថា "ព្រោះហេតុនោះឯងអានន្ទ! អ្នកទាំងឡាយចូរមានខ្លួនជាកោះជាទីគោង ចូរមានខ្លួនជាទីពឹងអាស្រ័យ កុំមានវត្ថុដទៃជាទី

ពឹងឡើយ" ដូច្នេះជាអាទិ ។ សេចក្ដីដែលបានលើកមកនិយាយនេះគួរពិចារណាមើលៈតើអ្វីជាហេតុឲ្យព្រះអង្គត្រាស់នឹងព្រះអានន្ទថា "ព្រោះហេតុនោះឯង អានន្ទ! អ្នកទាំងឡាយចូរមានខ្លួនជាកោះជាទីពឹង ចូរមានខ្លួនជាសរណៈទីពឹង" សំឡឹងពិនិត្យទៅក៏នឹងឃើញថា ព្រោះបានទ្រង់ប្រើអនិមិត្តចេតោសមាធិវិហារសម្រាប់រម្ងាប់ទុក្ខវេទនា អនិមិត្តចេតោសមាធិវិហារនោះជាអ្វី ក៏គឺគួរអសង្ខតធាតុដែលបានសេក្ដីបរិសុទ្ធជានិព្វានដែលរាប់ថាជាអត្តាដូចពោលមកហើយនោះឯង ព្រោះដូច្នោះ អត្តា ក្នុងព្រះពុទ្ធភាសិតនេះគឺព្រះនិព្វាន ។

មានរឿងមួយទៀត ពោលទុកថា ពួកកំឡោះ ៣០ នាក់ ហៅគ្នាថា ភទ្ទវគ្គិយៈ នាំគ្នាដើរតាមរកស្ត្រីម្នាក់ ដែលបានរត់អំពីពួកខ្លួនទៅព្រួចយកគ្រឿងប្រដាប់ទៅផង គេទាំងនោះបានជួបព្រះសម្មាសម្ពុទ្ធម្ចាស់ប្រថាប់នៅក្រោមដើមព្រឹក្សា ១ ដើម នៅទីដំបន់ចម្ការកប្បាស ។ បុរសម្នាក់ជានាយចូលទៅគាល់ ហើយទូលសួរថា បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ បានទ្រង់ឃើញស្ត្រីម្នាក់មកតាមផ្លូវនេះឬទេ? ។ ព្រះអង្គត្រាស់សួរដល់ដើមហេតុរបស់រឿងរ៉ាវថាកើតរឿងគ្នាយ៉ាងម៉េច ។ គេបានទូលរៀបរាប់ថ្វាយគ្រប់ប្រការ ។ ព្រះអង្គត្រាស់ថា អ្នកទាំងឡាយចូរត្រិះរិះថាយើងនឹងរកស្ត្រីនោះល្អជាង ឬថានឹងរកខ្លួនល្អជាង ។ គេចូលចិត្តឃើញព្រមគ្នាថារកខ្លួននោះឯងល្អជាង ហើយទើបបានទូលឲ្យទ្រង់

ជ្រាប ៗ ព្រះសម្ពុទ្ធត្រាស់តបថា ល្អហើយ បើដូច្នោះចូរអង្គុយ តាំងចិត្តចាំស្តាប់ តថាគតនឹងសំដែងធម៌ដល់អ្នកទាំងឡាយ ហើយទ្រង់សំដែងព្រះធម្មទេសនាដល់គេទាំងនោះ ៗ

រឿងនេះបើយើងនឹងស្មាន់ក៏គង់មិនខុសច្រើនពេក ព្រោះតាមធម្មតាមនុស្សសាមញ្ញរមែងចូលចិត្តប្រកាន់ស៊ប់តាំងពីតូចរហូតដល់ធំ ហើយថាអត្តភាពរាងកាយនេះឯងជាអត្តា (ខ្លួនប្រាណ) កាលព្រះអង្គទ្រង់ត្រាស់មកថា ស្វែងរកស្ត្រីនោះល្អជាង ឬស្វែងរកខ្លួនល្អជាងដូច្នេះហើយ អ្នកទាំងនោះគង់នឹកប្លែកក្នុងចិត្តថាខ្លួនប្រាណមានគ្រប់គ្នាហើយ ហេតុអ្វីព្រះអង្គទើបទ្រង់ត្រាស់ដល់ការស្វែងរកខ្លួនទៀត ប្រហែលជាខ្លួននោះនឹងមានជាវិសេសទៀត ព្រះអង្គគង់នឹងស្គាល់អត្តានោះជាប្រាកដពិត ទើបគេតបថាត្រូវការរកខ្លួននោះល្អជាង ដើម្បីព្រះអង្គទ្រង់ចង្អុលអត្តាតាមរឿងដែលលើកមកឲ្យឃើញនេះ ៗ នឹកមើលចុះបើអត្តាក្រៅពីខន្ធ ៥ នេះមិនមានទៀតហើយ ព្រះអង្គត្រាស់យ៉ាងនោះមិនបាន, អត្តាមានពិតប្រាកដ តែជាវត្ថុដែលកំបាំងមនុស្សសាមញ្ញរមែងមិនឃើញ តែអ្នកប្រាជ្ញមានបញ្ញាវិសេសទើបជួប, ព្រោះដូច្នោះព្រះអង្គទើបទ្រង់ត្រាស់ដាស់តឿនសតិដល់ពួកភទ្ទវគ្គិយ:ថា ស្វែងរកខ្លួនហ្នឹង ព្រោះមនុស្សសាមញ្ញមិនស្គាល់អត្តានោះឯង ទើបប្រកាន់យកខន្ធ ៥ ដែលជាអនត្តា (មិនមែនខ្លួនប្រាណ) ថាជាអត្តា (ខ្លួនប្រាណ) ព្រះអង្គទ្រង់ត្រាស់

ដល់ពួកបញ្ចវគ្គិយថា ខន្ធ ៥ ជាអនត្តា (មិនមែនខ្លួនប្រាណ) ដូចមានសំដែងទុកក្នុងអនត្តលក្ខណសូត្រនោះ ។

អនត្តានេះ លោកខ្លះប្រែថា "បង្គាប់បញ្ជា មិនបាន" ថា "ស្តីមិនបានស្តីមិនស្តាប់" ។ ប្រែយ៉ាងនេះ សូម្បីបានសេចក្តីខ្លះ ក៏ខូចសព្ទត្រឡប់ជាខូចការណ៍ណាស់ទៅទៀត ព្រោះនរណា ៗ ក៏ត្រូវដឹងថាខន្ធ ៥ នោះឯងជាអនត្តា ។ ខន្ធ ៥ គេបង្គាប់បញ្ជាមិនបានពិតក្នុងវត្ថុដែលហួសវិស័យដូចចាស់ ឈឺ ស្លាប់ កាលដល់ពេលហើយទីងឃាត់មិនបាន តែគង់បង្គាប់បញ្ជាបានក្នុងវត្ថុដែលមិនហួសវិស័យ, ចូរត្រិះរិះមើលឲ្យជុំវិញចុះ បើតាំងចិត្តនឹងបង្គាប់បញ្ជា ក៏បង្គាប់បញ្ជាបានពិត ៗ, អ្នកមិនបានបង្គាប់បញ្ជាទេ ទើបខន្ធ ៥ ផ្តេសផ្តាស; បើសិនជាខន្ធ៥បង្គាប់បញ្ជាមិនបានពិត ៗ ហើយ អត្តភាពរាងកាយនេះ យើងក៏គ្រប់គ្រងមិនបាន ព្រោះដៃនឹងជើងមិននៅក្នុងបង្គាប់បញ្ជា, ថ្នាំផ្សេង ៗ សម្រាប់កែពេគ រម្ងាប់ទុក្ខវេទនាក៏មិនត្រូវប្រើ ។ មួយទៀត គតិរបស់មនុស្សរមែងមានទាំងល្អទាំងអាក្រក់ ជាប់នៅនឹងសេចក្តីប្រព្រឹត្តិ បើប្រព្រឹត្តល្អក៏មានគតិល្អ បើប្រព្រឹត្តអាក្រក់ក៏មានគតិអាក្រក់, បើបង្គាប់បញ្ជាខន្ធ ៥ មិនបានហើយ មនុស្សយើងរកសេចក្តីសុខសេចក្តីចម្រើនទៅសួគ៌ ទៅនិព្វានមិនបានសោះតែម្តង, ព្រោះខន្ធ ៥ ហាក់បីដូចជាគ្រឿងដៃ ប្រើបានទាំងខាងល្អខាងអាក្រក់ បុណ្យក្តីបាបក្តី ឬអរិយមគ្គ៨ប្រការក្តី ក៏មិននៅក្រៅអំពីខន្ធ

ទេ ។ សេចក្តីពិតខន្ធ ៥ នោះជាអព្យាក្រឹត (ធម៌ជារបស់កណ្តាលៗ មិនល្អមិនអាក្រក់) ជារបស់គេអាចបង្គាប់បញ្ជាបាន បើបង្គាប់ឲ្យល្អក៏ល្អ បង្គាប់ឲ្យអាក្រក់ក៏អាក្រក់ ។ បើខន្ធប្រាសចាកការបង្គាប់បញ្ជាហើយ ក៏ស្មើគ្នានឹងកំណាត់ឈើដុំដីដុំថ្មផ្សេងៗ ឬមនុស្សដែលស្លាប់ទៅហើយ នឹងធ្វើល្អធ្វើអាក្រក់ពុំបានឡើយ ព្រោះដូច្នោះការប្រែអនត្តាយ៉ាងនោះ ឈ្មោះថាប្រែទៅតាមអំពើចិត្ត មិនអាស្រ័យគោលឡាក់ហាន អត្ថយ៉ាងណាឡើយ គួរនឹងថាដែលប្រែយ៉ាងនេះប្រើការមិនបាន ។

មនុស្សដែលឃើញថា យើងឬអត្តា (ខ្លួនប្រាណ) មិនមាននោះ ចូលចិត្តនិយាយថា ព្រះពុទ្ធសាសនាជាសាសនាជាន់ខ្ពស់ មិនមានអ្នកធ្វើ មិនមានអ្នកទទួលទេ ។ តែគេត្រឡប់ទទួលពិបរងការធ្វើថាមាន ដូចឧបាទាន (សេចក្តីប្រកាន់) នឹងមគ្គ៨ប្រការ ។ បើឃើញថាយើងឬអត្តាមិនមានហើយ ក៏ត្រូវថាមិនមានអ្នកធ្វើ មិនមានអ្នកទទួលទៅផង ព្រោះយើងឬអត្តាមិនមាន នឹងយកអ្នកធ្វើអ្នកទទួលឯណាមកហ៎ះ? តែបើព្រះពុទ្ធសាសនាដូច្នោះពិតហើយ ក៏ៈយើងមិនគួរនឹងសិក្សារៀនសូត្រធ្វើអ្វីត្រូវទុកជាសាសនាផ្តេសផ្តាសមិនមានឡាក់ហាន នឹងសិក្សាឲ្យដឹងល្អទៅ ក៏មិនមានអ្នកទទួលប្រយោជន៍ក្នុងការសិក្សា, ឧស្សាហ៍លះកម្លាំងពលំនឹងជីវិតចិត្តថ្លើមចុះទៅប្រព្រឹត្តប្រតិបត្តិធ្វើអ្វី បើជាមនុស្សល្ងង់មនុស្សអាក្រក់ប៉ុន្មាន ក៏មិនមានអ្នកទទួលទោសនោះបានទេ បើជាពាល

ឬបណ្ឌិត ក្នុងទីបំផុតក៏ស្មើគ្នា បើធ្វើល្អឬធ្វើអាក្រក់ក៏ស្មើគ្នា នឹងយកអ្នកឯណាទីណាមកជាអ្នកទទួល ជាអ្នកធ្វើនឹងផុតទុក្ខទៅបាន ៗ ដែលទទួលរាប់រងការធ្វើនោះ ក៏ទទួលដោយមិនមានហេតុផល, កាលអ្នកធ្វើមិនមានហើយ ការធ្វើនោះនឹងមានម្ដេចកើត ព្រោះការធ្វើជាកិរិយារបស់អ្នកធ្វើ លក្ខណៈជាអាការរបស់វត្ថុ, បើអ្នកធ្វើនឹងវត្ថុមិនមានហើយ ការធ្វើនឹងលក្ខណៈក៏មិនមានដូចគ្នា ៗ ដូច្នេះអ្នកសង្វាតក្នុងការសិក្សាត្រូវប្រើសេចក្ដីពិនិត្យឲ្យល្អ ៗ

សូមបញ្ចប់រឿងមិនជាឡាក់ហានត្រឹមប៉ុណ្ណេះ ៗ

អ្នកឧកញ៉ាឥស្សរៈវង្សា សំ-ស៊ុន ជាអ្នកប្រែចេញពីស្យាមភាសា

៣០ មេសា ព.ស. ២៤៩៤

ស្រណុកដូចជ្រូកអាយុខ្លី
នឿយដូចក្របីអាយុវែង
មានទីពឹងគឺមនុស្សខ្នះខ្នែង
កំព្រាឯកឯងគឺមនុស្សខ្ជិល។

ការបណ្ដុះនិស្ស័យ

ព្រះមហាឧត្ដមវិជ្ជា ផលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

## ឧបាយបណ្ដុះនិស្ស័យទី ៤

### និស្ស័យសុចរិត

សុចរិតជាធម៌ ល្អក្រៃលែង
ខាំងការពារខែង ឲ្យសុខបាន
ហេតុនេះបើចង់ សុខក្សេមក្សាន្ត
ត្រូវយើងគ្រប់ប្រាណ ធ្វើសុចរិត ៗ

លោក-អ្នកសុចរិតទាំងឡាយ! វត្ថុដែលជាទីប៉ុនប៉ងនៃចិត្តរបស់យើង តែងរមែងនៅត្រង់ទីបំផុតនៃបំណងគឺសេចក្ដីសុខ នៅត្រង់ទីបំផុតប្រាថ្នាគឺឥស្សរភាព សេរីភាព សមភាព ភាតរភាព និងនៅត្រង់ទីបំផុតអំណាច គឺកម្មសិទ្ធិក្នុងទ្រព្យសម្បត្តិដែលយើងមានយើងបានមកដោយត្រឹមត្រូវ ៗ តែយើងនឹងបានដល់ទីបំផុតរបស់ទាំងនេះ សមតាមបំណងនោះ ដោយសារតែគុណគឺដំឡៃនៃភាពជាមនុស្ស បើយើងមិនមានគុណគឺដំឡៃនៃភាពជាមនុស្សនៅក្នុងខ្លួនទេ នឹងបាត់ថាជាមនុស្ស

មានចំណែកសមគួរនឹងបានទទួលនូវទីបំផុតរបស់ទាំងនោះពុំបានឡើយ ។ សូម្បីភាពជាមនុស្ស ហើយមានដំឡៃនោះសោត ក៏នៅត្រង់យើងមានមនុស្សធម៌នៅក្នុងខ្លួន គោរពចំពោះមនុស្សធម៌ ។ សេចក្តីសុចរិតចាត់ថាជាមនុស្សធម៌ ១ ផ្នែក ដែលយើងគួរបង្កើតទុកលើសរសា ។ ព្រោះទីបំផុតនៃបំណង ទីបំផុតនៃសេចក្តីប្រាថ្នា និងទីបំផុតនៃអំណាចជារង្វាន់នៃសុចរិត ដែលអ្នកប្រាថ្នាគុណសេចក្តីចំរើន ប្រតិបត្តិតាមពេលណាក៏បានពេលនោះ ។

សេចក្តីសុចរិត ជាអាវក្រោះនៃកិត្តិយស និងជាអាវក្រោះនៃកិត្តិយសបែបសាកល គឺមិនមាននិយមរើសនឹងភេទជាន់ថ្នាក់ វណ្ណៈណាមួយឡើយ ។ គ្រហស្ថបព្វជិត ស្រីប្រុស កម្មករ អ្នកស្រែ អ្នកចំការ អ្នកជួញនិងអ្នករាជការ ប្រើបានដូចគ្នាទាំងអស់ ។ សុចរិតនេះ ក្រៅអំពីប្រើជាអាវក្រោះនៃកិត្តិយសហើយក៏គង់ប្រើជាអាវុធតេជះសម្រាប់ឃុំគ្រងការពារឲ្យយើងផុតភ័យ បានសេចក្តីសុខសម្រាន្តទៀត ។ បើយើងខ្លាចភ័យ ចូរពាក់អាវក្រោះនៃកិត្តិយសនិងអាវុធតេជះគឺសុចរិតនេះចុះ ត្រូវកុំអៀនខ្មាស និងកុំលុបគុណមើលងាយគេឡើយ ។ បុរាណពោលថា "ពួកគណៈណា មើលងាយមនុស្សសុចរិត និយមរាប់អានតែមនុស្សទុច្ចរិត លើកដំកើងមនុស្សខ្ជិលច្រអូសស្មើនឹងមនុស្សឧស្សាហ៍ លើកដំកើងមនុស្សខ្លាចស្មើនឹងមនុស្សហ៊ាន ពួកគណៈនោះមុខ

ជាវិនាស " ។ ហេតុនេះ យើងគួរខ្លាចសេចក្ដីវិនាសទើបល្អជាង កុំខ្លាចសេចក្ដីសុចរិតដែលអំណោយផលគឺទីបំផុតនៃបំណង, ទីបំផុតនៃសេចក្ដីប្រាថ្នានឹងទីបំផុតនៃអំណាចឲ្យយើងនោះឡើយ ។ អ្នកប្រព្រឹត្តសុចរិត ឈ្មោះថាពាក់អាវក្រោះនៃកិត្តិយសនឹងអាវត្នុកតេជះដ៏បរិសុទ្ធផូរផង់ ប្រើការពារភ័យបាននឹងដុសខាត់កិត្តិយសឲ្យមានរស្មី ។

ការតាំងចិត្តសុចរិត ជាឫសកែវធ្វើឲ្យកាយកម្មនឹងវចីកម្មជាសុចរិតតាម មានផលចេញប្រាកដមកតាមត្រៃទ្វារល្មមឲ្យឃើញថាជាទីតាំងមាំនៃសុចរិត សំដែងអាការចេញមកឲ្យមនុស្សដទៃឃើញថាជាមារយាទពេញក្នុង ជាភាពត្រូវចិត្ត ព្រោះសុទ្ធតែជាសុចរិតគ្រប់តែពេលដែលធ្វើគ្រប់តែពេលដែលនិយាយ នេះជានិស្ស័យសុចរិតដែលជាដើមហេតុចេញមកនៃទីបំផុតបំណងទីបំផុតប្រាថ្នានឹងទីបំផុតអំណាច ។ មនុស្សមាននិស្ស័យសុចរិត រមែងប្រាថ្នាសន្តិសុខដល់លោក ចូលចិត្តគិត ចូលចិត្តនិយាយនឹងចូលចិត្តធ្វើចំពោះមនុស្សដទៃៈដោយចិត្តបរិសុទ្ធ រាប់អានអ្នកដែលចាស់ជាងក្នុងឋានៈជាទីសក្ការបូជា រាប់អានអ្នកមានកេរ្តិ៍ឈ្មោះក្នុងឋានៈជាទីគោរព រាប់អានអ្នកអន់ជាងក្នុងឋានៈជាទីមេត្តាករុណានឹងរាប់អានកូនក្មេងក្នុងឋានៈជាទីស្រឡាញ់គួរចង់មើល ។ សន្តិសុខនឹងវឌ្ឍនាការជាស្ពានរបស់សង្គម រមែងកើតឡើងអំពីនិស្ស័យសុចរិតរបស់មនុស្សក្នុងសង្គម ។ ឯទុក្ខភ័យក្តៅក្រហាយនៃសង្គមតែងនៅត្រង់និស្ស័យទុច្ចរិតរបស់មនុស្សក្នុងសង្គមនោះ ។

ធម្មសម្បត្តិដ៏ប្រសើរក្រៃលែង  ក៏គឺសេចក្តីល្អ  សេចក្តីបរិសុទ្ធ, ការត្រូវគន្លងធម៌ ៗ ធម្មសម្បត្តិទាំងនេះ ជាហេតុឲ្យមនុស្សប្រព្រឹត្តអ្វីមិនបៀតបៀនខ្លួននឹងអ្នកដទៃ មិនប្រាថ្នា មិនប្រព្រឹត្ត ខុសតែដែលការត្រូវធម៌ប្រាប់មិនឲ្យប្រាថ្នា មិនឲ្យប្រព្រឹត្ត ទឹងពេញចិត្តលះបង់អំពើអាក្រក់ ស៊ូគ្រប់ចិត្តនឹងអំពើល្អ ប្តូលចិត្តជំរះអធ្យាស្រ័យរបស់ខ្លួនឲ្យស្អាតបរិសុទ្ធ ប្រាសចាកមន្ទិលទោសនឹងការពិរុទ្ធផ្សេងៗ នេះឈ្មោះថាសុចរិតពិត ៗ សុចរិតនេះ ទុកដូចជាផ្ទាំងមាស ឃុំគ្រង់ព្រះមហាសាសនា និងចាត់ជាជាអន្ទាក់មាសចងផ្លាក់លោកទុកក្នុងសន្តិសុខ ទាំងជាថ្នាំលើកកម្លាំងចិត្តឲ្យត្រេកអរីករាយផង ៗ កាលបានធ្វើសមតាមគំនិតហើយចិត្តក៏រីករាយក្រៃលែង សូម្បីធ្វើតែម្តង ក៏លើកចិត្តឲ្យសប្បាយរីករាយរាប់រយ-ពាន់ដង ៗ

ឯទុច្ចរិតគឺសេចក្តីអាក្រក់ ពិរុទ្ធ ការខុសគន្លងធម៌វិញ ទុកដូចជាច្រវាក់ចងលោកទុកក្នុងការចលាចលកោលាហល និងទុក្ខក្តៅក្រហាយ មនុស្សធ្វើទុច្ចរិតឈ្មោះថាលេងនឹងពស់មានពិស មុខជាត្រូវលំបាកចិត្តពុំខាន ព្រោះកាលបានធ្វើសម្រេចទៅតាមបំណងពិតៗ សូម្បីត្រឹមតែបន្តិចបន្តួច ក៏មុខជាបានទទួលលទ្ធផលក្តៅក្រហាយយ៉ាងខ្លាំងក្លាមកវិញ គឺចិត្តត្រូវជាប់ទោស ត្រូវតក់ស្លុតរន្ធត់ញាប់ញ័រជានិច្ច មិនខុសអ្វីអំពីការនៅជិតពស់មានពិសទេ ៗ ព្រោះការធ្វើទុច្ចរិតតែ ១ ដងនោះ រមែងបានទទួលទុក្ខក្តៅក្រហាយមកវិញរាប់រយ-ពាន់ដង សូម្បីនឹងព្យាយាម

បិទបាំងទុកមិនឲ្យនរណាដឹង ក៏ដូចគ្នានឹងលាក់ភ្លើងទុកក្នុងទ្រូង មុខជាត្រូវក្ដៅក្រហាយអន្ទះអន្ទែងខ្លួនឯងរាប់ពេលមិនអស់ ។

“សុចរិត” ជាពាក្យហៅសេចក្ដីល្អឧត្តម មានសារសំខាន់នៅត្រង់ការប្រព្រឹត្តល្អ គឺធ្វើល្អ, និយាយល្អនិងគិតល្អ ដោយមានចេតនាដែលប្រកបដោយការអៀនខ្មាសនៃចិត្តនិងខ្លាចក្រែងខុសឬខ្លាចទោសទុក្ខជាគ្រឿងនាំមុខ, មានការដឹងខុស-ត្រូវជាប្រតិកូ, មានសេចក្ដីត្រូវបរិសុទ្ធស្អាតហ្មត់ចត់ផូរផង់ ជាលក្ខណៈ រាប់ថាជាគោលរបស់ជីវិតដែលមានឧបាយជាន់ខ្ពស់ ។

“ទុច្ចរិត” ជាពាក្យហៅអំពើអាក្រក់ដោយរួបរួម មានសារៈសំខាន់នៅត្រង់ការប្រព្រឹត្តអាក្រក់គឺធ្វើអាក្រក់, និយាយអាក្រក់និងគិតអាក្រក់ដោយមានចេតនាដែលឥតអៀនខ្មាសនិងមុខរឹងជាគ្រឿងដឹកមុខ, ប្រកបដោយសេចក្ដីល្ងង់ខ្លៅវង្វេងវិលវល់ ជាឫសគល់ មានអធ្យាស្រ័យនិងសេចក្ដីប្រព្រឹត្តជារបស់ពារុទ្ធ ខុសក្បាំងក្បាត់ សៅហ្មងលាមកមិនមានរស្មី ជាលក្ខណៈ រាប់ថាជាគោលជីវិតដែលមានឧបាយជាន់ទាប ។ អញ្ជើញរើសយកគោលរបស់ជីវិតដែលមានឧបាយជាន់ខ្ពស់មកប្រើចុះ ។ ព្រោះយើងកើតមកមានទាំងអ្នកមើលទាំងអ្នកបង្ហាញ ។ តែគួរមើលដើម្បីឲ្យកើតជាបែបផែននៃសុចរិតនិងគួរបង្ហាញបែបផែននៃសុចរិត ក្នុងកាលដែលដឹងហើយឲ្យឃើញថាសុចរិតនោះគឺអ្វី ។

បើយើងខ្មាសសេចក្តីអាក្រក់ នឹងខ្លាចក្រែងសេចក្តីខុសហើយ ក៏អាចវៀរចាកការធ្វើទុច្ចរិតបានជានិច្ច នឹងធ្វើនិយាយគិតអ្វី មិនចូលក្នុងលក្ខណៈនៃទុច្ចរិត ធ្វើតែការងារល្អដែលជាកាយសុចរិត និយាយតែពាក្យសុភាសិតដែលជាវចីសុចរិត គិតតែអំពើល្អ ដែលជាមនោសុចរិត ដែលខ្លួនឯងនឹងអ្នកដទៃតិះដៀលខ្លួនមិនបាន ទាំងអ្នកប្រាជ្ញ កាលបានពិចារណាហើយ ក៏សរសើរទៀត នេះឯងឈ្មោះថា ហើងប្រព្រឹត្តល្អ ៗ ការប្រព្រឹត្តល្អ តែងមិនត្រូវខ្មាសនឹងខ្លាចមិត្តភក្តិមនុស្សដូចគ្នា ៗ ឯមនុស្សដែលឥតខ្មាសមុខរាំង ប្រព្រឹត្តអាក្រក់បានទាំងទីវាល ទាំងទីកំបាំងវិញតែងត្រូវអៀនខ្មាសនឹងស្លុតចិត្តខ្លាចមិត្តភក្តិក្នុងកាលជាខាងក្រោយ ៗ ដូច្នេះលក្ខណៈនៃសុចរិត ទើបនៅត្រង់ការមិនធ្វើអាក្រក់ មិននិយាយអាក្រក់ នឹងមិនគិតអាក្រក់ មានលក្ខណៈល្អប្រាកដនៅក្នុងរូបបុគ្គលជា ៥ ប្រការ គឺសុចរិតក្នុងធម្មចរិយា, សុចរិតក្នុងបុគ្គល, សុចរិតក្នុងការអាជីវៈ, សុចរិតក្នុងការងារ នឹងសុចរិតក្នុងមុខក្រសួង ៗ

១ — សុចរិតក្នុងធម្មចរិយា — ធម្មចរិយាជាសេចក្តីល្អរបស់មនុស្ស ៗ ការអប់រំខ្លួនឲ្យមានធម្មចរិយា សំខាន់ជាងការអប់រំខ្លួនឲ្យមានវិជ្ជា ៗ ពិតមែន យើងនឹងទៅជាមនុស្សឈ្លាសវៃ មានសេចក្តីល្អពិសេសចំណែកខ្លួនឡើង ក៏ដោយសារតែវិជ្ជា ចូលក្នុងលក្ខណៈថា "ចេះអ្វីមិនស្មើនឹងចេះវិជ្ជា" តែបើយើងមានធម្មចរិយាប្រកបគ្នាផង ក៏រឹង

រឹតតែប្រសើរក្រៃលែង នៅក្នុងលក្ខណៈថា "ចេះរក្សាខ្លួនឲ្យបានល្អបំផុត" ។ សេចក្ដីចេះដឹងមិនមែននាំទៅកាន់ធម្មចរិយាបានបន្តិចបន្តួចទេ ។ អ្នករៀនបានចេះដឹងត្រឡប់ទៅជាចេះខូច ចេះច្រើនឡើងរឹតតែខូចខ្លាំងឡើង សូម្បីវិជ្ជាជារបស់ឲ្យកើតសេចក្ដីឈ្លាសវៃក៏ពិត ប៉ុន្តែសេចក្ដីឈ្លាសវៃនោះ អាចឲ្យផលទាំងខាងល្អទាំងខាងអាក្រក់ មិនទៀងទាត់ ស្រេចហើយតែអ្នកប្រើឈ្លាសវៃខាងត្រូវផ្លូវឬខុសផ្លូវ ។ តាមពិត ការចេះដឹងរបស់មនុស្សយើង ផ្ដើមមកអំពីបញ្ញាសេចក្ដីគិតរបស់អ្នកប្រាជ្ញរាជបណ្ឌិត តែបើមនុស្សយកមាត់ដ៏ស្មោកគ្រោក ទៅទទួលសេចក្ដីចេះដឹងនោះមកបរិយាយចេញ មនុស្សដទៃក៏មិនបង្អោនចិត្តស្ដាប់ឡើយ ប្រៀបដូចបាយស្អាតតែភាជនៈដែលដាក់បាយនោះស្មោកគ្រោក ក៏មិនមាននរណានឹងបរិភោគដូច្នោះ ។

ចំណែកធម្មចរិយា ជារបស់ទៀងតែធ្វើឲ្យអ្នកប្រព្រឹត្តបានទៅជាមនុស្សល្អពិតៗ ។ អ្នកមានចំណេះវិជ្ជា នឹងខ្ជាប់ខ្លួននៅក្នុងធម្មចរិយា កាលបានចេះច្រើនឡើង រឹងរឹតតែប្រើចំណេះនោះក្នុងផ្លូវសុចរិតច្រើនដែរ ជួយការរកចិញ្ចឹមជីវិតឲ្យរុងរឿងជាប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ មិនមែនយកចំណេះនោះទៅប្រើយកមុខឬបៀតបៀនមនុស្សផងគ្នាទេ ។ ចូរនាំគ្នាជួយស្អប់មនុស្សដែលចេះច្រើន តែចេះខាងវៀចខ្ជិលធ្វើការងារ ក្អឹតក្អឹនតែខាងដំកើងខ្លួន ខ្លាចសេចក្ដីលំបាកនឿយហត់ ល្អតែខាងទៅ

ប្រជុំបរិភោគពោរសក្អែលរបស់មនុស្សល្ងង់ ។ ត្រូវនាំគ្នាជួយស្រឡាញ់មនុស្សបេះដូងច្រើន តាំងល្បាសក្កុងផ្លូវត្រូវខំប្រឹងប្រែងធ្វើការចិញ្ចឹមជីវិតសម្បូរជាការលំបាក ក៏មិនរួញរា បេះប្រយ័ត្ន ជាមនុស្សធ្វើការងារដែលត្រូវ ... សីលធម៌បានគ្រប់បែប និងដើរតាមមាគ៌ារបស់មនុស្សដែលមានសីលធម៌ ។

ពិតមែន អារ្យជាតិនោះ គឺមនុស្សជាតិដែលទទួលកប់រងធម្មចរិយា ។ មនុស្សសម្បូរបានរៀនបេះដូងចប់សព្វគ្រប់ក៏ដោយ បើមិនប្រតិបត្តិឲ្យត្រូវតាមគន្លងធម្មចរិយាទេ ក៏ត្រឡប់ជាមនុស្សព្រៃផ្សៃវង្វេងទៅវិញ លុះតែបានប្រព្រឹត្តត្រឹមត្រូវតាមគន្លងធម្មចរិយាផង ទើបចាត់ថាជាមនុស្សបេះចប់ ។ មើលចុះ ថ្នាំដែលពេទ្យផ្សំយ៉ាងល្អបើមានតែឈ្មោះល្អ ក៏និងរក្សាពេគរបស់អ្នកជម្ងឺឲ្យជាពុំបាន ។ មនុស្សយើងក៏ដូចគ្នា មានចំណេះវិជ្ជាច្រើន តែប្រព្រឹត្តអាក្រក់ ជាទំនាស់នឹងមតិរបស់មនុស្សដទៃហើយ ក៏រមែងជាមនុស្សមានចំណេះសម្រាប់ខ្លួន យោងខ្លួនមិនរួច មិនល្អអ្វីជាងមនុស្សល្ងង់ដែលប្រព្រឹត្តល្អត្រូវតាមមតិរបស់អ្នកដទៃនោះឡើយ ។ ក្នុងលោកនេះមិនមានវត្ថុអ្វីជាខ្លឹមសាររបស់មនុស្ស ឲ្យក្រៃលែងជាងការទទួលកប់រងថាកាយវាចាចិត្តជាសុចរិតឡើយ សុចរិតនេះឯងជារបស់ល្អក្រៃលែង ។

ហេតុនេះ ទើបយើងមិនត្រូវគិតតែពីរៀនវិជ្ជាម្យ៉ាងឡើយ គួរបណ្ដុះសុចរិតក្នុងធម្មចរិយាឲ្យកើតឡើងព្រមគ្នាផង, ព្រោះ ..

អ្នកសូត្ររៀន បើគ្មានធ-ម្មចរិយា
មិនអាចតាំង ទីអាត្មា បានយូរឡើយ
ប្រព្រឹត្តខុស ធម៌រឿយៗ មិនអស់ហើយ
ផលដល់ត្រើយ គឺបង្អោន ខ្លួនចូលគុក ។

បើយើងអប់រំខ្លួនឲ្យមានវិជ្ជា នឹងប្រតិបត្តិត្រូវតាមគន្លងធម្មចរិយា រក្សាការប្រព្រឹត្តិរបស់ខ្លួនឲ្យសុចរិត ទៀងត្រង់ចំពោះប្រយោជន៍ទឹងបំណងរបស់មនុស្ស មិនធ្វើអំពើដែលត្រូវចិត្តតែខ្លួនម្នាក់ឯង ព្យាយាមធ្វើតែរបស់ដែលមនុស្សល្អច្រើនគ្នានិយមធ្វើ ធ្វើតែអំពើដែលជាទីគាប់ចិត្តរបស់មនុស្សល្អច្រើនគ្នា នឹងធ្វើ-និយាយ-គិតអ្វីក៏តាំងនៅតែក្នុងលក្ខណៈនៃសុចរិត លះវៀរកិច្ចដែលអាក្រក់ៗ គ្រប់យ៉ាងបានហើយ យើងនឹងបានឈ្មោះថាជាមនុស្សសុចរិតក្នុងធម្មចរិយា ។

ដំរីសារ ចូលកាន់សង្គ្រាម មិនលះបង់លំនាំលីលាកែក្រាយ, ខ្លឹមចន្ទន៍ ទោះស្ងួតក្រៀម ក៏មិនលះបង់ក្លិនក្រអូប, អំពៅ ទោះត្រូវឃ្នាប ក៏មិនបាត់រសផ្អែមល្ហែមតាមប្រក្រតី នេះយ៉ាងណា មនុស្សសុចរិតក្នុងធម្មចរិយា ក៏យ៉ាងនោះដែរ សូម្បីបានទុក្ខលំបាកគោកយ៉ាកយ៉ាងណា ក៏នៅតែខ្ជាប់ខ្ជួនក្នុងធម្មចរិយាជានិច្ច ដូចភាសិតក្នុងលោកនីតិថា

ជាតិខ្លឹមចន្ទន៍ ទោះក្រៀម ស្ងួតក្រញង់
មិនលះបង់ ក្លិនក្អូប សុគន្ធា

ដំរីសារ ទោះចូល សឹកយុទ្ធនា
មិនលះបង់ លីលា លួងក្រាយ ៗ
ជាតិអំពៅ ទោះនៅ ក្នុងយន្តគាប
មិនលះបង់ សភាព រសផ្អែមសាយ
ជាតិបណ្ឌិត ទោះមាន ទុក្ខក្នុងកាយ
មិនដិនណាយ លះបង់ ព្រះធម៌ថ្លៃ ៗ

បណ្ឌិតជន តែងមានអាហារត្រឹមតែដើម្បីឲ្យជីវិតរស់នៅ តែងប៉ងក្នុងការប្រព្រឹត្តិធម៌ជាសំខាន់ មិនកាន់យកគ្រឿងបំណងខាងក្រៅឲ្យជាហេតុនៃធម៌ ស្វែងរកសេចក្ដីសំពន្ធដោយឧបាយដ៏សុចរិត ដែលមិនធ្វើឲ្យមនុស្សដទៃបានទទួលទុក្ខ រន្ធត់ខ្លាចចំពោះការកាន់សិទ្ធិដែលមិនមែនជាធម៌ ដូចជាក្រែងខ្លាចចំពោះថ្នាំបំពុលក្នុងអាហារដូច្នោះ ទើបបានឈ្មោះថាគន្លងនរកដែលជារណ្ដៅដ៏លំបាកផុតទៅបាន ៗ នរកមិនមាននរណាសាងឲ្យនរណាទេ គឺចិត្តទុច្ចរិតរបស់ខ្លួនហ្នឹងឯងសាងឲ្យកើតឡើងសម្រាប់ដុតខ្លួនឯង ៗ បើនរណាធ្វើទុច្ចរិត អ្នកនោះឈ្មោះថាបង្កាត់ភ្លើងនរកឡើងខ្លួនឯង ទឹងត្រូវភ្លើងនរករបស់ខ្លួនឆេះខ្លួនឯងឲ្យក្ដៅក្រហាយជរាបទៅអស់ ១ ជាតិ ៗ (មានត)

# រឿងសាមកុក

## កណ្ឌទី ១២

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> **រឿងសាមកុកទុកជាយុទ្ធសាស្ត្រ**
> **អ្នករាងវៃឆ្លាសបើបានអាន**
> **នឹងបេះឧបាយកលបំណាន**
> **ទាំងមានសន្ដានស្នេហាជាតិ ។**

ចាប់តាំងពីអ៊ួនស៊ុតចៅហ្វាយស្រុកឡាំយ៉ុង រៀបជប់លៀងនាហ្មឺនសព្វមុខមន្ត្រីរហូតដល់ស៊ុនសិកលើកទ័ពទៅច្បាំងនឹងងៀមប៉ិះហ ដែលតាំងខ្លួនជាស្ដេចនៅស្រុកតងង៉ ។

---

ឯគួនអ៊ូ តៀវហ៊ុយ ក៏នៅចាំចិត្តគិតព្យាបាទលីប៉ោជាដរាប ។ ឡៀតីដឹងក្នុងកិរិយា គួនអ៊ូ តៀវហ៊ុយ ក៏និយាយលួងលោមថា ចៅទាំង ២ កុំអាលគិតធ្វើការអ្វីឲ្យវឹកវរចលាចលឡើយ ចូរទ្រាំទំរាំតែបានឱកាសល្អរបស់យើងសឹមគិតការតទៅ ។ ចំណែកឯលីប៉ោ ក៏បញ្ជូនរបស់គួរសមទៅឲ្យឡៀតីជារឿយៗ ឡៀតីនឹងលីប៉ោក៏រាប់អានគ្នាជាប្រក្រតី ដោយមេត្រីដ៏ស្មោះសរដរាបមក ។

ចំណែកអ៊ួនស៊ុតចៅហ្វាយស្រុកឡាំយ៉ុងនោះ មាន ១ ថ្ងៃក៏ឲ្យរៀបតុៈតាំងលៀងអាហារភោជន អស់បណ្ដានាហ្មឺនសព្វមុខមន្ត្រីទាំងពួង,

កាលកំពុងបរិភោគអាហារ ទទួលស៊ុនសិកនៅស្រុកកាំងតាំង ដែលវិលពីច្បាំងយកស្រុកលោកាំងបាន ចូលទៅរកអ៊ួនស៊ុត។ ក្រឡេកឃើញស៊ុនសិក ក៏ចាប់ដឹកដៃឲ្យចូលទៅបរិភោគជាមួយ ។

ឯស៊ុនសិកនេះ នឹងបានជាបាវព្រាវអ៊ួនស៊ុតពីដើមក៏ទេ គឺជាបុត្ររបស់ស៊ុនគៀន លុះដល់ស៊ុនគៀនជាបិតាស្លាប់ទៅក៏លើកទៅនៅស្រុកកាំងណាំ កាលដែលតោគៀមចៅហ្វាយស្រុកឈីជីវនៅមិនទាន់ស្លាប់ ទាស់គ្នានឹងងីកេងចៅហ្វាយស្រុកតាន់អៀងជាមាស៊ុនសិក។ នឹងនៅក្នុងស្រុកកាំងណាំឃើញមិនសុខ ព្រោះស្រុកនោះចំណុះស្រុកឈីជីវ ស៊ុនសិកក៏នាំមាតានឹងគ្រប់គ្រួទៅទុកឯតំបន់ខយ៉ុកទុ ជិតស្រុកតាន់អៀង ឯខ្លួនស៊ុនសិកទៅនៅធ្វើរាជការជាមួយនឹងអ៊ួនស៊ុត។ ស្រឡាញ់រាប់អានតាំងឲ្យធ្វើកៅអ៊ុយនាយទាហាន បានប្រើឲ្យទៅវាយយកស្រុកកេងគួនបាន ១ គ្រា ហើយថែមទៅវាយយកបានស្រុកលោកាំងទៀត មានសេចក្តីគាប់ប្រសើរណាស់ តែអ៊ួនស៊ុតមិនឲ្យបំណាច់រង្វាន់ គ្រាន់តែឲ្យស៊ីលៀង, លុះបរិភោគរួចហើយនាហ្មឺនតាំងតួងក៏លាទៅអស់ ស៊ុនសិកក៏លាអ៊ួនស៊ុតទៅផ្ទះ ហើយដើរលេងក្នុងសួនផ្កាក្រោយផ្ទះខ្លួន នឹកក្រំក្រួនតូចចិត្តណាស់ថា ព្រោះអ៊ួនស៊ុតមិនសូវរាប់អាន ស៊ុនសិកអង្គុយយំក្នុងសួននោះ ។ ទទួលជូទីជាសេនាស៊ុនគៀនជាបិតាស៊ុនសិក ដើរទៅប្រទះឃើញស៊ុនសិកកំពុងអង្គុយយំ ជូទីក៏សើចហើយថា កាលបិតាអ្នក

រស់នៅ នឹងគិតផ្ដើមធ្វើការអ្វី តែងពិគ្រោះនឹងយើងគ្រប់គ្រា ឥឡូវអ្នក ទោមនស្សទាស់ចិត្តដូចម្ដេច ទើបបានជាមិនដែលពិគ្រោះនឹងយើងដល់ម្ដងសោះ ហើយបែរជាមកអង្គុយយំដូច្នេះ ៗ ស៊ុនសិកក្រឡេកទៅឃើញដូទីក៏បានធូរស្រាលក្នុងចិត្ត ហើយអញ្ជើញដូទីឲ្យអង្គុយជិតប្រារព្ធនិយាយថា ខ្ញុំបានធ្វើសេចក្ដីគាប់ប្រសើរដល់អួនស៊ុតជាច្រើនលើកមកហើយ ម្ដេចឡើយគេមិនសូវរាប់អានខ្ញុំសោះ ហេតុនេះបានជាខ្ញុំឈឺចិត្តមកអង្គុយយំដូច្នេះ បើខ្ញុំនឹងគិតធ្វើការតទៅឲ្យដូចបិតា ឃើញថាកម្លាំងនឹងសតិបញ្ញាក៏គិតមិនផុះផ្លាយ ៗ

ដូទីតបថា ខ្លួនអ្នកមានត្រកូលខ្ពង់ខ្ពស់ឧត្ដុង្គឧត្ដម នឹងមកអង្គុយយំដូច្នេះ ដូចមិនមែនជាជាតិទាហាន ឲ្យអ្នកគិតអានចូលទៅនិយាយនឹងអួនស៊ុត សុំទាហានលើកទៅជួយចិនកេងដែលជាមាអ្នក នៅស្រុកតាន់អៀងគង់នឹងមានកម្លាំងខ្លាំងឡើង ៗ ទទួលលីហាមទីប្រឹក្សាអួនស៊ុតចូលទៅរកស៊ុនសិក ព្រដូទីនិយាយនឹងស៊ុនសិកក៏ឈរអែបស្ដាប់សព្វសេចក្ដី ហើយក៏ដើរចូលទៅនិយាយនឹងស៊ុនសិកថា ដែលអ្នកគិតគ្នាអម្បាញ់មិញនេះល្អណាស់ ទាហានរបស់ខ្ញុំដែលមានថ្វីដៃខ្លាំងពូកែមានដល់ ១០០ នាក់ ចិត្តរាប់ចង់ធ្វើការនឹងអ្នកណាស់ តែខ្ញុំក្រែងអួនស៊ុតមិនព្រមឲ្យទាហាន ៗ ស៊ុនសិកថា "អ្នកកុំមានសេចក្ដីព្រួយ ត្រាផ្ទាក់សម្រាប់ព្រះមហាក្សត្ររបស់បិតាខ្ញុំក៏មាននៅនឹងខ្ញុំ ៗ នឹងនាំត្រានោះ ទៅជូន

អ៊ួនស៊ិតៗ អស់សង្ស័យគង់នឹងឲ្យទាហានមកខ្ញុំដោយងាយ” និយាយហើយក៏ចូលទៅរកអ៊ួនស៊ិតជំរាបថា តាំងពីបិតាខ្ញុំបាទអនិច្ចកម្មទៅ នៅមិនទាន់បានសងសឹកឡៅអ៊ីវសោះ ឥឡូវនេះ ខ្ញុំបាទនាំមាតានឹងភរិយាទៅផ្ញើទុកនឹងនីកេងជាមា ទៅតាន់អៀង; ឯឡៅអ៊ីវជាពូជព្រះពង្សព្រះចៅហៀនគេធ្វើការសព្វថ្ងៃមែងបៀតបៀនបណ្ដារាស្ត្រតាមអំពើចិត្ត ខ្ញុំបាទទើបគិតនាំយកត្រាថ្នាក់នេះមកប្រចាំទុកនឹងលោក សុំលោកឲ្យទាហានលើកទៅជួយនីកេងជាមា ខ្ញុំបាទនឹងបានសងសឹកឡៅអ៊ីវ ។

ចំណែកអ៊ួនស៊ិតបានឃើញត្រាថ្នាក់ដូច្នោះ ក៏មានចិត្តត្រេកអរជាពន្លឹក ទទួលយកមកមើលហើយធ្វើជាថា “យើងនឹងប្រាថ្នាអ្វីដល់ត្រាថ្នាក់នោះ តែបើអ្នកបានដាយកមកហើយក៏ត្រូវរក្សាទុកឲ្យ” និយាយហើយក៏ចាត់ទាហាន ៣ ពាន់ នឹងសេះ ៥០០ ឲ្យស៊ុនសិកហើយផ្ដាំថា បើអ្នកទៅធ្វើការបានសម្រេចសេចក្ដីប្រាថ្នាហើយចូរត្រឡប់មកវិញ កុំអាលធ្វើការអ្វីតទៅទៀត ព្រោះខ្លួនអ្នកនៅក្មេងសេចក្ដីគំនិតទាំងបណ្ដាស័ក្ដិក៏តូចណាស់ បើកាលណាអ្នកត្រឡប់មករកយើងនឹងតាំងឲ្យធ្វើជានាហ្មឺនធំឡើងទៀត ។

ស៊ុនសិកក៏សុំជូទនឹងលីហាមជាទីប្រឹក្សា សុំជៀកៅ, ហានគុង, អ៊ុយកាយជានាយទាហាន ដែលធ្លាប់ធ្វើការនឹងបិតានោះយកទៅផង ។ អ៊ួនស៊ិតក៏ព្រមព្រៀងប្រគល់ឲ្យពេលនោះ ។ ស៊ុនសិកក៏លើកព្យុហៈទ័ព

ចេញចាកស្រុកឡាំយ៉ុង តម្រង់ទៅកាន់ស្រុកតាន់អៀង ក៏បានជួបប្រទះនឹងជីវយីលើកតាហាននឹងទៅសួរមាតាឯស្រុកស៊ីសេង ។ ស៊ិនសិកក៏បញ្ឈប់ទ័ព ជីវយីក្រឡេកឃើញស៊ិនសិកក៏លោតចុះពីលើសេះ ទៅគំនាប់ស៊ិនសិកៗ ក៏គំនាប់តបវិញ ។

ឯជីវយីនោះ កាលបិតាស៊ិនសិករស់នៅទៅច្បាំងនឹងតាំងតុ:នោះ បិតាស៊ិនសិកបាននាំយកគ្រប់គ្រួសារទៅទុកឯស្រុកស៊ីសេង ជិតផ្ទះជីវយីៗ នឹងស៊ិនសិកក៏បានស្គាល់រាប់អានគ្នាមក តែស៊ិនសិកចាស់ជាងជីវយី ២ ខែ ជីវយីហៅថាបង ។

បណ្ដាអ្នកទាំង ២ នាក់ដែលបានជួបគ្នានោះ ស៊ិនសិកក៏ប្រាប់រឿងទាំងពួងឲ្យជីវយីស្ដាប់គ្រប់ប្រការ ។ ជីវយីស្ដាប់ហើយឆ្លើយថា ខ្ញុំនឹងសុំយកអាសាចូលធ្វើការជាមួយនឹងអ្នក នឹងបានជួយគ្នាគិតការធំទៅ ។ ស៊ិនសិកតបថា ប្រសិនបើអ្នកស្ម័គ្រចិត្តគិតមកនៅនឹងយើងហើយ ការដែលយើងគិតទុកទាំងប៉ុន្មាន ក៏គង់នឹងបានសម្រេចដោយងាយ" ហើយក៏នាំជីវយីទៅនិយាយគ្នានឹងជូទី, លីហាម ។ ជីវយីជំរាបថា ក្នុងស្រុកកាំងតាំងនោះមានមនុស្សល្អ ២ នាក់ អ្នកដែលឮដែរឬ? ។ ស៊ិនសិកសួរថា អ្នក ២ នាក់នោះឈ្មោះអ្វី? ។ ជីវយីថា ម្នាក់ឈ្មោះតៀវដៀវជាពួកអ្នកស្រុកផេងសៀ ម្នាក់ទៀតឈ្មោះតៀវហៀនជាពួកអ្នកស្រុកកងឡេង អ្នកទាំងពីរនេះមានប្រាជ្ញាឆ្លៀវឆ្លាតណាស់ ឥឡូវគេពីបោរមកនៅស្រុក

កាំងតាំង អ្នកបូរទំរិះគិតយកចិត្តមនុស្សទាំង២ ឲ្យបានចូលមកជួយធ្វើការតទៅ ៗ ស៊ុនសិកត្រេកអរណាស់ក៏ចាត់ប្រើទាហាន ឲ្យនាំយកគ្រឿងឧបភោគនឹងបរិភោគជាច្រើនមុខ យកទៅជូនតៀវជៀវ នឹងតៀវហៀន ហើយឲ្យអញ្ជើញចូលមក នោះឈ្មោះទាំង២ ក៏បានចូលមករកស៊ុនសិកៗ ក៏ពណ៌នារឿងរ៉ាវទាំងពួងឲ្យស្ដាប់ ៗ តៀវជៀវ, តៀវហៀនព្រមចូលធ្វើរាជការជាមួយនឹងស៊ុនសិកៗ ក៏តាំងតៀវជៀវជាធំ ត្រួតទាហានឆ្វេងស្ដាំ តាំងតៀវហៀនជាទីប្រឹក្សា លុះប្រជុំគ្នារួចស្រេចហើយ ក៏ប្រុងប្រៀបរៀបនឹងលើកទ័ពទៅវាយឡាវអ៊ីវនៅតំបន់ខយ៉ុកឧ ៗ

ឯឡាវអ៊ីវនេះ កាលពីដើមនៅស្រុកអេងជីវ ក្រោយមកនៅស្រុកឈីវឈុន កាលគ្រាអ៊ួនស៊ុតលើកទ័ពមកច្បាំង ក៏រត់មកតាំងនៅតំបន់ខយ៉ុកឧ លុះដឹងថាស៊ុនសិកៈលើកទ័ពមក ទើបហៅទីប្រឹក្សាមកប្រជុំគិតគ្នាថា ឥឡូវស៊ុនសិកលើកទ័ពមកហើយតើយើងនឹងគិតធ្វើដូចម្ដេច? ៗ តៀវអេងនាយទាហានក៏ឆ្លើយទទួលយកអាសាថា ខ្ញុំនឹងសុំកងទ័ពទៅតាំងនៅតំបន់ងីវជូ ទីនោះមានទំនងស្រួលព្រោះជាទីទំនាប សូម្បីស៊ុនសិកនឹងលើកទ័ពមកប៉ុន្មានរយម៉ឺនក៏ល្មមនឹងតស៊ូបាន ៗ

ថៃស៊ូជូបានឮតៀវអេងនិយាយក៏យល់ឃើញត្រូវ ចេញទទួលយកអាសាសុំទាហានលើកទៅជាទ័ពស្រួច ៗ ឡាវអ៊ីវមិនព្រមថា ខ្លួនឯងនៅក្មេងសេចក្ដីណាស់ បើនឹងតាំងជានាយទ័ពក៏នៅមិនទាន់ទុកចិត្ត ៗ

ស៊ីជូខឹងណាស់ក៏នៅស្ងៀម ទៀវអ៊ីវក៏ចាត់ចែងសេនាទាហានឲ្យតៀវថៃអេងទៅតាំងនៅតំបន់ងីវជូ តៀវអេងក៏តាំងទ័ពខ្ជាប់ខ្ជួន ហើយក៏ហ្វឹកហាត់ទាហានហើយប្រមូលយកស្រូវមកដាក់ជង្រុកទុកនៅតំបន់ គេកោះប្រហែល ១ ម៉ឺនថាំង ។

ឯស៊ិនសិកលុះលើកកងទ័ពទៅឈប់នៅតំបន់ងីវជូ ក៏ជួបប្រទះនឹងទ័ពតៀវអេងៗ ស្រែកជេរជាពាក្យអាស្រូវកាសផ្សេងៗ ឲ្យស៊ិនសិកៗ ខឹងណាស់ ក៏ប្រើអ៊ុយកាយចេញទៅតយុទ្ធនឹងតៀវអេងបាន ៥ ក្រុង ។

ក្នុងខណៈនោះ ឈ្មោះជីវយិមជាពួកស្រុកឈីវឈុនទឹងជីវថាយជាពួកស្រុកហៃឈដែលធ្វើជាចោរនៅក្នុងព្រៃ លុះឮដំណឹងថា ស៊ិនសិកជាមនុស្សមានប្រាជ្ញាវិះគិតចិត្តក៏ល្អនឹងអាណាប្រជានុរាស្ត្រ មេចោរទាំងពីរនេះក៏នាំបក្សពួកប្រហែល ៣០០ នាក់ លើកមកប្រាថ្នានឹងចូលនៅជាពួកស៊ិនសិក លុះមកដល់តំបន់ងីវជូឃើញស៊ិនសិកនឹងតៀវអេងកំពុងច្បាំងគ្នាជាប់ដៃ ជីវយិម ជីវថាយក៏លបចូលទៅដុតភ្លើងក្នុងបន្ទាយតៀវអេង ទាហានក្នុងបន្ទាយឃើញភ្លើងឆេះរាលឡើង ក៏រត់ទៅប្រាប់តៀវអេងៗ ភ័យស្លុតក៏រត់ពីក្នុងស្នាមចម្បាំងចូលក្នុងបន្ទាយ ។ ស៊ិនសិកឃើញបានការក៏បរពលចូលទៅដេញកាប់ទ័ពតៀវអេងៗ ចូលបន្ទាយមិនទាន់ក៏រត់ចោលទាហាន ពានកាត់ព្រៃត្រឡប់ទៅដល់តំបន់ខយ៉ុកជុវិញ ។ ពេលនោះស៊ិនសិកឲ្យទាហានរើសយកបានគ្រឿងសស្ត្រាវុធ នឹងរបស់

ទ្រព្យសម្បត្តិទាំងពួងជាច្រើនក្រៃលែង ហើយតាំងបញ្ចុះបញ្ចូលទាហានបានប្រហែល ៤ ពាន់ក្ងាយ រួចលើកទៅបោះទ័ពផ្ទាប់ភ្នំខយ៉ុកទុ ៗ

ឯឡៅអ៊ីវ កាលឃើញតៀវអេងបែកទ័ពត្រឡប់មកក៏ខឹងណាស់ថា "ខ្ញុំសុំទទួលយកអាសាចេញទៅធ្វើការនឹងស៊ុនសិក ហេតុម្តេចក៏បែកទ័ពត្រឡប់មកតែខ្លួន" ថាហើយបង្គាប់ទាហានឲ្យចាប់តៀវអេងយកទៅសម្លាប់ ៗ ខណៈនោះធុកយ៉ុង, ស៊ីឡេជាទីប្រឹក្សា ក៏នាំគ្នាទៅអង្វរឡៅអ៊ីវថា តៀវអេងជាសេនាមានប៉ុនដៃខ្លាំងពូកែ បើលោកឲ្យយកទៅសម្លាប់គ្រានេះ ដឹងទៅដល់ស៊ុនសិកហើយក៏នឹងបានចិត្តឥតកោតខ្លាច ឥឡូវខ្ញុំសុំឲ្យតៀវអេងលើកទ័ពទៅតាំងនៅស្រុកកង់ឡេងម្តងទៀត ដើម្បីនឹងបាំងទទួលទ័ពស៊ុនសិកយកជ័យជំនះឲ្យបាន ៗ ឡៅអ៊ីវបានស្ដាប់ក៏ត្រឡប់លើកទោស ព្រមឲ្យតៀវអេងលើកកងទ័ពទៅតាំងតាមពាក្យធុកយ៉ុងស៊ីឡេថានោះ ៗ តែឡៅអ៊ីវនៅមិនទុកចិត្ត ខ្លាចស៊ុនសិកនឹងលើកទាហានពីខាងជើងមក ក៏លើកទ័ពទៅតាំងនៅជើងភ្នំ ស៊ុនតេង ខាងទិសឯជើង ៗ

ស៊ុនសិកលើកទ័ពទៅដល់ភ្នំស៊ុនតេង ក៏បោះទ័ពផ្ទាប់ជើងភ្នំខាងត្បូង ហើយឲ្យគេហៅអ្នកស្រុកសួរថា ទីភ្នំស៊ុនតេងនេះមានរោង (សាល) ទេពារក្សឬទេ? ៗ អ្នកស្រុកប្រាប់ថា មាននៅលើកំពូលភ្នំ ៗ ស៊ុនសិកនិយាយថាកាលពីយប់មិញ យើងយល់សប្តិឃើញថា មានទេពារក្សឲ្យមករកយើងឡើងទៅ ឥឡូវនេះយើងនឹងឡើងទៅគោរពទេពារក្សនោះ

សិនទើបគួរ ៗ តៀវចៀវហាមឃាត់ថាដែលលោកនឹងទៅនោះ ខ្ញុំឃើញមិនស្រួលទេ ខ្លាចឡៅអ៊ុវដឹងនឹងលើកទាហានឡើងទៅចាំស្កាត់ធ្វើអន្តរាយដល់លោកពុំខាន ៗ ស៊ុនសិកមិនស្តាប់ក៏បាប់ខ្លួនឡើងជិះសេះទៅជាមួយនឹងទាហាន ១២ នាក់ ឡើងទៅដល់ពេង (សាល) ទេពារក្ស ហើយក៏ធ្វើអភិវាទនមស្ការបន់ស្រន់ថា "បើខ្ញុំបានស្រុកកាំងតាំងសម្រេចដូចចិត្តគិតវេលាណា ខ្ញុំនឹងឡើងមកធ្វើពលីកម្មបូជាវេលានោះ" លុះបន់ស្រន់ហើយក៏ចុះចាកទីនោះមកដល់កណ្តាលផ្លូវ បែរទៅពិគ្រោះនឹងទាហានទាំងពួងថា យើងចង់ទៅលបមើលទ័ពឡៅអ៊ុវនឹងក្បួនដូចម្តេចខ្លះ ៗ ទាហានទាំងអស់ក៏ហាមឃាត់ស៊ុនសិកមិនស្តាប់ ក៏បរសេះនាំទាហាន ១២ នាក់ ជ្រៀតចេញទៅតាមជើងភ្នំ ៗ

ឯទាហានឡៅអ៊ុវឃើញស៊ុនសិកច្បាស់ ក៏រូតរះរត់ទៅប្រាប់ឡៅអ៊ុវថា ឥឡូវស៊ុនសិកនឹងទាហានប្រមាណ ១១ ឬ ១២ នាក់ កន្ទុងឡើងមកលើកំពូលភ្នំ ៗ ឡៅអ៊ុវដឹងសេចក្តីហើយក៏គិតសង្ស័យថា ដែលស៊ុនសិកឡើងទៅលើភ្នំនោះ ប្រហែលប្រើឧបាយ បញ្ឆោតយើងជាកលសឹកទេដឹង យើងកុំទៅឡើយ ៗ ថៃស៊ូជូឆ្លើយឡើងថា "គ្រោះនេះបានការល្អហើយ ហេតុម្តេចមិនគិតចាប់ខ្លួនស៊ុនសិក លោកនឹងបង្អង់ទុកដល់ណាទៅទៀត" ថាហើយថៃស៊ូជូក៏កាន់ខ្លួនឡើងជិះសេះចេញទៅបញ្ឈរនៅមុខបន្ទាយ ហើយស្រែកប្រកាសដល់ទាហានទាំងពួងថា ឥឡូវនឹងចេញ

ទៅចាប់ខ្លួនស៊ិនសិក អ្នកឯណាដែលមានថ្មីដៃខ្លាំងពូកែ ស្ម័គ្រចិត្តចូលធ្វើការជាមួយនឹងយើងក៏ឲ្យប្រញាប់ចេញមុខមក ។ ទាហានទាំងពួកក៏នៅស្ងៀម មានទាហានម្នាក់សរសេរថា ថៃស៊ីជូនេះមានថ្មីដៃខ្លាំងពូកែមែន យើងសុំទៅជាមួយផង ហើយក៏ឡើងជិះសេះតាមថៃស៊ីជូទៅ ។ ថៃស៊ីជូ២នាក់នឹងទាហាននោះក៏បរសេះឡើងទៅលើភ្នំ ទាហានក្មួនបន្ទាយទាំងប៉ុន្មានក៏បបួលគ្នាតាមមើលហើយនាំគ្នាសើច ។ ឯស៊ិនសិកនោះលុះក្រឡេកឃើញក្បួនទ័ពឡៅអ៊ីសេតូគ្រប់ ហើយក៏ញាក់សេះចុះពីលើភ្នំមកប្រទះនឹងថៃស៊ីជូៗ ស្រែកថា ស៊ិនសិកឯងរត់ទៅណា ស៊ិនសិកក្រឡេកមើលក្រោយឃើញទាហាន ២ នាក់បំផាយសេះតាម ស៊ិនសិកក៏ឲ្យទាហានបង្អង់នៅក្បែរជើងភ្នំ ខ្លួនឯងក៏បញ្ឈរសេះពីមុខទាហាន ថៃស៊ីជូមកជិតហើយស្រែកសួរថា នរណាឈ្មោះស៊ិនសិកនោះ? ។ ស៊ិនសិកឆ្លើយថា អញឈ្មោះស៊ិនសិកចុះខ្លួនឯងឈ្មោះអ្វី? ។ ថៃស៊ីជូឆ្លើយថា អញឈ្មោះថៃស៊ីជូនឹងមកចាប់ខ្លួនឯង ។ ស៊ិនសិកសើចហើយថា ឯងមកចាប់អញតែ ២ នាក់នេះអញមិនខ្លាចទេ បើត្រឡប់ខ្លាចវិញមិនពេញជាជាតិទាហាន ។ ថៃស៊ីជូឆ្លើយថា អញតែម្នាក់គត់ ឲ្យឯង ១២ នាក់ចេញមកគតចុះអញមិនខ្លាចទេ ។ ស៊ិនសិកខឹងណាស់បរសេះចូលប្រយុទ្ធនឹងថៃស៊ីជូបាន ៥ ក្បួន ថៃស៊ីជូឃើញកំឡាំងនឹងថ្មីដៃស៊ិនសិកខ្លាំងពូកែពេក ក៏ក្រឡះញាក់សេះថយរត់ទៅ ។

ស៊ិនសិកស្រែកថា តស៊ូគ្នាមិនបានបាញ់ឈ្នះម្ដេចក៏ក្រឡះរត់ទៅដូច្នេះ នេះហៅថាមិនមែនជាតិទាហានទេ ថៃស៊ូជូធ្វើជាមិនឮក៏ប្រែងបំផាយសេះបញ្ឆោតឲ្យដេញ ៗ ស៊ិនសិកក៏បរសេះដេញពីក្រោយទៅទាន់នៅតំបន់ផេងឈូន ថៃស៊ូជូក៏ងាកមកវិញតយុទ្ធគ្នាបាន ៥០ ក្បួន ស៊ិន-សិកយកទួនចាក់ថៃស៊ូជូៗ យកដៃចាប់ទួនជាប់ ថៃស៊ូជូយកទួនចាក់ស៊ិន-សិកវិញ ស៊ិនសិកយកដៃចាប់ទួនជាប់ទាំងសងខាង ទាំង ២ នាក់ក៏កន្ត្រាក់ដណ្ដើមទួនគ្នាទាល់តែរបូតធ្លាក់ពីលើសេះ ឯទួននោះក៏ក្លាត់របូតផុតពីដៃទាំងសងខាងនៅតែខ្លួនទទេ ទាំង ២ នាក់ក៏ក្រោកឡើងជាល់គ្នានឹងដៃទាល់តែក្រឹសទឹងអាវនោះរហែកជាប់អស់ ស៊ិនសិកកន្ត្រាក់យកទួនខ្លីដែលសៀតបង្កប់ពីក្រោយខ្នងថៃស៊ូជូបាន ថៃស៊ូជូក៏ដណ្ដើមបានមួកពីស៊ិនសិកៗ ចាក់ថៃស៊ូជូ នឹងទួនខ្លី ថៃស៊ូជូយកមួកស៊ិនសិករងជាប់ទទួលទាហានទាំងសងខាងតាមមកទាន់ ទាហានថៃស៊ូជូច្រើនប្រហែល ១ ពាន់ប្លាយ ទាហានស៊ិនសិកតែ ១២ នាក់ស្រែកហ៊ោជុំវិញ ស៊ិនសិកនឹងថៃស៊ូជូឃើញទាហានមកទាំងសងខាង ក៏ដោះថយផុតពីគ្នាទាំងសងខាង ថៃស៊ូជូក៏រត់ចូលទៅក្នុងហ្វូងទាហានកន្ត្រាក់បានទួន ១ ក៏ឡើងសេះបរចេញមកតនឹងស៊ុនសិកៗ ក៏ឡើងសេះកាន់ទួនតស៊ូគ្នាទៀត ស៊ិនសិកទាហានតិចណាស់ ក៏តក្លាំងរត់ថយក្លាំង ថៃស៊ូជូក៏ដេញតាមដល់មាត់បន្ទាយ ទទួលជីវយីឃើញក៏ឲ្យទាហានចេញទៅជួយ ស៊ិនសិកប្រយុទ្ធ

គ្នានឹងថៃស៊ូដូទាល់តែព្រលប់ងងឹត ធ្លាក់ព្រះវស្សាលក្រៀងធំក៏នាំគ្នាលើកទាហានចូលបន្ទាយទាំងសងខាង ។

ឯស៊ុនសិកនឹកខ្ញាញ់ក្តៅក្នុងចិត្តដេកមិនលក់ លុះព្រឹកឡើងស៊ុនសិកក៏លើកទាហានទៅដល់បន្ទាយឡៅអ៊ុវ១ ក៏លើកទាហានចេញពីបន្ទាយបង្ហាំងគ្នានឹងស៊ុនសិក ។ បរសេះចេញឈរពីមុខទាហាន ហើយយកមួនរបស់ថៃស៊ូដូដែលដណ្តើមបាននោះ លើកឡើងហើយស្រែកចំអកថាកាលពីម្សិលមិញ បើកុំតែថៃស៊ូដូរត់រួចទាន់កុំអីនឹងស្លាប់ដោយមួននេះ ។ ថៃស៊ូដូក៏ហើយក៏លើកមួកស៊ុនសិកឡើងហើយ ស្រែកចំអកតបថា "នេះក្បាលរបស់នរណាយើងយកបានមក" ទាំង ២ នាក់ក៏ចំអកឲ្យគ្នាទៅវិញទៅមក ។

ទើបឡៅអ៊ីរដេញឲ្យថៃស៊ូដូចេញទៅតយុទ្ធគ្នានឹងស៊ុនសិកម្តងទៀត ធៀកៅឃើញថៃស៊ូដូជិះសេះចេញមក ក៏បរសេះចេញទៅតយុទ្ធនឹងថៃស៊ូដូ ។ ក៏ស្រែកឲ្យធៀកៅថា ឯងជាមនុស្សថោកទាបណាស់ មិនសមមកតនឹងអញសោះ ឯងនឹងស្លាប់អសារឥតការ ឲ្យស៊ុនសិកចៅហ្វាយឯងចេញមកទើបសមគ្នានឹងដៃអញ ធៀកៅខឹងណាស់ក៏បរសេះចូលតយុទ្ធនឹងថៃស៊ូដូបាន ៣០ ក្បួន ។ (មានត)

# រឿងអារ័ក្សថ្លែងរឿងម្ភៃប្រាំ

## លោកវ៉ាយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

*ប្រែពីភាសាបារាំងមកជាខ្មែរ*

(តមក)

## រឿងទីប្រាំបួន

អារ័ក្សក្រាបបង្គំទូលមហារាជថា: "ពីអតីតកាល មានព្រះមហាក្សត្រមួយអង្គ ទ្រង់ព្រះនាមព្រះបាទពិរពរ (Birbar) សោយរាជសម្បត្តិនៅមទនបុរ: (Madanpur) (១) ។ នៅប្រទេសនោះមាននាយពាណិជម្នាក់ឈ្មោះហិរណ្យទត្ត (Hiranyadatt) (២) មានបុត្រីម្នាក់ ឈ្មោះនាងមទនសេនា (Madanséna) ។

មានមួយថ្ងៃ, ក្នុងនិទាឃៈរដូវ, នាងមទនសេនាបានអញ្ជើញទៅលេងក្នុងសួនមានទាសីជាច្រើន ហែហមទៅជាមួយ ។ តែមុននឹងនាងចេញចាកគេហដ្ឋានបន្តិច, មានបុរសម្នាក់ឈ្មោះសោមទត្ត (Somdatt) ជាបុត្រានាយពាណិជធម៌ទត្ត (Dharmdatt) បានទៅលេងព្រៃជាមួយនឹងមិត្តភក្តិជាច្រើន, ហើយដល់វិលត្រឡប់មកវិញ អ្នកទាំងនោះត្រាច់មកចំសួន ដែលនាងមទនសេនាកំពុងលេងសប្បាយជាមួយនឹងទាសី ។ ដល់ឃើញនាងមទនសេនា, សោមទត្តមានហាសនចិត្តព្រួចព្រឺពន់ពេក

---

១ ក្រុង មទន (ស្នេហា) ។ ២ កើតឡើងដោយមាស ។

ហើយលាន់មាត់ថា: "នុសំឡាញ់! បើខ្ញុំបាននាងនេះធ្វើជាភរិយា ជីវិតខ្ញុំប្រកបដោយសេចក្ដីសុខបម្រើន, បើមិនដូចនេះទេ, ជីវិតខ្ញុំក្នុងពិភពលោកនេះ ដូចជាប្រហោងគ្មានអ្វីជាទីពុំនាក់សោះឡើយ" ។ សោមទត្តពោលពាក្យដូចនេះ ក៏ចិត្តចូលទៅជិតនាងមទនសេនាដោយមិនដឹងខ្លួនហើយកាន់ដៃនាង រួចចេញវាចាថា: 'បើនាងមិនព្រមទទួលនូវសេចក្ដីស្នេហារបស់ខ្ញុំទេ ខ្ញុំធ្វើពលីជីវិតខ្ញុំដោយហេតុនាង" ។

នាងមទនសេនាតបទៅវិញថា "កុំអ្នកធ្វើកិរិយាបែបនេះ ព្រោះជាបាបអកុសល" ។

សោមទត្តពោលទៅនាងវិញថា: "វាចារបស់នាងពីរោះដូចឈើស្រចាក់ហទយវត្ថុរបស់ខ្ញុំ ហើយចក្ខុគិតឃាតពីនាងធ្វើរូបកាយខ្ញុំក្ដៅដូចភ្លើងឆេះ ។ សេចក្ដីទុក្ខលំបាកធ្វើឲ្យវិនាសនូវស្មារតី ទីងវិចារញ្ញាណរបស់ខ្ញុំ ហើយដោយសេចក្ដីស្នេហានោះមានសភាពក្លាហានពន់ពេកខ្ញុំទៅជាក្មេងន័យល្អបុគ្គគ្រក់ ។ តែសូមនាងសន្យាចំពោះខ្ញុំ, ជីវិតខ្ញុំនឹងត្រឡប់មកកាន់ហទយវត្ថុវិញ" ។

នាងមទនសេនាតបទៅវិញថា: "ខ្ញុំនឹងរៀបវិវាហមង្គលការខ្ញុំ ក្នុងរយៈវេលា ៥ ថ្ងៃខាងមុខ, តែមុននឹងខ្ញុំស្ថិតនៅជាមួយស្វាមី, ខ្ញុំនឹងប្រគល់ខ្លួនខ្ញុំជូនបងជាមុនសិន" ។

អ្នកទាំងពីរបានសន្យាគ្នាទៅវិញទៅមក ហើយធ្វើសច្ចាប្រណិធានក៏វិលត្រឡប់ទៅកាន់គេហដ្ឋានសព្វៗខ្លួនវិញ ។

លុះប្រាំថ្ងៃតមក, នាងមទនសេនាក៏រៀបវិវាហមង្គលការ រួចស្រេច, ស្វាមីនាងបាននាំនាងមកកាន់គេហដ្ឋាន ។ ដល់ស្ថិតនៅទីនោះ ក្នុងរយៈវេលាមិនបានប៉ុន្មានថ្ងៃ, បងថ្លៃស្រីទាំងពីរនាក់បានបង្ខំឲ្យនាងចូលទៅនិទ្រាជាមួយនឹងស្វាមីក្នុងពេលយប់ ។ នាងក៏ចូលទៅក្នុងបន្ទប់ផ្សំដំណេក, នាងអង្គុយស្ងៀមនៅគៀនជញ្ជាំង, ហើយកាលណាស្វាមីឃើញនាង, ស្វាមីនោះកាន់ដៃនាងហើយលើកនាងឲ្យអង្គុយលើគ្រែ ។ ដោយស្វាមីនាងឱបនាង ៗ មិនព្រម ហើយនាងថ្លែងជំរាបស្វាមីអំពីកិច្ចសន្យារបស់នាងចំពោះបុត្រពាណិជម្នាក់ ។ ស្វាមីនាងស្ដាប់សព្វាក់ចាសព្វគ្រប់ ក៏តបទៅនាងថា: "បើពិតជានាងចង់ឃើញបុរសនោះ ចូរនាងទៅចុះ" ។ នាងក៏ចេញពីគេហដ្ឋានតម្រង់ទៅកាន់ទីនោះ ។

មានចោរម្នាក់សប្បាយចិត្តពន់ពេក ដោយឃើញស្ត្រីនោះដើរតាមផ្លូវតែម្នាក់ឯង ៗ ក៏ចូលមកជិតនាងសួរថា: "តើនាងអញ្ជើញទៅណាតែម្នាក់ឯងក្នុងកណ្ដាលយប់ងងឹត, ស្លៀកពាក់ល្អហើយមានពាក់គ្រឿងមាសប្រាក់ពេញខ្លួន?" ។

នាងក៏តបទៅចោរវិញថា: "ខ្ញុំទៅកាន់ទីនៃបុរសដែលខ្ញុំស្រឡាញ់" ។

ចោរនោះសួរទៅនាងថា "តើអ្នកណាអាចការពារនាងបាន?" ។

នាងតបទៅវិញថា: "មទនៈ[១] នឹងព្រមទាំងសរទៅជាមួយនឹងខ្ញុំ, ការពារខ្ញុំ" ។

---

១ ឈ្មោះនៃកាមៈ គឺកាមទេព ។

រួចនាងក៏ថ្លែងរឿងសព្វគ្រប់ប្រការប្រាប់ចោរនោះហើយថា: "កុំឲ្យបំបាក់គ្រឿងមាសប្រាក់ខ្ញុំ ខ្ញុំសន្យានឹងអ្នកថាដល់ខ្ញុំវិលត្រឡប់មកវិញ, ខ្ញុំនឹងជូនគ្រឿងមាសប្រាក់មកអ្នកវិញមិនខាន" ។

ចោរនោះ ដល់បានស្តាប់សព្ទវាចានាងក៏គិតក្នុងចិត្តថា: "ម្តេចក៏អញដណ្តើមយកគ្រឿងមាសប្រាក់ពីនាង, បើនាងសន្យាថានឹងប្រគល់គ្រឿងប្រដាប់នេះមកឲ្យអញ?" ។ ចោរនោះគិតដូចនោះហើយក៏បើកឲ្យនាងនោះទៅ ។

នាងក៏ត្រាច់តម្រង់ទៅកាន់បន្ទប់នៃគេហដ្ឋាន ដែលសោមទត្តដេកលក់ ។ ដល់នាងទៅដល់, បុរសនោះក៏ភ្ញាក់ឡើង, ភ័យ, ក្រោកពីដំណេកសួរថា: "តើនាងជាបុត្រីព្រះអាទិទេព ឬសត្តបុគ្គល ឬពស់? ចូរប្រាប់ខ្ញុំឲ្យពិត, តើនាងឯងនៅឯណា, មកពីណា?" ។

នាងក៏ឆ្លើយតបទៅសោមទត្តថា "ខ្ញុំជាបុត្រីនៃមនុស្សជាតិ, ខ្ញុំជាបុត្រីនៃនាយពាណិជហិរណ្យទត្ត ឈ្មោះនាងមទនសេនា ។ តើអ្នកភ្លេចហើយ ដែលអ្នកចាប់ដៃខ្ញុំទាំងអំណាចទៅគុម្ពោតផ្កា? ។ តើអ្នកភ្លេចហើយអំពីរឿងឲ្យខ្ញុំធ្វើកិច្ចសន្យាថា ឲ្យបោះបង់ចោលស្វាមីខ្ញុំមកយកអ្នកវិញ? ឥឡូវខ្ញុំយកខ្លួនមកប្រគល់ជូនអ្នក, ស្រេចលើបំណងអ្នកចុះ" ។ សោមទត្តសួរនាងថា: "តើនាងបានពយរឿងប្រាប់ស្វាមីនាងគ្រប់សព្វឬទេ?" ។

នាងមទនសេនាតបទៅវិញថា: "ខ្ញុំបានជំរាបស្វាមីនូវរឿងរ៉ាវសព្វគ្រប់ប្រការ, ស្វាមីខ្ញុំក៏អនុញ្ញាតឲ្យខ្ញុំមករកអ្នក" ។

សោមទត្តគិតថា: នេះជាការមិនសមរម្យ, ដូចជាគេនៅត្រូវគ្មានគ្រឿងស្លៀកពាក់ម្ហូបអាហារ គ្មានឃី(១) ចម្រៀងគ្មានស្បូវពីរពេះ ។ ដូចជាគ្រឿងស្លៀកពាក់ប្រឡាក់ដោយមន្ទិលផ្សេងៗ ធ្វើឲ្យខូចនូវលំអរូបស្ត្រី, ដូចជាអាហារអាក្រក់ដកយកកម្លាំងចេញ, កិរិយាអាក្រក់ធ្វើឲ្យជីវភាពកករល្អក់ ហើយបុត្រអាក្រក់ធ្វើឲ្យអន្តរាយដល់គ្រួសារ... ពួកពាលស្ហសពីឃាដ, កាលពាំខឹងទោមនស្ស, តែនារីជាហេតុឲ្យកើតទុក្ខដោយនាងនេះស្នេហា ឬ ស្អប់ ។ ស្ត្រីមិនស្ទូវធ្វើកិច្ចការអាក្រក់ទេដោយហេតុថាចិត្តដែលនាងគិតមិនអាចផ្ទេរមកដល់មាត់នាងក្លាយទេ, សំដីដែលនៅទីងមាត់នាងមិនមានសភាពដូចគ្នា នឹងចិត្តដែលនាងគិត, ហើយនាងមិនដែលនិយាយអ្វីមានសភាពដូចគ្នា នឹងកិច្ចការដែលធ្វើ... ព្រះអាទិទេពទ្រង់ធ្វើវត្ថុប្លែកអស្ចារ្យ ដោយដាក់ស្ត្រីទៅលើផែនដីនេះ" ។

ដល់បានពិចារណាសព្វគ្រប់ សោមទត្តតបទៅនាងមទនសេនាវិញថា: "ខ្ញុំមិនចង់ប្រព្រឹត្តល្មើសនឹងប្រពន្ធអ្នកដទៃទេ" ។

ដោយសោមទត្តមិនព្រមទទួល, នាងក៏វិលត្រឡប់ទៅគេហដ្ឋានវិញ, នាងបានជួបប្រទះនឹងចោរតាមផ្លូវ, ហើយនាងក៏ថ្លែងនូវរឿងរ៉ាវដែលមានមកអម្បាញ់មិញនេះប្រាប់ចោរនោះ ។ ចោរនោះក៏ស្រែកឲ្យពរសព្វសាធុការនាងហើយបើកឲ្យនាងទៅ ។ ដល់នាងវិលត្រឡប់ទៅដល់ស្វាមីវិញ នាងក៏ជំពាបស្វាមីនូវព្រឹត្តិការណ៍នេះ, តែស្វាមីនោះលែង

១ ប្រហែលជាគ្មានគ្រឿង ។

សំដែងអាកប្បកិរិយាស្នេហាចំពោះនាង ហើយចេញវាចាថា: "សំឡេងជាលំអនៃបក្សីករវិក, ព្រហ្មចារ្យជាលំអនៃស្ត្រី វិជ្ជាជាលំអនៃប្រុសកាឡី, ការអត់អោនទោសជាលំអរបស់អ្នកទទួលទោស" ។

ដល់បាននិទានទូវរឿងរ៉ាវខាងលើនេះសព្វគ្រប់, អារក្សក្រាបទូលមហាក្សត្រថា: "ឱព្រះមហាក្សត្រ! តើមនុស្សទាំងបី, អ្នកណាមានគុណសម្បត្តិជាង?" ។ ព្រះមហាក្សត្រមានបន្ទូលតបទៅនឹងអារក្សវិញថា: "ចោរមានគុណសម្បត្តិជាងគេ" ។ អារក្សក្រាបទូលសួរព្រះមហាក្សត្រថា: សូមទ្រង់ព្រះមេត្តាប្រោស! ម្ដេចក៏ដូចនោះ?" ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលតបទៅនឹងអារក្សវិញថា: ស្វាមីនាងលះលែងដោយឃើញនាងមានចិត្តស្រឡាញ់បុរសដទៃ, សោមទត្តលះបង់នាង, ខ្លាចព្រះមហាក្សត្រ, តែចោរមិនមានវិចារណញ្ញាណអ្វីដើម្បីបើកនាងឲ្យទៅ ។ គឺចោរនេះឯងមានគុណសម្បត្តិជាងគេ" ។

ដល់បានស្ដាប់ព្រះតម្រិះព្រះមហាក្សត្រ, អារក្សក៏វិលត្រឡប់ទៅព្យួរខ្លួននឹងរុក្ខជាតិដូចដើម, ហើយព្រះមហាក្សត្រ ទ្រង់យាងទៅស្រាយអារក្សចេញពីចំណងហើយក៏នាំយកទៅ ។

ចប់ រឿងទី ៩ មានរឿងទី ១០ តទៅទៀត

# រឿងស្នេហាជាតិ

លោក គង់-លឹម និស្សិតសាលាគរុវិជ្ជា ភ្នំពេញ តែង

(តមក)

---

## ឈុតទី ៣ ឆាកទី ៤

## មិត្តភាព ផលនារី

ផលនារី

បងមិត្តភាពគ្មានជំងឺខ្លួនទេ  បងនៃប៉ារៀបការល្ងាចហ្នឹង
កូនគេលោកប៉ាបានដណ្ដឹង  គេបង្ខំឲ្យការល្ងាចហ្នឹងហើយ ៗ

មិត្តភាព

យីការបង! យីការបង!  បងឥតបំណងឥតដឹងឡើយ

ផលនារី

ការឲ្យហើយទៅ កុំខ្ចីឆ្ងើយ  បងអើយតាមគេទាំងអស់ទៅ ៗ

មិត្តភាព

ស្រីណាមួយទៅគូនឹងបង  ប្រាប់ផងឲ្យឆាប់មកអូនពៅ
ព្រោះបងចង់ដឹងពេលឥឡូវ  ប៉ាដណ្ដឹងកូវឥតប្រាប់ខ្ញុំ ៗ

ផលនារី

គឺអ្នកបង! (សើចរួចទើរ)  អ្នកបងវណ្ណនារី (សើច)

## មិត្តភាព

ទុនាងវណ្ណនារី ថ្លើមជីវិត    ជាមិត្តនឹងខ្ញុំកាលនៅក្មេង
ឥឡូវនាងបានជាគូព្រេង

## ផលនារី

មកគេងខ្នើយមួយគ្នាពីរនាក់!!! ។

## មិត្តភាព

ផលនារីអូនស្គាល់វណ្ណនារីដែរ ដឹងចិត្តនាងទេ អូនបងស្ម័គ្រ
បងសែនស្រឡាញ់ជាអន័គ្ឃ    តែម្នាក់ឯងឥតឲ្យប៉ាដឹង ។
លោកប៉ាបេះរកត្រូវចិត្តខ្ញុំ    កិរិយាឧត្តមល្អប៉ុណ្ណឹង
ស្រីល្អបែបហ្នឹងខ្ញុំឥតខឹង    យ៉ាងហ្នឹងសប្បាយចិត្តម្ល៉េះទេ ។

## ផលនារី

វណ្ណនារីជាបងសំឡាញ់ខ្ញុំ    ក្រមុំត្រឹមត្រូវឥតវៀចវេរ
អ្នកបេះដាំស្ទូងប៉ាក់ដេរ    ទំនេរគ្មានទេការរកស៊ី ។
ចិត្តបងវណ្ណនារីសែនប្រពៃ    ល្អបួសអស់ស្រីក្នុងធានី
រូបគាត់ក៏គ្រាន់ដូចនារី    ឯទៀតនៅទីក្រុងនេះដែរ ។

## មិត្តភាព

ពោះរូបនាងល្អមិនសូវគិត    ឲ្យតែគំនិតគេបេះថៃ
ក្រុមញាតិយើងនៅឲ្យស្និតស្នេរ ថ្កើងកេរ្តិ៍ឈ្មោះយើងបងចូលចិត្ត ។

ចុះកាលដែលបងមានរឿងហេតុ មានគេទទឹងបងការណាវិទ្ធ
តើវណ្ណនារី ជាគូស្និទ្ធ វរមិត្តនាងបានដឹងឬទេ? ។

ផលនារី

ទុរឿងហ្នឹងអ្នកដឹងជាស្រេច ហើយកិច្ចនេះព្រួយគ្មានទំនេរ
ប្រហែលអ្នកបង អ្នកល្អបវរ ការណាវិទ្ធគ្មានគេរ មោហាក្រៃ ។
តែអ្នកអាណិតដល់ចិត្តបង អ្នកបានសាសងកាលពីថ្ងៃ
អាណិតរូបបងហួសវិស័យ ចិត្តបងជូនក្រៃមិនសងសឹក ។

មិត្តភាព

ចិត្តបងប៉ងនឹងសងសឹកដែរ តែមិត្តាណាប្រែចិត្តពន្លឹក
ឃាត់បងមិនឲ្យទៅសងសឹក បងនឹកឃើញទើបធ្វើសន្តោស ។
មិត្តាណាបង់ឃើញពិសេសណាស់ មិនចង់ផ្តេសផ្តាសមិនចាប់ទោស
បងតែងមានធម៌មេត្តាប្រោស សង្គ្រោះដល់យើងប្អូនជាប ។

ផលនារី

ចុះគាត់ជាមនុស្សលើសស៊ីយេ ជាប្រាជ្ញពូកែដឹងបុណ្យបាប
គំនិតគាត់ខ្ពស់មិនមែនទាប សុភាពកិរិយាមារយាទថ្លៃ ។

មិត្តភាព

អ្នកបេះមួយ ៗ របៀបហ្នឹង ចិត្តគេក៏រឹងមិនក្រោធក្រៃ
ពោលពាក្យកាលណាមានដំរៀ ខ្ញាក្រៃក៏សឹងស្តាប់បានដែរ ។

គាត់ថ្ងៃងរ៉ាចាគាត់បេះដូង　　ឯកាលបងខឹងក៏បានល្ហៃ

ស្បើយពីក្ដៅចិត្តអស់ឥតឯ　　គ្មានសល់នៅទេ អូនមងអើយ ! ៗ

## ផលស៊ារ៍

បើសិនពេលនោះបងសម្លាប់　　បងភាណរិទ្ធិស្លាប់ទុក្ខគ្មានស្បើយ

ធ្លាក់ដល់រូបបងសម្បើមហើយ　　ទឹងនៅព្រងើយក្រោយ ។ ណ្ណា

ណោម ៗ

ស្ទៀកពាក់ខោ·អាវសុទ្ធពណ៌ខៀវ សាច់ឈាមឡើងរាវដើរដូចទោម

ប្រឹងខំធ្វើការបងរូបគោម (ស៊ើប) មិនធ្វើគេបោមវាយពី

ក្រោយ ៗ

## មិត្តភាព

កុំបានមិត្តាណា　បងក៏ខ្លៅ　នេះហើយគេហៅថាចិត្តឆ្ងាយ

កុំអីបានអូនយកបាយឲ្យ! ចេញចូលបណ្ដោយ គេស្គាល់ដែរ ៗ

## ឃុតទី ៣ ឆាកទី ៦

## ម៉ារ៉ា មិត្តភាព

### ម៉ារ៉ា

ឪពុកចាស់ហើយ មិត្តភាពកូន! ថ្ងៃណាឪសូន្យបាត់សង្ខារ

កូនរស់នៅឥតមានមេបា　　មុខការក៏គ្មានធ្វើទឹងគេ ៗ

បងៗ សឹងមានការធ្វើហើយ　　នៅឡើយរូបឯងសឹងទំនេរ
ឪពុកក៏គ្មានអ្វីជាកេរ្តិ៍　　ហេតុនេះកូនគ្នេរឲ្យវែងឆ្ងាយ ៗ
រៀនសូត្របានពាក់កណ្ដាលផ្លូវ ឱប៉ាគិតទៅហៅសែនស្ដាយ
ប៉ុន្តែធ្វើម្ដេចឯងឥតម្ដាយ　　តែអញប្រែកាយជាខ្មោចទៅ ៗ
បងប្អូនមិនមែនចិញ្ចឹមទេ　　ខ្វបប្រែពន្លគេមុខក្រញូវ
កូនស្ដាប់ឲ្យបានសំដីឪ　　ញាតិផៅសន្ដានក៏ដូចគ្នា ៗ

## មិត្តភាព

ចុះធ្វើដូចម្ដេចលោកឪពុក !　　ឲ្យផុតពីទុក្ខវេទនា
តែប៉ាស្លាប់ទៅខ្ញុំក៏ព្រា　　ឃើញជាផលនារ៉ែតតមេប៉ា ៗ
ផលនារ៉ីអ្នកនៅតូចជាងខ្ញុំ　　ទំពាំក្រមុំដឹងថ្ងៃណា
បើរូបខ្ញុំមានពិតា　　រក្សាអូនស្រីមិនឲ្យហ្មង ៗ

## ម៉ារ៉ា

ឪពុកបានគិតយូរណាស់ហើយ　　កូនអើយប៉ាគិតធ្វើជន្ទង
ទឹងអ្នកស្រុខាមានចម្បង　　គេសឹងប្រែខ្នងមកឲ្យប៉ា ៗ

## មិត្តភាព

ប្រែខ្នងប្រែចុះប៉ាកុំខឹង　　មិនត្រូវធ្វើដឹងគង់ពេលណា
យើងរស់នៅតាមធម្មតា　　ឲ្យតែសុខាខ្ញុំអរណាស់ ៗ
បុកពាសុភាពទន់សំដី　　គឺស្រីចិត្តធ្ងន់មិនខឹងផ្ដាស់

ឯរូបនាងនោះ ខ្ញុំស្គាល់ច្បាស់ ព្រោះបានប្រទះធ្លាប់ទៅមក ។

ម៉ារ៉ា

ចុះឯងស្គាល់ហើយរូបនាងនោះ តើនាងមានឈ្មោះអ្វីប្រាប់មក?

មិត្តភាព

គឺកែវវណ្ណនារី ស្រស់ពន្លក ដែលប៉ាគួរជ្រករស់នៅបាន ។

ម៉ារ៉ា

អើនេះចំជាកូនប្រុសប៉ា!!! ឯងបេះត្រូវការត្រង់អញស្មាន

មិត្តភាព

ខ្ញុំក៏អរដែរបានរូបប្រាណ កល្យាណអ្នកនាងខ្ញុំអរណាស់! ។

ម៉ារ៉ា

ការល្អបនេះហើយកូនប្រុសប៉ា

មិត្តភាព

ការចុះ! ចិន្តា! ខ្ញុំអរណាស់

ម៉ារ៉ា

អើទៅហើយ! អញនឹងទៅផ្ទះ ដម្រះការហ្នឹងឲ្យបានស្រេច ។

(ញញឹមទៅរកកូនហើយចេញទៅ)

ឈុតទី ៣ ឆាកទី ៧

# ភាណនក ភាណី

## ភាណនក

គិតទៅគិតមក ! ស្រាប់តែឆាយ សំពាយខ្ញុំវេចរួចជាស្រេច
ឥឡូវស្រាប់តែរាផ្ទុះលេច ប៉ាដឹងការខួបឥតបានការ ៗ
មិនដឹងពេលណាទឹងសម្រេច អំពីរឿងកិច្ចស្នេហា
ខ្ញុំបានស្រឡាញ់យូរវេលា អាពាហ៍ពិពាហ៍មិនបានរៀប ៗ
មិត្តភាពបានរៀបការព្រងើយ ហ្នឹងហើយគេហៅថាចាញ់ប្រៀប
វណ្ណ៍តាពអូនអើយសែនខាតលាក វណ្ណ៍នារី នាងរៀបការមុនហើយ ៗ

## ភាណី

មិត្តភាពរៀបការនឹងវណ្ណ៍នារី ជាទីស្នេហាខ្ញុំឥតស្បើយ
អាប្អូនលូកថើមខ្ញុំព្រងើយ ឯងហើយ ! ខ្ញុំប្រឹងប្រែងតម្រូវ ៗ
កាលពីរាំឈើនៅ ដកពេទ្យ ឯងអស់លុយគ្រែហែតពីហោប៉ៅ
តែទឹកឃើញឡើងហៅសែនក្តៅ បើត្រូវការរាំមិនប្រាប់អញ? ៗ

## ភាណនក

ណ្ហើយអូនកុំក្តៅចិត្តធ្វើអ្វី ! មិនខ្វះទេស្រីអូនកុំខ្វាញ់
តាមតែចិត្តឯងចង់ស្រឡាញ់ ត្នេរការាញ់តាមចិត្តមួយទីក្រុង ៗ

## ភាណី

គិតតែរូបខ្ញុំ បងមិនគិត　　គំនិតប្រយ័ត្ន ប្រឹត បំរុង
ប្រយ័ត្នយូរទៅខាតដើមចុង　　ខ្លួនផុងដោយសារនាងផ្កាយមាសៗ
តែធ្វើផ្តេសផ្តាសចុះបុណ្យស័ក្តិ　　ព្រោះរឿងស្រីទាក់ ច្រើនវិនាស
អាប់កេរ្តិ៍អាប់ឈ្មោះបងគួរជៀស　　ដកកៀសខ្លួនចេញទៅបងអើយ ! ៗ

## ភាណាតា

ប្អូនថាដូច្នោះចេះតែបាន !　　តែបងបានប្រាណនាងទៅហើយ
បើផ្លាស់ចិត្តលែងទៅកៀកកើយ　　ប្អូនអើយសំនាងទុក្ខប្រាកដ ៗ
ធម្មតារូបស្រីដូចសំឡី　　កប្បាសយ៉ាងថ្មីសយ៉ាងហ្មត់
ធ្លាក់ចូលក្នុងជ្រាំស្អុយប្រាកដ　　សន្មតថាលាងមិនជ្រះទេ ៗ
ហេតុនេះភាណីប្អូនសំឡាញ់　　ឲ្យបងកាត់ចេញពីចិត្តស្នេហ៍
នាងវណ្ណ៍តាភ　មិនរួចទេ　　ព្រោះមានក្តីស្នេហ៍ណាស់អូនអើយ ៗ
ទោះស្លាប់ទោះរស់បងមិនគិត　　ស៊ូប្តូរជីវិតនឹងនាងហើយ
បើបងកាត់ចិត្តនាងឥតស្បើយ　　ម្ល៉េះហើយនាងក្អួតឈាមមិនខាន ៗ

ចប់ ឈុតទី ៣

(មានត)

## រឿងម៉ុលដឹងវីស៊ីង

## លោក ផេង-ជ្រីវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែរៀបរៀង

(តមក)

---

ត្រកូលទាំងពីរបណ្ដេញចោលចេញពីសន្ដានទាំងអស់ នូវការនិយាយដើមអ្នកដទៃ មានអាការខាងក្រៅដូចជាសេចក្ដីពិត ដែលនាំបណ្ដាលធ្វើដួងចិត្តឲ្យក្លាយទៅជាចិត្តព្យាបាទ ឬទៅជាចិត្តអាក្រក់ ដ្បិតថា វាពិបាកថានឹងមិនព្យាបាទមនុស្សណាស់ បើគេជឿជាក់ថា មនុស្សទាំងនុ៎ះមានពុតកំណាច ហើយវាពិបាកនឹងរស់នៅជាមួយមនុស្សកំណាចណាស់ បើគេដឹងថាវាតែងតែលាក់បំពួន នូវសេចក្ដីគុំគួនក្នុងអាការល្អខាងក្រៅមិនឲ្យដឹង ៗ ហេតុដូច្នេះ ការនិយាយដើមអ្នកដទៃ នាំយើងឲ្យទៅជាមនុស្សអាក្រក់ជាមួយនឹងគេផង ហើយធ្វើឲ្យអាក្រក់ដោយខ្លួនយើងផង ៗ ដោយមិនយកជនមានទ្រព្យ ឬមានបណ្ដាសក្ដិជាប្រមាណ ត្រកូលទាំងពីរចេះចាំតែពីរកចំនងនឹងធ្វើការកុសលដល់មនុស្សជាសាធារណ៍ ហើយទោះបីជាគ្មានអំណាចនឹងធ្វើបាន គេក៏គង់មានគំនិតមួយនឹកមិនភ្លេច ដែលជាគំនិតធ្វើឲ្យត្រកូលនុ៎ះពេញដោយចិត្តល្អ តែងប្រុងជានិច្ចនឹងផ្សាយនូវអំពើល្អទៅខាងក្រៅ ៗ នៅក្នុងព្រៃ ចិត្តមិនព្រៃ ត្រឡប់ទៅជាចិត្តមនុស្សពេញទី ៗ ប្រសិនណាបើរឿងអ៊ុកឡុកនៃ

ពួកក្រុមហ៊ុនមិនជាប្រយោជន៍ដល់ការនិយាយស្តី ក៏គង់មានរឿងជម្លោះ លោកសំកប់និយាយលេង ដែលធ្វើឲ្យត្រកូលនេះពេញចិត្តនឹងរីករាយដែរ ។ គេនាំគ្នាគោរពនឹងសរសើរដោយចិត្តជ្រៀជ្រៃ ដែនទូវអំណាចព្រះជាម្ចាស់ដែលជួយឲ្យដំណាំគេដុះល្អបរិបូណ៌ នៅកណ្តាលដីស្រែសៀន នឹងបណ្តាលឲ្យគេសប្បាយរីករាយមិនចេះដាច់ ។

អាប៉ូលអាយុទើបតែដប់ពីរឆ្នាំទេ តែមានកម្លាំងកាយនឹងកម្លាំងប្រាជ្ញាជាងពួកក្មេងអឺរុបអាយុដប់ប្រាំឆ្នាំ គឺអាប៉ូលនេះឯងជាអ្នករៀបចំទុកដាក់ថែសំអាតរបស់ដែលឪម៉ាំងរកឬដាំបានមក ។ វាទៅព្រៃក្បែរខាងជាមួយតាខ្មៅគាស់កូនក្រូចឆ្មារ កូនក្រូចពោធិសាត់ កូនអម្ពិល កូនល្ពៅដែលផ្លែមានរសផ្អែមឆ្ងាញ់ពិសា ព្រមទាំងមានកូនក្រអូបផង យកមកដាំនៅជុំវិញរបងផ្ទះ ។ មិនតែប៉ុណ្ណោះទៀយ វាព្រោះគ្រាប់ផ្កាឯទៀតជាច្រើន ។

អាប៉ូល ដាំស្វាយ ត្របែក លុង ជាដើម ។ បណ្តាឈើទាំងឡាយនុះ មានឈើខ្លះឲ្យផ្លែ ខ្លះឲ្យម្លប់ទៅឈដល់កុមារជាម្ចាស់ ។ វាដាំតាំងពីផ្ទះរហូតដល់ទីដីដែលគ្មានដីជាតិដាំអ្វីមិនកើត ។ ពួកជាតិអាឡូអែសមានផ្កាលឿងឆ្នូតក្រហម ពួករល្ងទៀនសុទ្ធតែបន្លា វាឡើងលើថ្មខ្មៅហាក់ដូចជាចង់ឈានគោនរល្ងផ្កាផ្លែមេឃក្រហមឆ្អៅដែលពោរសំយុងធ្លាក់មករណោងរណោងឯនេះឯនោះតាមចង្កេះភ្នំ ។

អាប៉ូលបេះរៀបដើមឈើទាំងអស់នោះឲ្យដុះមានរបៀបល្អជាទីទស្សនីយនៃភ្នែកជនទាំងឡាយដទៃ ៗ ក៏ដាំជាវង់មូល នៅកណ្ដាលសួនតែស្មៅកាត់ឲ្យខ្លីគួរសម ហើយដាំពួកកូនឈើជាថ្នាក់បន្ទាប់ រួចឈើមធ្យមមួយថ្នាក់ទៀត ទើបដើមឈើធំថ្នាក់ក្រោយបង្អស់ព័ទ្ធជុំវិញ គឺជាទីមួយកន្លែងនោះ លេចឡើងដូចជាពេងល្ហានធ្វើពីស្លឹកឈើ ពីផ្លែ ពីផ្កា ថែមមានទាំងសួនបន្លែនឹងចំការដាំស្រូវ នឹងស្រូវសាលី ៗ តែបើគេគន់ដំណាំក៏សត្វៗទៅ ហាក់ដូចជាឈើទាំងអស់នោះដុះឯងតាមធម្មតា ៗ ក៏បេះដាំដើមឈើណាមានគ្រាប់ហើរដោយខ្យល់បាន នៅលើទួល ឈើណាគ្រាប់អណ្ដែតទឹក ដាំនៅក្បែរស្ទឹង ៗ ហេតុដូច្នេះដំណាំទាំងប៉ុន្មានដុះឡើងសមគួរដល់ជាតិនឹងទីរបស់វា ហាក់ដូចជាដុះឯងគ្មាននរណាដាំ ៗ ទឹកដែលមានទៅក្នុងទីនោះ គឺហូរមកពីកំពូលភ្នំត្រង់នេះគឺជាកន្លែងសម្រាប់ដក់ទឹកផឹក ឯនោះគឺជាកណ្ដាលស្ទឹងដែលឆ្លុះស្រមោលស្លឹកឈើ ដើមឈើ ផ្កាឈើ ចន្ទនឹងផ្ទៃមេឃ ៗ

ទីត្រង់នោះ ពិតមែនជាទីប្រកបដោយដីមិនស្មើ ប៉ុន្តែគេអាចទៅបេះដំណាំទាំងប៉ុន្មានបានទាំងអស់ ៗ ក៏ធ្វើថ្នល់មួយព័ទ្ធជុំវិញប្រទេសនោះ ហើយបណ្ដាមែកឈើទាំងឡាយដុះរួមពីខាងក្រៅចូលមកកណ្ដាលវង់ ៗ ក៏រៀបចំដីរដិបរដុប ឈើស្រុកនឹងឈើព្រៃឲ្យមានបែបផែនទាក់ទងរកគ្នា គួរជាទីទស្សនា នឹងសម្រាប់ដើរកំសាន្តយ៉ាងស្រួល ៗ ក៏ប្រមូលថ្ម

ដែលនៅផ្លូវ យកមករៀបធ្វើជាចេតិយ ហើយដាំផ្កាកូលាបនិងផ្កាផ្សេងៗឯទៀត នៅតាមថ្នាក់ចេតិយនោះ ៗ មិនយូរប៉ុន្មាន ចេតិយទាំងឡាយពាសពេញសុទ្ធតែផ្កានិងស្លឹកគ្រប់បែប ៗ នៅមាត់ជ្រែកហូងជួបព្រែកតូចព្រែកក្រាទាំងឡាយ ដែលដុះយូរមកហើយ ដុះជួបចុងគ្នាពីខាងលើ ហើយទីនោះត្រឡប់ទៅជាដំរងស្អាតថ្ងៃចាំងមិនធ្លុះ ហើយគេតែងទៅសម្រាកក្នុងទីនោះវេលាថ្ងៃក្តៅ ៗ បើចង់ឆ្ពោះទៅដំរុំនុះ មានផ្លូវតូចមួយនាំទៅ ហើយទៅកណ្តាល ដោយអំណាចខ្យល់បក់មិនសូវត្រូវ គេឃើញមានដុះឈើស្រកមួយដើម ផ្លែពាសពេញ ៗ ឯនោះ គឺជាចំការស្រូវ ឯនេះគឺច្បារដើមឈើស៊ីផ្លែ ៗ តាមផ្លូវនោះ គេឃើញផ្ទះតាមផ្លូវដទៃទៀត គេឃើញកំពូលភ្នំដែលគ្មាននរណាទៅដល់ ៗ

នៅក្រោមកន្ទុំឈើមួយ មានវល្លិ៍រព័ទ្ធធ្លាក់ស្រែះពីលើ សូម្បីនៅវេលាថ្ងៃត្រង់ក៏គេមើលអ្វីមិនស្គាល់ នៅលើកំពូលភ្នំជិតខាង គេអាចមើលឃើញវត្តទាំងឡាយនៅក្នុងភូមិ សមុទ្រដែលវែងឆ្ងាយនិងសំពៅមកពីប្រទេសអឺរ៉ុបឬវិលត្រឡប់ទៅវិញ ៗ គឺនៅលើកំពូលភ្នំនុះហើយដែលត្រកូលទាំងពីរចំណាំតែទៅប្រជុំគ្នាយកខ្យល់អាកាសបរិសុទ្ធ និងបេះបុប្ផាលេងក្នុងសាយណ្ហសម័យ ៗ

គ្មានឈ្មោះអ្វីពីរោះជាងឈ្មោះដែលគេឲ្យដល់កន្លែងនោះឡើយ ៗ កំពូលភ្នំដែលខ្ញុំ (តាចាស់) ទើបនឹងនិយាយប្រាប់អ្នកឯងហ្នឹង គេហៅ

ថាៈ "សិនេហទស្សនា" អាប៉ូលនិងវីរស៊ីន កាលណាកំពុងលេង ហើយក្រឡេកឃើញខ្ញុំ ក៏យកកន្សែងដែលពាក់លើចុងមែកឫស្សីមួយ ហើយលើកដោតបញ្ឈរឡើង ដើម្បីនឹងឱ្យដំណឹងដល់អ្នកឯទៀតថាខ្ញុំ (តាចាស់) មកហើយ ដូចជាគេលើកទង់ជ័យសម្រាប់ឱ្យសញ្ញាដល់កប៉ាល់ ៗ ខ្ញុំគិតថាត្រូវចារិកអក្សរនឹងដើមឫស្សីនោះ ៗ លោតែកាលណាខ្ញុំមានបំណងនឹងដើរមើលលេង នូវរូបនឹងគេហដ្ឋានបុរាណ ខ្ញុំមានចារិកហ្នឹងទុកសម្រាប់មើល គឺហាក់ដូចជាសំដីមនុស្សដែលចេញមកពីថ្ម ធ្វើឱ្យព្ខធ្ង កាត់សតវត្សអស់កាលជានិច្ច ហើយដូចជានិយាយនឹងអ្នកដំណើរកណ្ដាលទីស្ងាត់ថា អ្នកឯងមិនមែនតែឯងទេ គឺមានមនុស្សជាច្រើននៅក្នុងទីនេះ ចេះដឹង ចេះគិត ចេះព្រួយដូចអ្នកឯងដែរ ហើយបើចារិកនោះជាចារិកចាស់ពេកមិនអាចស្ថិតនៅជាស្ថាពរបាន ក៏គង់អាចផ្សាយនូវដួងចិត្តរបស់យើងឱ្យប្រព្រឹត្តទៅក្នុងលោករកទីបំផុតគ្មាន ហើយធ្វើគំនិតរបស់ដួងចិត្តឱ្យជាអមតធម៌ទៀត ព្រមទាំងបង្អុលប្រាប់ថា គំនិតរបស់គេនីមួយ ៗ អាចរស់នៅបានកណ្ដាលដែន សូម្បីអន្តរាយហើយ ៗ

ខ្ញុំ (តាចាស់) ចារិកពាក្យនៃលោកវីរស៊ីល នឹងសំបកឈើមួយដើមដែលអាប៉ូលចំណាំតែទៅអង្គុយក្រោមម្លប់ឈើនោះ ហើយមើលរលកទឹកសមុទ្រ : ' ឱកូនអើយ! អ្នកណាហើយបានប្រកបការងារតែនឹងដីស្រែ គឺអ្នកនោះហើយជាអ្នកមានសន្តានសុខស្រួល " ៗ

រួចខ្ញុំជារើកមួយកន្លែងទៀតនៅលើមាត់ទ្វារនាងឡាគួរ ដែលជាកន្លែងសម្រាប់ប្រជុំគ្នា "ទីនេះជាទីប្រកបដោយសុចរិតធម៌នឹងជាទីនៅនៃមនុស្សប្រកបដោយចិត្តជាកុសល" ។

តែនាងវីរស៊ីទី មិនព្រមយល់តាមខ្ញុំ នាងថាពាក្យហ្នឹងវែងពេក ហើយសេចក្ដីក៏ជ្រៅផង ។ ត្រកូលទាំងពីរ តែងផ្សាយមុទុតាចិត្ត ចំពោះវត្ថុដែលនៅជុំវិញទាំងអស់ ។ សូម្បីតែរបស់អ្វីទំនងដូចជាមិនមានប្រយោជន៍ឬមិនសមគួរនឹងដាក់ឈ្មោះ ក៏សុទ្ធតែមានឈ្មោះទាំងអស់ ហើយឈ្មោះទាំងនោះតែក្នុងកាលណាគួរឲ្យអាណោចអធម្មពេក ។ ចំការក្រូចពោធិសាត់ ចំការបេក ចំការស្ពឺដាំនៅជុំវិញកលស្មៅ ដែលអាប៉ូលនឹងនាងវីរស៊ីទី ចំណាំតែទៅកំលេង គេហៅថា: ឯកសមចិត្ត" ។ ដើមឈើមួយចាស់ដែលនាងឡាគួរនឹងម៉ារគីរីត ចំណាំទៅអង្គុយដំណាលសេចក្ដីទុក្ខរៀងខ្លួន ហៅថា: វិតសោកា ។ ចំការស្រូវសាលី ចំការហ្វ្រែះ ចំការពែរ កាត់យកនាមភូមិភាគឯស្រុកបារាំងខ្លះមកដាក់: ខ្លះហៅព្រេតាញ ខ្លះហៅនរមណ្ឌី ។ ឌូម៉ាំងនឹងម៉ារី ចង់ធ្វើត្រាប់តាមចៅហ្វាយខ្លួនក៏ឲ្យឈ្មោះ កន្លែងធ្វើកញ្ញីនឹងកន្លែងដាំឃ្លោក ហៅថា: អង្គូឡា ហ្យៀ យៀប៉ង់ ជាឈ្មោះស្រុកកំណើតរៀងខ្លួនឯប្រទេសអាហ្វ្រិក ។ ត្រកូលទាំងពីរដែលអន់មិនសូវនឹកដល់ស្រុកកំណើតនៃខ្លួន ដោយសារក្នុងទីនេះប្រកបដោយដំណាំដាំដុះល្អណាស់ ។ បណ្ដាទីកន្លែងនឹងដើមឈើទាំងប៉ុន្មានដែលមានឈ្មោះល្អៗ ឥឡូវនេះហិនហោចអស់ហើយ ។

តែបណ្ដាត្រពាំងឡាយដែលមានសល់នៅក្នុងប្រទេសនេះ មិនមានទីណាមាននាមពីរោះជាងកន្លែងដែលគេហៅថាៈ "ទីសំពកនៃវីរស៊ីនី" នាដើងក៏ហៅថាៈ "សិនេហាវស្សនា" មានចង្អូរមួយ ទឹកដែលហូរចេញពីចង្អូរនោះ បង្កើតបានជាថ្លុកមួយនៅកណ្ដាលវាលស្មៅយ៉ាងស្អាត ៗ ក្នុងឱកាសដែលនាង ម៉ាគើរីត សំពលអាប៉ូល ខ្ញុំឲ្យផ្លែដូងមួយដែលបានមកពីប្រទេសកុក្គដល់នាងជារង្វាន់ ៗ នាងម៉ាគើរីតដាំដូងនោះ នៅមាត់ត្រពាំងនោះ ដើម្បីឲ្យដឹងថាកំណើតកូននាងគឺជាថ្ងៃដែលដាំដូងនោះ ៗ នាងឡាតួរ ឃើញដូច្នោះក៏ធ្វើតាម ហើយដាំដូងមួយទៀត វេលាដែលវីរស៊ីនីកើត ៗ ដើមដូងទាំងគូកើតបានជារបស់សម្រាប់ឲ្យដំណឹងដល់ត្រកូលទាំងពីរ ដើមមួយឈ្មោះឈើអាប៉ូល ដើមមួយឈ្មោះឈើនាងវីរស៊ីនី ៗ ដូងទាំងគូនេះ ដុះខ្ពស់ជាងគ្នាបន្តិច ដូចជាអាប៉ូលខ្ពស់ជាងវីរស៊ីនី ហើយដល់ដប់ពីរឆ្នាំ ដូងនោះក៏ដុះផុតខ្ទម ៗ ធាងវាប្រទាក់គ្នា ហើយមានផ្លែនៅចំពីលើត្រពាំងទឹក ៗ វៀរលែងតែដើមដូងពីរ រុក្ខជាតិឯទៀតព្រមទាំងទីកន្លែងនោះគេទុកឲ្យវាប្រព្រឹត្តទៅតាមធម្មតាលោកគាត់ តែង ៗ មានដើមពពាយរព័ន្ធព័ទ្ធដើមដូង មានផ្កាសខៀវ ៗ ដើមម្ទេសផ្លែក្រហមច្រាលដុះពាសពេញនៅពីក្រោម ៗ មានដើមផ្កាជាច្រើន ខ្លះមានស្លឹកដូចបេះដូង មានផ្កាក្រអូបឈ្ងុយឈ្ងប់ក្នុងទីនោះ ៗ នៅចង្កេះភ្នំ លតាវល្លិជាច្រើនដុះចាក់ស្រែះគ្នាសំយុងមក ហើយកាល

ណា ត្រូវខ្យល់បក់មករំភើយ ៗ ហាក់ដូចជាកម្រោលអណ្ដែតទឹក វល្លិទាំងនោះវារគ្របពីលើថ្ម មើលទៅដូចជាវាំងននដែលគេចងយកទៅបាំង ៗ សមុទ្រសកុណាទាំងឡាយ ឃើញកន្លែងហ្នឹងសុខស្រួល ក៏នាំគ្នាមកជ្រកអាស្រ័យវេលាយប់ ៗ ថ្ងៃជិតចូលរន្ធ គេឃើញកុកសាប់ ទឹងត្រដេវរិចសមុទ្រ ហើរជាសតាមឆ្នេរ លើអាកាសសុទ្ធតែក្អែកទឹកខ្មៅងងឹត ទឹងសត្វរំពេ ៗ នាងវីរ៍ស៊ីនី ចូលចិត្តមកសម្រាកលេងនៅមាត់ត្រពាំងដែលព្រឹក្សាលតាវល្លិទាំងឡាយខ្នាន់ខ្នាប់ គួរជាទីរមិលមើលពេក ៗ

នាងមកលាងសំពត់អាវនៅក្រោមដើមដូងទាំងពីរជាញឹកញយ ៗ ជួនណា នាងបណ្ដើរពពែឲ្យស៊ីស្មៅក្នុងទីនោះ ៗ ក្នុងវេលាជិតដល់ពេលបាយដែលនាងបរិភោគនំបុ័ងនឹងហ្វូម៉ាសជាមួយនឹងទឹកដោះពពែ នាងចូលចិត្តមើលពពែស៊ីវល្លិនៅចង្កេះភ្នំ ឈរតែជើងពីរខាងក្រោយ ជើងមុខពីរនឹងស្នែងអើតឡើងក្ដក់ ក្រឡេកមើលទៅដូចជាសណ្ឋានជើងទៀន ៗ អាប៉ូលឃើញកន្លែងនោះជាទីស្នេហានៃនាងវីរ៍ស៊ីនី ក៏នាំយកសំបុកសត្វនឹងកូនសត្វពីព្រៃជិតខាង មកដាក់ឲ្យនៅកន្លែងនោះ ៗ សត្វស្លាបឈ្មោលញី ដោយរលឹកសំបុកនឹងកូនវារៀងខ្លួន ក៏នាំគ្នាតាមសំបុកមក ៗ វីរ៍ស៊ីនី បាចគ្រាប់ពោតគ្រាប់ស្រូវជាញឹកញយឲ្យដល់បក្សីបក្សាទាំងនោះបរិភោគ ៗ កាលណាឃើញនាងមកដល់ ស្រកាកែវឥឡូងស្លាបខ្មៅរលើប សត្វល្វាបេកស្លាបក្រហមដូចភ្លើងចេញមកក្រែតពីក្នុងសំបុក

សត្វសេកស្លាបបាយតង់ខ្ចីដូចត្បូងមរកត ហើរចុះមកពីដើមស៊ឹករឹតជិតខាង សត្វទទារត់ប្រឹលលើស្មៅ បក្សីទាំងអស់នេះចូលមកលាយឡំគ្នារហូត ដល់ជើងនាង ដូចជាមាន់ស្រុក ៗ បងប្អូនពីរនាក់សប្បាយចិត្តណាស់ ឃើញសត្វទាំងនោះដណ្ដើមគ្នាប្រញាយ ស៊ីចំណីដោយសេចក្ដីទុកចិត្ត ៗ

ក្នុងពេលបាយ អាប៉ូលច្រើននិយាយតែអំពីការដែលវាបានប្រែកប រូបហើយ និងការដែលវាត្រូវធ្វើទៅថ្ងៃស្អែក ៗ វាគិតតែរបស់ណាដែល មានប្រយោជន៍ដល់ត្រកូល ៗ ត្រង់នេះផ្លូវមិនសូវស្អាត ត្រង់នោះកន្លែង អង្គុយមិនសូវស្រួល ៗ ទឹកទ្រូបត្រង់ឯណោះមិនសូវមានម្ហូបល្អ វីស៊ុទិ ប្រហែលជាមិនសូវសប្បាយ ៗ

រដូវក្ដៀង ម្ចាស់ទីងបារនៅតែក្នុងផ្ទះ ត្បាញកន្ទេល កញ្ជើ ល្អី ៗ នោះសព្វថ្ងៃទីងបបរៀបជាជួរទៅតាមកៀនផ្ទះ ហើយជិតប្រដាប់ប្រដា អស់នោះគេឃើញសុទ្ធតែផលិតផលដែលបានមកពីដំណាំដាំដុះ ការុង ស្របំបើងនីងស្នូកបេក ៗ នាងមារគីរត នឹងនាងឡាតួរ បង្ហាត់បង្ហាញ វីស៊ុទិឲ្យចេះរបៀបសព្វគ្រប់ គឺឲ្យចេះធ្វើមេយ៉ លាយនឹងទឹកអំពៅ លាយស្ករ លាយទឹកក្រូច ៗ

កាលណាយប់ គេប្រមូលគ្នាអុជចង្កៀងស៊ីបាយរងំ ៗ រួចបាយហើយ នាងម្ដាយទាំងឡាយ និយាយរឿងឲ្យកូនទាំងពីរស្ដាប់ អំពីអ្នកដំណើរ វង្វេងផ្លូវ ចោរប្លន់យករបស់ទ្រព្យ អំពីអ្នកជិះសំពៅលិច ហើយខ្យល់

ព្យុះបក់បោកទៅទើរនឹងថ្មក្បែរកោះមួយឥតមានមនុស្សនៅ ។ ព្ទដូច្នោះ ក្មេងទាំងពីរមានចិត្តអាណិតណាស់ បន់សូមឲ្យព្រះជាម្ចាស់ជួយអ្នកទាំងនោះកុំឲ្យប្រកបដោយការអន្តរាយខ្លាំងពេក ។ និយាយស្រេចកាលណា ត្រកូលទាំងពីរក៏បែកគ្នា ទៅដេកដោយផ្ទះរៀងខ្លួន ទឹកចាំឲ្យតែភ្លឺឡើង នឹងជួបគ្នាទៀត ។ ជួនណាគេដេកលក់កំពុងភ្លៀង ឬកំពុងតែព្យុះបូរលកសមុទ្របោកគ្រាំៗ នៅមាត់ច្រាំង ហើយតែងបន់ព្រះជាម្ចាស់ឲ្យជួយឲ្យបានសេចក្ដីសុខរៀងខ្លួននឹងជនទាំងឡាយដទៃនៅជិតឬឆ្ងាយ ។

នាងឡាគួរ មើលធម៌ឲ្យអ្នកផ្ទះទាំងអស់ស្ដាប់មួងៗ អំពីរឿងរ៉ាវដែលកើតមានមុនព្រះយេស៊ូ នឹងរឿងដែលមានជាខាងក្រោយព្រះយេស៊ូ ។ ពួកអ្នកទាំងអស់មិនសូវយកធម៌នោះជាគម្រាប់ប៉ុន្មានឡើយ ព្រោះក្នុងធម៌នោះ មាននិយាយតែពីចិត្តល្អដូចជាធម្មតាលោកតាក់តែងមកដែរ ហើយពួកនេះតែងមានធម៌នៅក្នុងខ្លួនជានិច្ចដូចជាកន្លែងដែលគេប្រដៅដំណឹងល្អដែរ ។ មិនចេះមានថ្ងៃព្រួយ ថ្ងៃសប្បាយចិត្តទេ គេចេះតែសប្បាយពល់ថ្ងៃ ។ គំនិតរបស់គេៗ ផ្ញើទៅលើព្រះជាម្ចាស់ទាំងអស់ ដែលធ្វើបែបហ្នឹង គឺនាំឲ្យគេទាំងអស់គ្នា មិនក្ដៅក្រហាយក្នុងការដែលកន្លងទៅហើយ នាំឲ្យមានសេចក្ដីក្លាហានក្នុងបច្ចុប្បន្ន នឹងនាំឲ្យមានចិត្តសង្ឃឹមទៅក្នុងអនាគត ។ មើលចុះ? ជាតិស្ត្រីសោះ សេចក្ដីទុក្ខនាំខ្លួនឲ្យឃ្លាតមកនៅក្នុងព្រៃ ហើយអំណាចព្រៃ ចេះធ្វើខ្លួនព្រមទាំងកូនឲ្យប្រាសចាកពីសេចក្ដីទុក្ខបាន ។ (មានត)

# ពិធីបុណ្យបើកសាលាធម្មវិន័យ

## នៅវត្តរាជបូរណ៍ ខេត្តសៀមរាប

## ព្រះអាចារ្យ ស៊ុន-ស៊ាន វត្តរាជបូរណ៍ រៀបរៀង

កាលពីថ្ងៃ ១ ៗ ១៤ ៣ ឆ្នាំថោះត្រីស័ក ព. ស. ២៤៩៤ ត្រូវនឹងថ្ងៃទី ២៤ កុម្ភៈ គ. ស. ១៩៥២ ក្នុងវត្តរាជបូរណ៍ ឃុំ-ស្រុក-ខេត្តសៀមរាប មានបុណ្យជាឧឡារិក បានកើតឡើង ។ បុណ្យនេះជាអស្ចារ្យក្រៃលែងណាស់ គួរជាបែបយ៉ាងដល់វត្តនានា ក្នុងកម្ពុជា ។

បុណ្យដែលជាអស្ចារ្យនេះ គឺផ្តើមឡើង អំពីលោកវរសេនីយត្រី មេទ័ពកងឯកទេសខ្មែរ នៅបន្ទាយប្រជាក សៀមរាប ដែលជារដ្ឋបុរសដ៏សំខាន់របស់ជាតិមួយ ហើយលោកជាឧបាសកអ្នកឧបត្ថម្ភផ្សរសាសនា ដែលជាជំហរនឹងជាទីពឹងដល់ព្រះពុទ្ធសាសនា ក្នុងខេត្តសៀមរាប គឺលោកវរសេនីយត្រី ឈួន-ម្ជុលពេជ្រ នឹងលោកគ្រូចៅអធិការនាម ហ៊ីង-មៅ វត្តរាជបូរណ៍ សៀមរាប ទាំងពីររូបនេះ លោកបានរលឹកដល់ព្រះពុទ្ធដីកាថា ព្រះពុទ្ធសាសនា ដែលនឹងចំរើនរុងរឿងស្ថិតស្ថេរចិរកាលទៅបាន ក៏ព្រោះអាស្រ័យមានអ្នកបួសរៀនសូត្រធម្មវិន័យត្រឹមត្រូវ ដោយផ្លូវបដិបត្តិ ហើយភិក្ខុសាមណេរដែលទ្រង់សីលសិក្ខា សិក្សានៅក្នុងពុទ្ធសាសនាយូរទៅបាន ក៏ត្រូវមានឧបាសកឧបាសិកាជួយឧបត្ថម្ភជាកំឡាំងផង អាស្រ័យគ្នាយ៉ាងនេះ ទើបពុទ្ធសាសនាដើរលឿនទៅមុខរួចបាន ។

ព្រោះហេតុនេះហើយ ទើបលោកវរសេនីយត្រី មេទ័ពកងឯកទេសខ្មែរនឹងលោកគ្រូចៅអធិការវត្តពជបូរណ៍ ព្រមទាំងមេក្រុមនឹងមេឃុំ រហូតទាំងឧបាសក-សិកាចំណុះវត្តទាំងអស់ មូលចិត្តគំនិតរួមសាមគ្គី ព្រមព្រៀងគ្នា ចាត់តាំងសាលាធម្មវិន័យនឹងអាចារ្យបង្រៀន ឲ្យមានឡើងក្នុងវត្តពជបូរណ៍ តាមថ្ងៃ ខែ-ឆ្នាំ ដូចមានខាងដើមនោះ ។

កាម្មវិធី

១ – វេលាម៉ោង ១៥ ៥ នាទី រថយន្តលោកមេទ័ពកងឯកទេសខ្មែរ បាននិមន្តព្រះអាចារ្យ ធម្មកោសល ឯក-ស៊ុន-ស៊ាន ពីវត្តដំណាក់មកកាន់វត្តពជបូរណ៍ ។

២ – វេលាម៉ោង ១៦-១០ នាទី ប្រកបពិធីបួងសួង គឺលោកមេទ័ពបានប្រជុំក្រុមទាហានទាំងអស់ ឲ្យឈរថែវហើយសូត្របាលីបួងសួងនឹងប្រៀងបទភ្លេងអញ្ជើញទេវតា ។

៣ – វេលាម៉ោង ១៦-៣៥ នាទី លោកគ្រូចៅអធិការវត្តពជបូរណ៍សូត្រសុន្ទរកថា ។

៤ – តាំងអាចារ្យ ឧបត្ថម្ភវត្តពជបូរណ៍ ៤ នាក់ គឺ:

ឃ្លោក-សួង ១

សាត់-សាន ១

សេង-កួយ ១

ពៅ-ភឹង ១ ។

៥ - វេលាម៉ោង ១៦-៥៥ នាទី ព្រះគ្រូវិន័យធរអនុគណ ឯក-ញឹម វត្តធម្មិស្សរារាម ស្រុកស្វទ្រទិគម សំដែងធម៌ទេសនា លុះចប់ធម៌ទេសនាហើយក៏ស្រេចកិច្ចតែត្រឹមប៉ុណ្ណោះ ។

ក្នុងកិច្ចប្រជុំបើកធម្មវិន័យនេះ មានព្រះថេរានុត្ថេរៈគណសង្ឃជាចំនួនច្រើន គឺ:

ព្រះសុមង្គលសីលាចារ្យ មេគណខេត្តសៀមរាប
លោកគ្រូចៅអធិការនាម ហ៊ីង-មៅ វត្តកជបូរណ៍
លោកវរសេនីយត្រី ឈួន-មួលពេជ្រ
ព្រះគ្រូវិន័យធរអនុគណ ឯក-ញឹម វត្តធម្មិស្សរារាម
ព្រះអាចារ្យ ស៊ុន-ស៊ាន គ្រូបង្រៀន ជាដើម

មករួមប្រជុំក្នុងទីនោះ ។ លុះដល់ម៉ោង ១៨ យប់ មានភ្លេងកំដរគណៈកងឯកទេសខ្មែរ, ដល់ម៉ោង ២៤-៥ នាទីឈប់អស់កិច្ចតែប៉ុណ្ណោះ ។

សូមឲ្យកម្មជវជ្ជទាំងមូល ចូរដល់នូវសេចក្តីសុខសាន្តរុងរឿងអស់កាលជានិច្ចជានិរន្តរ៍ ។

ចប់

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

## របស់ក្រសួងធម្មការ

(តមក)

---

សញ្ញាប័ត្រលេខ ៧៤៧ ចុះថ្ងៃពុធ ៣ កើតខែមិគសិរ ឆ្នាំជូតឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ សុក-ឯម នាមឆាយា ឥន្ទជោត កើតឆ្នាំ... អាយុ ៣៤ វស្សា ១៤ ជាគ្រូសូត្រស្តាំ វត្តស្តៅ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ក់-លឿង នាមឆាយា ធម្មសុវណ្ណ កើតឆ្នាំរក អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្វាយ-ក្រឹម នាមឆាយា បញ្ញាថេរ កើតឆ្នាំរក អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តត្បែង ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៥០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រំ-គប់ នាមឆាយា ព្រហ្មត្ថេរ កើតឆ្នាំរក អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៥១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សាត់-នុន នាមឆាយា និលជោត កើតឆ្នាំរក អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តកោះកណ្តាល ឃុំស្វាយយស ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៥២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ង៉ែត - ម៉ោល នាមធាយា ព្រហ្មសុវណ្ណ កើតឆ្នាំរក អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៥៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន - ផន នាមធាយា ចន្ទត្ថេរ កើតឆ្នាំរក អាយុ ៣០ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្តវិហារហ្លួង ឃុំអន្សាចំបក់ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៥៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម - បូរ នាមធាយា ឥន្ទត្ថេរ កើតឆ្នាំច អាយុ ២៨ វស្សា ៧ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៥៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស - សែម នាមធាយា ធម្មជោត កើតឆ្នាំរក អាយុ ៤២ វស្សា ២២ ជាគ្រូសូត្រស្តាំ វត្តកោះរំដួល ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៥៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម - ទុង នាមធាយា និលត្ថេរ កើតឆ្នាំរក អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៥៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខាត់ - ផន នាមធាយា សុវណ្ណជោត កើតឆ្នាំមមី អាយុ ៣០ វស្សា ១១ ជាគ្រូសូត្រស្តាំ វត្តរំដេញសុវណ្ណ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៥៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-គាត នាមធាយា សីលធរោ កើតឆ្នាំច អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រធ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៥៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មុឹង-ម៉ៃ នាមធាយា ធម្មតេរ កើតឆ្នាំថោះ អាយុ ៣៥ វស្សា ១៦ ជាគ្រូសូត្រស្តាំ វត្តពុទ្ធវង្ស ឃុំអូរសណ្តាន់ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៦០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សិន អៀន នាមធាយា គន្ធជោត កើតឆ្នាំមមី អាយុ ៣២ វស្សា ១០ ជាគ្រូសូត្រធ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៦១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់ ម៉ាន់ នាមធាយា ធម្មសុវណ្ណ កើតឆ្នាំរកា អាយុ ៤១ វស្សា ២០ ជាគ្រូសូត្រស្តាំ វត្តឈូកមាស ឃុំគោកធ្លុំ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៦២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-គិត នាមធាយា គណសុវណ្ណ កើតឆ្នាំកុរ អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រធ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៦៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទិត-ឈិម នាមធាយា ទិលជោត កើតឆ្នាំរោង អាយុ ៥៨ វស្សា ៣៨ ជាគ្រូសូត្រស្តាំ វត្តយាគាប ឃុំ-ស្រុក-ខេត្តដដែល ។

(មានត)

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៤ ខែសីហា លេខ ៨

ព.ស. ២៤៩៥–គ.ស. ១៩៥២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ព្រះពុទ្ធសាសនានៅប្រទេសចិន ....... | លោក ប៉ាយ-ប៊ុក ........ | ៥៦៣ |
| ធម៌សង្គ្រោះ ................. | ព្រះមហា ឡុច ........ | ៥៧៣ |
| វិសារទធម៌ ................. | ព្រះមហាឧត្តមវិជ្ជា កែ-អៀន .. | ៥៨១ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| ការបណ្ដុះនិស្ស័យ (តមក) ........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម ... | ៥៨៧ |
| រឿងសាមកុក (តមក) .......... | ឧកញ៉ា នូ-កន ........ | ៥៩៧ |
| រឿងអារ័ក្សថ្លែងរឿងម្តេប្រាំ (តមក) .... | លោក ប៉ាយ-ប៊ុក ........ | ៦០៩ |
| រឿងស្នេហាជាតិ (តមក) .......... | លោក គង់-លឹម ........ | ៦១៤ |
| រឿងប៉ូលនិងវីរ៍ស៊ីនី (តមក) ......... | លោក ផេង-ជ្រីវ ........ | ៦២២ |
| **កំណត់នឹងប្រវត្តិការណ៍** | | |
| ព្រះថេរៈពីររូបនិមន្តមកពីលង្កាទ្វីប ទៅទស្សនាខេត្តសៀមរាប ............... | ព្រះមហាឧត្តមវិជ្ជា កែ—អៀន .. | ៦៣២ |
| បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក). | ក្រសួងធម្មការ ......... | ៦៣៩ |


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជារ ១៨៣រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

### PARTIE RELIGIEUSE


| | | Pages |
|---|---|---|
| Le Buddhisme en Chine ....... | *M. Ray-Buc* ................ | 563 |
| Dharmasangroh .... ......... | *Vén. Lach* .................... | 573 |
| Visâradadharma ............... | *Vén Ker-Œun* ................. | 581 |


### PARTIE LITTERAIRE


| | | |
|---|---|---|
| Education morale (suite)....... | *Vén. Pœung-Pam* ....... | 587 |
| Histoire de SAMKOK (suite) .... | *Oknha Nou-Kan* ....... | 597 |
| Les vingt cinq récits du Mauvais Génie (suite) ................ | *M. Ray-Buc* ........... | 609 |
| L'Amour de la Patrie (suite).... | *M. Kong-Lim* ......... | 614 |
| Paul & Virginie (suite)....... . | *M. Phéng-Chrieu* ........ | 622 |


### NOTES ET CHRONIQUES


| | | |
|---|---|---|
| Voyage à Siemréap de deux religieux de Ceylan ......... | *Vén. Ker-Œun* ................ | 632 |
| Nomination des nouveaux Chau-adhikar (suite) ....... .... | *Ministère des Cultes* ......... | 639 |


Prix d'abonnement annuel comprenant (12 numéros:) 18$00

# ព្រះពុទ្ធសាសនានៅប្រទេសចិន

## លោកញ៉ុយ-ប៊ុកក្រមការ ក្រុមពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

១.— ប្រទេសចិនមុនព្រះពុទ្ធសាសនា: មានព្រះភិក្ខុខ្លះបាននិមន្តទៅផ្សាយព្រះពុទ្ធសាសនានៅប្រទេសកាស្មៀរ រួចបានផ្សាយទៅប្រទេសចិន? ។

ក្នុងពេលនោះ ប្រទេសចិនមិនទាន់និយមកាន់សាសនាអ្វីពិតប្រាកដ លទ្ធិដែលប្រជាជននិយមកាន់នោះ គឺ:

១ — ជំនឿខាងភូតបិសាច (លទ្ធិភូតនិយម) បើតាមសៀវភៅ ជី-គីង និងគម្ពីរបុរាណចិន ច្រើនមានពោលអំពីការគោរពអ្នកតានៅភ្នំ, ទន្លេ, ស្ទឹង, រុក្ខជាតិ, ។ល។

នៅសៀវភៅ កិយាយូថា: "ពួកភូតនោះ គឺជាជីវសត្វមិនចេះបរិភោគអាហារ តែមិនចេះស្លាប់" ។

អ្នកប្រាជ្ញ លៀង-សេ ពោលថា: "នៅលើខ្នងភ្នំមានបិសាចមួយយ៉ាងហៅថា "សិន" ពួកសិននោះ បរិភោគខ្យល់ ផឹកទឹកសន្សើម; ហទយវត្ថុ ដូចជាប្រកពៃរព្រោះភ្នំ, ទម្រង់ប្លុទន់ទ្រាយដូចស្រីក្រមុំ; តែគ្មានកាមតណ្ហា គ្មានជំរេក. . . " ។

២ — ជំនឿខាងភូតបិសាចល្អនិងភូតបិសាចអាក្រក់ ។

បើតាមសៀវភៅចាំង-ហៃ គឹង ដែលលោកលេអុងដឺរុសនី បានប្រែមកជាភាសាបារាំងថា: " មានភូតបិសាចពិសេសស្ថិតនៅតាមភ្នំជាច្រើន ហើយមានរឿងរ៉ាវខាងពិធីផ្សេងៗ ជាកិត្តិយសចំពោះបិសាចមួយៗ គឺសែនបាយ, ស្រា, សម្លាប់សត្វ, មានតាំងគ្រឿងបណ្ណាការ, របាំសាសនា, កីឡាផ្សេងៗ ទីងក្លងជ្រៀងទ្រី ឬមហោស្រព" ។ មានបិសាចល្អឲ្យសុខ (ប្រហែលជាទេវតា?) បិសាចអាក្រក់ឲ្យទុក្ខ ។

៣.— លទ្ធិអនន្តអាទិទេវគតិ ការយល់ថាមានអាទិទេពច្រើន (polythéisme)

បើតាមសៀវភៅ ចាន់ ហៃ-គីង ខាងលើថា: " នៅសន្តតិវង្សជៀវ មានសៀវភៅអក្សរសាស្ត្រចិន ព្រមទាំងសៀវភៅបុរាណពោលថា ប្រជាជនចិនគោរពទេវតាជាច្រើន, ទេវតានៅលើមេឃ លើផែនដី ទីងមនុស្សទេវតាឬមនុស្សទេព, មេឃទុកជាទេវតាមួយអង្គ មានអានុភាពអស្ចារ្យហើយស្ថិតនៅពីលើទេវតា, ភូត, បិសាច, អារក្សទាំងអស់" ។ មេឃនេះ រួមរួមទីងព្រះធរណីបង្កើតជាធម្មជាតិគ្រប់យ៉ាង ព្រះរាជធម្ម: ជាអ្នករបនាទូវជាគាប់សនាសត្វហើយប្រគល់រង្វាន់ ឬដាក់ទណ្ឌកម្ម ។ មេឃជាគ្រូសាកលមានព្រះអាទិត្យ ព្រះចន្ទ្រ តារា ជាដើម ជាព្រះរាជបរិវារ ។ ព្រះធរណីមានភេទជាស្រី ហើយត្រួតត្រាខាងបិសាចដែលស្ថិតនៅតាមស្ទឹង, ទន្លេ, ភ្នំ ។ល។

លោកឡាមេរេស អ្នកនិពន្ធសាសនាប្រទេសចិននិងទីបេត៍ពោលថា: " ពិធីបុណ្យទាំងប៉ុន្មាន គឺរដ្ឋជាអ្នកចាត់ចែង មានរដ្ឋមន្ត្រីម្នាក់ជាប្រធានត្រួតត្រាលើពួកមន្ត្រីតូច-ធំក្នុងពិធីនោះ ។ ព្រះអធិរាជ តែមួយព្រះអង្គគោរពព្រលឹងមហាមេឃ, មហាក្សត្រិយ៍បន្ទាប់គោរពព្រលឹងព្រះធរណី ហើយបូជានូវផ្លែឈើ ពួកមន្ត្រីធំៗ គោរពទេវតាទាំងប្រាំដែលនៅគ្រប់គ្រងគ្រួសារ ។ល។ " ។

" ព្រះមហាក្សត្រចិន ពីបឋមសម័យគោរពព្រលឹងដីដូនដីតាដែលហៅថាច័ងទី" ។

" តាមឯកសារចិន, ព្រះមហាក្សត្រពីបឋមសម័យ មានមួយអង្គធ្វើខ្លួម អង្គទីពីរ ភ្លើង, អង្គទីបី សិល្ប និងសន្តិភាព, អង្គទីបួន ក្សេត្រកម្ម, អង្គទីប្រាំ នគរនិងគ្រឿងសស្ត្រាវុធ, អង្គទីប្រាំមួយ ទ្រង់ធ្វើគោរពខ្មោច, បិសាច, អង្គទីប្រាំពីរ ទ្រង់ចេះរបៀន, មន្ត, អាគម, សម្រាប់តស៊ូនឹងខ្មោចបិសាចទាំងនោះ, អង្គទីប្រាំបី គោរពសពនៅក្នុងបូជដ្ឋាន, អង្គទីប្រាំបួន ទ្រង់បានយកវិទ្យាលេខជាប្រមុខ . ." ។

" ប្រវត្តិសាស្ត្រចិនសម័យបុរាណ ២០០០ ឆ្នាំមុន គ.ស. ។ ដំបូងមានព្រះមហាក្សត្រមួយអង្គទ្រង់ព្រះនាមយ៉ាវ ទ្រង់បានព្យាយាមរក្សាសន្តិភាពក្នុងគ្រួសារ រៀបថ្នាក់មន្ត្រីតាមរបៀបនិងសេចក្តីសាមគ្គីចំពោះប្រទេសផ្សេងៗ . ." ។

"ព្រះមហាក្សត្រយ៉ាវទ្រង់បានតែងតាំងលោកដុន ជានាយករដ្ឋមន្ត្រី ហើយបានរៀបសមរសនឹងព្រះរាជបុត្រីទាំងពីរព្រះអង្គ ដែលឥឡូវគេទុកជានាងទេវធីតារក្សាទន្លេ ទាំងពីរនៃប្រទេសចិន ។ ដល់ព្រះមហាក្សត្រយ៉ាវទិវង្គតទៅ, ព្រះមហាក្សត្រដុនសោយរាជ្យតមកជាលំដាប់ ហើយទ្រង់បានចាត់ការរៀបចំខាងក្រុមព្រះនគរបាល ។ តមកលោកមេទំពយូបានសោយរាជ្យ ។ ព្រះមហាក្សត្រិយ៍យូ ដើម្បីនឹងធ្វើឲ្យប្រជាជនកុំឲ្យគោរពអ្នកតា, បិសាច, ខ្មោច, អសុរកាយ ទ្រង់បានឲ្យពួកវិចិត្រករគូរលើថូដី រូបបិសាចមានទ្រង់ទ្រាយអាក្រក់អស្ចារ្យ ហើយធ្វើឲ្យពួកគេពេញខាងខ្មោចនោះថយអានុភាព, ទ្រង់បានរចនាក្សេត្រកម្ម ឲ្យចំរើនប្រទេសជាតិមាតុភូមិ ដោយដីករែក . . . " ។

"លំដាប់ពីព្រះអធិរាជទាំងបី មានសន្តតិវង្សហ៊ានឹងចាំង សោយរាជ្យក្នុងសន្តតិវង្សនីមួយៗ ៥០០ ឆ្នាំពី ២.២០៥ ទៅដល់ ១.៧៦៦ មុន គ.ស ពី ១.៧៦៦ ទៅដល់ ១.១២២ មុន គ.ស. ។ សន្តតិវង្សហ៊ាបានវែកដីឲ្យគ្រួសារ, គ្រួសារនីមួយៗបានកាប់គាស់ដីនោះផលពាក់កណ្តាលសម្រាប់គ្រួសារ, ផលពាក់កណ្តាលទៀតសម្រាប់មហារាជ . . . " ។

ការបដិវត្តន៍នៃប្រទេសក្នុងសម័យនោះ គឺ មកពីច្បាប់ក្សេត្រកម្មមួយយ៉ាងនឹងការតស៊ូរវាងគ្រូមន្តអាគម នឹងបណ្ឌិតខាងអក្សរសាស្ត្រ: ជនកនៃសន្តតិវង្សចាំងទ្រង់បានទំនុកបំរុងចម្រៀងពួកក្សេត្រករ ; ព្រះមហាក្សត្រ

ក្រោយសន្តតិវង្សនេះ ទ្រង់នៅជាបក្ខពួកគ្រូមន្តអាគម ហើយទ្រង់និយមលទ្ធិគោរពភូត, បិសាច, ព្រះមហាក្សត្រអង្គនេះ ទ្រង់ព្រះនាមចៅ ស៊ីយ ព្រះអគ្គមហេសី ព្រះនាងមេយី ទ្រង់បានចាត់ឲ្យវះពោះនារីមានគភ៌ ដើម្បីនឹងទ្រង់ព្រះតម្រិះនូវការចលនាពងនៅក្នុងស្បូនស្ត្រី . . . ។

“ សន្តតិវង្សជៀវសោយរាជ្យ ពីឆ្នាំ ១១២២ ទៅដល់ ៨៧៨ មុន គ.ស. ។ ជនកនៃសន្តតិវង្សនេះគឺព្រះបាទវូ-វ៉ាង បានព្យាយាមរចនាច្បាប់ក្សត្រកម្ម ឲ្យបានចំរើនព្រមទាំងបែងចែកប្រទេស នៅណោស្ថានមានកងទ័ពប្រចាំទៅវិញ ព្រះអង្គទ្រង់អនុញ្ញាតឲ្យប្រជាជន-គោរព ទេវតា, ខ្មោច, បិសាច និងគ្រូមន្ត, អាគម, តែព្រះអង្គទ្រង់ស្ថាបនានូវបិសាចល្អហៅថា “កេន”, ជាបរិវារព្រះអធិរាជ ហើយជាបច្ចាមិត្តនឹងបិសាចអាក្រក់ហៅថា “គួយ”? ។

៤ – ទស្សនវិជ្ជាគឺ: មួយជាមូលហេតុដ៏សំខាន់លំដាប់តមក ទើបប្រទេសចិនមានអ្នកប្រាជ្ញ, បណ្ឌិត ឬ វិញ្ញូជន មានឡៅ-ស៊ី, កុងហ្វូ-ស៊ី, ម៉េង-ស៊ី ។

ក) ឡៅ-ស៊ី បដិសន្ធិនៅឆ្នាំ ៦០៤ មុន គ.ស. នៅក្នុងព្រះរាជ-អាណាចក្រស៊ូ (ខេត្តហូណាន់) ហើយអនិច្ចកម្មនៅឆ្នាំ ៥០០ មុន គ.ស. លោកបានប្រព្រឹត្ត “តាវ” នូវគុណធម៌ លោកបានសរសេរសៀវភៅមួយនាម “តាវ-តេក-គិញ” ។

នៅកថាភាគ ៤២ នៃសៀវភៅនេះ ពោលថា: "តាវ ជាហេតុឲ្យកើតមួយ, មួយជាហេតុឲ្យកើតពីរ, ពីរជាហេតុឲ្យកើតបី, បីជាហេតុឲ្យកើតសត្វនិងសង្ខារគង់គត ។

តាវបើតាមពិចារណាប្រៀបធៀបនឹងព្រះពុទ្ធសាសនាគឺធម៌ពុទ្ធ ។ តាវជាទីពឹងនៃសត្វលោក, ជាឃ្លាំងធម៌នៃមនុស្សដែលមានគុណធម៌ ។ មនុស្សដែលស្គាល់ "តាវ" មានចិត្តស្មើចំពោះការជោគជ័យ ឬចាញ់, បំរើន ឬវិនាស, សរសើរ ឬនិន្ទា, មិនរំភើបញាប់ញ័រ . . . ។

គតិបណ្ឌិតគឺឲ្យស្គាល់ខ្លួនឯង; អ្នកណាដែលឈ្នះ គុណវិបត្តិ, អ្នកនោះទុកជាអ្នកមានពលភាព, អ្នកណាដែលគ្មានលោភ, អ្នកនោះហៅថា អ្នកមានទ្រព្យ, ធ្វើល្អចំពោះសត្វ តែកុំរង់ចាំទទួលផលឬកម្រៃ, នេះហៅថា គុណធម៌ដ៏ខ្ពស់ . . . ។

១) កុងហ្វូង-ស៊ឺ បដិសន្ធិនៅឆ្នាំ ៥៥០ មុនគ.ស. ៥០ ឆ្នាំ ក្រោយបណ្ឌិត ឡៅ-ស៊ឺ (ព្រះសម្មាសម្ពុទ្ធទ្រង់បដិសន្ធិឆ្នាំ ៦២២ មុនគ. ស., ស្វយាស្ត្រឆ្នាំ ៦៥០ មុនគ.ស. ពីតាគូរ ពីឆ្នាំ ៦០៨ ទៅដល់ ៥៧២ មុនគ. ស ); កុងហ្វូង-ស៊ឺ ទទួលមរណភាពនៅឆ្នាំ ៤៨០ មុនគ. ស. ។ លោកជាទស្សនវិទូ ល្បីល្បាញនៅប្រទេសចិន, បានទុកនាមឲ្យប្រជាជនចិនធ្វើសក្ការៈគោរពបូជាលុះសព្វថ្ងៃ; លោកបានសរសេរសៀវភៅច្រើន គឺ :

១.- ជីគឹង សៀវភៅកាព្យថ្លែងអំពីសកម្មភាពនៃពិធីផ្សេងៗ តាមទំនៀមទម្លាប់ប្រពៃណី,

២.- លី-គីង សៀវភៅទំនៀមទម្លាប់,

៣.- ឯកសារព្រះអធិរាជ មានកថាភាគ១០០,

៤.- សៀវភៅតិកនិកពណ៌នាអំពីវិជ្ជាផ្សេងៗ ឬសិល្បៈក្នុងសម័យនោះ ៗ លោកបានបារិកទុកនូវសុភាសិតមានទុជាសេវ្ទមច្បាញ់ដែលយើងបានឮជាប់ដឹងឃើញ;

" ធម្មជាតិធ្វើឲ្យស្ត្រីសារនៅក្រោមបង្គាប់បញ្ជាមាតាបិតា, ឲ្យស្ត្រីនៅក្រោមអធិបតីភាពមនុស្សឧត្តម ទាំងនេះធ្វើឲ្យយើងយល់ថា ត្រូវបណ្ឌិតជាអ្នកត្រួតត្រាពីព្រោះបណ្ឌិតមានចរិយាហួសមនុស្សសាមញ្ញ ៗ

" ចិត្តខន្តិក្នុងមជ្ឈដ្ឋានដោយប្រាសចាកសេចក្តីក្រោធទីងគឺជាគុណធម៌ដ៏ឧត្តម ៗ តែមជ្ឈដ្ឋាននិមួយ ៗ មានលក្ខណៈផ្សេងគ្នាទៅតាមកាលៈទេសៈ ៗ

"ឧត្តមបុរសកើតទុក្ខព្រោះធ្វើការកុសលមិនបាន, តែឥតមានព្រួយ, បើអ្នកដទៃមិនស្គាល់លោក ៗ

ហ្វង់-បេសួរលោកកុងហ្វង់-ស៊ីថា " គុណធម៌នៃមនុស្សជាតិគឺអ្វី?" លោកទស្សនវិទូតបទៅវិញថា: " ស្រឡាញ់មនុស្សទាំងអស់" ៗ

"ឧត្តមបុរសក្រឡេកទៅមនុស្ស ដែលនៅក្នុងមហាសមុទ្រទាំងបួន ដូចបងប្អូនសាច់ឈាមជាមួយ ។

"ការប្រព្រឹត្តិចំពោះអ្នកដទៃ គឺត្រូវធ្វើឲ្យដូចខ្លួនយើងមានបំណងចង់ឲ្យគេប្រព្រឹត្តចំពោះខ្លួនយ៉ាងណាដូចនោះ នេះជាលទ្ធិមនុស្សជាតិ, វិធាននៃជីវភាពគឺយើងត្រូវប្រព្រឹត្តខ្លួនយើង ដូចជាអ្នកដទៃបំណងនឹងប្រព្រឹត្តមកលើយើង ។

ក្រៅពីសុភាសិត, លោកកុងហ្វូង-ស៊ឺ បានពន្យល់ថាទំនៀមទម្លាប់ប្រពៃណីជាបទបញ្ញត្តិនៃមហាមេឃ, តែលោកថាត្រូវធ្វើចិត្តសន្តោសចំពោះកិច្ចនេះ, ប្រពៃណីសំខាន់បំផុត គឺពិធីសែនដូនតា ។

លោកបានកាន់ទុកមាតារបស់លោកបីឆ្នាំ តែលោកមិនបានពណ៌នាអំពីជីវភាពបរលោក, មានគេសួរលោកថា: "អ្វីមរណភាព?" ។ លោកឆ្លើយតបវិញថា: "បើគេមិនអាចដឹងបានថាអ្វីជីវភាព គេក៏មិនអាចដឹងថាអ្វីជាមរណភាពដែរ" ។

ចំពោះភូត, បិសាច, ខ្មោច, អារក្ស, អ្នកតា ...ល.. នឹងកម្មិកភាពនៃថាំងទីគីលូ បានសួរលោកទស្សនវិទូនេះថា: តើត្រូវបំរើគោរពភូតបិសាចនោះយ៉ាងណាខ្លះ? ។ លោកតបទៅគីលូវិញថា: "បើគេមិនអាចបំរើនូវមនុស្សជាតិបាននៅឡើយ, ហេតុម្តេចក៏ចង់ទៅបំរើភូត, បិសាចឯណោះទៅវិញ" ។

នៅសៀវភៅ " លីលី " លោកពណ៌នា អំពីពលីកម្មនៃព្រះអធិរាជ ចំពោះមហាមេឃ នឹងព្រះធរណី, ព្រះអង្គម្ចាស់ចំពោះទេវតា, មន្ត្រីថ្នាក់ទីបីចំពោះវត្តទេវតា . . . ។

គ) មិង-ស៊ី ប្រទេសចិនសមតិនាម កុងហ្វឹង-ស៊ីជាសន្តបុរសទី ១ លោកមិង-ស៊ីជាសន្តបុរសទី២ ; លោកបដិសន្ធិឆ្នាំ ៣៩៨ មុន គ.ស. មរណភាពឆ្នាំ ៣១៤ មុនគ.ស. ។ បណ្ឌិតនេះ កើតក្នុងសម័យជាមួយនឹងទស្សនវិទូក្រិកប្លាតុងនិងអារីស្តូត " ។

លោកបានប្រមូលលទ្ធិលោកកុងហ្វឹង-ស៊ី នឹងលទ្ធិឡៅ-ស៊ី មករួបរួមជាលទ្ធិមួយទៀត បែបជាលទ្ធិទស្សនវិទូក្រិក សូក្រាតទៅវិញ ។

" ធម្មជាតិនៃមនុស្សនាំឲ្យមនុស្សប្រព្រឹត្តនូវបាប, តែបាបមិនមែនជាធម្មជាតិនៃមនុស្សទេ . . . ។

" មិនមែនព្រះអធិរាជទេ ត្រូវមានសិទ្ធិតែងតាំងនូវព្រះរាជានុសិទ្ធ, ទ្រង់ត្រូវមានព្រះរាជប្រតិភូចំពោះមហាមេឃនឹងព្រះធរណី ។ មហាមេឃអាចឲ្យឆន្ទៈបានចំពោះការព្រមព្រៀងនូវប្រជារាស្ត្រ . . . ។

" មហាមេឃទតឃើញបានចំពោះតែចក្ខុប្រជារាស្ត្រ: មហាមេឃទ្រង់ព្រះសណ្តាប់បានចំពោះតែសោតបសាទប្រជារាស្ត្រ . . . ។

" ប្រជាកស្ត្រ គឺជាសភាពប្រកបដោយសេចក្ដីខ្ពង់ខ្ពស់ ក្នុងពិភពលោក, បន្ទាប់មក គឺទេវតារក្សាព្រះធរណី; ព្រះអង្គម្ចាស់ទុកជាថ្នាក់មិនជាប្រយោជន៍សំខាន់ប៉ុន្មានទេ . . . "

" គ្មានសភាពខុសគ្នាទេ ចំពោះការពិឃាតមនុស្សនឹងជាវនឹងវដ្ដាភិបាលអយុត្តិធម៌ "

" ចំពោះចិនគ្មានវណ្ណៈទេ គ្មានឋានន្តរៈសង្គមទេ . . . "

" មនុស្សមានពីរបែប គឺមនុស្សធ្វើការនឹងប្រាជ្ញា ១ មនុស្សធ្វើការនឹងដៃ ១; ជនទីមួយ ត្រួតត្រា, ជនទីពីរចិញ្ចឹមជនទីមួយ គឺជាច្បាប់សាកលលោក . . . "

៤ .– ពួក-តាវ-តេវ្រ នឹងពួកបណ្ឌិតផ្សេងៗ ក្នុងប្រាំសតវត្សរ៍មក តាំងពីលោកកុងហ្វូ-ស៊ី នឹងលោកឡៅ-ស៊ី អនិច្ចកម្ម ទៅដល់សម័យដែលព្រះពុទ្ធសាសនាមកប្រតិស្ឋាន ជាផ្លូវការនៅប្រទេសចិន, ពួកប្រកាន់លទ្ធិទាំងពីរបានបែងចែកប្រទេសចិនជាពីរផ្នែកៗ នៅសត្តវត្សរ៍ វៀរពី ១.១២២ ទៅដល់ ២៦៩ មុន គ.ស. ពួកបណ្ឌិតបានស្ថាបនាប្រទេសចិនទៅជារបៀបសហរដ្ឋ នឹងពួកកាន់លទ្ធិ " តាវ " គេបោះបង់លែងកប់អាន ហើយគ្មានសកម្មភាពចំពោះកិច្ចការសាធារណៈសោះឡើយ ។

(មានត)

## ធម៌សង្រ្គោះ

# របស់ព្រះមហា ឡាប វត្តឧទ្ទុមធាម ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើតខែអស្សុជ

ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ (១៨-១០-៤៨)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ខ្ញុំព្រះករុណា សូមនមស្សការ ចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដោយសេចក្តីគោរព ជាសន្ធើបតែប៉ុណ្ណោះ ។

លំដាប់ពីនេះទៅ អាត្មាភាព នឹងប្រារព្ធសំដែងព្រះសទ្ធម្មទេសនា ដូចតទៅនេះ ៖

ទានញ្ច បេយ្យវជ្ជញ្ច   អត្ថចរិយា ច យា ឥធ
សមានត្តតា ច ធម្មេសុ   តត្ថ តត្ថ យថារហំ ។
ឯតេ ខោ សង្គហា លោកេ   រថស្សាណីវ យាយតោ
ឯតេ ច សង្គហា នាស្សុ   ន មាតា បុត្តការណា
លភេថ មានបូជំ វា   បិតា វា បុត្តការណាតិ ។

វេលានេះ អាត្មាភាព បានដកស្រង់ព្រះពុទ្ធដីកាមួយកន្លែង ដែលមានមកក្នុងគម្ពីរទីឃនិកាយ ត្រង់សិង្គាលោវាទសូត្រ យកមក

សំដែង ដើម្បីថ្វាយដល់ទ្រង់និងអស់លោកអ្នកសាធុសប្បុរសទាំងឡាយ ដែលជាអ្នកប្រតិបត្តិក្នុងព្រះពុទ្ធសាសនា ជាហេតុធ្វើខ្លួនឲ្យដល់នូវអរិយ-ធម៌ ដែលជាធម៌របស់ព្រះអរិយបុគ្គលទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ។

សមដូចធម្មភាសិត ដែលបាននិពន្ធទុកខាងដើមថា ទានញ្ច បេយ្យវជ្ជញ្ច ។ល។ បិតា ក៏ បុគ្គការណា ដូច្នេះជាដើម តែប្រែថា ធម៌សម្រាប់សង្គ្រោះរបស់មនុស្សក្នុងលោកមាន ៤ យ៉ាង គឺ: ១– ទាន, ២- បេយ្យវជ្ជ, ៣– អត្ថចរិយា, ៤– សមានត្តតា ។

នឹងលើកយកមាតិកាទី ១ មកអធិប្បាយជាបុព្វភាគ ឲ្យឃើញថា ការឲ្យនូវវត្ថុដែលគួរឲ្យ មានវត្ថុសម្រាប់ទទួលទាន និងវត្ថុសម្រាប់ប្រើប្រាស់ជាដើម នេះឈ្មោះថាទាន; ប៉ុន្តែទាននេះ មានច្រើនយ៉ាងគឺ មានក្នុងព្រះសូត្រ ១០, ព្រះវិន័យ ៤, ព្រះអភិធម្ម ៦, តែបើបំប្រួញរួបរួមនូវទានទាំងអស់នោះឲ្យខ្លីចុះមក ដើម្បីជាសេចក្ដីងាយកំណត់កត់សំគាល់ចាំបាននោះ មានត្រឹមតែពីរយ៉ាងគឺ: អាមិសទាន ១ ធម្មទាន ១ ។

ការចែកនូវភោគទ្រព្យរបស់ខ្លួន ឲ្យដល់មនុស្សកំសត់ទុគ៌តអនាថា ឬសមណព្រាហ្មណ៍ដែលបួសក្នុងព្រះពុទ្ធសាសនា ឬបូជាដល់មាតាបិតា ដែលលោកមានគុណចំពោះបុត្រាបុត្រីទាំងអស់គ្នា នេះហៅថា អាមិស-ទាន ។

បើចែកទៅតាមអ្នកឲ្យមានពីរយ៉ាង គឺ: ១- សង្ឃទាន, ២- បាដិបុគ្គលិកទាន; មាតាបិតាចែកទ្រព្យសម្បត្តិដល់កូនប្រុសស្រី មានសំពត់អាវដ៏ស្រស់ស្អាត ជាដើម ឈ្មោះថាបាដិបុគ្គលិកទាន ឬហៅថា អសាធារណទាន ។

ទាយកឲ្យទេយ្យវត្ថុរបស់ខ្លួនដល់បុគ្គលដទៃ មិនចំពោះមុខថាព្រះថេរអង្គនេះអង្គនោះដូច្នេះជាដើម ឈ្មោះថាសង្ឃទាន ឬហៅថា សាធារណទាន ។

ឯធម្មទាននោះ បានដល់ការចែករំលែកនូវធម្មវិន័យ ដែលខ្លួនបានរៀនចេះចាំមកហើយ គឺត្រូវប្រៀនប្រដៅណែនាំបុគ្គលដទៃ ដែលល្ងិតល្ងង់ខ្លៅជាងខ្លួន ឲ្យបានដឹងនូវធម៌ដែលអាចធ្វើខ្លួនឲ្យបានទទួលយកនូវសេចក្ដីសុខក្នុងលោកទាំងពីរ ពុំនោះសោតដូចជាមន្ត្រីធំ-តូចដែលជាអ្នកចេះចាំច្បាប់ក្បួនប៉ែកខាងផ្លូវលោក ត្រូវប្រដៅណែនាំដល់អាណាប្រជានុរាស្ត្រ ដើម្បីធ្វើជាតិរបស់ខ្លួនឲ្យឡើងកាន់អារ្យធម៌មិនសន្តិសន្តិនរំបជាន់ដោយឥស្សរភាពរបស់ខ្លួនទេ នេះហៅថាធម្មទាន ។ បើបុគ្គលមានសង្គហធម៌ទី ១ ដក់ជាប់ក្នុងចិត្តហើយ ទោះបីគ្រហស្ថបព្វជិតមន្ត្រីធំ-តូច ក៏អាចធ្វើខ្លួនឲ្យជាទីពឹងអាងនៃជនដទៃបាន, នេះជាសង្គហធម៌ទី ១ ។

កាលបើឲ្យតែប៉ុណ្ណោះ ប៉ុន្តែមិននិយាយពាក្យពីរោះ គួរឲ្យជាប់ចិត្តផង ទោះបីឲ្យច្រើនក៏ដូចជាឲ្យតិច ព្រោះមិនពោលវាចាពីរោះផ្អែមចំពោះ

អ្នកផងដែលទទួលយកទេយ្យវត្ថុនោះ បានជាព្រះឈ្មោះមារជាម្ចាស់ទ្រង់សំដែងនូវបេយ្យវជ្ជ ជាសង្គហធម៌ទី ២ ។

បើបុគ្គលណា ជាអ្នកមានវាចាពីរោះផ្អែម គួរឲ្យពេញចិត្តជាប់ចិត្តដូចជាមាតាបិតា ហៅបុត្រាបុត្រី អានាង ម៉ែ នាងដូច្នេះ ជាហេតុធ្វើចិត្តកូនឲ្យស្រឡាញ់រាប់អានដោយសារពាក្យនោះផង ឬក៏ចៅហ្វាយហៅរកបាវព្រាវ ដោយសំដីទន់ភ្លន់ពីរោះផ្អែម ជាគ្រឿងធ្វើអ្នកបំរើនោះឲ្យស្មោះស្ម័គ្រចំពោះខ្លួន អាចបំរើខ្លួនឥតគិតនឿយហត់សោះ បើជាពួកក្រុមរាជការវិញ ត្រូវពោលពាក្យរក់ទាក់តាមថ្នាក់ តាមជាន់ ស្គាល់ចាស់ព្រឹទ្ធាចារ្យ កាលបើមន្ត្រីណាមានវាចាដ៏សភាពរាបសាដូច្នេះ ជាគ្រឿងពូតផ្គួរគំនួនសេចក្តីល្អរបស់ខ្លួនផង ជាឧបាយធ្វើឲ្យរាស្ត្រស្រឡាញ់ផង បើនឹងទៅឈរនៅទីណា ជាទីរាប់អានបូជារបស់អាណាប្រជានុរាស្ត្រ បុណ្យស័ក្តិទៀតសោតក៏ឡើងដោយផលដែលខ្លួនប្រព្រឹត្តល្អ ចុះបើមនុស្សមានសំដីជូរល្វីងទ្រគោះបោះបោកអសុរោះ ដោយអំណាចឥស្សរភាពរបស់ខ្លួន កុំថាឡើយតែគ្រឿងបូជា ដោយហោចទៅសូម្បីតែឈ្មោះក៏មិនទឹកផង បើបែកខាងបព្វជិតវិញ ត្រូវនិយាយពាក្យឲ្យសមរម្យតាមភាពជាសមណភេទ មិននិយាយញុះញង់ចាក់ដោតត្លុកកំប្លែងលេងសើចក្អាកក្អាយដូចជាគ្រហស្ថនោះទេ ទើបរាប់ថាបេយ្យវជ្ជ ជាសង្គហធម៌ទី ២ ។

ការឲ្យទីពឹងនិយាយពីរោះ ជាគុណសម្បត្តិដ៏សំខាន់មែនហើយ តែបើជាមនុស្សមើលបំណាំ មិនធ្វើកិច្ចធុរៈអ្វីមួយដែលជាប្រយោជន៍ដល់ពួកក្រុមញាតិមិត្តកូនចៅទេ ជាហេតុធ្វើអំពើរនោះ ឲ្យអន្តរាយសាបសូន្យបាត់បង់ទៅវិញជាមិនខាន ឬក៏តាំងនៅដែរ តែមិនបានជាប់នៅយូរឡើយ ព្រោះហេតុនោះ បានជាសម្តេចព្រះបរមសាស្តាចារ្យ ទ្រង់សំដែងអត្ថចរិយា ជាសង្គហធម៌ទី ៣ ។

បើបុគ្គលណាមួយ ជាអ្នកធ្វើនូវអំពើដែលជាប្រយោជន៍ដល់ជនដទៃ ដូចយ៉ាងមាតាបិតាជួយធ្វើកិច្ចធុរៈ កូនប្រុស-ស្រី មានសង់គេហស្ថានឲ្យជាដើម ឬក៏ពួកបណ្ឌិតដែលជាអ្នកប្រាជ្ញ បានរៀនចេះចាំព្រះពុទ្ធ-វចនៈច្រើន ហើយខ្នានៈប្រៀនប្រដៅដល់គ្រហស្ថដែលមិនទាន់មានទាន សីល ភាវនា ឲ្យមានទាន សីល ភាវនាឡើង មិនតែប៉ុណ្ណោះ សូម្បីពួកក្រុមនាហ៉ឺនរាជការធំ តូច ដែលជាអ្នកចេះចាំច្បាប់ក្បួនប៉ែកខាងផ្លូវលោកច្រើន ក៏ត្រូវណែនាំពួករាស្ត្រដែរ ឬក៏ពួករាស្ត្រចូលទៅប្តឹងក្តីក្រសួងផ្សេងៗ ត្រូវជួយយកអាសាផង មិនត្រូវសង្កត់សង្កិនអ្នកម្ចាស់ឲ្យខូចប្រយោជន៍ ហើយស្រឡាញ់ពេញចិត្តអ្នកម្ចាស់ដែលបន់ស្រន់ដោយទ្រព្យនោះទេ ការធ្វើចិត្តជាអសប្បុរសដូច្នេះ មិនមែនជាឧបាយធ្វើប្រទេសជាតិមាតុភូមិឲ្យឡើងកាន់វឌ្ឍនធម៌ឡើយ មានតែបំផ្លិចបំផ្លាញជាតិ ឬធ្វើជាតិរបស់ខ្លួនឲ្យធ្លាក់ថោកទាប បើបុរសស្ត្រី មន្ត្រីធំ-តូចឯណា

លះបង់នូវអំពើដែលធ្វើទៅមិនសម្រេចប្រយោជន៍ដល់បុគ្គលដទៃទេ ត្រូវកុំធ្វើ តែត្រូវធ្វើអំពើដែលជាប្រយោជន៍វិញ ទើបរាប់ថា អត្ថចរិយាជាសង្គហធម៌ទី ៣ ។

ការឲ្យនឹងនិយាយពីរោះ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ ជាការប្រពៃណាស់ហើយ ប៉ុន្តែត្រូវធ្វើខ្លួនឲ្យស្មើក្នុងកុសលធម៌ទាំងពួង ឬប្រព្រឹត្តខ្លួនឲ្យស្មើដល់ជនដទៃ ទើបអាចអប់រំនូវសេចក្តីល្អនោះឲ្យរឹងរឹតតែឋិតថេរយឺនយូរតទៅទៀត ព្រោះហេតុនោះ បានជាសម្តេចព្រះលោកនាថសាស្តាចារ្យ ទ្រង់សំដែងនូវសមានត្តតា ជាសង្គហធម៌ទី ៤ ។

បើបុគ្គលឯណាធ្វើខ្លួនស្មើចំពោះបុគ្គលដទៃ មិនសំដែងអាការក្អេងក្អាងក្រអឺតក្រទមជាអ្នកសភាពកបស គួរឲ្យអ្នកផងក្រឡេកមើលទៅតែងស្រឡាញ់រាប់អានដោយបុកពាមារយាទរបស់ខ្លួន ដូចយ៉ាងពួកញាតិមិត្តដែលមានវ័យតិចជាង ប៉ុន្តែមានយសសក្តិបរិបូណ៌ដោយភោគទ្រព្យសម្បត្តិបរិវារ ត្រូវគោរពកោតក្រែងដល់ក្រុមញាតិមិត្តដែលមានវ័យចំរើនជាង ជាឧបាយមួយយ៉ាង ដែលអាចតាំងវង្សត្រកូលឬញាតិមិត្តឲ្យមានសេចក្តីសុខសាលស្មោះស្ម័គ្រឥតមានល្អៀងឡើយ ទាំងមាតាបិតារបស់ខ្លួនទៀតសោត ក៏រីករាយសប្បាយចិត្តដោយសារកូនបេះគួរសមផងពុំនោះសោតដូចពួកពជការ ត្រូវប្រព្រឹត្តខ្លួនឲ្យស្មើក្នុងកុសលធម៌ទាំងពួងជាគ្រឿងដំកល់ខ្លួនឬដំកើងខ្លួនឲ្យល្អក្នុងលោកទាំងពីរ ម្យ៉ាងទៀត ត្រូវ

ធ្វើខ្លួនឲ្យស្មើ ចំពោះពួកបណ្តាកស្ត្រីដែលមានវ័យចាស់ជាងខ្លួនមិនត្រូវធ្វើក្អេងក្អាងគ្របសង្កត់ជនដទៃ ដោយអានុភាពរបស់ខ្លួនទេ ការដែលតាំងខ្លួនមានសភាពបែបនេះ ជាហេតុធ្វើខ្លួនឲ្យជាទីពប់អានរបស់មហាជនមិនខានឡើយ ទើបរាប់ថា សមានត្តតា ជាសង្គហធម៌ទី ៤ ។

សង្គហវត្ថុទាំង ៤ យ៉ាងនេះ មានក្នុងសន្តាននៃបុគ្គលណាហើយ អាចយឹតយោងបុគ្គលនោះឲ្យឡើងកាន់ឋានៈដ៏ខ្ពង់ខ្ពស់ ឬជាឧបាយឲ្យកើតសាមគ្គីធម៌ គឺសេចក្តីព្រមព្រៀងគ្នាជាពួកក្រុមផង ប៉ុន្តែសង្គហធម៌ទាំង ៤ យ៉ាងនេះ ដែលដុះដាលកើតមានឡើងក្នុងសន្តាននៃបុគ្គលនីមួយៗ មិនមែនកើតឡើងឯងៗទេ លុះណាតែអាស្រ័យគ្រឿងផ្សំ គឺការសិក្សារៀនសូត្រទើបកើតឡើងបាន មិនមែនតែផ្លូវព្រះពុទ្ធសាសនាទេ សូម្បីផ្លូវលោកក៏ដូចគ្នាដែរ សមដូចព្រះបរមពុទ្ធោវាទថា:

យោគា វេ ជាយតេ ភូរិ អយោគា ភូរិសង្ខយោ

"ប្រាជ្ញាកើតឡើង: ព្រោះគ្រឿងផ្សំ ការអស់ទៅនៃប្រាជ្ញា ព្រោះខ្វះគ្រឿងផ្សំ" ។

ហេតុនេះ យុវជន កុមារ-កុមារីទាំងឡាយ ត្រូវខំស្វះស្វែងរៀនសូត្រលេខនព្វន្ត អក្សរសាស្ត្រទាំងប៉ុន្មានឲ្យមាំមួនឡើង ដើម្បីកពូនប្រាជ្ញារបស់អ្នកផង នឹងធ្វើប្រទេសជាតិមាតុភូមិរបស់អ្នកឲ្យឡើងកាន់វឌ្ឍនធម៌

ផង ព្រោះថាក្នុងស្រុកប្រទេសណា មានមនុស្សសិក្សារៀនសូត្រច្រើន ស្រុកប្រទេសនោះ តែងមានសេចក្ដីចំរើនជានិច្ច ។

បើប្រាសចាកការសិក្សារៀនសូត្រហើយ កុំថាឡើយតែការ កសាងជាតិ ដោយហោចទៅ សូម្បីតែសេចក្ដីចិញ្ចឹមជីវិតផ្ទាល់ខ្លួន ក៏លំបាកដែរ បើយុវជនកុមារកុមារីណា ឃើញសេចក្ដីវិនាសនិងសេចក្ដី ចំរើនដូចពណ៌នាមកខាងលើនេះ ត្រូវប្រឹងប្រែងក្នុងការរៀនសូត្រឲ្យមុត មាំមិនត្រូវខ្ជិលច្រអូសឡើយ ។

អាត្មាភាពសំដែងមក ក្នុងធម៌សគ្រោះទាំង ៤ យ៉ាង ព្រមទាំង លើកគាថាយកមកជាពស្ដុតាង ក៏សន្មតថា ចប់ តែប៉ុណ្ណេះ ។

ធម្មទេសនានុភាវេន និច្ចំ ហោន្តុ សព្វទា ដោយ អានុភាពនៃធម្មទេសនានេះ សូមពុទ្ធបរិស័ទនិងជនរួមជាតិ ព្រមទាំង ជនរួមលោកទាំងឡាយ កុំឲ្យមានទុក្ខសព្វៗ កាល ឯវំ ។

ចប់

# វិសារទធម៌

## ព្រះមហាឧត្តមវិជ្ជាកែ-អឿន វត្តព្រះព្រហ្មរតន៍

ទេសនានៅមន្ទីរព្រះដាក់ កាលពីថ្ងៃចន្ទ ១៥ កើតខែផល្គុន ឆ្នាំថោះ ត្រីស័កព. ស. ២៤៩៤
ត្រូវនឹងថ្ងៃទី ១០ ខែមីនា ឆ្នាំ ១៩៥២ ។

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

*វេលានេះ អាត្មាភាពនឹងសំដែងវិសារទធម៌ គឺ: ធម៌ធ្វើឲ្យមានសេចក្តីក្លាហាន ដើម្បីជាសណ្តាប់ដល់សប្បុរសទាំងឡាយ ដូចមានសេចក្តីតទៅនេះ :–*

*ធម្មតាមនុស្សដែលកើតមកក្នុងពិភពលោកនេះ ទោះបីក្រុមបុគ្គលណាមួយ ដែលនឹងធ្វើកិច្ចការអ្វីគ្រប់យ៉ាងសម្រេចទៅបាន ក្នុងផ្លូវលោកនឹងផ្លូវធម៌ ត្រូវអាស្រ័យសេចក្តីក្លាហាន ឬសេចក្តីអង់អាចក្នុងកិច្ចការងារនោះៗ ទើបកិច្ចការនោះៗ សម្រេចទៅបាន ។ ឯធម៌ដែលសម្រាប់ធ្វើសេចក្តីក្លាហានឲ្យកើតឡើងបាននោះ ហៅថា វិសារទធម៌ៗ នោះព្រះបរមគ្រូ ទ្រង់សំដែងទុកក្នុងគម្ពីរអង្គុត្តរនិកាយបញ្ចកនិបាតថា មាន ៥ ប្រការគឺ :*

១ — សទ្ធា *ការជឿរបស់ដែលគួរជឿ ។*

២ — សីល *ការរក្សាកាយវាចាឲ្យរៀបរយ ។*

៣— ពាហុសច្ចំ ភាពជាអ្នកបានស្តាប់បានរៀនច្រើន ។

៤— វីរិយារម្ភ ការព្យាយាមមុតមាំ ។

៥— បញ្ញា ការដឹងរបស់ដែលគួរដឹង ។

ធម៌ទាំង ៥ ប្រការនេះ ជាធម៌ធ្វើឲ្យកើតសេចក្តីក្លាហាន. គប្បីជ្រាបសេចក្តីអធិប្បាយដោយការប្រតិបត្តិព្រះធម៌វិន័យ ជានិទស្សន: ដូចតទៅនេះ :-

១ - សទ្ធា សេចក្តីជឿជាក់ក្នុងចិត្ត គឺជឿថាព្រះធម៌នោះជា និយ្យានិកធម៌ នាំសត្វឲ្យផុតចាកទុក្ខបានពិតហើយមានគុណានុភាព អាចគប់គ្រងរក្សាអ្នកប្រតិបត្តិមិនឲ្យធ្លាក់ទៅក្នុងទីអាក្រក់ ព្រមទាំងជឿក្នុងចិត្តរបស់ខ្លួនថា ការប្រតិបត្តិនោះខ្លួនអាចនឹងប្រតិបត្តិបាន, ទាំងជឿថាសេចក្តីសុខនោះសោតខ្លួនក៏បានព្រោះការប្រតិបត្តិនេះ, មិនមែនបានព្រោះផ្សងដៃទេឡើយ, កាលបើមានសេចក្តីជឿទាំងពីរប្រការដូចពោលមកនេះហើយ, លំដាប់នោះសេចក្តីរីករាយក្នុងកុសលរមែងកើតឡើងអាចដឹកនាំការប្រតិបត្តិធម៌វិន័យនោះឲ្យប្រព្រឹត្តទៅបានមិនរួញរា បើទុកជាមានទំនាស់ចូលមកពាំងក្នុងចន្លោះខ្លះ ក៏អាចវែកសេចក្តីពាំងនោះៗបានដោយមិនញញើតឡើយ ។

សេចក្តីនេះ គួរជ្រាបដូចបុគ្គលដែលរាប់អានខ្សែកឬខ្សែចង្កេះ ។ ខ្សែកឬខ្សែចង្កេះដែលចងនៅត្រង់ក ឬត្រង់ចង្កេះរបស់គេ គេប្រកាន់

ជឿថា អាចការពារខ្លួនគេបាន សូម្បីមានហេតុណាមួយកើតឡើង គេក៏មិនញាញើតរួញរាអាខ្វាចសោះឡើយ ។ នេះព្រោះតែសេចក្ដីជឿរបស់គេ ។ ព្រោះហេតុនោះ សទ្ធាលោកទើបចាត់ថាជាធម៌ធ្វើសេចក្ដីក្លាហានប្រការមួយ ។

២ – ចំណែកសីល មានសេចក្ដីអធិប្បាយថា: បុគ្គលដែលមានកាយវាចារៀបរយ គឺវៀរចាកអំពើអាក្រក់ដោយកាយនិងវាចា រមែងជាមនុស្សស្រុកពពបសា បើទុកជានៅក្នុងទីណា ឬទៅក្នុងទីណា ក៏រមែងធ្វើអ្វីមិនរួញរា មិនញាញើតចំពោះអន្តរាយណាទីមួយឡើយ តែងមានសេចក្ដីក្លាហានជានិច្ច សូម្បីចូលទៅក្នុងសមាគមនានា ក៏រមែងមានសេចក្ដីអង់អាច មិនខ្វាចទោសឯណាទីមួយ មិនក្រែងគេនិន្ទាក្នុងសេចក្ដីប្រព្រឹត្តនៃខ្លួន ។ ព្រោះហេតុនេះ សីលលោកទើបចាត់ថាជាធម៌ធ្វើសេចក្ដីក្លាហានប្រការមួយ ។

៣ – ពាហុសច្ចៈ បើពោលដោយប្រភេទ បានដល់ពាហុសច្ចៈ ២យ៉ាង គឺអាគារិកពាហុសច្ចៈ=ភាពនៃការសិក្សារៀនសូត្រច្រើនជារបស់គ្រហស្ថ ១, អនាគារិកពាហុសច្ចៈ = ភាពនៃការសិក្សារៀនសូត្រច្រើនជារបស់អ្នកបួស ១ ។ ការសិក្សារៀនសូត្រវិទ្យាសាស្ត្រផ្សេងៗ ក្នុងផ្លូវលោក គឺ នីតិសាស្ត្រ (វិជ្ជាខាងច្បាប់) វេជ្ជសាស្ត្រ (វិជ្ជាខាងពេទ្យ) យុទ្ធសាស្ត្រ (វិជ្ជាខាងទាហាន) យន្តសាស្ត្រ (វិជ្ជាខាងគ្រឿងចក្រ)

សិល្បសាស្ត្រ (វិជ្ជាខាងហត្ថកម្មធ្វើគ្រឿងផ្សេងៗ សម្រាប់ប្រើប្រាស់) ប៉ុណ្ណោះជាដើម ហៅថា អាគារិកពាហុសច្ចៈ ឬហៅថា ពាហុសច្ចៈផ្លូវលោក ដូច្នេះក៏បាន ។

ការសិក្សារៀនសូត្រក្នុងផ្លូវធម៌ បានដល់ការរៀនព្រះបរិយត្តិធម៌ក្នុងព្រះពុទ្ធសាសនា គឺព្រះត្រៃបិដក ដើម្បីឲ្យចេះដឹងយល់ច្បាស់លាស់ក្នុងផ្លូវធម៌ ហៅថា អនាគារិកពាហុសច្ចៈ ឬហៅថា ពាហុសច្ចៈផ្លូវធម៌ដូច្នេះវិញក៏បាន ។

ពាហុសច្ចៈ ដោយអានិសង្ស សំដៅយកការស្គាល់ហេតុផល បុណ្យ បាប គុណ ទោស ព្រោះអាស្រ័យការចេះដឹងច្រើន ។ ពាហុសច្ចៈអាចកំចាត់បង់នូវសេចក្តីល្ងង់ខ្លៅ ជាគុណជាតនាំឲ្យមានឧត្តមគតិ គឺដំណើរខ្ពង់ខ្ពស់ថ្លៃថ្នូរ នាំឲ្យមានសមត្ថភាពគ្រប់គ្រាន់ នាំឲ្យបានទទួលឋានៈជាអ្នកប្រាជ្ញក្នុងផ្លូវលោកឬផ្លូវធម៌ នាំឲ្យបានកិត្តិយសជាអ្នកបំភ្លឺដល់ជាតិត្រកូលឲ្យស្គាល់សារប្រយោជន៍ នាំឲ្យមានវឌ្ឍនធម៌ បានសេចក្តីសុខ ចំរើនដោយភោគសម្បទ និងបរិវារសម្បទ ឃើញជាក់លាក់ក្នុងលោកនេះ ។

៤ – វីរិយារម្ភនោះ មានអធិប្បាយថា បុគ្គលដែលមានចិត្តប្រារព្ធព្យាយាមជានិច្ចហើយ តែងប្រកបការងារឯណាទីមួយៗ ទោះជាគតិលោកក្តី គតិធម៌ក្តី រមែងកំចាត់បង់នូវសេចក្តីខ្ជិលច្រអូសដែលជាសឹក

សត្រូវទាំងគ្នា រមែងមិនគិតសេចក្ដីលំបាក រមែងមិនញញើតចំពោះភ័យអន្តរាយ ដែលកើតមកអំពីការងារនោះៗ មិនញញើតចំពោះហេតុណាមួយឡើយ រមែងប្រឹងប្រែងក្នុងការងារ ស្រៀតស្រែកឧបសគ្គៈដែលកើតឡើងក្នុងចន្លោះ ដែលខ្លួនកំពុងធ្វើកិច្ចការនោះៗ បានទាំងអស់ ។ ទាំងអម្បាលនេះ ក៏សុទ្ធតែជាអង្គរបស់សេចក្ដីព្យាយាម ។ កាលបើអង្គរបស់សេចក្ដីព្យាយាមទាំងនេះនៅក្នុងបុគ្គលណាហើយ បុគ្គលនោះរមែងក្លាហានក្នុងកិច្ចការទាំងពួង ដូចជាមេទ័ពដែលជាអ្នកអង់អាចពុះពារសឹកសត្រូវទៅបាន ។ នេះក៏ព្រោះវិរិយារម្ភនេះឯង ព្រោះហេតុនោះវិរិយារម្ភទើបលោកចាត់ថាធម៌ជាគ្រឿងធ្វើសេចក្ដីក្លាហានប្រការមួយ ។

៥ - បញ្ញា នោះមានសេចក្ដីអធិប្បាយថា: បុគ្គលដែលឆ្លៀវឈ្លាសស្គាល់ហេតុដែលជាគ្រឿងចំរើន និងហេតុដែលជាគ្រឿងវិនាស រមែងចូលចិត្តប្រកបកិច្ចការមិនឲ្យវិកវរ អាចញុំាងប្រយោជន៍ខ្លួន និងប្រយោជន៍បុគ្គលដទៃឲ្យសម្រេចបាន បើទុកជាមានភ័យដែលគួរឲ្យញញើតមកព័ទ្ធជុំវិញខ្លួន ក៏រមែងត្រិះរិះត្រូវគ្នានធ្វើខ្លួននិងបុគ្គលដទៃឲ្យផុតអំពីភ័យបាន ទោះបីប្រកបការងារឯណានីមួយ ដែលលំបាកឥតមានប្រៀបក៏ដោយ តែងអាចកែខៃបានទាំងអស់ មិនព្រួយចំពោះសេចក្ដីលំបាកនោះឡើយ ។ សេចក្ដីនេះ គួរប្រៀបដូចជាមនុស្សដើរផ្លូវទៅក្នុងទីងងឹត បើមិនមានពន្លឺជាគ្រឿងធ្វើឲ្យភ្លឺ ម្ដេចនឹងដើរទៅកើត,បុគ្គល

ដែលមានពន្លឺគឺបញ្ញាក៏ដូចគ្នា ព្រោះហេតុនេះ បញ្ញាទើបចាត់ជាធម៌ធ្វើឲ្យក្លាហានប្រការមួយ ។

ធម៌ទាំង៥ប្រការនេះ អាចធ្វើបុគ្គលឲ្យក្លាហានបាន ដូចអធិប្បាយមកនេះ, ទើបលោកហៅថាវិសារទធម៌ ឬវេសារជ្ជករណធម៌ ជាធម៌ធ្វើសេចក្ដីក្លាហាន ។

សំដែងមកក្នុងវិសារទធម៌ចប់ដោយសង្ខេបតែប៉ុណ្ណេះ ឯវំ ។

## មិនមែនព្រះនារាយណ៍ក្លែងខ្លួនជាព្រះនារាយណ៍

ឧបាយកល

សត្វពស់បើទុកជាមិនមានពិសក៏ត្រូវតែបញ្ចេញពពារ ហើយបើកវែកផង ទោះជាមានពិសក្ដីមិនមានពិសក្ដី ការបើកវែកជាការមួយ នាំឲ្យគេភ័យ ។

## បើស្លាប់ក៏គង់មានកេរ្តិ៍ឈ្មោះ

នរណាមួយលះបង់ជីវិតខ្លួន ដើម្បីគោព្រាហ្មណ៍ គ្រូ ករិយា និងរាជធានីរបស់ខ្លួន នរជននោះនឹងមានខ្លួនជាទីពឹង ។

បញ្ចតន្ត្រៈ

# ការបណ្ដុះនិស្ស័យ

## ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

---

ត្រូវសំដែងកិរិយាឲ្យប្រកបទៅដោយមេត្តាកាយកម្ម អនុគ្រោះចំពោះគ្នាដោយមេត្តាករុណា ផ្ដល់សេចក្ដីសុចរិតដល់ជីវិតរបស់គេ និងជួយដោះទុក្ខ ឬជួយជីវិតរបស់គេដែលបានទទួលទុក្ខ ឬជិតដល់អន្តរាយនោះឲ្យបានរួចមកវិញ កុំធ្វើចិត្តអាក្រក់បំផ្លាញជីវិត និងប្រទូសរ៉ាយកាយរបស់គេ ព្រោះជីវិតជារបស់មានដំឡៃបំផុតសម្រាប់អ្នកមានជីវិត ត្រូវរក្សាកម្មសិទ្ធិ គឺអំណាចដែលត្រូវធម៌ក្នុងទ្រព្យសម្បត្តិរបស់មនុស្សដទៃដែលគេខំរកបានមកដោយបែកញើសហូរញើស តាំងចិត្តស្វែងរកចិញ្ចឹមជីវិតក្នុងផ្លូវត្រូវ និងកាន់យកកម្មសិទ្ធិក្នុងទ្រព្យសម្បត្តិដោយគន្លងនីតិធម៌ កុំបន្លំលួចប្លន់ឬឆបោករបស់គេយកមកធ្វើជារបស់ខ្លួនដោយអាការនៃចោរ ត្រូវរក្សាការប្រព្រឹត្តិរបស់ខ្លួនកុំឲ្យខុសផ្លូវបវេណី ប៉ុនប៉ងថែរក្សាវង្សត្រកូលរបស់គេនិងរបស់ខ្លួនឲ្យបរិសុទ្ធ ដើម្បីឲ្យបានវឌ្ឍនាស្ថាពរតទៅ នេះចាត់ថាជាកាយសុចរិត ។

ត្រូវបញ្ចេញវាចាឲ្យប្រកបទៅដោយមេត្តាវចីកម្ម រក្សាសំដីរបស់ខ្លួនឲ្យទៀងទាត់ ទីងល្អត្រឹមត្រូវ មិនជាការប្រទូស្តរាយគេ គឺនិយាយឲ្យពិតកាន់សច្ចាទីងប្រជ្ញាដែលបានធ្វើទុកឲ្យខ្ជាប់ខ្ជួនមិនបែបបាំង, ពន្យល់ដឹកនាំគ្នាឲ្យតាំងនៅក្នុងសេចក្តីសាមគ្គីដ៏ប្រពៃ បរបាពីពោះផ្អែមល្ហែមគួរក្រេបជញ្ជាក់ទុកក្នុងចិត្ត ព្រមទាំងមានមារយាទរៀបរយទនលំទោន សំដែងសេចក្តីស្ម័គ្រស្មាគម ស្រឡាញ់រាប់អានគ្នាយ៉ាងរាក់ទាក់ និយាយសំដីដែលជាប្រយោជន៍ទីងត្រូវធម៌ ទាំងដឹកនាំគ្នាឲ្យលះអាក្រក់ប្រព្រឹត្តល្អផង កុំធ្វើឲ្យអន្តរាយដល់ខ្លួនទីងមនុស្សដទៃ ដោយពាក្យសន្ធនារបស់ខ្លួនជាដើម វៀរការសង្កត់សង្កិនអ្នកដទៃ ដើម្បីរស្មីសិរីយសសក្តិរបស់ខ្លួនដែលជាការរំលាយខ្លួនឲ្យវិនាស ក្នុងកាលខាងក្រោយនោះបេញ ។ បើនិយាយអ្វី ចូរនិយាយឲ្យកើតប្រយោជន៍ដល់អ្នកស្តាប់ ទាំងជាសិរីរបស់ខ្លួន មានគតិជាសុភាសិតប្រាសចាកទោសជាគ្រឿងសៅហ្មងរបស់វាចា នេះបាត់ថាជាវចីសុចរិត ។

ត្រូវសំដែងទឹកចិត្តឲ្យប្រកបទៅដោយមេត្តាមនោកម្ម កុំយកសុចរិតមកទុកត្រឹមតែរមបបូរមាត់សម្រាប់លលួងមនុស្សដទៃឡើយ ចូរយកសុចរិតទៅដាក់ខាងក្នុងហ្ឫទ័យឲ្យជ្រៅ កុំនៅមុខក្លែងធ្វើគោរពខាងក្រោយឡក ដែលជាហេតុសឲ្យឃើញថាឆ្អិនក្រៅឆៅក្នុង ។ ត្រូវឲ្យចេះស្គាល់ប្រមាណខ្លួន ល្មមចិត្តក្នុងកិច្ចការរបស់ខ្លួនដែលមាននៅ មាន

សន្ដោសជាគ្រឿងបញ្ចេញទឹកចិត្តឲ្យរីករាយសប្បាយ  អត់ធ្មត់តស៊ូចំពោះ លោភៈ ទោសៈ មោហៈ អត់សង្កត់ចិត្តមិនឲ្យគិតលោភចង់បានរបស់គេ ត្រេកអរតែក្នុងសម្បត្តិរបស់ខ្លួនដែលរកបានមកដោយគន្លងធម៌  កុំបង្កឲ្យ កើតសេចក្ដីក្ដៅក្រហាយឡើងដល់ខ្លួន  កុំធ្វើសេចក្ដីវិនាសឲ្យកើតឡើង ដល់អ្នកដទៃ  និងដល់មុខក្រសួងរបស់ខ្លួន  ព្រោះតែសេចក្ដីប្រាថ្នាហួស ហ៊ានៈឡើយ  កុំគិតប៉ងប្រទូសរ៉ាយគ្នាដោយទឹកចិត្តយង់ឃ្នង ៗ ត្រូវឲ្យ មានមេត្តាផ្សាយមេត្រី  ប្រាថ្នាសេចក្ដីសុខសេចក្ដីចំរើនដល់គ្នា  និងឲ្យ ឃើញត្រូវតាមគន្លងធម៌  ដែលជាហេតុនាំឲ្យខ្លួនគិតត្រូវ  ធ្វើត្រូវ  និង និយាយត្រូវ  នេះចាត់ថាជាមនោសុចរិត ។

ពួកសុចរិតក្នុងធម្មចរិយានេះ  ចាត់ថាជាកំពូលនៃវិថីចរិយារបស់ មនុស្សអាចហាមនូវកិរិយាខុស  ពាក្យខុសនិងគំនិតខុសបានទាំងអស់ ។ ព្រោះអ្នកតាំងនៅក្នុងធម្មចរិយា ជាមនុស្សមានចិត្តខ្ពស់ ជារបៀបរៀបរយ ប្រាថ្នាឲ្យជាគុណប្រយោជន៍ដល់ខ្លួននិងអ្នកដទៃ  មានការប្រតិបត្តិតាម ហេតុផល  មានសតិបញ្ញានៅជាប់និងការគិត ការនិយាយ ការធ្វើ មិន ឃើញខ្លី គិតសំឡឹងឃើញការណ៍វែងឆ្ងាយ មានសីលធម៌ប្រចាំខ្លួនទាល់តែ មនុស្សដទៃជឿជាក់ក្នុងចិត្តថា អ្នកនោះជាមនុស្សល្អគ្រប់គ្រាន់ មិនប្រើ កលោបាយ ប្រាសចាកខ្សែបន្ទាត់ ប្រើសត្យជាធម៌មាគ៌ា មានសម្មាអាជីវ ជាឧត្ដមគតិយ៉ាងក្រៃលែងជាងជីវិត  មានទឹកចិត្តសុចរិតម៉ឺងម៉ាត់មាំមួន

គោរពក្នុងផលប្រយោជន៍របស់មនុស្សដទៃ ដូចជារបស់ខ្លួនឯង មិនជាមនុស្សអាបព្រាយលាមកលោកប្រើនក្នុងផ្លូវខុសធម៌ មិនបំណងឲ្យអ្នកដទៃអន្តរាយ មិនតាំងចិត្តធ្វើទោសដល់អ្នកដែលអង្វរសូមទោស លើកទោសឲ្យដល់មនុស្សដែលអង្វរសូមទោស ព្យាយាមធ្វើតែល្អ សូម្បីការទុច្ចរិតបន្តិចបន្តួចក៏មិនគិតប្រាថ្នានឹងធ្វើ ឬមិនឲ្យជាហេតុដែលត្រូវធ្វើ ។

សេចក្ដីពិត ដួងចិត្តដែលសុចរិតនោះ លោកឲ្យឈ្មោះថាជាចិត្តប្រសើរបំផុត នឹងបាត់ថាជាកំពូលនៃចិត្តទាំងអស់ ។ អ្នកណាគោរពចិត្តត្រូវ ព្យាយាមអប់រំចិត្តរបស់ខ្លួនឲ្យគិតត្រូវ អ្នកនោះលោកបាត់ថាជាអ្នកប្រកបដោយភូមិធម៌ជាន់ខ្ពស់ ។ មនុស្សមានភូមិធម៌ជាន់ខ្ពស់ ក៏គឺមនុស្សសុចរិត ព្រោះមានចិត្តបរិសុទ្ធថ្លាស្អាត ប្រាសចាកគំនិតបាប, មនុស្សសុចរិតអាចគេចសង្កត់ អារម្មណ៍ អាមិស នឹងអំណាចអធម៌ណា ៗ បានទាំងអស់ ធ្វើនឹងនិយាយ តែងប្រកបដោយសេចក្ដីស្ងប់ដោយស្មើភាគ ដោយសេចក្ដីសុភាពទន់លំទោន ដោយប្រយ័ត្នប្រយែងនឹងដោយព្រមព្រៀងគ្នាគ្រប់យ៉ាង វៀរចាកការចិញ្ចឹមជីវិត ដែលជាការបៀតបៀនស៊ីសាច់ហុតឈាមមនុស្សផងគ្នា ទើបបាត់ថាជាអ្នកមានការប្រព្រឹត្តល្អពេញទាំងត្រៃទ្វារ ជាទីពេញចិត្តនៃមនុស្សទាំងពួង ។

ចំណែកមនុស្សទុច្ចរិតវិញសោត មានចិត្តវឹកវរទៅដោយគំនិតថោកទាប ជាទាសៈរបស់អារម្មណ៍ ជាទាសៈរបស់អាមិសនឹងជាទាសៈ

របស់អំណាចអធម៌ ឆ្លាតតែខាងផ្លូវកោងបោកប្រាស់ ប្រើក្នែករឡេម រឡោម ដើងឯកក្នុងការបង្អោនទឹកចិត្តខ្លួនដោយមាយាសាថេយ្យ ពេញទៅដោយកលោបាយលល្បួង គ្រាន់បើតែខាងលល្បួង ខាងក្អេងក្អាង ព្រងើយកន្តើយក្នុងសីលធម៌ ប្រាថ្នាតែប្រយោជន៍ផ្ទាល់ខ្លួនជាធំ មិនគិតដល់ទ្រព្យអ្នកដទៃផង ជាមនុស្សក្រហកក្រូតករ រកឧកាសតែទឹងស៊ីសាច់ហុតឈាមអ្នកដទៃ ជាមនុស្សលោភកន្ត្រាប់ស្រាពព្យាបាទ ប្រាសចាកមេត្តាប្រណីចំពោះអ្នកដទៃ ចូលបក្សពួកបំផ្លាញញាតិមិត្រទំលាយពួកគណៈ រហូតដល់ប្រទេសជាតិ មិនមានអៀនខ្មាស ហ៊ានធ្វើអាក្រក់ទាំងក្នុងទីកលទាំងក្នុងទីកំបាំង ទើបចាត់ថាជាមនុស្សមាន លោភៈ ទោសៈ មោហៈ ជាម្ចាស់ផ្ទះ ។

ក្ដីលោភ ក្រោធ និងវង្វេង ជាបុសគល់
នៃពួកខាង អកុសល គ្រប់តែមុខ
អ្នកណាល្ងង់ គង់វានាំ ឲ្យកើតទុក្ខ
បំផុតទៅត្រូវផ្តោះមុខ ទៅអបាយ ។

មនុស្សសុចរិត រមែងឃើញការដែនដីសំខាន់ជាងការផ្ទាល់ខ្លួន បើធ្វើអ្វី តែងធ្វើដើម្បីប្រយោជន៍អ្នកដទៃ ព្រោះជឿជាក់ យល់ច្បាស់ក្នុងហេតុផលថា "ការឲ្យសេចក្ដីល្អដល់លោក មិនមានអ្វីប្រសើរជាងសេចក្ដីសុចរិតឡើយ" ។ អ្នកបូជាគេ រមែងបានទទួលការបូជាតបវិញ ។ អ្នកថ្វាយ

បង្កំគេ រមែងបានទទួលការថ្វាយបង្គំតបវិញ ។ សេចក្ដីសុចរិតនេះក៏ដូច្នោះដែរ បើយើងឲ្យដល់លោកហើយ មិនបាត់ទៅណាឡើយ គង់នឹងត្រឡប់សងផលមកឲ្យយើងវិញ ដូចជាអុំទូក ទឹករមែងសាចចូលមករកខ្លួនយើងវិញដូច្នោះ ។ ឯមនុស្សទុច្ចរិត ច្រើនតែឃើញការផ្ដល់ខ្លួនសំខាន់ជាងការផែនដី បើធ្វើអ្វី តែងធ្វើដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ប៉ុន្តែច្រើនតែត្រឡប់ខូចផលដែលខ្លួនត្រូវបានទទួលនោះវិញ ដូចបាចទឹកចូលមករកខ្លួន តែទឹកនោះត្រឡប់ខ្ចាយទៅខាងៗ ខ្លួនវិញដូច្នោះ ព្រោះការធ្វើនោះមិនមែនជាវិធីនៃសុចរិត ឬធម្មចរិយាដែលគួរគោរពឡើយ ។ ពិតមែនមនុស្សទុច្ចរិត តែងមានកិរិយាចោរនៅពេញពោរសព្វកាយ នៅត្រង់មាត់ តែងពោរពាសទៅដោយការកុហកលាក់លៀម, នៅត្រង់មុខ តែងមានលក្ខណៈវៀចវេរចេញកំសួលមកឲ្យគេឃើញ, នៅត្រង់ដួងចិត្ត តែងមានលោភៈ ទោសៈ មោហៈ ជានាយចៅហ្វាយ ។ ឱ! អនិច្ចា! កាលបើយ៉ាងនេះក្នុងខ្លួនគេទាំងមូល គ្មានត្រង់ណាដែលឥតសេចក្ដីអាក្រក់ឡើយ ។

ចេះវិជ្ជា ជាហេតុ កំចាត់ខ្លៅ
ចេះមើលអាន សៀវភៅ កើនបញ្ញា
ចេះនព្វន្ត ចាយទ្រព្យ ដោយសម្មា
ចេះធម្មចរិយា ផុតទុក្ខភ័យ ។

២– **សុចរិតក្នុងបុគ្គល** យើងជាពួកពក្យនៃមនុស្សជាតិ ដែលជាប់ទាក់ទងគ្នា កើតមកជាមួយគ្នា នៅរួបរួមគ្នាធ្វើការងារឲ្យផលគ្នា ទីងនៅតែតាមទំនើងចិត្តខ្លួនឯងមួយមិនបាន សូម្បីយើងនៅឆ្ងាយពីគ្នា ចុងផែនដីម្ខាងម្នាក់ ក៏អាចមានចំណែកទាក់ទងគ្នាបាន ។ អ្នកដែលទាក់ទងគ្នាក្នុងជីវិតនោះ គឺគ្រួសាររបស់ខ្លួនឯង, ចំឆ្ងាយចេញទៅ ក៏គឺឧបអរសោទរចំពោះកឿនភក្តិក្នុងផ្នែកភូមិជាមួយគ្នា ក្នុងខែត្រដែនជាមួយគ្នា ក្នុងប្រទេសជាមួយគ្នា ដរាបដល់ក្នុងផែនដីជាមួយគ្នា ។ តែបុគ្គលដែលជាប់ទាក់ទងគ្នាហើយ ដែលត្រូវប្រតិបត្តិល្អចំពោះគ្នានឹងគ្នាជានិច្ចនោះ គឺស្វាមីនឹងភរិយា, មាតាបិតានឹងបុត្តធីតា, អាចារ្យនឹងសិស្ស, មិត្តនឹងមិត្ត, នាយចៅហ្វាយនឹងខ្ញុំកំដរ ។ ព្រោះថា កាលបើអ្នកដែលជាប់ទាក់ទងគ្នាទាំងអម្បាលនេះ បានប្រតិបត្តិត្រូវចំពោះគ្នានឹងគ្នាតាមចារិកប្រពៃណីនិយមហើយ មុខជាបានឈ្មោះថាជាអ្នកមានសុចរិតក្នុងបុគ្គល ។

**ស្វាមីនិងភរិយា** ·— ប្ដីប្រពន្ធដែលល្អគឺគូសង្សាររួមជីវិត រួមសុខរួមទុក្ខ ធ្លាប់ឧបត្ថម្ភគ្នាគ្រប់ជាតិ ដែលលោកចាត់ថាជាគូព្រេង ។ ឯប្ដីប្រពន្ធដែលថោកទាបវិញគឺគូវេរា ធ្លាប់ឈ្លោះទាស់ទែងគ្នា និងបង្ខិចបង្អោចបំផ្លាញប្រទូសរ៉ាយគ្នាគ្រប់ជាតិ ដែលចាត់ថាជាគូកម្មត្រូវសងកម្មពៀរដល់គ្នា ។

ស្វាមីដែលល្អនោះ គឺគេផ្គាប់ទុបអរទឹកចិត្តភរិយារហូតដល់បុត្រធីតា កូនក្មួយនិងមនុស្សបំរើ ឲ្យកើតសេចក្តីរីករាយស្និទ្ធស្នាលស្នេហាទៅគ្រប់គ្នា ជាហេតុនាំមកនូវសេចក្តីសុខសម្រាន្ត ហើយនិងមិនភ្លេចសេចក្តីស្រឡាញ់ជាដំបូងចំពោះភរិយា តាំងចិត្តប្រតិបត្តិត្រឹមត្រូវចំពោះភរិយាដែលត្រូវជានាទីរបស់ខ្លួន ។ "អ្នកស្រីដូចជាផ្កាឈើដែលជារបស់ទន់ភ្លន់ល្អត្រូវថែរក្សា" នេះជាសុភាសិត ដែលលោកប្រុសត្រូវនឹករឭកជានិច្ច ។

នាទីដែលស្វាមីត្រូវប្រតិបត្តិឲ្យត្រូវក្នុងភរិយារបស់ខ្លួននោះ គឺលើកដំកើងថាជាភរិយាពិតៗ ប្រគល់ឲ្យនូវសេចក្តីសុខ ឥស្សរភាព-សេរីភាពដល់ភរិយា សរសើរភរិយាឲ្យមានមុខមានមាត់ប្រាកដក្នុងពួកញាតិមិត្ត មិនមើលងាយថាជាមនុស្សថោកទាបដូចទាសី សំដែងសេចក្តីស្រឡាញ់រាប់អានគោរពក្រែងចិត្តគ្នា មិនក្បត់ចិត្ត គឺត្រេកត្រអាលឬសមល្មមតែក្នុងភរិយារបស់ខ្លួន ចិញ្ចឹមគ្នារៀងទៅរហូតដល់អស់ជីវិត ប្រគល់ឲ្យឥស្សរភាពក្នុងកិច្ចការផ្ទះសំបែង និងការបង្គាប់មនុស្សបំរើរហូតដល់ការចាត់ចែងចាយវាយលុយកាក់ឲ្យភរិយា ឲ្យគ្រឿងអលង្ការតែងកាយដល់ភរិយាតាមសមគួរដល់ឋានៈ ដែលជាការសំដែងសេចក្តីស្រឡាញ់និងការរាប់អានលើកដម្កើងឲ្យប្រាកដ ។ ប្រុសដូច្នេះ រមែងជាសិរីរបស់ត្រកូល ។ ស្រីណាបានប្តីបែបនេះធ្វើជាស្វាមី ស្រីនោះឈ្មោះថា មានជោគ-វាសនា បានរលត់ទុក្ខ បានសេចក្តីត្រជាក់ចិត្តឥតក្តៅក្រហាយ ។

ឯកិរិយាដែលល្អនោះ នៅត្រង់ការធ្វើនាទីប្រតិបត្តិដោយត្រឹមត្រូវ កុងស្វាមីរបស់ខ្លួន ៗ នាទីសំខាន់បំផុត គឺស្មោះត្រង់ចំពោះស្វាមីដែលជាការថ្នមចិត្ត ៗ ព្រោះកិរិយាដែលគួរសរសើរចំពោះមុខមនុស្សទាំងពួងនោះ នៅត្រង់ការស្មោះត្រង់ មិនក្បត់សេចក្ដីស្រឡាញ់ជាដំបូងចំពោះស្វាមី មិនគិតរៀបរាបចំផ្លាញទ្រព្យដោយការលេបលាក់ ស៊ីចាយផឹកស្រា លេងល្បែងភ្នាល់ មិនជាមនុស្សគេញ៉ើផ្ទះ បេះរក្សាទ្រព្យដែលស្វាមីរកយកមកឲ្យមិនឲ្យវិនាសខូចខាតទៅដោយហេតុមិនគួរ បេះចាយទ្រព្យតែល្មមសមគួរមិនខ្ជះខ្ជាយពេក មិនត្បិតត្បៀតពេក នឹងជាមនុស្សឈ្លាសវៃ ធ្វើខ្លួនឲ្យជាខ្សែព្រួរសម្រាប់ចងពួងពង្សត្រកូលមិនឲ្យប្រូលចិត្តនឹងគ្នា បេះទទួលប្រស្រ័យជាមួយនឹងមនុស្សជិតខាងរបស់ស្វាមី នឹងរបស់ខ្លួនឯងឲ្យស្និទ្ធស្នាលគ្នាលោយសាប់មួយ មិនឲ្យបែកបាក់គ្នាខូចសាមគ្គីបាន ៗ

នាទីដែលកិរិយាត្រូវប្រតិបត្តិដោយប្រពៃចំពោះស្វាមីនោះដូច្នេះ គឺជាអ្នកបេះចាត់ការងារបានល្អ បេះសង្គ្រោះមនុស្សជិតខាងរបស់ស្វាមីឲ្យល្អ មិនប្រព្រឹត្តក្បត់ចិត្តស្វាមី បេះរក្សាទ្រព្យសម្បត្តិដែលស្វាមីរកបានមក នឹងជាមនុស្សរឹងប៉ឹងអង់អាចមិនខ្ជិលប្រអូសក្នុងកិច្ចការទាំងពួង ៗ បើអ្នកស្រីប្រតិបត្តិបានដូច្នេះហើយ ក៏នឹងបានជាទីរីករាយសប្បាយចិត្ត អាចរម្ងាប់សេចក្ដីនឿយហត់ក្នុងពេលធ្វើការងាររបស់ស្វាមីបាន "លោកប្រុសដូចត្បូងពេជ្រ ដែលមានលក្ខណៈយ៉ាងរឹងប៉ឹង គួរឲ្យកក់ក្ដៅចិត្តបានក្នុង

ការគ្រប់គ្រងជីវិត" នេះជាស្លោកដែលអ្នកស្រីត្រូវនឹករឭកជានិច្ច ។ ប្រុសណាបានស្រីបែបនេះធ្វើជាគូសង្សារ ប្រុសនោះឈ្មោះថាបានត្រជាក់ត្រជំសប្បាយរីករាយគ្មានកង្វល់ដរាបដល់អស់ជីវិត ។

នារីណា ប្រាថ្នា បុរសគាប់
ចង់ឲ្យជាប់ រឿយៗ សព្វជាតិណា
គួរគោរព ស្វាមី នៃអាត្មា
ដូចអច្ឆរា បំរើ ព្រះកោសីយ ។
ចង់បានប្រាណ ជាប្រុស ឲ្យគាត់ទៀង
រៀងៗ ទៅ រាល់ជាតិ អសង្ខេយ្យ
គួរវៀរ កូនប្រពន្ធ អ្នកដទៃ
ព្រោះនិស្ស័យ កាមេ ទឹងប្រភេទ ។

(លោកនីតិ)

(មានត)

# រឿងសាមកុក

## កណ្ឌទី ១៣

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

កាលស៊ុនសឹកលើកទ័ពទៅច្បាំងនឹងឡាវអ៊ីវ ជីវយីក៏លើកទាហានគេចទៅពីក្រោយចុះទៅដល់តំបន់ខយ៉ុកឆ វេលានោះតាន់ប៊ូពួកស្រុកលោតាំងនាំប័ក្សពួកចូលមករកស៊ុនសឹក នៅតំបន់ខយ៉ុកឆនោះ ។ តាន់ប៊ូនេះជាមនុស្សមានកម្លាំងច្រើន រូបធំខ្ពស់ប្រហែល ៩ ហត្ថចាយ មុខលឿង រង់ភ្នែកក្រហម លុះដឹងថាជីវយីលើកពលទៅដល់តំបន់ខយ៉ុកឆ តាន់ប៊ូក៏បើកទ្វារទទួលជីវយី ៗ ក៏ចូលទៅក្នុងបន្ទាយខយ៉ុកឆ ទាហានឡាវអ៊ីវដែលនៅរក្សាបន្ទាយនោះ ក៏រត់មកតាមឡាវអ៊ីវ ៗ ដឹងហើយក៏ភ័យស្លុតចិត្ត ទើបឲ្យវាយឃ្មោះហៅថៃស៊ូជូ ៗ ត្រឡប់ថយទៅដល់ឡាវអ៊ីវ ៗ ថៃស៊ូជូសួរឡាវអ៊ីវថា ខ្ញុំបានច្បាំងនឹងធៀវគាវជិតនឹងមានជ័យហើយ ហេតុអ្វីលោកវាយឃ្មោះហៅខ្ញុំបាទមកវិញ? ៕

ឡៅអ៊ីវនិយាយពាក្យរឿងឲ្យថៃស៊ូជូស្ដាប់ ហើយក៏លើកទ័ពទៅរកស៊ីឡៀទឹងធុកយ៉ុងនៅតំបន់វូឡៀង ។ ឯតាន់ប៊ូក៏លើកបក្សពួកមករកស៊ុនសឹក ប្រាប់ពត៌មានដែលបានធ្វើការទាំងឡាយឲ្យស៊ុនសឹកស្ដាប់គ្រប់ប្រការ ។ តៀវជីវទៃប្រឹក្សាក៏ជំរាបស៊ុនសឹកថា ឥឡូវតំបន់ខយ៉ុកឆក៏មកជារបស់យើង ឡៅអ៊ីវលើកទ័ពរត់ទៅហើយ សង្គ្រាមយើងក៏មានជ័យជំនះ ដូច្នេះត្រូវតែយើងលើកតាមទៅទៀត ។ ស៊ុនសឹកក៏យល់ឃើញត្រូវ ទើបនាំខ្លួនតាន់ប៊ូលើកទាហានតាមទៅទាំងយប់ថ្ងៃ ក៏បានទាន់ឡៅអ៊ីវកណ្ដាលផ្លូវ ឡៅអ៊ីវក៏ឲ្យថៃស៊ូជូចេញច្បាំង ថៃស៊ូជូតទល់កម្លាំងទឹងថ្វីដៃស៊ុនសឹកមិនបាន ក៏នាំទាហាន ១៥ នាក់រត់ទៅស្រុកកេងកួន ទ័ពឡៅអ៊ីវក៏បែកខ្ញែកទៅតាំងនៅតំបន់ងីវជូ ។

ឯធុកយ៉ុងទឹងស៊ីឡៀ ក៏លើកទ័ពចេញពីបន្ទាយទឹងមកទទួលឡៅអ៊ីវ តែមិនទាន់ ក៏ជួបប្រទះទឹងស៊ុនសឹកៗ ក៏ប្រើតាន់ប៊ូចេញវាយទ័ពធុកយ៉ុងទឹងស៊ីឡៀ អ្នកទាំង ២ ក៏បែកខ្ញែកគ្នាទៅដោយខ្លួន ឯធុកយ៉ុងរត់ទៅតំបន់ងីវជូជួបប្រទះទឹងឡៅអ៊ីវ; ចំណែកស៊ីឡៀត្រឡប់ចូលបន្ទាយបាន សម្លាប់ពលទាហានស៊ីឡៀស្លាប់ប្រហែល ៦០ នាក់ ។ ស៊ុនសឹកក៏ឲ្យលើកទ័ពត្រឡប់ទៅតាមឡៅអ៊ីវៗក៏លើកចេញចាកបន្ទាយ ស៊ុនសឹកឃើញពីចម្ងាយក៏ស្រែកថា ឯងរត់ពីអញមក ឥឡូវអញតាមមកទាន់ហើយ ហេតុម្ដេចឯងមិនទទួលចាញ់? ។

អ៊ីប៉ីបានឮស៊ិនសិកថាដូច្នោះ ក៏ស្ទុះជិះសេះចេញមកតទល់នឹងស៊ិនសិកបាន ៣ ក្បួង ស៊ិនសិកចាប់ខ្លួនអ៊ីប៉ីបានក៏ចងសេកទុក ហើយបរសេះនឹងចូលទៅក្នុងបន្ទាយ ។

វ៉ឡេងគ្រឡេកឃើញក៏បំផាយសេះកាត់ខ្លួនចូលទៅដណ្តើមយកខ្លួនអ៊ីប៉ី ទាហានស៊ិនសិកឃើញវ៉ឡេងស្ទុះទៅជិតខ្លួនស៊ិនសិក ក៏ស្រែកប្រាប់ស៊ិនសិកៗ គ្រឡេកឃើញក៏ស្រែកគំហកដូចរន្ទះ វ៉ឡេងភ្ញាក់ធ្លាក់ពីលើសេះបែកក្បាលស្លាប់ ។ ស៊ិនសិកបំផាយទៅដល់មុខបន្ទាយហើយស្រាយចំណងអ៊ីប៉ីចេញ អ៊ីប៉ីក៏អស់ជីវិតស្លាប់ទៅទីនោះ ទាហានទាំងពួងក៏សរសើរថ្វីដៃស៊ិនសិកថា មានកម្លាំងខ្លាំងពូកែនឹងរកអ្នកឯណាស្មើគ្មាន ។ បណ្តាសេនាទាហានក៏ហៅស៊ិនសិកថា សៀវអង់ គឺមហាឧបរាជ ។

ឯទៀវអ៊ីវដែលខូចខាតរេហ៍ពលជាច្រើនក្រៃលែង ក៏នាំធុកយ៉ុងរត់ទៅនៅស្រុកអ៊ីចៀង ស៊ិនសិកក៏លើកទ័ពត្រឡប់មកព័ទ្ធបន្ទាយស៊ីឡេងទុកយូរថ្ងៃ ឲ្យទាហានស្រែកហៅស៊ីឡេងចេញមកតស៊ូ ។ ស៊ីឡេងក៏ឡើងទៅមើលលើជើងបន្ទាយ យកធ្នូបាញ់ត្រូវជើងស៊ិនសិកធ្លាក់ពីលើសេះ ។ ទាហានឃើញដូច្នោះ ក៏នាំគ្នាស្ទុះទៅគ្រាហ៍នាំចូលបន្ទាយ ឲ្យពេទ្យរក្សារបួសស៊ិនសិកជាយូរថ្ងៃទើបសះ ។ ស៊ិនសិកក៏នឹកគិតរកឧបាយឲ្យទាហានថយបន្ទាយអំពីទីនោះ ហើយឲ្យនាំគ្នាយំសោកថា ស៊ិនសិកត្រូវព្រួញស្លាប់ ។ លុះវេលាយប់ ស៊ិនសិកក៏ញែកទាហានចេញទៅបង្កប់ទុក

ជា ៤ កង ៗ ស៊ីឡេមិនបានដឹងជាកល់ឧបាយសំគាល់ថា ស៊ុនសិកស្លាប់ប្រាកដ លុះពេលយប់ស្ងាត់ក៏នាំត្រៀវអេង, គាន់ហេងលើកទាហានចេញទៅចាប់ទាហានស៊ុនសិក ៗ ឯពួកទាហានដែលបង្កប់គ្រប់កន្លែងឃើញស៊ីឡេចេញពោលបន្ទាយ ក៏បបួលគ្នាស្រែកហ៊ោព័ទ្ធស៊ីឡេជាប់ជុំវិញ ស៊ុនសិកក៏បរសេះកាន់ទួនទៅឈរមុខទាហាន ឲ្យស៊ីឡេឃើញហើយស្រែកថា អញឈ្មោះស៊ុនសិក ៗ ទាហានស៊ីឡេក៏ភ័យស្លុតនាំគ្នារត់ចោលសស្ត្រាវុធទាំងអស់មិនបានតស៊ូ នៅតែស៊ីឡេ, ត្រៀវអេងនឹងគាន់ហេងឈរកាន់ទួន ទាហានស៊ុនសិកក៏ស្ទុះស្រូចចូលទៅសម្លាប់ស៊ីឡេស្លាប់ ៗ គាន់ប៉ុក៏រត់ចូលទៅចាក់ត្រៀវអេងធ្លាក់ពីលើសេះស្លាប់ ជីវឃើមក៏យឹតធ្នូបាញ់ទៅត្រូវគាន់ហេងស្លាប់ទៅទៀត ៗ

ស៊ុនសិកក៏លើកទ័ពចូលបន្ទាយស៊ីឡេបាន តាំងបញ្ចុះបញ្ចូលទាហានស៊ីឡេបានជាច្រើន ហើយក៏លើកទៅតាមថៃស៊ូជូស្រុកកេងគួន កាលទៅដល់ស្រុកនោះក៏បោះទ័ពជាប់កំពែងស្រុក ហើយប្រឹក្សានឹងជីវឃើថា ធ្វើម្តេចយើងចាប់ខ្លួនថៃស៊ូជូបាន? ៗ ជីវឃើតបថា សុំឲ្យលោកចាត់ទាហានលើកចូលវាយស្រុកជា ៣ ប៉ែក បើកទុក ១ ប៉ែក ហើយឲ្យទាហានទៅបង្កប់នៅពីមុខស្រុក ចម្ងាយ ១ ទំហឹងសេះ យកពួរចងសន្ទឹងរាំងផ្លូវចាំចាប់ថៃស៊ូជូ ធ្វើដូច្នេះឃើញនឹងបានដោយងាយ ៗ ស៊ុនសិកយល់ឃើញត្រូវ លុះដល់ពេលយប់ក៏លើកទ័ពចូលវាយស្រុកនោះជា ៣ ប៉ែក បើកទុក ១ ប៉ែក ៗ

ឯថៃស៊ីជួក៏នឹកតូចចិត្តណាស់ ថាកាលនឹងលើកទាហានចេញតយុទ្ធនឹងស៊ុនសិក ទាហានក៏មានតិចមានប្រហែលតែ ១ ពាន់ប្លាយ ហើយសុទ្ធតែមិនប្រសប់ក្នុងការសង្គ្រាម ព្រោះជាពួកព្រៃ ៗ ថៃស៊ីជួគិតហើយ ក៏បើកទ្វារបន្ទាយរត់ចេញទៅទិសឯកើត ទាហានក៏លើកដេញតាម ហើយក្រែងញែកគ្នាឲ្យថៃស៊ីជួរត់រហូតទៅតាមផ្លូវដែលគិតទុកនោះ ថៃស៊ីជួក៏ប្រះពេលទាហានរត់ចេញទៅ សេះនោះក៏ប៉ះជាប់នឹងពួរដែលចងសន្ទឹងទទឹងផ្លូវដួលចុះ ទាហានដែលបង្កប់ប្របនោះ ក៏ចេញស្រែមកពោមពេមចាប់ថៃស៊ីជួចងបាន ហើយនាំទៅឲ្យស៊ុនសិក ៗ ឃើញក៏រត់ទៅស្រាយចំណងចេញ ហើយទាញដៃឲ្យអង្គុយនិយាយគ្នាថា ឡៅស៊ីរចិញ្ចឹមរក្សាអ្នកមិនសួននឹងគុណបំណាច់ទេ បើអ្នកចូលចិត្តមកនៅធ្វើការនឹងយើង ៗ នឹងចិញ្ចឹមរក្សាអ្នកឲ្យប្រពៃជាងឡៅស៊ីរ ៗ

ថៃស៊ីជួបានឮស៊ុនសិកនិយាយដូច្នោះ ក៏មានសេចក្ដីត្រេកអរជាពន្ទឹក ហើយគិតក្នុងចិត្តថា ស៊ុនសិកមិនមានសេចក្ដីអាឃាតព្យាបាទដល់ខ្លួនអញទេ ទើបថាខ្ញុំសុំស្ម័គ្រចូលធ្វើជាការនឹងលោកតទៅ ៗ ស៊ុនសិកចាប់ដៃថៃស៊ីជួហើយសើចថា កាលគ្រាយើងច្បាំងគ្នានៅតំបន់ស៊ុនតេងនោះ បើប្រសិនជាអ្នកចាប់យើងបានប្រហែលនឹងសម្លាប់យើងឬអ្វី? ៗ ថៃស៊ីជួឆ្លើយតបថា ការនោះនឹងនិយាយមិនត្រូវទេ ៗ ស៊ុនសិកនឹងថៃស៊ីជួក៏បបួលគ្នាអស់សំណើចទាំង ២ នាក់ រួចឲ្យរៀបតុះលៀងអាហារ

ព្រមទាំងសេនាទាហានទាំងពួង ក៏បរិភោគជាមួយគ្នា ។ ថៃស៊ូជូ និយាយថា ស្ម័គ្របក្សពួកឡៀវអ៊ីវក៏នៅព្រាត់ប្រាសនិពសគ្នាទៅផ្សេងៗ ខ្ញុំសុំលាលោកទៅបញ្ចុះបញ្ចូលប្រមូលយកមកជាពួករបស់យើង នឹងបាន ជាកំឡាំងធ្វើការតទៅ ឬលោកមិនជឿចិត្តខ្ញុំទេ? ។

ស៊ុនស៊ិកតបថា ខ្ញុំជឿណាស់ទៅហើយ តែបើអ្នកចេញទៅព្រឹកស្អែក ដល់ពេលថ្ងៃត្រង់ឲ្យស្រូតត្រឡប់មកវិញ ខ្ញុំនៅចាំនៅទីនេះ ។ ថៃស៊ូជូទទួលពាក្យហើយក៏គំនាប់លាចេញទៅ, ឯទីប្រឹក្សាទាំងអស់ និយាយដំរាបស៊ុនស៊ិកថា លោកបើកលែងឲ្យថៃស៊ូជូចេញទៅដូច្នេះ ប្រហែលមិនវិលត្រឡប់មកវិញទេ ។ ស៊ុនស៊ិកតបថា ថៃស៊ូជូជាមនុស្ស សុចរិតល្អណាស់ បានទទួលពាក្យប្តេជ្ញានឹងយើងដូច្នេះហើយ ដែលនឹងមិនត្រឡប់មកវិញ នោះយើងមិនឃើញផងទេ ។ ទីប្រឹក្សាទាំងអស់គ្នា នៅតែមិនអស់សង្ស័យ ដោយគោតញញើតស៊ុនស៊ិកហើយក៏ស្ងៀមនៅ ។ លុះព្រឹកឡើងក៏នាំគ្នា យកឈើទៅបោះបញ្ឈរនៅមុខបន្ទាយ ដើម្បីនឹងចាំចាប់ពិរុធវៀចរបស់ថៃស៊ូជូ ។ លុះដល់ពេលសន្ទតស្រមោលត្រង់ ក៏នាំស្ម័គ្របក្សពួកមកដល់បន្ទាយ ១ ពាន់ប្លាយ ។ ទាហានទាំងពួង ឃើញថៃស៊ូជូមកដល់បន្ទាយដូចពាក្យស៊ុនស៊ិកនិយាយ ក៏បបួលគ្នាសរសើរស៊ុនស៊ិកថា ស្គាល់មនុស្សវៀចត្រង់ក្នុងដួងចិត្តជាប្រាកដ ។

ស៊ុនស៊ិកបានសេនាទាហានប្រហែល ៣ ម៉ឺន ក៏លើកព្យុហៈទ័ពទៅនៅស្រុកកាំងតាំង ។ បណ្តាមនុស្សម្នាមហាជនក្នុងស្រុកនោះ លុះ

ឃើញស៊ុនសិកចូលទៅដល់ ក៏បបួលគ្នាស្ម័គ្រចិត្តចូលមកនៅជាប័ក្សពួកស៊ុនសិកទាំងអស់ ។ ស៊ុនសិកដាក់អាជ្ញាហាមប្រាមសេនាទាហានមិនឲ្យទៅបៀតបៀនអាណាប្រជានុរាស្ត្រឲ្យមានសេចក្តីក្តៅក្រហាយ ។ មនុស្សទាំងឡាយក៏នៅជាសុខក្សេមក្សាន្ត មានពាក្យហៅស៊ុនសិកថាស៊ុនល្អ ខ្លះក៏នាំយកសុរាមានទាំងចំណីអាហារគ្រឿងបរិភោគ នាំមកជូនជាជំនូនស៊ុនសិកៗ ក៏ឲ្យគំនាប់ទៅវិញជាមាសប្រាក់សំពត់អាវសារស្បៃតាមដំឡៃដ៏សមគួរដល់បណ្តាជនទាំងពួង ។ តែបណ្តាទាហានរបស់ឡៅអ៊ីដែលនៅក្នុងស្រុកកាំងតាំងនោះ នរណាទឹងស្ម័គ្រចិត្តចូលមកធ្វើការជាមួយស៊ុនសិកៗ ចិញ្ចឹមរក្សាតាមគួរសម នរណាមិនព្រមនៅដោយបង្ខំ ស៊ុនសិកក៏ឲ្យមាសប្រាក់គ្រឿងសម្លៀកបំពាក់គ្រប់គ្នា ហើយបើកឲ្យលាទៅនៅរកស៊ី ធ្វើការតាមភូមិលំនៅ ។ កិត្តិស័ព្ទក៏រន្ទឺឮខ្ចរទៅថាស៊ុនសិកជាមនុស្សល្អគួរជាទីពឹងដល់ជនទាំងពួង ។

ស៊ុនសិកក៏ចាត់ចែងទាហានទៅទទួលមាតាទីងមា ហើយទីងប្អូនប្រសស្រីមកទុកនៅតំបន់ខយ៉ុកឌុ ហើយតាំងស៊ុនគួនជាប្អូនប្រុសទីងជីវចាយ ឲ្យទៅឈររក្សាស្រុកហ៊ួនសៀ ខ្លួនស៊ុនសិកក៏លើកសេនាទាហានទាំងពួងទៅវាយស្រុកតងឌឺ ។

គ្រានោះ ជើមប៉ុះហាដែលតាំងខ្លួនឡើងជាស្តេចហៅថាតិកអងនៅស្រុកតងឌឺ ផ្ញើទាហានឲ្យលើកទៅរក្សាស្រុក នៅតំបន់អសេង

កែហ៊ានដែលជាដែនស្រុកតងង៉ ចាត់ចែងរៀបចំស្រុកជាស្រេច ក៏មានទាហានទៅប្រាប់ថា ស៊ុនស៊ិកលើកទ័ពមក ងៀមប៉ុះហាក៏ប្រើប្អូនប្រុសឈ្មោះងៀមអ៊ុ លើកទ័ពទៅតាំងនៅស្ពានហងកៀវជាផ្លូវសំខាន់ ងៀមអ៊ីជិះសេះកាន់ក្របីឈរចាំស៊ុនស៊ិកនៅលើស្ពាន ។ ទាហានយកសេចក្ដីទៅប្រាប់ស៊ុនស៊ិកថា ងៀមអ៊ីលើកទ័ពមកចាំច្បាំងទឹងលោកនៅលើស្ពាន ។

ស៊ុនស៊ិកបង្គាប់ទាហានថា យើងត្រូវលើកទ័ពទៅច្បាំងទឹងងៀមអ៊ីវេលានេះ ។ គៀវហៀនទីប្រឹក្សាជំរាបថា ទាហានដែលមានថ្មីដៃក៏ច្រើនខ្លួន មិនគួរលោកចេញទៅច្បាំងខ្លួនឯងទេ បើលោកទៅបីដូចយកមាសទៅដុះនឹងថ្ម ។

ស៊ុនស៊ិកយល់ឃើញត្រូវ ក៏ប្រើហាន់តុងលើកទាហានទៅតទឹងងៀមអ៊ីលើស្ពាន ហើយឲ្យគាន់ប៉ូ, ជីវឃឹមចុះទូកតូច ១ យកធ្នូបាញ់ប្រម៉ះផ្ទប់ទាំងសងខាងស្ពាន ។ ងៀមអ៊ីខូចខាតទាហានជាច្រើនក៏ថយទ័ពត្រឡប់ចូលទៅក្នុងស្រុកវិញ ហាន់តុងក៏ដេញសង្កិញទៅទល់ទឹងជើងកំពែង ។ ស៊ុនស៊ិកលើកកងទ័ពចូលឡោមព័ទ្ធជុំវិញស្រុកតងង៉ ទាំងផ្លូវគោកទាំងផ្លូវទឹកដល់ ៣ ថ្ងៃមិនបានឃើញអ្នកឯណាចេញមកតស៊ូ ។ ស៊ុនស៊ិកក៏លើកទាហានដើរមើលជុំវិញកំពែងស្រុក ហើយស្រែកថា នរណាចូលមកជាពួកយើងក៏ឲ្យបើកទ្វារចេញមក យើងមិនធ្វើឲ្យអន្តរាយទេ ។

ខណៈនោះទាហានង៉ៀមប៉ែះហាម្នាក់ឈរលើសែនបន្ទាយ បានឮសំឡេងស៊ុនសិកស្រែកដូច្នោះក៏ខឹងណាស់ យកដៃឆ្វេងច្រត់លើសំយាបសែនយកដៃស្តាំបង្អុលមុខស៊ុនសិកហើយស្រែកជេរពីលើសែន ៗ ថៃស៊ីជូក្រឡេកឃើញក៏ដំឡើងធ្នូផ្គងបាញ់ហើយងាកមកប្រាប់ទាហានថា យើងនឹងដោតដៃអាមនុស្សកំណាចភ្ជាប់នឹងសែន ៗ មនុស្សទាំងពួងងាកមើលទៅក៏ឃើញព្រួញដោតដៃទាហាននោះ ក៏នាំគ្នាសរសើរថៃស៊ីជូថាស្ទាត់ជួរកែអ្នកណាស្មើគ្មាន ៗ

ឯទាហានពោនាទី ក្រឡេកឃើញថ្វីដៃថៃស៊ីជូ ក៏នាំសេចក្តីនោះទៅជុំពបង៉ៀមប៉ែះហា ៗ ក៏គ្រវីក្បាលហើយថា "បើយើងបានទាហានយ៉ាងនេះតែម្នាក់មកធ្វើការជាមួយផង យើងក៏មិនត្រូវខ្លាចអ្នកឯណាឡើយ" ហើយក៏ប្រឹក្សានឹងទាហានទាំងពួងថា សឹកគ្រានេះធំពន្ធឹកក្រៃលែង យើងនឹងគិតប្រការម្តេច? ៗ ង៉ៀមអ៊ីឆ្លើយថា ខ្ញុំបាទនឹងសុំយកអាសាចេញទៅនិយាយនឹងស៊ុនសិកដោយល្អ ៗ ង៉ៀមប៉ែះហាក៏យល់ព្រមផង ៗ ង៉ៀមអ៊ីក៏ចេញទៅរកស៊ុនសិកក្នុងបន្ទាយ ស៊ុនសិកឃើញង៉ៀមអ៊ីដើរចូលទៅក៏ធ្វើជាស្រួក ក្រោកឡើងគំនាប់ហើយអញ្ជើញឲ្យអង្គុយតាមទីសមគួរ ចាក់ស្រាឲ្យផឹក លុះង៉ៀមអ៊ីស្រវឹងស្រាហើយស៊ុនសិកក៏សួរថា ង៉ៀមប៉ែះហាជាបងអ្នក ឥឡូវនេះនឹងគិតការដូចម្តេចទៅវិញ? ៗ ង៉ៀមអ៊ីឆ្លើយថា បងខ្ញុំនឹងប្រឹក្សាទាំងពួងពិគ្រោះយល់ថា នឹងសុំចូលមកអង្វរបែងស្រុកឲ្យលោកកាត់កណ្តាល ៗ

ស៊ុនសិកព្រួយព្រោះខឹងណាស់និយាយថា "ស្រុកគងនឹងនេះនៅក្នុងកណ្ដាប់ដៃអញអស់ហើយ ឯងម្ដេចក៏ហ៊ានមកបរបាជ្ញេះ?" ថាហើយក៏ស្រែកហៅទាហានឲ្យចាប់នៀមអ៊ុទីងយកទៅសម្លាប់ នៀមអ៊ុព្រួយព្រោះក៏ហូតក្រិសក្រោកឡើងទីងកាប់ស៊ុនសិកៗ ហូតក្រិសដែលសៀតបង្កប់ពីក្រោយនោះគេរាសទៅត្រូវនៀមអ៊ុដាច់កស្លាប់ ហើយឲ្យទាហានលើកយកក្បាលនៀមអ៊ុចោលទៅក្នុងកំពែង ៗ នៀមបែះហាឃើញក៏ភ័យស្លុតរន្ធត់ស្មារតី ទីងរិះគិតលើកកងទ័ពចេញទៅច្បាំងទីងស៊ុនសិកក៏ទឹកគោត ញញើត លុះដល់ពេលយប់ស្ងាត់ នៀមបែះហាក៏នាំទាហានបើកទ្វាររត់ចេញទៅ ។

ស៊ុនសិកដឹងថា នៀមបែះហារត់ចោលស្រុកទៅហើយ ក៏ចាត់ប្រើអ៊ុយកាយទៅរាយតំបន់កែហ៊ុន ឲ្យថៃស៊ូជូទៅរាយតំបន់អសេង លុះរាយបានស្រុកទាំង ២ តំបន់នេះហើយ ស៊ុនសិកក៏ចាត់ចែងឲ្យបណ្ដាស្ដុកស្រុកគងនឹងនៅជាសុខក្សេមក្សាន្ត ហើយក៏លើកទាហានទៅតាមនៀមបែះហាដែលរត់ទៅនោះ ។

នៀមបែះហាក្លែងខ្លួនជាចោរព្រៃ នាំស្ម័គ្របក្សពួកលើកទៅដល់តំបន់អ៊ុខង ប្រព្រឹត្តធ្វើចោរកម្មផ្សេងៗ ។ ឡើងឆោពួកស្រុកអ៊ុខងក៏ប្រមូលគេណ្ដាស្ដុកស្រុកលើកចេញទៅរាយនៀមបែះហាៗ ក៏រត់ឆ្លងទៅត្រើយម្ខាងមាត់ស្ទឹង តាំងបន្ទាយនៅតំបន់សៃស៊ុនដើម្បីទីងរំហូតទៅស្រុកហាយខេ ។

ឯស៊ិនសិកដែលលើកទ័ពតាមទៅនោះ បានទៅដល់តំបន់អ៊ុខង ៗ ឡេងតោដឹងដំណឹង ក៏នាំយកកូនប្រុស ២ នាក់មករកស៊ិនសិកហើយជំរាបថា ងៀមបែះហរត់សំដៅតាមផ្លូវទៅស្រុកហាយខេ ៗ ស៊ិនសិកក៏តាំងឡេងតោជានាយទាហានវេង. ហើយក៏ស្រូតលើកកងទ័ពទៅតាមងៀម-បែះហទៀតបានលើកទៅទាន់គ្នានៅដំបន់សៃស៊ិន ឈៀកៅក៏បរពលចូលវាយទ័ពងៀមបែះហ ៗ ក៏បែកទ័ពរត់ទៅស្រុកហាយខេ ៗ

ឯអងឡេងចៅហ្វាយស្រុកហាយខេដឹងថា ងៀមបែះហបែកទ័ពរត់មក ក៏ឲ្យប្រមូលទាហានទឹងលើកចេញទៅជួយងៀមបែះហ នោះងីហួនពួកស្រុកអ៊ុហៀវដែលជាទីប្រឹក្សានិយាយថា ស៊ិនសិកនោះជាមនុស្សមានថ្វីដៃខ្លាំងពូកែ ហើយតាំងនៅក្នុងសេចក្ដីសត្យសុចរិតល្អណាស់ ឯងៀមបែះហជាមនុស្សប្រព្រឹត្តទុច្ចរិតអាក្រក់ ហេតុម្ដេចលោកគិតទៅជួយខាងមនុស្សអាក្រក់វិញមិនគួរសោះ សូមឲ្យលោករិះគិតប្រើគំនិតជាកល់ឧបាយ ចាប់ខ្លួនងៀមបែះហបញ្ជូនទៅឲ្យស៊ិនសិកវិញប្រសើរជាង ៗ អងឡេងស្ដាប់មិនត្រូវចិត្តក៏ខឹងណាស់ ស្រែកគំហកឲ្យងីហួនៗទាល់គំនិតក៏នៅស្ងៀម ៗ អងឡេងក៏លើកទាហានចេញទៅជួបនឹងងៀមបែះហ ហើយនាំគ្នាទៅតាំងបន្ទាយបោះទ័ពនៅកណ្ដាលវាលស្រែ ក្បែរជើងភ្នំចាំទទួលទ័ពស៊ិនសិក ៗ

កាលស៊ិនសិកលើកទ័ពទៅដល់បន្ទាយងៀមបែះហ ក៏ក្រឡេកឃើញអងអងឡេងជិះសេះឈរនៅមុខទាហានកាន់ក្រប៊ី ស៊ិនសិកស្រែកថា

យើងធ្វើការទាំងនេះប្រាថ្នានឹងឲ្យបណ្ដារាស្ត្របានសេចក្ដីសុខ ឯងៀមបែះហាជាមនុស្សអន្ធពាល ហេតុម្ដេចខ្លួនធ្វើជាចៅហ្វាយស្រុកខុំពជាការផែនដី ទៅចងមេត្រីនឹងមនុស្សគ្រោកគ្រក់ទៅវិញ ។

អង់ឡេងបានឮដូច្នោះ ក៏ស្រែកដេរទៅស៊ុនសិកថា ឯងនេះជាមនុស្សលោភក្រោធមិណាស់ ស្វះស្វែងដើរច្បាំងដណ្ដើមយកស្រុកទេសរបស់គេជាច្រើនតំបន់ នៅមិនទាន់អស់ចិត្ត ឥឡូវលើកមកលំអិតញាំញីក្នុងទឹកដែនរបស់អញ បានជាអញត្រូវលើកទ័ពមកជួយងៀមបែះហាវិញ ប្រាថ្នានឹងសងសឹកឯងឲ្យបាន ។

ស៊ុនសិកខឹងណាស់ ក៏បរសេះចូលទៅប្រយុទ្ធនឹងអង់ឡេងបាន ៦ ភ្លេង ថៃស៊ូជូឃើញដូច្នោះ ក៏បរសេះស្ទុះទៅកាត់មុខស៊ុនសិក ដីរជៀវទាហានអង់ឡេងក៏ចេញមកតស៊ូនឹងថៃស៊ូជូបាន ៥ ភ្លេង ទទួលដីវយីជៀវសៅលើកទាហានមកទាន់ក៏ត្រឡប់ព័ទ្ធពីក្រោយ ឡោមជុំវិញអង់ឡេងៗ ក៏នាំងៀមបែះហាត្រឡប់ចូលស្រុកវិញ ហើយទាញស្ពានទម្លាក់បិទទ្វារជិតយ៉ាងមាំមួន ។ ស៊ុនសិកក៏លើកទាហានឡោមព័ទ្ធជុំវិញស្រុកនោះ ។

(មានត)

រឿងអារក្សថ្លែងរឿងខ្មោចច្រាំ

លោករ៉ាយ-ប៊ុក ក្រមការ ក្រុមពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

(តមក)

## រឿងទី ១០

អារក្សថ្លែងថា: "ឱព្រះមហាក្សត្រិយ៍! សូមក្រាបទូលទ្រង់, នៅប្រទេសគូរ (Gaur) មាននគរមួយឈ្មោះ វឌ្ឍមាន (Varddhaman) ហើយព្រះមហាក្សត្រិយ៍ដែលសោយរាជ្យនៅប្រទេសនោះ ទ្រង់ព្រះនាមព្រះបាទគុនសេខារ (Gunshekar) មានរដ្ឋមន្ត្រីម្នាក់កាន់លទ្ធិជ័យនិស្ត (jainiste) នាមអភ័យចន្ទ (Abhaichand) ។ ព្រះមហាក្សត្រិយ៍នោះលុះដោយអំណាចសេចក្ដីណែនាំនៃរដ្ឋមន្ត្រីនេះ ទ្រង់ក៏កាន់សាសនាជ័យនិស្តដែរ ។ ទ្រង់បានហាមប្រាមមិនឲ្យប្រជារាស្ត្ររបស់ព្រះអង្គគោរពព្រះសិវៈ, ព្រះវិស្ណុៈ, បូជាគោញី, ដី, បិណ្ឌាស៍ (Pindas) ល្បែងនឹងការសេពសុរានឹងមេរ័យ ។ ទ្រង់ប្រកាសហាមមិនឲ្យអ្នកណាយកអដ្ឋិធាតុទៅបោលនៅទន្លេគង្គាសោះឡើយ, ហើយរដ្ឋមន្ត្រីនោះ ក៏បាត់ឲ្យមនុស្សដើរស្រែកប្រកាសនូវព្រះបំរាមនោះដោយរាយស្គរឡូងគេរីថា:

"ព្រះមហាក្សត្រិយ៍ ទ្រង់នឹងរឹបអូសយកភោគទ្រព្យ ធ្វើទណ្ឌកម្ម ហើយនិរទេសចេញពីនគរ នូវជនណាមួយដែលមិនប្រតិបត្តិតាមព្រះរាជបំរាមនោះ" ។

មានមួយថ្ងៃ លោកអភ័យចន្ទក្រាបទូលព្រះមហាក្សត្រិយ៍ថា: "សូមទ្រង់ព្រះមេត្តាប្រោស ! ទូលព្រះបង្គំនឹងក្រាបទូលនូវគោលការណ៍នៃគុណធម៌ អ្នកណាដែលពិឃាតញាតិមិត្តក្នុងជីវភាពបច្ចុប្បន្ននេះ អ្នកនោះមុខជានឹងពិឃាតដល់ទៅជីវភាពអនាគតផង, អ្នកនោះដែលមកកើតក្នុងពិភពលោក ដោយផលនៃបាបកម្មខាងលើ, ជីវិតមិនមែនរលត់រលាយទៅនៅពេលដែលសេចក្ដីស្លាប់មកដល់ទេ ព្រោះមនុស្សកើតម្ដងទៀត ហើយស្លាប់តៗគ្នាជានិរន្តរ៍ តាំងពីមនុស្សនោះចាប់បដិសន្ធិមកត្រូវបំពេញនូវករណីយកិច្ចផ្សេងៗ, សូមទ្រង់ទតនូវព្រះព្រហ្ម, ព្រះវិស្ណុ, ព្រះមហាទេពដែលបរាជ័យចាញ់សេចក្ដីស្នេហា (រាគៈ), ខឹង (ទោសៈ), សេចក្ដីកំណាញ់ (មច្ឆរិយៈ) ហើយនឹងតណ្ហាត្រូវច្យុតមកកើតលើផែនដី មានអាការផ្សេងៗ, តែគោញីមានសភាពខ្ពង់ខ្ពស់ជាងព្រះខាងលើ គោញីនេះ លះបង់នូវទោសៈ, អបិយៈ (សេចក្ដីស្អប់), អបាយមុខ, ឧម្មត្តកៈ (ឆ្កួត), មច្ឆរិយៈ នឹងការស្រវឹងដែលជាបង្អែកនៃពិភពលោក, ជីវសត្វនៅលើដីជាកូននៃអកុសលខាងលើ, គោញីនេះបានថ្នាក់ថ្នមនូវសត្វលោកទាំងមូល ធ្វើឱ្យសត្វនេះបានសុខស្រួល ដោយមធ្យោបាយផ្សេងៗ, បានជាសត្វលោកស្រឡាញ់គោញីនេះ, ព្រោះហេតុដូចនេះ បានជាទេវតាឥន្ទព្រហ្ម នឹងពួកមុនីទទួលស្ដាប់បង្គាប់គោញីនេះទាំងអស់, បានជាមិនត្រូវធ្វើតាមឱវាទនៃទេវតាព្រះឥន្ទព្រះព្រហ្មនោះ

ឡើយ; បពិត្រមហារាជ គួរតែទ្រង់គោរពកោតខ្លាចនូវគោញីក្នុងពិភពលោក, នេះគឺជាករណីយកិច្ចមួយដ៏ប្រសើរចំពោះការគោរពនូវជីវិតទាំងអស់, មនុស្សសត្វតិរច្ឆានទាំងបក្សា តាំងពីសត្វដំរី រហូតដល់សត្វស្រមោច, គ្មានករណីយកិច្ចអ្វីក្នុងពិភពលោកមានសភាពពិសិដ្ឋជាងករណីយកិច្ចខាងលើ, មនុស្សលោក, ដើម្បីនឹងធ្វើរូបកាយឲ្យមានពលភាព, បរិភោគសាច់សត្វ, រងទុក្ខលំបាកឯនរក, ករណីយកិច្ចរបស់មនុស្សត្រូវតែការពារជីវិតគ្រប់យ៉ាង, ហើយបើអ្នកណាមិនយល់នូវទុក្ខរបស់ជីវសត្វ, អ្នកណាដែលសម្លាប់សត្វបរិភោគ អ្នកនោះមានអាយុខ្លីហើយដល់កើតមកក្នុងលោកទៀត ទៅជាមនុស្សវិកលវិការ, ខ្វិន, ខ្វាក់ក្អែកម្ខាងឬទាំងពីរខាង, មនុស្សតឿ, គម, ខុសខ្នាត, បើបរិភោគរូបសត្វតិរច្ឆានទាំងបក្សា អ្នកទាំងនោះធ្វើឲ្យវិនាសរូបខ្លួន ហើយសេចក្តីទុក្ខនឹងមានឡើងក្នុងការសេពសុរានឹងមេរ័យ, ហេតុនេះទ្រង់មិនត្រូវសោយនូវសាច់ ព្រមទាំងសុរានឹងមេរ័យឡើយ ។ ។

ដោយហេតុដែលបានពណ៌នានូវយោបល់ទាំងនេះ ក្រាបទូលព្រះបាទគុនសេហ្ការ បានជាលោកនាយករដ្ឋមន្ត្រីណែនាំទ្រង់ឲ្យកាន់សាសនាជ័យនិស្ត ។ ព្រះមហាក្សត្រិយ៍ទ្រង់ធ្វើតាមបង្គាប់លោកនាយករដ្ឋមន្ត្រីនេះទាំងអស់ ហើយត្រួតត្រាប្រជារាស្ត្រដោយសេចក្តីប្រកាន់ជឿជាក់នៃសាសនានេះជាមូលដ្ឋាន, ទ្រង់លះបង់នូវពួកព្រាហ្មណ៍, យោគី

(យោគាវចរ), តាបសមហាហ្ម័ត (Fagenis) ទេវៈ (ទេវតា), សន្និយាសីស៍ (Sannyasis, (ប្រហែលជាឥសី ?), លោកសង្ឃមហាហ្ម័ត (Derviches) ។

មានមួយថ្ងៃ, ព្រះបាទគុនស្ទេការ ទ្រង់សោយទិវង្គត, ព្រះរាជបុត្រទ្រង់ព្រះនាម ធម៌ធ្វជៈ (Dharmdhwaj - មហាក្សត្រិយ៍មានគុណធម៌) បានឡើងសោយរាជសម្បត្តិស្នងអង្គព្រះបិតា ។ មានមួយថ្ងៃ, ទ្រង់មានព្រះរាជបញ្ជាឲ្យចាប់នាយករដ្ឋមន្ត្រីអភ័យចន្ទ ត្រាស់បង្គាប់ឲ្យកោរក្បាលទុកតែសក់ប្រាំពីរសរសៃ, យកពណ៌ខ្មៅលាបមុខ ហើយឲ្យជិះលាជុំវិញព្រះរាជធានី មានប៉ាវគងទូងកើរ រួចនិរទេសចេញពីព្រះរាជអាណាចក្រ ។ ទ្រង់ក៏ត្រួតត្រាប្រទេសតាមព្រះទ័យព្រះអង្គ គ្មានព្រួយបារម្ភអ្វីឡើយ ។

មានកាលមួយថ្ងៃ គឺក្នុងទិវាយវដ្ដរ, ព្រះបាទធម៌ធ្វជៈ ទ្រង់យាងទៅប្រពាតនឹងព្រះអគ្គមហេសី ក្នុងព្រះរាជឧទ្យានមួយ ដែលមានស្រះបទុមធំមួយ ។ ដោយទ្រង់សព្វព្រះរាជហឫទ័យចង់ស្រង់ទឹក, ទ្រង់ក៏ផ្លាស់ព្រះពស្ត្រ យាងចុះទៅក្នុងស្រះនោះ ។ ទ្រង់បានបេះបុប្ផាមួយ យាងចូលទៅជិតមាត់ត្រាំង ដើម្បីនឹងបាចទៅឲ្យព្រះអគ្គមហេសី, តែបុប្ផានេះជ្រុះពីព្រះហស្តព្រះអង្គធ្លាក់ទៅលើព្រះបាទព្រះនាងបាក់បែកខ្ទេចខ្ទីអស់ ។

ទ្រង់ភ័យជាខ្លាំង ឡើងពីស្រះហើយក៏យកឱសថទៅលាបព្រះបាទព្រះនាង, តែដូនជាក្នុងពេលយប់នោះ ព្រះចន្ទភ្លឺចាំងថែងអស្ចារ្យ ។

ព្រះចន្ទនោះមានរស្មីចាំងមកលើព្រះអគ្គមហេសីទីពីរ ស្រាប់តែទ្រង់មានកន្ទួលពាសពេញព្រះរូប, ហើយក្នុងមួយរំពេចនេះ ស្រាប់តែឮសូរអង្រែបុកខ្ទាំងទៅក្នុងត្បាល់ឈើ ស្រាប់តែព្រះអគ្គមហេសីទីបី ទ្រង់ឈឺព្រះកេសខ្ទាំងដល់ទ្រង់ព្រះវិសញ្ញី (ដួលសន្លប់) នៅទីនោះ ។

អារក្សនោះថ្លែងរឿងចប់សព្វគ្រប់ហើយ ក៏ក្រាបទូលសួរទៅព្រះមហាក្សត្រិយ៍ថា: "បណ្ដាព្រះអគ្គមហេសីទាំងបីអង្គ, តើព្រះអគ្គ-មហេសីអង្គណា មានគុណសម្បត្តិជាងគេ?" ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលតបទៅនឹងអារក្សថា: "ព្រះអគ្គមហេសីដែលទ្រង់ដួលសន្លប់មានគុណសម្បត្តិជាងគេ ។" ។

អារក្សនោះបាន ស្ដាប់ព្រះបន្ទូលហើយក៏វិលត្រឡប់ទៅកាន់រុក្ខជាតិវិញ, ព្យួរខ្លួនលើមែកឈើសិរិសើវិញ, ហើយព្រះមហាក្សត្រិយ៍ទ្រង់បានយាងទៅចាប់ទាញអារក្សនោះលើកលីលើព្រអង្សាទៅ ។

ចប់ រឿងទី ១០ មានរឿងទី ១១ តទៅទៀត ។

# រឿងស្នេហាជាតិ

## ៤ ឈុត

## លោក គង់-លឹម និស្សិតសាលាគរុវិជ្ជា ភ្នំពេញ តែង

(តមក)

---

### ឈុតទី ៤ ឆាកទី ១

### (កាព្យលំនាំបារាំង)

### វណ្ណតារា វណ្ណនារី

វណ្ណតារា

កន្ទង់ត្រូវការតែផ្ការីក ទើបចាប់ចិត្តត្រេកនឹងរូបផ្កា
កន្ទង់សប្បាយនឹងស្នេហា ឯផ្កាក៏ត្រេកត្រអាលក្រៃ
តែផ្កាល្អមិនប្រក្រតី គង់មានថ្ងៃណានឹងរុះរោយ ៗ
ម្ល៉េះផ្កាត្រូវចិត្ត! ប្រព្រឹត្តផ្ដោយ កន្ទង់បែរក្រោយលែងត្រូវការ
ហេតុតែកំដៅព្រះសុរិយា បានជាផ្កាស្វិតនឹងកន្ទង់! ៗ
ឱព្រះអើយរូបខ្ញុំដូចតួអង្គ បុប្ផា! កន្ទង់! ដូច្នេះណា
ភាណនពសម្ងាញ់គូស្នេហា កុំភ្លេច! សង្សារសម្ងាញ់អ្នក! ៗ

(និយាយទៅកាន់វណ្ណនារី)

វណ្ណនារី! ប្អូនបងមិនគួរសោះ! ប្អូនឃើញ! រូបបងប្រព្រឹត្តខុស

ម្តេចមិនសន្តោសដល់បងផង ប្រញាប់តែប្រាប់ម៉ាក់តែម្តង
ប្អូនគ្មានគិតបងទេប្អូនស្រី ។

## វណ្ណ៍ធារី

ព្រោះតែគិតហើយបាននិយាយ! ការនេះមិនងាយទេអ្នកស្រី
ចុះបើរូបបងចង់បានប្តី! ម្តេចមិននិយាយឲ្យម៉ាក់ដឹង? ។
បងមិនដឹងទេ! ម៉ាក់គាត់ខឹង សឹងទាំស៊ីសាច់បងទាំងរស់
ដោយអំពើបងប្រព្រឹត្តខុស យកប្រុសសហាយមកលើផ្ទះ ។
បងបេះច្បាប់នេះយ៉ាងជ្រៅជ្រះ ម្តេចមិនសំពះគោរពច្បាប់
បើបេះបទអ្វី! ត្រូវតែងត្រាប់ ឲ្យគាប់ជាវង្សយើងអ្នកខ្ពស់!
បងធ្វើយ៉ាងហ្នឹងនាំអ័បឈ្មោះ ពូជយើងអ្នកខ្ពស់តែបុកទាប ។

## វណ្ណ៍តារា

បងគិតថាបងធ្វើសុភាព រាបទាបកិរិយាឲ្យត្រឹមត្រូវ
បងគិតយ៉ាងនេះគិតដល់ឪ ប៉ុន្តែឥឡូវធ្វើដូចម្តេច!
បើក្តីស្នេហាបងសម្រេច ចូរប្អូនកុំភ្លេចថាយល់ត្រូវ ។
ប៉ាយើងយៀកមិញចាប់យកទៅ ម្តេចប្អូនមិនគិតឲ្យវែងឆ្ងាយ
ចុះប្អូនដឹងទេរូបអ្នកម្តាយ សប្បាយចិត្តទេ រាល់តែថ្ងៃ ៖
ណាមួយរៀបប្អូនឲ្យមានប្តី តើម៉ាក់សព្វថ្ងៃព្រួយយ៉ាងណា?
ឯរូបបងយកប្តីហ៊ានក្លា មិនទាន់រៀបការបងស្ម័គ្រមុន

អូន ! គំនិតបង ! មិនមែនស៊ិន ប្រពន្ធ ! មិនគាប់ដល់សង្ហារ
ជាតិប្រុសនរណាដូច ! នរណា តែងរៀបការហើយមិនសូវទេ ! ។

វណ្ណនារី

ខ្ញុំគិតដូចបងក៏បានដែរ តែត្រូវការកេរ្តិ៍ខ្លួនជាស្រី
បើត្រឹមតែពាក្យទឹងសំដី ខ្ញុំឥតនិយាយធ្វើអ្វីទេ
តែបងប៉ះពាល់ដល់កាយគេ គេឲ្យខ្ញុំធ្វើជាដូចម្ដេច ? ។
បើចាំការហើយដឹងសម្រេច ម្ដេចបងទ្រាំចាំមិនបានឬ ? ។

វណ្ណតារា (ទឹង)

មិនបាច់អូនឯងនាងបញ្ឆី ! គឺជារូបបងមិនមែនអូន !

វណ្ណនារី (ទឹង)

ប្រយ័ត្នមុនការសម្រាលកូន ! សណ្ដានដុំថ្លៃថ្លែងពោលទៅ !
មិនបាច់ថាបងគិតដល់ទេ ! ដែលយួនចាប់ទៅបីខែហើយ ! ។
ម្ល៉េះរាំសម្លាប់បាត់ទៅហើយ ! មិនបាច់បងឆ្លើយរកដោះសា
តែបានដល់ដៃរប្រហារ មិនថាស័ក្ដិធំស័ក្ដិតូចទេ ។

វណ្ណតារា (ទឹង)

វណ្ណនារីឈប់លែងនិយាយទៅ បើឯងមិនគិតដល់រូបគេ
អញគិតឃើញត្រូវបានអញធ្វើ ការល្បិចនឹងហើយនៅធ្វើកើ

នៅតែដដែលចង់តែឈ្នះ ! ។ ពោលពាក្យឲ្យអញតែផ្ដេសផ្ដាស
គិតទះកំភ្លៀងឲ្យវិលខួរ និយាយសំដីគ្មានបេះគួរ
ជួតាំងពីក្បាលដល់ចុងជើង និយាយស្រួលបួលចង់ដំឡើង
បបើងធ្វើបុកឯងគ្រាន់បើ ។ (ចេញ)

## វណ្ណនារី

អាងតែគេធំ ! ប្រើអំណាច ធ្វើបង់គេពិតតែកោងកាច
ខ្ញុំ ! ប្អូនគ្មានខ្លាចគោរពទេ ការណទកមិតយក ! ច្បាស់ជាអេរ
គេសោកកំល្អនោកង់លោក គង់មានថ្ងៃណាទឹងដេកសោក !
ឲ្យមាកកំពោកចេញពីផ្ទះ ។ គិតឃើញខ្លួនឯងថាត្រូវណាស់
កិរិយាផ្ដេសផ្ដាសបែបជូរេះ អាសូរតែល្ងង់ទៅ ! អ្នកបេះ
ទៅ (Collège) បីឆ្នាំដែរនៅធ្វើក្អើ ធ្វើជាបង់គេបុករើ
ក្អីក្អើហើយនៅថាគ្រាន់បើ ! ។

## ភាគ ទី ២

## សុខា វណ្ណនារី

### សុខា

មានរៀនហេតុអ្វី ! ទៀតគូនស្រី ! (naturelle)
បានបេះតែព្រួសូរសំដី ឈ្មោះគ្នារៀនអ្វី ! ទៀតហើយហ្នឹង ។
ឲ្យស្គាល់តែព្រួសំដីតឹង ទឹងអ្វីកំទឹងតែពល់ថ្ងៃ

តែដល់ការហើយអញដាក់ដៃ ឲ្យប្ដីឯងមើលឫកបន្ទិច ។
តែខឹងអ៊ុំឡើងឲ្យញៀចៗ ដូចចាបពពែចតែរកពង ។

## វណ្ណនារី

ចុះបងវណ្ណាភាពមិនគិតផង ខឹងឡើងម្ដងៗ ដូចគេឆ្កួត
ប៉ើធ្វើអ៊ុំ ៗ ចង់ប្រកួត អួតឡើងតែព័យធ្វើជាមុខ ។
មិនដែលត្រូវសួរសំដីសុខ មុខសោតមិនដែលឃើញសប្បាយ
មិនចេះពោលទេរឿងសហាយ យកមកនិយាយពល់វេលា ។
កាលពីថ្ងៃមិញគេជួបគ្នា នៅក្នុងទីធ្លានៃសួនច្បារ
គេឈរខ្សឹបគ្នាពីរឿងការ ធ្វើជាសញ្ញាខ្ញុំកាត់យល់ ! ។

## សុខា

ណើយលែងគិតទៅពីរឿងនោះ បើក្មួនឯងឃើញព័ធ្វើខុស
កុំក្មួនបន្ទោសអ៊ុំព័ឡើយ ។
ពនឹងអញហួសកែទៅហើយ ក្មួនហើយធ្វើស្ងៀមលែងគិតទៅ ។

## វណ្ណនារី

តែពោលកាលណាបានរឿងឲ្យ ចែចូវយកមកនិយាយក្ដាម
គេថាប្ដីគេនឹងសងឈាម សង្គ្រាមតតាំងនឹងជាតិយួន
យកមកនិយាយឲ្យផ្ដួនៗ ថាខ្លួនគេស្រឡាញ់ឲ្យណាស់ ។
តែចិត្តគេគិតទៅតែផ្កាស ខ្ញុំក្ដៅណាស់មាក់ពីរឿងនេះ !

សុខា

កូនលែងក្តៅទៅនានអ្នកបេះ    ដម្រេះកូនឯងប្រុងរៀបចំ ៗ
ការលួចនេះហើយធ្វើឲ្យសម!    ក្រមុំកូនម៉ាក់ចាំថែជូន
តុបតែងរាងកាយសំអាតខ្លួន    មាសស្ងួនកូនម៉ាក់ ! ទៅក្នុងចុះ ៗ
បិទទ្វារឲ្យជិតកុំឲ្យប្រុស !    កំឡោះរង់ចាំរកមើលកូន
កុំមាត់កុំកនៅឲ្យស្ងៀម    បងប្អូនកៀរមកពេញឥឡូវ
បើចេញមកក្រៅកុំក្រញូវ    ញញឹមបើកផ្លូវឲ្យស្រួលភាយ ៗ

ភាគទី ៣

## សុខា ភាណី

ភាណី

អ្នកម៉ង! ឃើញបងខ្ញុំមកទេ?

សុខា

ទេ! មិនឃើញទេ! ភាណីអើយ

ភាណី

អ្នកម៉ងច្បាស់លាក់បងហើយ! ណ្ហីយអ្នកម៉ងអើយ! កុំលាក់អ្វី...

សុខា

អាព្រើល! ផ្ទះអញមានកូនស្រី    និយាយស្រួលបួលកុំមាយា
ប្រយ័ត្នតែអញប្រាប់លោកមា    ទុំឯងដឹងគ្នាឥឡូវហ្នឹង

### ភាណី

អ្នកមិនរាយខ្ញុំៗ ឥតខឹង !		ប៉ុន្តែខ្ញុំដឹងចិត្តមីងហើយ
មីងខឹងទឹងខ្ញុំអ្វីក៏ដោយ		មីងអើយខ្ញុំនិយាយលេងទេ !

### សុខា

ចុះអញក៏គ្មានថាអ្វីដែរ		តែឯងនិយាយមិនគួរសម ៗ
តែបើឮឆ្ងាយមានការធំ		ព្រោះខ្លួនអញមានកូនក្រមុំ
ក្រោយៗ ឯងកុំពោលបែបហ្នឹង ! ៗ

### ភាណី

បាទ !		បងមិត្តណា ខ្ញុំបាត់មួយថ្ងៃ
មិនឃើញមកផ្ទះទឹងអាស្រ័យ		បាយបាត់មួយថ្ងៃមិនឃើញសោះ
ខ្ញុំស្អប់អាដែងប្រុសកំឡោះ		វាហោះហើរដើរមិនបាយទឹក ! ៗ

### សុខា

ទៅស្រុកគេយូរក្រែងគ្មានទឹក !		រលឹកទឹកឃើញដីដែនខ្មែរ
ឯងកុំខឹងអ្វីក្មួយមីងនែ !		ស្រុកខ្មែរយើងគ្រាន់ដែរសព្វថ្ងៃ ! ៗ

### ភាណី

ឱ ! មិនដែលបានឮសំដី		បងខ្ញុំនិយាយរឿងបាំង
តែថ្ងៃកាលណាខ្ញុំសើចគាំង		កំប្លែងចម្លាំងពីរោះណាស់
បើសិនអ្នកមីងបានប្រទះ		ច្បាស់សើចលេចនោមផងមិនខាន ! ៗ

សុខា

ពីព្រោះយ៉ាងណាក៏មិនបាន ក្ខេចប្រាណទៅដល់លេចនាមទេ
សុំដឹងឯងជ្រុល! អញចង់ដេរ ឲ្យគេឯងពួតឡូវហ្នឹង!
ហើយចុះរឿងអីសើចដល់ម្ល៉ឹង? ឯងដឹង! ប្រាប់មីងឲ្យយល់ផង
ឯងប្រាប់ឲ្យតែតាមទំនង កុំឆ្គងកុហកឲ្យសោះក្មួយ! ៗ

ភាណី

សួររបៀបហ្នឹងនាំឲ្យព្រួយ តែក្មួយមិនលាក់ធ្វើអ្វីទេ
តែខ្ញុំមិនដឹងរឿងអ្វីដែរ! តែពួកគេសើចខ្ញុំសើចដែរ ៗ
រឿងនោះហួរហៃខ្ញុំតតយល់

សុខា

គ្មានបានការអ្វី! នាំអំពល់ រវល់! ខាតពេលណាស់លោកក្មួយ

ភាណី

មិនធ្វើការអ្វី! ចាំខ្ញុំជួយ កុំព្រួយឲ្យសោះពីរឿងការនោះ! ៗ
ការម្តេចក៏ដោយស្រេចលើប៉ា! លោកទទឹងធានារងទាំងអស់ ៗ
លោកប៉ាខ្ញុំចាស់ដូចកំឡោះ គាត់រងទាំងអស់ការអ្វីៗ
ចំណែកប៉ែកខ្ញុំក្បៀវខាងស្រី! ទំគមទំខ្ញុំទុកឲ្យខ្ញុំ ៗ

(មានត)

# រឿងប៉ូល និង វីរស៊ីនី

## លោកផេង-ជ្រើរ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

### ប្រែរៀបរៀង

(តមក)

ដួនកាល ណោជាអ្នកបែបព្រួយ ជនឯទៀតប្រជុំគ្នា ហើយនាំគ្នាធ្វើអ្នកនោះឲ្យបាត់ព្រួយ ៗ រូបជនម្នាក់ៗប្រើគំនិតផ្សេងៗគ្នាទាំងអស់ នាងម៉ាគើរីត បានខាងបេះរកកាយ, នាងទ្យាតួរ ខាងឯញញឹមស្ងៀម, វីរស៊ីនី ខាងឯបេះថ្នាក់ថ្នមបបោសអង្អែល, អាប៉ូលខាងឯនិយាយត្រង់ និយាយពិត, នាងម៉ារីនិងឌូម៉ាំងខាងឯជួយអែបអបខាងក្រៅ ៗ បើកាលណាឃើញគេព្រួយ គាត់ក៏ព្រួយដែរ បើឃើញគេយំ គាត់ក៏យំដែរ ឧបមាដូចជាវល្លិជួយរួបរឹតដើមឈើធំៗ ដើម្បីទប់ទឹងខ្យល់ព្យុះ ៗ

កាលណារដូវល្អ គេនាំគ្នាទៅវិហារ ប៉មពើម៉ុះ រាល់អាទិត្យ ៗ មានពួកអ្នកមានទ្រព្យជិះសុទ្ធតែអង្រឹងស្នែងមកវិហារនោះដែរ ហើយចង់ស្គាល់ត្រកូលទាំងពីរ ចង់ចូលដៃនិយាយរឿងផ្សេងៗ តែត្រកូលទាំងពីរនេះមិនព្រមទទួលចូលដៃផង ដោយយល់ឃើញថា ធម្មតាអ្នកមានអំណាចស្វែងរកអ្នកខ្សត់ខ្សោយ គ្រាន់តែនិយាយបញ្ជោរសើចលេងហើយ ការនិយាយច្រើនតែរៀបរាប់អំពីការអាក្រក់ល្អនៃជនដទៃ ៗ ម្យ៉ាងទៀតត្រកូលទាំងពីរនេះ រៀររហូតទាំងមិនព្រមទៅដើរចូលទីងរប៉បរបោច

ដែលចូលចិត្តតែនិយាយដើមគេ ឬហៅថាមនុស្សកម្រោល ៗ គឺដើរជិតអ្នកមានបណ្ដាស័ក្តិធ្វើបែបខ្លាច ដើរជិតមនុស្សផ្តេសផ្តាសធ្វើបែបមិនរវល់ព្រងើយ ៗ តែកិរិយាមារយាទរបស់ត្រកូលនោះ តែងប្រកបដោយច្បាប់ចេះគួរសម ជាអ្នកជួយទុក្ខធុរៈអ្នកក្រីក្រ ជាអ្នកមានសេចក្តីកោតក្រែងដល់មនុស្សមានសម្បត្តិ ជាអ្នកទំនុកទុកចិត្តនៃអ្នកខ្សត់ ៗ

កាលបើស្ត្រីធម៌ហើយ គេច្រើនតែមកសូមពរអំពីត្រកូលទាំងពីរ គឺមនុស្សដែលមានទុក្ខមកសូមជំបូនខ្ទាន ឬក៏កូនក្មេងមកអញ្ជើញឲ្យទៅជួយម្ដាយកាប់ឈើនៅភូមិជិតខាង ៗ នាងតែងមានក្បួនផ្សំថ្នាំជាប់ជាមួយមិនដែលដាច់ ហើយថែមទាំងមានមន្តគាថាអមថ្នាំនោះទៀតឲ្យរឹតតែពូកែឡើង ៗ នាងអាចបណ្ដេញទុក្ខព្រួយចេញពីចិត្ត ពីក្នុងកាយអ្នកជម្ងឺបាន ៗ នាងឡាគួរជាអ្នកនិយាយពីអានុភាពព្រះជាម្ចាស់ឲ្យអ្នកជម្ងឺស្ដាប់ ហាក់ដូចជាព្រះមកគង់នៅពីមុខ ៗ វីរស៊ុទី សប្បាយចិត្តណាស់ លុះត្រឡប់មកវិញ ព្រោះមានឱកាសធ្វើអំពើកុសល ៗ គឺវីរស៊ុទីជាអ្នកផ្សំថ្នាំកុំឲ្យមនុស្សឈឺ នឹងជាអ្នកសូត្រធម៌ផ្លុំឲ្យពូកែ ៗ ជួនណារូបពីឲ្យថ្នាំដល់អ្នកជម្ងឺ នាងដើររហូតដល់ផ្ទះខ្ញុំ ៗ រៀបចំអាហារឲ្យពួកត្រកូលនេះអាស្រ័យនៅមាត់ស្ទឹងលេងសប្បាយ ៗ ហើយជួនណាខ្ញុំយកកេសជ្ជៈមកចាក់ចែកជូនអ្នកទាំងអស់ផឹក ដើម្បីឲ្យអ្នកទាំងអស់គ្នារឹតតែមានសេចក្តីសប្បាយរីករាយឡើង ៗ ជួនណាយើងនាំគ្នាទៅផឹកលេងក្បែរមាត់

សមុទ្រ ។ យើងនាំគ្នាបេះអន្ទក់សមុទ្រដែលដុះពាសពេញយកទៅអាស្រ័យជាមួយម្ហូបអាហារដែលយកពីផ្ទះទៅ ។ យើងនាំគ្នាស្ទូចត្រី ស្ទូចបង្កង ចាប់ក្តាម ភរខ្ចៅ ភរត្រី គ្រប់បែបតាមឆ្នេរសមុទ្រ ។ យើងមានសេចក្តីសប្បាយក្រៃពេក នឹងក្រឡេកមើលព្រៃព្រឹក្សាលតាវល្លិទាំងពួង ។ ជួនណានាំគ្នាទៅអង្គុយលើដុំថ្មក្រោមម្លប់ឈើ ហើយមើលរលកទឹកសមុទ្រ ផាត់ពពកពីកណ្តាល មកបែកខ្ចាយនៅក្បែរជើងភល់គ្នា ពុស្បូរគួរឲ្យខ្លាចពេក ។ អាប៉ូលប៉ុនហែលដូចត្រី ជួនណាហែលទៅទំលើដុំថ្មមួយនៅមុខរលក ហើយកាលណារលកបោកមកជិតដល់ក៏លោតហក់ហែលមកច្រាំងវិញ រលកបែកពពុះសំពោងដេញតាមក៏ប្រកិតៗ ហើយមកទាន់គ្នាត្រឹមឆ្នេរខ្សាច់ ។ វីរស៊ីទឃើញដូច្នោះស្រែកស្ទើរភ្ញាក់សំឡេងថា ក្រោយកុំធ្វើអ៊ីចឹងទៀត ខ្ញុំភ័យខ្លាំងណាស់ ។

កុមារទាំងពីរច្រៀងកំលេងសប្បាយ ក្នុងពេលបាយនោះ ។ វីរស៊ីទច្រៀងសរសើរសេចក្តីសុខស្រួលនៃអ្នកធ្វើស្រែចំការ នឹងច្រៀងអំពីការនឿយហត់ព្រួយជានិច្ចនៃអ្នកដើរសមុទ្រ គឺមកតែពីតណ្ហាបណ្តាលឲ្យស៊ីទៅដើររកលើទឹកជាវត្ថុដ៏កំណាចជាងដីដែលឲ្យសម្បត្តិដល់យើងប្រកបដោយសន្តិភាព ។ ជួនណា នាងកំបែបក្តិគ ជាមួយអាប៉ូល ធ្វើដំណើរគ្មានច្រៀងអ្វីឡើយ ។ ការធ្វើអ្វីតែដោយកាយសញ្ញា ហ្នឹងហើយជាភាសាដើមរបស់មនុស្សជាតិ ភាសាហ្នឹងគ្រប់សាសន៍ចេះទាំងអស់ ។ ជាតិក្មេង

តែងធ្វើត្រាប់កាយសញ្ញានៃមនុស្សចាស់ ។ ហេតុដូច្នេះ បានជាកុមារទាំងពីរគ្រាន់តែបានឃើញកិច្ចតែម្តងក៏អាចចាំបាន ។ វីរស៊ុទី ចាំរឿងដែលម្តាយវាមើលឲ្យស្តាប់ តែកាលណាពួឃុមាំងវាយស្គរទូងៗ នាងតាំងចេញមក ក្អមមួយទូលលើក្បាល ហើយដើរសន្សឹម បែបភ័យបំរុងទៅដងទឹក នាស្រះក្បែរវាំង ។ ឃុមាំងទីងម៉ារី ធ្វើជាពួកអ្នកគង្វាលចៀមឈ្មោះ ម៉ាដ្យាន ឃាត់មិនឲ្យវីរស៊ុទីចូលមកជិតស្រះ ហើយធ្វើជារុញច្រានឲ្យថយចេញ ។ អាប៉ូលរត់មកជួយវីរស៊ុទី ធ្វើជាវាយឃុមាំងទីងម៉ារី ហើយដងទឹកដាក់ក្អមឲ្យនាងក្រមុំ ក្នុងវេលាកំពុងលើកក្អមដាក់លើក្បាលឲ្យវីរស៊ុទី អាប៉ូលហុចផ្កាមួយដុំឲ្យទៅនាង ។ ឃើញវាធ្វើដូច្នោះ ខ្ញុំក៏ចូលដៃលេងជាមួយទីងវាផង : ខ្ញុំធ្វើជាមនុស្សម្នាក់ឈ្មោះវ៉ាគែល ហើយខ្ញុំយល់ព្រមឲ្យកូនស្រីក្រមុំរបស់ខ្ញុំទៅអាប៉ូលយកធ្វើជាភរិយា ។

ម្តងទៀត វីរស៊ុទី តែងខ្លួនធ្វើជាស្ត្រីកំសត់ម្នាក់ឈ្មោះរុត មេម៉ាយហើយក្រផង លុះត្រឡប់មកស្រុកដើមរបស់ខ្លួន គ្មាននរណាស្គាល់ទៅជាស្ត្រីបរទេសអនាថា ដោយសារនាងនោះដើរចោលស្រុកភូមិយូរពេក ។ ឃុមាំងទីងម៉ារីធ្វើជាអ្នកច្រូតស្រូវ ។ វីរស៊ុទីធ្វើជាដើរតាមក្រោយអ្នកច្រូត ហើយរើសកួរស្រូវដែលជ្រុះដោយដីឯណេះឯណោះ ។ អាប៉ូលធ្វើជាមេម្ចាស់ស្រែ បែបរីកក្រអឺត តាំងសួរដំណើរដើមទងទីង

វីរស៊ីទី ៗ ឆ្លើយតបទៅវិញ ដោយសំដីរញ៉េរញ៉ៃតក្កមា ៗ ប្រហែលមួយស្របក់ កើតមានសេចក្ដីមេត្តា អាប៉ូលយល់ព្រមឲ្យនាងកំសត់នៅជាមួយ អាប៉ូលយកគ្រឿងស៊ុគ្របមុខដាក់ពេញថ្ពក់វីរស៊ីទី ហើយនាំនាងមកនៅចំពោះមុខយើង ដូចជាកាលជាន់នោះ គេនាំទៅនៅចំពោះមុខអស់បណ្ដាពួកអ្នកក្រុង ហើយបន្លឺវាចាឡើងថា ខ្ញុំយកនាងនេះធ្វើជាភរិយា ទោះបីនាងនេះក្រដូច្នេះក៏ដោយ ៗ នាងឡាតួរ ឃើញលេងរឿងដូច្នោះ ក៏នឹកដល់ខ្លួនកាលដែលបងប្អូនទាំងអស់គេបោះបង់ចោលកាលខ្លួនជាស្រីមេម៉ាយ នឹកកាលដែលនាងម៉ារគីរតទទួលយកខ្លួនធ្វើជាសំឡាញ់ដោយចិត្តស្ម័គ្រស្មោះ នឹងនឹកដល់វាសនាកុមារទាំងពីរទៅក្នុងអនាគត កាលណាបានគ្នាជាប្ដីប្រពន្ធ នាងអត់ទ្រាំពុំបាន រហូតដល់យំហៀរហូរទឹកភ្នែក ៗ មែនពិត ការដែលទឹកឃើញសេចក្ដីទុក្ខខ្លាំងពេក ឬសេចក្ដីសប្បាយពេញចិត្ត តែងបណ្ដាលឲ្យយើងហៀរហូរទឹកភ្នែកជាមិនខាន ៗ

ជាច្រើនពេលណាស់ ដែលយើងកំពុងលេងសប្បាយ ហើយយប់មកដល់នៅក្នុងព្រៃ ៗ តែអំណាចខ្យល់ល្អនឹងធាតុអាកាសស្រួលអាចឲ្យយើងពល់គ្នាអាស្រ័យដំណេកនៅកណ្ដាលព្រៃក្រោមដើមឈើបាន មិនមានគិតភ័យអំពីចោរលួចឯផ្ទះ ឬនៅទីកន្លែងដេក ៗ ព្រឹកឡើង យើងត្រឡប់មកខ្ទមវិញរៀងខ្លួន ឃើញផ្ទះយើងគ្មានរទិកអ្វីសោះ

ទៅស្អាតដដែលដូចកាលដែលយើងចេញទៅ ៗ ទៅក្នុងកោះនេះមនុស្ស ច្រើនប្រកបដោយសេចក្តីសុចរិតពិតត្រង់ ផ្ទះមិនសូវត្រូវការបិទទ្វារនឹងសោឡើយ ហើយសោរទៀតជាវត្ថុដ៏ប្លែកដល់ក្មេងអ្នកស្រុក ៗ

ក្នុងមួយឆ្នាំ ៗ មានថ្ងៃ១ះ ជាថ្ងៃដែលអាប៉ូលនឹងវីរស៊ីនីមានសេចក្តីសប្បាយអស់ថែប គឺថ្ងៃដែលកុមារទាំងពីរធ្វើបុណ្យ ៗ តាំងពីព្រលឹម វីរស៊ីនីរៀបចំម្ហូបច្រើនយកទៅចែកឲ្យពួកត្រកូលបារាំងដូចគ្នា តែក្រពេក ដែលមានកំណើតក្នុងកោះហ្នឹង ហើយមិនដែលស្គាល់ជាតិនំអឺរុបកំសត់ពេក គ្មាននរណាជាទីពឹង បរិភោគតែមើមក្តួចនៅកណ្តាលព្រៃ ព្រោះជាត្រកូលថោកទាប មិនចេះបង្ហាត់គ្នាឲ្យមានសេចក្តីក្លាហានក្នុងការចិញ្ចឹមជីវិត ៗ អាប៉ូលគេជាអ្នកកាន់នំខ្លួនឯងយកទៅចែកឲ្យត្រកូលទាំងឡាយនោះ លុះពួកត្រកូលនេះបានទទួលនំហើយ ក៏សន្យានឹងមកលេងផ្ទះនាងឡាតួរ នាងម៉ារគឺរីតក្នុងថ្ងៃស្អែក ៗ ព្រឹកឡើង គេឃើញម្តាយត្រកូលពួកនេះមកដល់ មានកូនពីរបីនាក់ស្គម ៗ ថែបខ្លាចគេ ដើរមិនហ៊ានងើបមើលមុខអ្នកជិតខាងទេ វីរស៊ីនីឃើញដូច្នោះ ស្ទុះទៅចាប់ដៃចរចាកេចចាកអាក់ដើម្បីឲ្យគ្នាបាត់អៀនខ្មាស ហើយរៀបឲ្យអង្គុយស្រួល យកទឹកផ្អែមមកឲ្យផឹកឲ្យត្រជាក់ខ្លួនស្រួល ៗ កាលណាពួកនេះស្រួលខ្លួនហើយ វីរស៊ីនីប្រាប់អាប៉ូលឲ្យនាំកូនស្រីទាំងប៉ុន្មានពាំលេងសប្បាយ ៗ វីរស៊ីនីដើរតាមជាប់ជាមួយនឹងពួកនាងក្រមុំទាំងអស់នោះ

ជានិច្ច តែលុះឃើញនាងក្រមុំអស់នោះ ហាក់ដូចមិនសូវសប្បាយ វីរ៍ស៊ីទីដោយចង់ណាស់ឲ្យនាងក្រមុំទាំងឡាយរីករាយជាមួយនឹងត្រកូលនៃនាង ក៏មានវាចាថា: "គេមានសេចក្តីពេញចិត្ត តែកាលណាគេអាចធ្វើឲ្យអ្នកដទៃពេញចិត្តផង" ។ កាលណាពួកត្រកូលនេះត្រឡប់ទៅផ្ទះវិញ វីរ៍ស៊ីទីបង្គាប់ឲ្យយកតាមចំណង់ នូវរបស់ណាដែលខ្លួនគាប់ចិត្ត ធ្វើជាប្រាប់ថា: យកទៅ? អាហ្នឹងចំឡែកហើយ ហើយថ្មីផង ។ បើវីរ៍ស៊ីទីក្រឡេកឃើញសំពត់កណ្ដាប់កណ្ដាបពេក នាងរើសរកសំពត់ម្ដាយនាងពីរបី ហើយឲ្យអាប៉ូលលួចយកទៅដាក់នៅមាត់ទ្វារផ្ទះនៃត្រកូលកំសត់ ។ នាងធ្វើកុសលច្រើនបែប ដូចព្រះជាម្ចាស់ ហើយមិនចង់ឲ្យគេដឹងអ្នកកត្តា គ្រាន់តែសំដែងអំពើឲ្យឃើញ ។

អ្នកពលគ្នាជាសាសន៍អឺរុប ដែលតាំងពីកុមារភាព តែងមានគំនិតពេញទៅដោយការយល់ទុកជាមុន ជាគ្រឿងជំទាស់នឹងក័ព្វូរបស់ខ្លួន អ្នកមិនអាចយល់ថាធម្មជាតិអាចបេះឲ្យពន្លឺ នឹងឲ្យសេចក្តីរីករាយទេ ។ ដួងចិត្តអ្នកដែលចំណេះស្អួចស្ដើងនៅតែពីខាងក្រៅ មិនយូរប៉ុន្មានក៏ដល់នូវទីបំផុតនៃសេចក្តីសប្បាយនៃវិជ្ជានោះ តែចំណែកធម្មជាតិនឹងដួងចិត្តវិញ គឺដូចជាអណ្ដូងដែលមានទឹកផុសចេញជានិច្ច ។ អាប៉ូលនឹងវីរ៍ស៊ីទីគ្មាននាឡិកា មហាសង្ក្រាន្ត សៀវភៅបុរាណ គម្ពីររឿងនឹងគម្ពីរដែលនិយាយពីសភាពចិត្តឡើយ ។ ពេលវេលានឹងខែឆ្នាំនៃកុមារទាំងពីរ

គឺដឹងបានតាមធម្មជាតិទាំងអស់ ៗ ក៏ស្គាល់ពេលម៉ោងតាមស្រមោលដើមឈើ ក៏ស្គាល់រដូវដោយសារឈើផ្កាផ្លែ ក៏ដឹងចំនួនឆ្នាំតាមដំណាំដែលក៏ដាំប៉ុន្មានលើក ប៉ុន្មានគ្រា ៗ គំរូបែបនេះ តែងឲ្យសេចក្ដីពេញចិត្តដល់ក៏នឹងចំណាំទុក ៗ វីរ៉ស៊ុទីប្រាប់ថា ដល់ពេលបាយហើយ ព្រោះស្រមោលដើមចេកមកដល់គល់ ឬប្រាប់ថា ជិតយប់ហើយ ផ្សិតស្វិកអម្ពិលញោម ៗ បើអ្នកជិតខាងសួរថា អង្កាល់នាងឯងមកលេងឯផ្ទះយើង វីរ៉ស៊ុទីឆ្លើយថា ចាំអំពៅខ្ញុំធំសិន ៗ គេសួរអំពីអាយុអាប៉ូលនឹងអាយុនាង វីរ៉ស៊ុទីប្រាប់ថា អាយុបងខ្ញុំស្មើនឹងអាយុផងដើមដូងអាធំនៅមាត់ស្រះ អាយុខ្ញុំស្មើនឹងអាយុដើមដូងអាតូច ៗ ស្វាយផ្លែដប់ពីរដង ក្រូចផ្កាម្លូបួនដងហើយ តាំងពីខ្ញុំកើតមក ៗ ជីវិតនៃកុមារទាំងពីរ ដូចជាជាប់នឹងជីវិតដើមឈើនឹងជីវិតនៃព្រៃព្រឹក្សា ៗ រឿងដែលក៏ដឹង គឺដឹងតែអាយុរបស់ម្ដាយក៏ ដឹងថាសួនច្បារដាំពីកាលណាមក ដឹងថាត្រូវធ្វើអំពើល្អដល់អ្នកដទៃ ហើយមិនត្រូវទទឹងទាស់នឹងអាជ្ញារបស់ព្រះជាម្ចាស់ ៗ

ក្រៅអំពីនោះ កុមារទាំងពីរគ្មានត្រូវការចង់មាន ចង់ចេះដូចថែបយើងនេះទេ ៗ ការខ្វត់ខ្វាយនឹងការល្ងង់ខ្លៅ គឺសមនឹងភ័ព្វរបស់គ្នា ៗ មិនមានថ្ងៃណាមួយដែលក៏មិនគិតជួយនឹងបំរើអ្នកដទៃ ៗ ហើយប្រសិនណាបើក៏មានសេចក្ដីកាន់ចិត្តបន្តិចបន្តួច មនុស្សបរិសុទ្ធមិនសូវខ្លាចក្រែងលោមានគ្រោះថ្នាក់ប៉ុន្មាន ៗ អាប៉ូលនឹងវីរ៉ស៊ុទី តែង

មានជីវភាពនឹងការប្រព្រឹត្តិតែបែបដូច្នេះរៀងមក ៗ មិនមានសេចក្តីព្រួយណាមួយធ្វើឲ្យរាជ្រួញមុខ មិនដែលសេចក្តីអាក្រក់អ្វីមួយនាំឲ្យទឹកឈាមរាល្អក់ មិនដែលមានចំណង់ដ៏លាមកដែលជាគ្រឿងដាស់ដល់ចិត្ត: សេចក្តីស្នេហា សេចក្តីទៀងត្រង់ សេចក្តីអាណិត តែងញ៉ាំងរូបព្រមទាំងចិត្តរាឲ្យរឹងរឹតតែចម្រើនឡើងរាល់ថ្ងៃ ៗ កុមារទាំងពីរ កាលនៅជាទារកស្រស់ទ្រលុក ៗ ដូចជាជាតិមនុស្សជាន់ដំបូង ដែលព្រះជាម្ចាស់ឲ្យមកកើតក្នុងច្បារមួយឈ្មោះ អេដេន ជនទាំងពីរនេះ ដើមឡើយតែងអាស្រ័យនៅជាមួយគ្នា រាប់អានគ្នាដូចជាបងប្អូនបង្កើត វីរស៊ុនីស្លូតនឹងធឹង តែងទុកចិត្តគេដូចនាងអេវ អាប៉ូលដូចអ្នកដាំ ធំប៉ុនមនុស្សធម្មតាហើយ តែចិត្តជា ដូចកូនក្មេង ៗ ជួនកាលរាហានរាចាទៅកាន់វីរស៊ុនីក្នុងពេលដែលរាត្រឡប់មកពីធ្វើការវិញថា : "កាលណាបងអស់កម្លាំង គ្រាន់តែឃើញមុខអូនឯង បងបាត់ហេវមួយរំពេច ៗ កាលណាបងនៅលើភ្នំ ហើយឃើញអូនឯងដើរខាងក្រោម បងមើលអូនឯងល្អដូចផ្កាកុលាបលេចឡើងនៅកណ្តាលច្បារយើង ៗ កាលណាបងឃើញអូនដើរតម្រង់ទៅផ្ទះ រូបរាងនឹងដំណើររាងដែលគេនិយមថាល្អ មានរាងសមរម្យ ក៏យកមកប្រៀបនឹងរូប នឹងដំណើរអូនពុំបាន ៗ ទោះបីអូនចេញបាត់ពីមុខបងទៅ បងក៏មិនចាំបាច់រកអូនមើលទៀត មានអ្វីមួយដែលបងរកថ្លែងប្រាប់អូនពុំបាននោះ ជាប់នៅនឹងខ្យល់

ត្រង់កន្ទេលអូនដេរ ជាប់នៅស្មៅត្រង់កន្ទេលអូនអង្គុយ ។ កាលណាបងចូលជិតអូន បងព្រឺព្រួចអស់ទាំងកាយ ។ ពណ៌ផ្ទៃមេឃ មិនស្រស់ដល់ពណ៌ភ្នែកអូនឡើយ ។ សំឡេងសត្វស្លាបនៅប្រទេសបេង្គាល់ក៏មិនពីរោះដល់សំឡេងអូន ។ បើបងបានប៉ះអូនឯងតែនឹងចុងម្រាមដៃបន្តិច បងព្រឺអស់ទាំងខ្លួន ។ អូនមិនចាំទេឬ កាលយើងដើរត្រសងស្ទឹងក្នុងដោះបី ។ ក្នុងពេលដែលយើងមកដល់មាត់ស្ទឹង បងហេវណាស់ តែដឹងថា អូនមកទំលើខ្លួនបង ។ ហាក់ដូចជាមានស្លាបដូចសត្វហើរ ។ ចូរអូនប្រាប់បងបន្តិច ថាអូនមានអ្វី ក៏ធ្វើឲ្យបងស្រឡាញ់អីម្ល៉េះ ឬដោយគំនិតអូនឯង? តែម្ដាយយើងមានគំនិតពូកែជាងយើងទៅទៀត ឬដោយអូនចេះថ្នាក់ថ្នមបបោសអង្អែល? តែម្ដាយយើងចេះបបោសអង្អែលជាងអូនទៅទៀត ។ បងជឿថា អូនមានចិត្តល្អ ។ ទោះមុខទៅបងមិនភ្លេចសោះដែលអូនបានដើរតែជើងទទេទៅដល់ស្ទឹងទឹកខ្មៅ ដើម្បីសូមទោសឲ្យនាងកំសត់ម្នាក់នៅខ្ញុំគេលួចរត់មក ។ នែ? មាសព្រលឹងបង ចូរម៉ុមកាន់យកនូវក្រូចមួយមែកសុទ្ធតែផ្កានេះចុះ ដែលបងកាច់មកពីក្នុងព្រៃ ហើយចូរអូនយកមែកក្រូចហ្នឹងទៅទុកវេលាយប់ក្បែរគ្រែដែលអូនគេង ។ ចូរនាងញ៉ាំឃ្មុំនេះមើល ដែលបងយកមកពីថ្ពក តែចូរនាងមកអង្គុយលើភ្លៅបងបន្តិចសិន ឲ្យបងបាត់អស់កម្លាំង" ។

(មានត)

# ព្រះថេរពីររូបនិមន្តមកពីលង្កាទ្វីប

## ទៅទស្សនាការ ខេត្តសៀមរាប


ព្រះមហាឧត្តមវិជ្ជា កែ-អឿន (វីរិយប្បញ្ញោ)

រៀបរៀង

ដោយបានទទួលបទបញ្ជាការនៃព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យ

មេគណវត្តដំណាក់ - សៀមរាប


កាលពីថ្ងៃសៅរ៍ ១៤ រោចខែជេស្ឋឆ្នាំរោងចត្វាស័ក ព.ស. ២៤៩៥ គឺថ្ងៃទី ២១ ខែមិថុនា គ.ស. ១៩៥២ មានព្រះថេរពីរអង្គ គឺព្រះថេរអង្គមួយ នាម បិយទស្សី វស្សា ១៨ អាយុ ៣៨ ឆ្នាំ, មួយអង្គទៀតនាម បញ្ញាសិរី វស្សា ១៣ អាយុ ៤២ ឆ្នាំ ជាសមណទូតនៃសមាគមពិភពលោក និមន្តមកពីលង្កាទ្វីបទៅទស្សនាការខេត្តសៀមរាប បាននិមន្តពីភ្នំពេញមកដល់សៀមរាបវេលាម៉ោង ៧ ។ ថ្ងៃនោះមានភិក្ខុសាមណេរជាច្រើនក្នុងវត្តដំណាក់ មានព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យ មេគណជាប្រធាន នឹងពុទ្ធបរិស័ទជាច្រើនរង់ចាំទទួលបដិសណ្ឋារៈ ។ ក្នុងដំណើរនិមន្តមកនេះមានសមណទូតពីរអង្គពីក្នុងភ្នំពេញជូនដំណើរមកផង គឺព្រះសង្ឃសត្ថា ប៊ុណ្ណ - សម្ភាជ នឹងព្រះមហាឧត្តមវិជ្ជា សុខ - ឃាងដែលសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ចាត់ឲ្យជូនដំណើរមក ។ លុះនិមន្តមកដល់ហើយក៏ឡើងទៅថ្វាយបង្គំព្រះសុមង្គល

សីលាចារ្យមេគណ ព្រមទាំងព្រះថេរានុត្ថេរៈគ្រប់អង្គ នឹងទទួលបដិសណ្ឋារៈចំពោះពុទ្ធបរិស័ទដែលទៅថ្វាយបង្គំ, ក្រោយពីនោះបន្តិចគេនិមន្តលោកឲ្យទៅសម្រាកនៅទីសាលាបាលីរងដែលរៀបចំបំរុងទុកប្រគេន ។ វេលាម៉ោង ៩ យប់ ព្រះសង្ឃក្នុងវត្តដំណាក់ទៅធ្វើឧបោសថកម្មក្នុងព្រះវិហារ ។ ព្រះថេរទាំងពីរអង្គមានប្រាថ្នាចង់ទៅធ្វើជាមួយផង ដើម្បីនឹងមើលរបៀបព្រះពុទ្ធសាសនាក្នុងស្រុកខ្មែរ, ក្នុងពេលនោះនិមន្តព្រះគ្រូសង្ឃសត្ថា ប៊ុណ្ណ-សម្អាដ ឲ្យសម្ដែងព្រះបាតិមោក្ខដោយសង្ខេប ព្រោះពេលនោះព្រះថេរទាំងនោះលោកអស់កម្លាំងខ្លាំង ដោយមកតាមផ្លូវឆ្ងាយដាច់ស្រយាល; លុះធ្វើឧបោសថកម្មចប់ហើយ គេនិមន្តលោកមកសឹងនៅសាលាបាលី ។

លុះព្រឹកឡើងថ្ងៃអាទិត្យ ១ កើតខែអាសាឍ (២២,៦,៤២) វេលាម៉ោង ៨ ព្រះថេរទាំងនោះនិមន្តទៅទស្សនាទីអង្គរ, ក្នុងខែត្រសៀមរាប មានព្រះថេរខ្លះ តាមជូនទៅផង គឺវត្តដំណាក់ មានព្រះសុមង្គលសីលាចារ្យមេគណនឹងលោកមហាបរិយត្តិលី-លន លោកមហាបរិយត្តិម៉ៅ-ឡាយ, វត្តព្រះព្រហ្មរតន៍ ព្រះមហាឧត្តមវិជ្ជា កែ-អឿន, វត្តពោធិលង្កា ព្រះវិន័យធរអនុគណ ចាន់-ឡុង ព្រះមហាឧត្តមវិជ្ជា វេន-ព្រីង, វត្តធម្មស្សព្រហ្ម (រលួស) ព្រះវិន័យធរអនុគណ ឯក-ញឹម នឹងលោកធុតង្គពីរអង្គទៀត ព្រមទាំងមានឧបាសកឧបាសិកាវត្តដំណាក់ ៣០ នាក់ តាមទៅចាត់ចែង

រៀបចំភ្ញាន់ប្រគេនពេលថ្ងៃត្រង់ ដោយរាជការគន្លងត្រូវបានធ្វើអំណោយរថយន្តធំមួយឱ្យជូនដំណើរទៅ ។ មុនដំបូងចាប់ទស្សនាពីប្រាសាទនគរវត្តក្នុងពេលនោះលោកសង្កេតមើលអស់ពេលជាយូរ ហើយមានថតជាច្រើនកន្លែង លោកមានសេចក្ដីស្ងើចអស្ចារ្យណាស់អំពីបុរាណប្រាសាទទាំងនោះ ៗ លុះចុះពីប្រាសាទនគរវត្តបររថយន្តហួសទៅមើលពីប្រាសាទបាពួនរៀងទៅដល់ស្រះព្រះពិធូរ, ដោយវេលាជិតដល់ពេលឆាន់ត្រង់ហើយ, ដល់ស្រះព្រះពិធូរក៏ឈប់សម្រាកនៅសាលាក្បែរស្រះនោះហើយស្រង់ទឹក ពួកឧបាសកឧបាសិការៀបចំភ្ញាន់ប្រគេនឆាន់, ក្នុងពេលនោះហាក់ដូចជានឹងមានពិធីបុណ្យអ្វីមួយ, លោកលង្កាទាំងពីរអង្គមានសេចក្ដីរីករាយសប្បាយណាស់,ពោលជាភាសាបាលីថា "ទេព សុន្ទរ, អាហារំ សុន្ទរំ, ឧទកំ សុន្ទរំ, អរញ្ញំ សុន្ទរំ," ដូច្នេះស្ទើរតែមិនដាច់ពីមាត់; លុះព្រះសង្ឃឆាន់រួចហើយ ឧបាសកឧបាសិកា និមន្តព្រះថេរលង្កាពីរព្រះអង្គឱ្យអនុមោទនា "យថា" ភាសាបាលីលង្កា, រួចហើយលើកខាទនីយភោជនីយាហារ យកទៅបរិភោគ ។ រួចហើយ ធ្វើដំណើរជូនលោកទៅតាមផ្លូវធំ មើលប្រាសាទព្រះខាន់, នាគពន្ធ, មេបុណ្យ, ប្រែរូប, រៀងទៅដល់ស្រះស្រង់ឈប់ចុះស្រង់ទឹកសម្រាកសម្រាន្តក្នុងទីនោះអស់ពេលយូរ, តពីនោះទៅហួសទៅមើលប្រាសាទតាកែវ រួចត្រឡប់ទៅមើលប្រាសាទបាយន្តវិញអស់ពេលយូរនឹងថតជាច្រើនកន្លែង

ដកបដល់ម៉ោង ៦ កន្លះល្ងាចទើបត្រឡប់ទៅសៀមរាបវិញ ចៀងចូលទៅមើលវត្តពោធិលង្កា ដោយសេចក្តីនិមន្តនៃលោកគ្រូចៅអធិការនិងឧបាសកឧបាសិកាដើងវត្តនោះ, ក្នុងពេលនោះភិក្ខុសាមណេរឧបាសកឧបាសិកាជាច្រើនរង់ចាំទទួលបដិសណ្ឋារៈ ហើយប្រគេនគេសជ្ជៈដល់ព្រះថេរានុត្ថេរទាំងនោះផង ក្នុងទីបំផុតកិច្ចនោះ ព្រះថេរឲ្យទុកទដល់ភិក្ខុសាមណេរ ឧបាសក ឧបាសិកាទាំងមានសេចក្តីអំណរចំពោះបដិសណ្ឋារកិច្ចយ៉ាងក្រៃលែង ហើយអនុមោទនា "យថា" តាមសមគួរ ក្រោយពីនោះត្រឡប់ទៅកាន់វត្តដំណាក់វិញ នៅវេលាម៉ោង៧កន្លះ ។

លុះដល់ម៉ោង៩ យប់ មានសម្តែងធម៌ទេសនាក្នុងវត្តដំណាក់៣លើក មានភិក្ខុសាមណេរជាង ២០០ អង្គ និងឧបាសក ឧបាសិកា ជាង ៣៩០ នាក់ព្រមទាំងកជការក្នុងខេត្តគ្រប់ក្រសួង និមន្តនិងអញ្ជើញទៅស្តាប់ ។

លើកទី ១ និមន្តព្រះថេរធម្មទស្សីសំដែង, វេលាដែលលោកឡើងកាន់គ្រែធម្មាសនៈ ហើយពួកឧបាសក ឧបាសិកាក៏តាំងនមស្សការព្រះរតនត្រ័យ តាមទម្លាប់អ្នកកាន់ព្រះពុទ្ធសាសនា ទើបអារាធនាសុំសីល ៥ លុះទទួលសីលរួចហើយ អាចារ្យវត្តតាំងសូត្រ "ព្រហ្ម" ដើម្បីឲ្យសំដែងធម៌ទេសនា ស្រេចហើយទើបលោកតាំងប្រកាសអញ្ជើញទេវតាឲ្យស្តាប់ មានបាលីថា "សមន្តា ចក្កវាឡេសុ" ដូចក្នុងស្រុកយើងតែង

សូត្រក្នុងវេលាចំរើនព្រះបរិត្តដូច្នោះ ។ ស្រេចហើយទើបលោកប្រកាសដល់ព្រះថេរានុត្ថេរដែលជួបជុំក្នុងទីនោះ ព្រមទាំងឧបាសក ឧបាសិកា ហើយព្យាករសំដែងធម្មទេសនា អំពីឱវាទ ៣ យ៉ាង ជាភាសាបាលីថា:

"សព្វបាបស្ស អករណំ កុសលស្ស ឧបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធានសាសនំ"

(ប្រែថា) ការមិនធ្វើអំពើបាបទាំងអស់ ១ ការបំពេញកុសលឲ្យបរិបូណ៌ ១ ការជំរះជុសខាត់ចិត្តរបស់ខ្លួនឲ្យបរិសុទ្ធម៉ត់ចត់ ១ ឱវាទទាំង ៣ យ៉ាងនេះឯង ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គ្រប់ព្រះអង្គ ។ ធម្មទេសនានេះ ព្រះគ្រូសង្ឃសត្ថាបុណ្ណ-សម្មាជបានប្រែមួយឃ្លាម្តង ៗ ពីភាសាបាលីមកជាភាសាខ្មែរ, ព្រមទាំងអធិប្បាយជាសេចក្តីផ្សេងៗទៀត ដល់ទីបំផុតលោកប្រដៅពុទ្ធបរិស័ទឲ្យខំចំរើនមេត្តាភាវនា ជានិច្ចកាល ; ព្រះថេរអង្គនេះសំដែងចប់នៅម៉ោង ១០ ។

លើកទី ២ – និមន្តព្រះថេរបញ្ញាសារីឲ្យសំដែង, សំដែងលើកនេះខាងដើមមានទំនងដូចលើកទី ១ ដែរ គមកទើបលោកសំដែងធម្មទេសនាគាថា ១ មានក្នុងគម្ពីរធម្មបទខុទ្ទកនិកាយដែលព្រះសម្ពុទ្ធទ្រង់សំដែងប្រារព្ធនឹងនាងបេសការធីតា ជាភាសាបាលីថា

អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ
សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ

ប្រែថា: លោកិយមហាជននេះ មានងងឹតគឺមោហៈគ្របសង្កត់ហើយ បណ្តាលោកិយមហាជនទាំងនោះ អ្នកដែលពិចារណាឃើញច្បាស់នូវព្រះត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើមមានតិចគ្នាណាស់ (ព្រោះហេតុនោះបានជា) ជនតិចគ្នាណាស់ទៅកើតក្នុងស្ថានសួគ៌ ប្រៀបដូចជាសត្វស្លាបតិចណាស់ដែលរួចផុតអំពីសំណាញ់ (របស់ព្រាន) ដូច្នោះ ។

ធម្មទេសនានេះ ព្រះគ្រូសង្ឃសត្ថា ប៉ុណ្ណ-សម្ភាជ ប្រែមួយឃ្លាម្តងៗ ដូចលើកមុនដែរ, ហើយទើបលោកលើករឿងរបស់ការធីតាវត្ថុ មកសំដែង, ដល់ទីបំផុតលោកប្រដៅពុទ្ធបរិស័ទឲ្យចំរើនមរណស្សតិជានិច្ចកាលកុំឲ្យដាច់ ធម្មទេសនាលើកទី២ នេះចប់នៅម៉ោង ១១ ។

លើកទី ៣ — ពុទ្ធបរិស័ទ និមន្តព្រះគ្រូសង្ឃសត្ថា ប៉ុណ្ណ - សម្ភាជ ឲ្យសំដែងអំពីដំណើរដែលលោកនិមន្តទៅបុណ្យសម្ពោធព្រះអរហន្តធាតុព្រះសារីបុត្ត - ព្រះមោគ្គល្លាន ក្នុងប្រទេសនេប៉ាល់ លោកក៏សំដែងយ៉ាងពីរោះក្បោះក្បាយជាសេចក្តីសង្ខេប ។ ដោយលោកមានសេចក្តីនឿយហត់អំពីពេលថ្ងៃនោះជាខ្លាំងណាស់ ។ ធម្មទេសនានេះចប់នៅម៉ោង ១២, ធម្មទេសនាទាំង ៣ លើកនេះ សុទ្ធតែពីរោះចាប់ចិត្តនៃពុទ្ធបរិស័ទយ៉ាងក្រៃលែង ព្រោះក្នុងពេលនោះ គ្មានពុទ្ធបរិស័ទណាមួយក្រោកចាកធម្មសវនដ្ឋានសោះ មានសេចក្តីស្ញើចសរសើរតែគ្រប់ៗគ្នា,

ដល់ទីបំផុតធម្មទេសនាហើយ ព្រះសង្ឃក៏អនុមោទនាតាមទំនៀមរួចទើបឧបាសក ឧបាសិកាសូត្រផ្សាយចំណែកកុសល, ហើយក៏ធ្វើវន្ទនាការចេញចាកទីអាពាមទៅកាន់គេហស្ថានរៀងៗខ្លួន ។

ព្រះថេរលង្កាពីររូប និងព្រះថេរក្រុងភ្នំពេញពីររូប និមន្តទៅសឹងលុះដល់ម៉ោង ៥ ធ្វើដំណើរចេញចាកខែត្រសៀមរាបឆ្ពោះទៅកាន់ក្រុងភ្នំពេញវិញ ។

អស់លោក-អ្នកនាំផ្សាយ !

ដែលខ្ញុំខំធ្វើកិច្ចការលំបាកនឿយហត់ទាំងម្ល៉េះនេះ
មិនមែនយកប្រយោជន៍ផ្ទាល់ខ្លួនទេ
គឺប្រយោជន៍បំពោះជាតិនិងសាសនាប៉ុណ្ណោះ ។

ព្រះសុមង្គលសីលាចារ្យមេគណ

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

# របស់ក្រសួងធម្មការ

(តមក)

---

សញ្ញាប័ត្រលេខ ៧៦៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទេព-ណយ នាមឆាយា ឥន្ទជោត កើតឆ្នាំជូត អាយុ ៥០ វស្សា ៣០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៦៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មឿន-ជាត់ នាមឆាយា ធម្មបញ្ញា កើតឆ្នាំវក អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តកោះធំ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៦៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មុយ-ស៊ុប នាមឆាយា ធម្មសុវណ្ណ កើតឆ្នាំកុរ អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៦៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កាន់-ផន់ នាមឆាយា ឥន្ទសុវណ្ណ កើតឆ្នាំវក អាយុ ៥៤ វស្សា ៣៤ ជាគ្រូសូត្រស្តាំ វត្តត្បែងធំ ឃុំឈើតុម ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៦៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព៉ន់-ស៊ុន នាមឆាយា ឥន្ទសុវណ្ណ កើតឆ្នាំ - - - អាយុ ៣៧ វស្សា ១៥ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៦៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រំ-សាំង នាមធាយា ព្រហ្មសរ កើតឆ្នាំច អាយុ ៤០ វស្សា ២០ ជាគ្រូសូត្រស្តាំ វត្តយសវិន័យ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៧០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុច-ផល នាមធាយា ធម្មសុវណ្ណ កើតឆ្នាំរោង អាយុ ៣៤ វស្សា ១៣ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៧២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជឿក-ឯក នាមធាយា ឥន្ទជោតោ កើតឆ្នាំមមី អាយុ ៣២ វស្សា ១៣ ជាចៅអធិការវត្តដូងយ៉ាំង ឃុំត្រពាំងពុង ស្រុកភ្នំក្រវាញ ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៧៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ វ៉ឹត-ឈឿន នាមធាយា សុវណ្ណត្ថេរ កើតឆ្នាំមមែ អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៧៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មឿង-ស្រស់ នាមធាយា សិរីថេរោ កើតឆ្នាំកុរ អាយុ ២៧ វស្សា ៨ ជាចៅអធិការវត្តអង្គកែវ ឃុំខ្សាំង ស្រុក-ខេត្តដដែល ។

(មានត)

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៤ ខែកញ្ញា លេខ ៩

ព.ស. ២៤៩៥ – គ.ស. ១៩៥២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា* — បញ្ជីរឿង — *ទំព័រ*

ព្រះពុទ្ធសាសនានៅប្រទេសចិន (តមក).. លោក ភ៉យ-ប៊ុក ........ ៧២៣
ឃរាវាសធម៌ ................ ព្រះអរិយកស្សប កែវ—អ៊ួច ... ៧៣១
លទ្ធិពុទ្ធសាសនានឹងលទ្ធិប្រជាធិបតេយ្យ ... ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ..... ៧៣៨

*ផ្នែកអក្សរសាស្ត្រ*

ការបណ្ដុះនិស្ស័យ (តមក)........ ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម ... ៧៤៤
រឿងសាមកុក (តមក).......... ឧកញ៉ា ង្វៀ-កន ........ ៧៥១
រឿងអាវ័ក្សថ្លៃងរឿងម្ភៃប្រាំ (តមក).... លោក ភ៉យ-ប៊ុក........ ៧៦២
រឿងស្លាប់ព្រោះជាតិ ............ លោក គង់—លឹម ....... ៧៦៦
រឿងប៉ូលនឹងវីរ័ស៊ីនី (តមក)......... លោក ផេង-ជ្រឹវ ....... ៧៧៥

*កំណត់ទីនប្រវត្តិការណ៍*

ពិធីបុណ្យព្រះសារីរិកធាតុ នឹងព្រះអរហន្តធាតុ
នៃព្រះសារីបុត្តនឹងព្រះមោគល្លាន...... ពុទ្ធសាសនបណ្ឌិត្យ ....... ៧៨៥
បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក). ក្រសួងធម្មការ .......... ៧៩៩

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៨៣រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES


### PARTIE RELIGIEUSE

| | | Pages |
|---|---|---|
| Le Bouddhisme en Chine (suite). | *M. Ray-Buc* | 723 |
| Gharavasadharma | *Vén. Kèo-Ouch* | 731 |
| Le Bouddhisme et la Démocratie | *Commission des Mœurs et Coutumes* | 738 |

### PARTIE LITTERAIRE

| | | |
|---|---|---|
| Education morale (suite) | *Brah Maha Pœung-Pam* | 744 |
| Histoire de SAMKOK (suite) | *Oknha Nou-Kan* | 751 |
| Les vingt cinq récits du Mauvais Génie (suite) | *M. Ray-Buc* | 762 |
| Mort pour la Patrie (pièce du théatre) | *M. Kong-Lim* | 766 |
| Paul & Virginie (suite) | *M. Phéng-Chrieu* | 775 |

### NOTES ET CHRONIQUES

| | | |
|---|---|---|
| Cérémonies de la Réception des Reliques sacrées | *Institut Bouddhique* | 785 |
| Nomination des nouveaux Chau-adbikar (suite) | *Ministère des Cultes* | 799 |


**Prix d'abonnement annuel (comprenant 12 numéros:) 183$00**

# ព្រះពុទ្ធសាសនានៅប្រទេសចិន

## លោករ៉ាយ-ប៊ុក ក្រមការ រៀបរៀង

(តមក)

---

ដល់ ៩០៧ សន្តតិវង្សតាំង សាបសូន្យ, មានសន្តតិវង្សខ្សោយ អាទុភាព (៩០៧ ៩០៦) តមក ថែមទាំងមានខេត្តស្វោយកព្យជាច្រើន ។ ព្រះរាជអាណាចក្រចិនថយពលភាព: វដ្តកូប៉, មញ្ជូរី, តេ្តលីត្រូវនៅ ក្រោមបង្គាប់ពួកមុង្គោល គឺ-តាំង ដែលបានស្ថាបនាព្រះរាជធានីនៅទី ក្រុងប៉េកាំង (៩៣៨) ប្រទេសកាស្មារីធ្លាក់ទៅក្នុងកណ្តាប់ដៃពួកអ៊ុយ គួរទឹងការលុក ។ ប្រទេសយៀកណាម បានរើរួចពីបង្គាប់បញ្ជាប្រទេស ចិន (៩៣៩) ។ វដ្តកូរេ ដែលព្រះមហាក្សត្រទ្រង់ព្រះនាមកៅ-សុង (៦៥៣-៦៣៨) បានវាយយកបានមក ឥឡូវបានរើរួចចេញស្រឡះ, តាំងជា សន្តតិវង្សប្រជាជាតិមួយ ហៅថា សន្តតិវង្សវ៉ាំង (៩១៨-១៣៩២) ។

នៅក្នុងសន្តតិវង្ស សុង (៩៦០-១២៧៩), ប្រទេសចិនពិត មែនតែបានចំរើន តែមិនអាចទឹងឡើងឋានៈស្មើនឹងប្រទេសកាលនៅក្នុង សន្តតិវង្សតាំងទេ ។ មានពួកគីតាន់ខាងជើងនឹងពួកតាន់គុតខាងឡិច អ្នក ជនកនៃព្រះរាជអាណាចក្រ ស៊ី-ហៀ នៅកាំងស៊ូក៏បានចូលមកធ្វើ ចលាចលនៅព្រំដែន ។ ព្រះអធិរាជក្នុងសន្តតិវង្សសុងតាំង ពីព្រះបាទ

ត្រួន.ត្សុងទៅដល់ព្រះបាទហ៊ួ-អៃ-ត្សុង (ពីឆ្នាំ ៩៩៨ ទៅដល់ ១១២៥) ទ្រង់បានសោយរាជសម្បត្តិ នៅព្រះរាជធានីកៃ-ហុង, ទ្រង់សព្វព្រះរាជហឫទ័យខាងវប្បធម៌, អក្សរសាស្ត្រ, សិល្បកម្ម និងការពិសោធន៍នូវសង្គម ។

មានពួកចុនគុសមកតាំងកុលសម្ពន្ធនៅទីក្រុងប៉េកាំង បានដេញពួកគី-តាន់ពីព្រំដែនប្រទេសចិន ។ ពួកនេះមាននាយកុលសម្ពន្ធសន្មតព្រះនាមជា "សុវណ្ណមហារាជ" (គិន) មានបំណងចង់រាយប្រទេសចិនឲ្យមកនៅក្រោមអនិស្សរភាពខ្លួន, តែទទួលពួកមុង្គោលលើកកងទ័ពពីខាងជើង សម្បើមអស្ចារ្យធ្វើឲ្យពួក "គិន" បរាជ័យ ។

ប្រវត្តិសាស្ត្រនៃប្រទេសដែលនៅក្នុងចុងបូព៌ាប្រទេស មានព្រឹត្តិការណ៍ប្លែកៗ ជាច្រើននៅកោះសុមាត្រា, អានុភាពជាតិត្រូវព្រះរាជអាណាចក្រស្រីវិជ័យខាងសន្តតិវង្សសៃឡង់ (៦៧១) ។ ព្រះមហាក្សត្រក្នុងសន្តតិវង្សនេះ, ក្នុងសតវត្សទីប្រាំបីទ្រង់បានធ្វើឲ្យកោះជ្វាជ្រោយមលយូៈ និងមាត់សមុទ្រប្រទេសកម្ពុជា ចូលមកនៅក្រោមបង្គាប់បញ្ជាព្រះអង្គ ។ ដល់មកឆ្នាំ ៩២៥, មានព្រះរាជអាណាចក្រជ្វាមួយស្ថាបនាឡើង បែកញែកក្នុងសតវត្សទី ១១ តាំងឡើងជាថ្មីនៅសតវត្សទី ១៣ ដែលព្រះបាទកេន-អន្ទ្រកៈ ព្រះជនកនៃព្រះរាជអាណាចក្រតុម្ប៉ុលជាប្រមុខ ។ តមក កោះជ្វានិងសុមាត្រាក៏ធ្វើសង្គ្រាមគ្នាទៅវិញទៅមក

ដើម្បីនឹងតាំងអធិបតេយ្យនៅកោះឥណ្ឌូស៊ីយលិនទាំងមូល ។ សង្គ្រាមនេះឈប់នៅឆ្នាំ ១២៩៣ ដោយកោះជ្វាមានជោគជ័យ ។ ព្រះរាជ-អាណាចក្រស្រីវិជ័យក៏វិនាសសាបសូន្យក្នុងឆ្នាំ ១៣៧៧ ហើយអធិ-បទេសជ្វានៃព្រះបាទមជៈបហិត ក៏ផ្សាយឥទ្ធិពលខាងកោះឥណ្ឌូណេស៊ីឯកើតនឹងពាក់កណ្ដាលជ្រោយមលយូៈ ។

នៅឥណ្ឌូចិន, ពួកយួននឹងចាមបានឈ្លោះគ្នាដណ្ដើមមាត់សមុទ្រខាងកើត (៩៨២ ១០៧០) ។ ពួកចាមបរាជ័យ បានចុះសន្ធិសញ្ញាសន្តិភាពនឹងបច្ចាមិត្តរបស់ខ្លួន ហើយក៏លើកកងទ័ពមកច្បាំងនឹងជាតិខ្មែរដែលកំពុងមានឥទ្ធិពលអស្ចារ្យក្នុងពេលនោះ ។ អធិបទេសខ្មែរបានស្ថាបនាពីឆ្នាំ ៨០២ មានព្រះបាទជ័យវរ្ម័នទីពីរជាប្រមុខ; ប្រទេសនេះបានព្យាយាមកាត់ឥទ្ធិពលចំនួន ពីសតវត្សខាងលិច បានព្រះរាជអា-ណាចក្រមននៃទ្វារវតីមកជាអាណានិគម ។ ប្រទេសចម្ប៉ាបានលើកកងទ័ពទៅវាយជាតិខ្មែរបរាជ័យ (១០៧០) នឹង (១·១៣៧) ។ តែព្រះបាទឥន្ទ្រវរ្ម័នទីពីរនៃប្រទេសកម្ពុជាទ្រង់បានធ្វើសង្គ្រាម នឹងប្រទេសចម្ប៉ា (១២០១) ធ្វើឲ្យប្រទេសនេះបរាជ័យធ្លាក់មកជាអាណានិគមខ្មែរវិញ ខ្មែរទៅជាជាតិមួយល្បីល្បាញក្នុងអាស៊ីបូព៌ា ក្នុងសម័យនោះ ។

ប្រទេសជប៉ុន បានយកវប្បធម៌ខាងបស្ចិមប្រទេសមកអប់រំ ។ ព្រះអធិរាជជប៉ុនបានតាំងព្រះរាជធានីនៅ នរ (៧១០ ·៧៨៤) ។ តមក,

មានមេខាងទុត្តមត្រកូលនាម "ហ៊ូជីវ៉ារ៉ា" បានតស៊ូនឹងព្រះអង្គម្ចាស់ដណ្តើមរាជសម្បត្តិបាន ( ៧៨៤ ) បានទុកសិទ្ធិឲ្យព្រះរាជវង្សានុវង្សគង់នៅព្រះបរមរាជវាំងឯទីក្រុង គីយ៉ូតូ ។ ដល់ចុងសតវត្សទី ១០ គឺសម័យកលិយុគ ពួកដៃមីយ៉ូនឹងពួកសាមូរ៉ៃ (ព្រះអង្គម្ចាស់នឹងពួកយោធា) តស៊ូគ្នា សម័យដែលព្រះរាជវង្សានុវង្សទាំងពីរ តៃរ៉ា នឹងមីនាម៉ូតូ បានធ្វើសង្គ្រាមគ្នាទៅវិញទៅមក ។ ដល់មក គ.ស. ១១៨៩, ព្រះបាទយ៉ូរីតូម៉ូ កងពួកសុគ្ហណ កងសន្តតិវង្ស តៃរ៉ា កំសាបសូន្យ ។ ឆ្នាំ ១១៩៩, មានសន្តតិវង្ស "ហូជូ" សោយរាជសម្បត្តិតមក សន្មតព្រះនាមជា "សិក្កេន"; ១២៧៤ មានព្រះមហាក្សត្រកងសន្តតិវង្ស "ហូជូ" បានជួយប្រទេសជប៉ុនផុតពីកណ្តាប់ដៃជាតិម៉ុងហ្គោល ។

## ១) ដំណើរព្រះពុទ្ធសាសនាចូលប្រទេសចិន:

ក្នុងឆ្នាំ ២០៧ មុន គ.ស. មានព្រះសង្ឃខាងព្រះពុទ្ធសាសនានិមន្តមកពីប្រទេសឥណ្ឌាចូលទៅក្នុងប្រទេសចិន ហើយបានទៅផ្សាយព្រះពុទ្ធសាសនាក្នុងខេត្តបេនស៊ី ។ ដល់ឆ្នាំ ១២២ មុន គ.ស., មានមេទ័ពចិនបានចូលទៅធ្វើសង្គ្រាមក្នុងខេត្តយារកន្ទ៍ បានរកឃើញព្រះពុទ្ធរូបមាសមួយនៅភូមិភាគ យ៉ីតូ - ហ៊ូ យកមកថ្វាយព្រះអធិរាជ ។

គ.ស. ៦១, ព្រះពុទ្ធសាសនាផ្សាយចេញទៅពាសពេញប្រទេសចិន; ព្រះអធិរាជមេង - ទីទ្រង់បានចាត់រាជទូតឲ្យទៅចំឡងគម្ពីរពីប្រទេស

ឥណ្ឌា)ព្រមទាំងនិមន្តព្រះសង្ឃមកផ្សាយព្រះពុទ្ធសាសនា; រាជទូតវិលត្រឡប់មកប្រទេសចិនវិញ បាននាំទាំងនិមន្តព្រះសង្ឃជាច្រើន; កស្សបមា-តង្គ: ព្រះសង្ឃមួយអង្គដែលបាននិមន្តពីប្រទេសឥណ្ឌាកណ្ដាលមក បានបកប្រែព្រះសូត្រ ៤២ ខ្សែ (ហីនយាន) ។

ដុហ្វា-លុន បានបកប្រែព្រះសូត្រខ្លះ ក្នុង គ.ស. ១៥០ ។

ក្នុងពេលនោះ មានព្រះសង្ឃព្រះនាមជិល-ទិន និមន្តមកពីប្រជាជាតិសៃត បានបកប្រែព្រះនិព្វានសូត្រ ។

ព្រះបាទស៊ុន-គៀន នៃរដ្ឋ៉ូ (ប្រទេសចិនមានព្រះរាជអាណាចក្ររដ្ឋ៉ូជាព្រះរាជអាណាចក្រទីមួយ) ក្រោយដែលទ្រង់បានទទួលរាជទូតបី ពីព្រះបាទម៉ាក់-អូរ៉ែលនៃអធិបទេសរ៉ូម, ទ្រង់បានទទួលនូវសេដ្ឋពាណិជរ៉ូមម្នាក់និងព្រះសង្ឃឥណ្ឌាមួយអង្គ ដែលបានបកប្រែគម្ពីរព្រះត្រៃបិដកថ្វាយ ។

តមក មានព្រះសង្ឃឥណ្ឌាមួយអង្គព្រះនាមធម្មកាល: (ប្រហែលជាធម្មកលល:) បានបកប្រែព្រះវិន័យនៅទីក្រុងឡូយ៉ង ។

ក្នុងចុងសតវត្សទីបី គ.ស., មានជនជាតិឥណ្ឌានាមឈី-គុន-មេង នៅស៊ី-យ៉ាង-ហ្វូ បានបកប្រែគម្ពីរមហាយាន (បុប្ផាបទុមនៃបទបញ្ញត្តិល្អ, (le Lotus de la bonneLoi) តែសេចក្ដីបកប្រែនោះនៅខ្វះខាតជាច្រើនកន្លែង, ទើបមានចិនម្នាក់ជាពុទ្ធសាសនិកជន នាម "តាវ" បានកែប្រែអត្ថបទខ្លះ ដោយសេចក្ដីណែនាំពីព្រះគ្រូពុទ្ធជង្គ: ។

គ. ស. ២៩០, មានចិនម្នាក់នាមជូ - ស៊ី - ហីង នៅខេត្តហូណាន់ បានបកប្រែព្រះសូត្រ ៩០ ខ្សែ ( ប្រាជ្ញាសូត្រអាភា · Pradjna Sutra de la Lumière ដែលយកមកពីឥណ្ឌាខាងជើង ។ លំដាប់តមក, មានចិនម្នាក់ទៀតនាម ចុ - ហ្វា - កា នៅរដ្ឋសែត បានធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌាខាងជើងបានបកប្រែគម្ពីរនេះដែរ ។ មានបណ្ឌិតបកប្រែគម្ពីរជាច្រើនតមក, មានព្រះសង្ឃឥណ្ឌានាម ធម្មរក្ស: បានបកប្រែព្រះសូត្រ ។

គ. ស. ៤០៥, ព្រះមហាក្សត្រនៅព្រះរាជអាណាចក្រត្សិនទ្រង់បានតែងតាំងព្រះសង្ឃឥណ្ឌាមួយអង្គនាមកុមារជីវ: ដែលគេនាំជាឈ្លើយសឹកពីប្រទេសទីបេតមកថ្វាយ ឲ្យឡើងឋានន្តរ: ជាមន្ត្រីធំក្នុងព្រះបរមរាជវាំង ហើយទ្រង់បានចាត់ឲ្យបកប្រែគម្ពីរព្រះត្រៃបិដកព្រមទាំងព្រះសង្ឃ ៨០០ អង្គ បាន ៣០០ សៀវភៅ ។

លោកហ្វា - ហៀន បានធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌាបានចម្លងព្រះវិន័យនិងគម្ពីរឯទៀតសំខាន់ៗ, ដល់ត្រឡប់មកប្រទេសចិនវិញ លោកហ្វា - ហៀន ដោយសេចក្តីណែនាំពីព្រះសង្ឃឥណ្ឌាមួយអង្គព្រះនាមភទ្រ: បានបកប្រែគម្ពីរអេសន្ទ័យ - វិន័យ ( មហាយាន ) ។

គ. ស. ៤០០, ព្រះសង្ឃនាមសង្ឃទេវ: បានបកប្រែ អាគមសាស្ត្រ: ។

គ. ស ៥០២, មានជនជាតិឥណ្ឌាម្នាក់ បានបកប្រែសាស្ត្រ:ជាច្រើន ។

## ក) ជោគជ័យនិងបរាជ័យ
## នៃព្រះពុទ្ធសាសនារហូតដល់ពោធិធម៌

ព្រះអធិរាជ ហ៊័យ៉ន-ហ៊ូ នៃសន្តតិវង្សត្រៀន បានកសាងវត្តមួយនៅក្នុងព្រះបរមរាជវាំង ណាន់-កាំង ។

ព្រះពុទ្ធសាសនាបានទទួលនូវសេចក្តីរាប់អានពីប្រជាជនចិន ដោយសាសនានេះដូចគ្នានឹងលទ្ធិ តាវ-សេ ដែលសាមញ្ញជនច្រើនកាន់ប្រចាំ តែដោយសេចក្តីទុក្ខលំបាកសព្វយ៉ាង ព្រមទាំងការចលាចលក្នុងប្រទេស និងការអប់រំពួកបុគ្គលខាងព្រះពុទ្ធសាសនាធ្វើឲ្យព្រះពុទ្ធសាសនា បានចំរើនក្នុងប្រទេសចិន ។

យើងបានឃើញក្នុងប្រវត្តិសាស្ត្រចិន ច្រើនមានការប្រព្រឹត្តទារុណកម្ម, ការពិឃាតព្រមទាំងអកុសលផ្សេងៗ; ធម៌ព្រះសម្មាសម្ពុទ្ធជាបរមគ្រឿងជាទឹកត្រជាក់សម្រាប់យកទៅរំលត់ភ្លើងទុក្ខរបស់ប្រជាជន ។ សាវកព្រះពុទ្ធមានទេសនាផ្សាយតស៊ូនឹងសង្គ្រាម, អបាយមុខការឈ្លោះទាស់ទែងក្នុងគ្រួសារ ។ ព្រះសង្ឃទាំងនេះ បានតស៊ូនឹងពួកបណ្ឌិត (សាវកកុង-ហ្វូង-ស៊ី) ដោយនិមន្តទៅឲ្យដល់គ្រប់ទីកន្លែងព្រមទាំងពួកតាវ-សេ ដោយបញ្ចេញនូវគុណធម៌ដ៏វិសេសផ្សេងៗ ។ ព្រះសង្ឃបានពន្យល់អំពីករណីយកិច្ចព្រះអង្គម្ចាស់ចំពោះព្រះអធិរាជ, ត្រូវស្រឡាញ់ព្រះអធិរាជដូចព្រះបិតា, ករណីយកិច្ចនៃគ្រួសារទៅតាមប្រពៃណីចិន ។

ព្រះសង្ឃបានធ្វើចរិយាឲ្យសមរម្យប្រហែលនឹងពួកបណ្ឌិត (សាវកកុង-ហ្វុង-ស៊ី) គឺប្រើតាមវិចារណញាណវិធីបដិបត្តិដោយសុភវិនិច្ឆ័យ, ការសន្តោសចិត្ត, ព្រហ្មវិហារជាដើម តាមព្រះបរមពុទ្ធោវាទ ។ កិច្ចការដែលលោកសង្ឃត្រូវនៅលីវ ជាទំនាស់នឹងនយោបាយព្រះអធិរាជព្រមទាំងលទ្ធិបុរាណនិយម, តែសាវកព្រះពុទ្ធប៉ិនប្រសប់លៃលកកិច្ចការនេះឲ្យបានស្រួល ។

ក្នុងសន្តតិវង្សហាន់ (២០៦ មុន គ.ស. ទៅ ២២០ គ.ស.) ព្រះអធិរាជមិនសព្វព្រះរាជហឫទ័យនឹងព្រះពុទ្ធសាសនា, ពេញព្រះទ័យតែនឹងការឧបត្ថម្ភពួកបណ្ឌិតនឹងពួកតាវ-សេ ។

គេបានអនុញ្ញាតឲ្យពួកពុទ្ធសាសនិកជន កសាងវត្តអារាមនៅក្នុងក្រុងធំៗ តែមិនមានពលរដ្ឋចិនបួសជាសមណៈឡើយ; ទាល់តែមកដល់ គ.ស. ៣៣៥, ទើបព្រះអង្គម្ចាស់គង់ក្នុងព្រះរាជអាណាចក្រហៅក្នុងសន្តតិវង្សស៊ិន បានអនុញ្ញាតឲ្យពលរដ្ឋចិនបួស ដោយការស្នើពីព្រះសង្ឃឥណ្ឌាមួយអង្គព្រះនាមពុទ្ធជង្គៈ ។

ក្នុងពេលនោះ, នៅប្រទេសចិនខាងជើង មានវត្តខាងព្រះពុទ្ធ-សាសនាជាច្រើនហើយ ប្រជាជនក្នុងប្រាំបួនភាគដប់ជាអ្នកនិយមកាន់ព្រះពុទ្ធសាសនា ។

(មានត)

# ឃរាវាសធម៌

## ព្រះអរិយកស្សប កែវ-អ៊ុំ វត្តបទុមវតី ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៤ ខែអស្សុជ
ឆ្នាំជូតសំរិទ្ធិស័ក ព.ស. ២៤៩១ (១–១១–៤៨)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមក្រាបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ព្រមទាំងព្រះសទ្ធម្ម នឹងពពួកនៃព្រះអរិយសង្ឃ ដោយសេចក្ដីគោរព ៗ រួចហើយអាត្មាភាពនឹងសំដែងព្រះធម្មទេសនា អំពីឃរាវាសធម៌ ជាធម៌សម្រាប់ឃរាវាស អ្នកមានផ្ទះសំបែង ផ្សាយតាមវិទ្យុកម្ពុជាចែកជូនអស់លោក-អ្នកទាំងឡាយស្ដាប់ ដូចតទៅនេះ ។

ក៏ធម៌សម្រាប់ឃរាវាសមាន ៤ ប្រការ គឺ:

១ – សច្ចៈ = សេចក្ដីពិតត្រង់ដល់គ្នានឹងគ្នា

២ – ទមៈ = ការសង្កត់ចិត្តទុក

៣ – ខន្តិ = អំណត់ធត់ធន់

៤ – ចាគៈ = បែងចែករបស់ទ្រព្យខ្លួនដល់មនុស្សដែលគួរចែកឲ្យ ៗ

អធិប្បាយ: ជនអ្នកគ្រប់គ្រងផ្ទះដែលបាននាមបញ្ញត្តិថា គ្រហស្ថ សមគួរជាអ្នកមានសទ្ធា ជឿក្នុងកម្មស្សកតាញាណ គឺសត្វមានកម្មជារបស់ខ្លួន បើមិនដូច្នោះ ក៏នឹងស្វែងរកផលនៃឃរាវាស ក្នុងផ្លូវដែល

ប្រកបដោយទោស មិនប្រយ័ត្នចំពោះបាបកម្ម និងធ្វើអ្វីក៏មិនគិតថាជាទុច្ចរិតសាបសូន្យ ជាមនុស្សឃើញតែខាងបាន ចំពោះខ្លួនដោយចំណែកមួយ មិនរើសផ្លូវរកស៊ីយ៉ាងមិច្ឆាអាជីវៈ បៀតបៀនអ្នកដទៃឲ្យខូចប្រយោជន៍; ទោសទាំងពួងនេះមានមកអំពីគ្មានសទ្ធាជាខាងដើម កាលធ្វើដូច្នោះ ការគ្រប់គ្រងយកកាសក៏តាំងនៅមិនជាប់ សូម្បីតាំងឡើងបានហើយក៏មិនតាំងនៅយឺតយូរ បើបុគ្គលដម្រង់នូវយកកាស មានសទ្ធាជឿកម្មផល ក៏ទឹងតាំងខ្លួនទុកក្នុងផ្លូវដែលប្រពៃ ប្រកបការងារចាកទោស មិនសំឡឹងឃើញតែប្រយោជន៍ចំពោះខ្លួន បេះសំឡឹងដល់អ្នកដទៃខ្លះ រកស៊ីក្នុងផ្លូវសម្មាអាជីវៈ ដូច្នេះអាចគ្រប់គ្រងផ្ទះសំបែងឲ្យបរិបូណ៌បាន ហើយតាំងត្រកូលឲ្យថាវរៈរឹងប៉ឹងដោយបរិបូណ៌ពេញលេញ ។

សទ្ធាជាគុណជាតិដែលគប្បីប្រាថ្នាមុន ព្រោះជាធម៌សាមញ្ញរបស់គ្រហស្ថ; សម្ដេចព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ចាត់ជាគុណបទរបស់បុគ្គលអ្នកគ្រប់គ្រងផ្ទះ បានលើកឡើងតាំងជាបឋម ទ្រង់ត្រាស់សំដែងចំពោះគុណឯទៀត ៤ ស្ថាន មានពាក្យសត្យ គឺពាក្យពិតជាដើម ដោយសេចក្ដីជាគិហិធម៌ ។

សេចក្ដីពិតត្រង់ នោះជាគុណសំខាន់គួរគប់រករបស់ប្រជាជន តាំងតែអំពីត្រកូលមួយ ដូចជាស្វាមី និងភរិយា មាតាបិតា ព្រមទាំងបុត្រធីតា ។

បើស្វាមីនឹងភរិយាប្រព្រឹត្តឲ្យទីស៊ីគំនិតដល់គ្នានឹងគ្នា មិនជាទីទុកចិត្តបានទេ ចំណែកភរិយានឹងរង្កៀសក្នុងស្វាមីថា ប្រហែលមានសេចក្ដីត្រេកអរនឹងស្រីដទៃ ម្ល៉ោះហើយទ្រព្យសម្បត្តិដែលរកបាន ក៏មានតែយកទៅជប់លៀងបុរសដទៃ មិនសុចរិតត្រង់នឹងស្វាមីរបស់ខ្លួន ឯស្វាមីក៏សង្ស័យក្នុងភរិយាថា ប្រហែលប្រព្រឹត្តក្រៅចិត្តខ្លួន ហើយទៅគប់នឹងបុរសដទៃ ម្ល៉ោះហើយមិនរកស៊ីដោយសុចរិត ចាយវាយទ្រព្យសម្បត្តិខ្ជះខ្ជាយឥតសណ្ដាប់ ដូច្នេះត្រកូលនោះក៏រកសេចក្ដីសប្បាយគ្មាន ៗ បើជនពល់គ្នា ប្រព្រឹត្តសុចរិតឲ្យជាទីទុកចិត្តគ្នាទៅវិញទៅមកក៏នឹងនៅដោយសេចក្ដីពេញចិត្តត្រជាក់ចិត្ត ជួយគ្នាធ្វើ ជួយគ្នារក មាននាទីរីករាយសប្បាយ ៗ

ប្រការមួយទៀត មាតាបិតា នឹងបុត្រក៏ដូចគ្នា បើប្រព្រឹត្តមិនឲ្យជាទីទុកចិត្តទៅបាន ក្នុងការជាប់ទាក់ទងដោយទ្រព្យសម្បត្តិក្ដី ដោយការគប់គ្រងគ្រួសារក្ដី ដោយហេតុយ៉ាងដទៃក្ដី ដូច្នេះត្រកូលនោះក៏រកសេចក្ដីសុខគ្មាន បើប្រព្រឹត្តសុចរិតឲ្យជាទីទុកចិត្ត ជឿគ្នាទៅវិញទៅមក ត្រកូលនោះក៏នៅជាសុខសប្បាយចំរើនយឺនយូរតទៅ ៗ

បុត្រដែលមានចិត្តល្អជាតួយ៉ាង គឺព្រះបទុមកុមារ ជាព្រះឱរសព្រះចៅពារាណសី ព្រះបិតាស្ដេចទៅប្រាប់ប្រាមសត្រូវដែលចលាចលតាមជាយព្រះអាណាខេត្ត ទ្រង់ប្រោសឲ្យព្រះបទុមកុមាររក្សាព្រះនគរ

ព្រះមហេសីរបស់ព្រះបិតាមានចិត្តប្រតិព័ទ្ធនឹងព្រះបទុមកុមារ តែព្រះបទុមកុមារមិនព្រមស្ម័គ្ររួមសំវាស ដូច្នេះចាត់ថាជាសីរីរបស់ត្រកូល, សេចក្ដីមិនត្រង់ដល់គ្នានឹងគ្នា បើប្រព្រឹត្តទៅក្នុងរវាងចៅហ្វាយនាយ នឹងបាវព្រាវក្ដី ប្រព្រឹត្តទៅក្នុងញាតិមិត្រក្ដី ក្នុងទីបំផុតរហូតដល់មនុស្សអ្នកទិញឬអ្នកលក់ក្ដី រកទៅបានត្រឹមណា សេចក្ដីសាបសូន្យ ក៏រមែងមានទៅត្រឹមណោះ ។

បំណែកសច្ចៈ សេចក្ដីពិតត្រង់ផ្សាយបានទៅត្រឹមណា ក្នុងពួកមនុស្សនោះៗ តាំងអំពីចៅហ្វាយនាយ នឹងបាវព្រាវ សេចក្ដីចំរើនក៏មានទៅត្រឹមណោះ ។ ពុទ្ធាទិបណ្ឌិត ទ្រង់ឃើញអំណាចប្រយោជន៍ដូច្នេះហើយ ទើបទ្រង់ប្រដៅឲ្យមនុស្សក្នុងលោកមានសច្ចៈ គឺសេចក្ដីប្រព្រឹត្តឲ្យសុចរិតទៀងត្រង់ដល់គ្នាទៅវិញទៅមក ឲ្យនិយាយតែពាក្យពិត ឲ្យរក្សាបដិញ្ញា គឺសញ្ញាដែលល្អ ធម៌ល្អ ដែលមិនបានឲ្យទុក្ខដល់អ្នកណាៗ ហើយប្រព្រឹត្តជាធម៌ក្នុងបុគ្គល នឹងកិច្ចការនោះៗ ទ្រង់សរសើរសេចក្ដីសត្យទុក មានដើមថាជារសដ៏លើសលប់ ជាងរសទាំងឡាយ ជាវាចាមិនស្លាប់ គឺមិនចេះប្រែប្រួល នឹងជាហេតុឲ្យមានឈ្មោះពីរោះជាទីរាប់រកមហាជន ។

**ការសង្កត់ចិត្តទុក** នោះជាគុណដ៏សំខាន់ប្រការមួយរបស់ជនអ្នកនៅរួមគ្នា ក្នុងត្រកូល ក្នុងពួកមនុស្សទាំងឡាយ រមែងមានអធ្យា-

ស្រ័យផ្សេងគ្នា ដូចយ៉ាងមនុស្សខ្លះ រមែងស្រវឹងទៅដោយទោសៈ មនុស្សខ្លះមានចិត្តត្រជាក់ មានអ្នកមកខ្ចប់ប៉ះក៏ព្រងើយបាន ។ បើមនុស្សអធ្យាស្រ័យកាចមិនមានសតិដែលនឹងទប់ទល់ តែងប្រព្រឹត្តទៅតាមសង្កិ-លេសធម៌ដែលកើតឡើង ក៏នឹងចរចាអាក្រក់ដល់គេខ្លះ កាប់ប្រហារគេខ្លះយ៉ាងនេះជាដើម សាមគ្គីក៏មិនអាចតាំងនៅបាន; ស្វាមីភរិយាក៏នឹងបែកបាក់គ្នាទៅ ព្រោះហេតុនោះ មិនត្រូវពោលពាក្យអាក្រក់ដល់មនុស្សអ្នកគប់រកផងឡើយ ។ ពុទ្ធាទិបណ្ឌិតទ្រង់ឃើញទោសយ៉ាងនេះ ទើបប្រដៅឲ្យមានឧបាយសង្កត់ចិត្តរបស់ខ្លួន ទុកក្នុងកាលដែលសង្កិ-លេសធម៌អកុសលកើតឡើង ត្រូវសង្កត់ កុំឲ្យវិលវល់ទៅតាមអំណាចអកុសលនោះៗ តែកិលេសដែលជាអនុស័យរមែងដេកសង្កត់ទុក ដើម្បីនឹងកើតឡើង ដូចគ្រាប់កាំភ្លើងដែលគេគ្រាន់តែប្រកទុក មិនទាន់លោះកៃដូច្នោះ កាលអារម្មណ៍មកជទូ មកប្រាកដក្នុងទ្វារ រមែងកើតទាន់លំបាកសតិនឹងឃុំឃាត់បាន ដោយហេតុនោះលោកទើបប្រដៅឲ្យមានសតិរក្សាទ្វារខាងក្រៅ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត កាលណាអារម្មណ៍ គឺ រូប, សំឡេង, ក្លិន, រស, ផោដ្ឋព្វៈ មកប្រាកដក្នុងទ្វារខាងក្រៅក្តី កាលសេចក្តីនឹកគិតកើតឡើងក្នុងទ្វារខាងក្នុងក្តីកុំឲ្យអារម្មណ៍អម្បាលណោះ ធ្វើឲ្យចិត្តសៅហ្មងបាន ។ ជនអ្នកសង្កត់ចិត្តទុកនោះ មានទីឃាវុកុមារជាតួយ៉ាង ។

**អំណត់អត់ធន់** នោះជាគុណធំសំខាន់ប្រការមួយ របស់ជនអ្នកជាប់នៅក្នុងជំនុំ តាំងអំពីត្រកូលជាមួយគ្នា; ជនទាំងឡាយអ្នកមានចិត្តវិលវល់ដោយអំណាចទោសៈ សមគួរនឹងតាំងនៅក្នុងទមៈ គឺបេះសង្កត់ចិត្តខ្លួន តែថាមិនមែនជានាទីអ្នកពាល់គ្នា នឹងធ្វើបានទាំងអស់គ្រប់គ្នាទេ ព្រោះសង្កិលេសធម៌ ដែលជាម្ចាស់ផ្ទះរមែងកើតឡើង លំបាកសតិនឹងឃុំឃាត់បានទាន់ទី ដូចពោលហើយអំពីខាងដើម បើទោសៈកើតឡើងហើយ ញុំាងសាមគ្គីសេចក្តីព្រមព្រៀងឲ្យវិនាសទៅ នាំសេចក្តីក្តៅក្រហាយមកដល់ខ្លួន នឹងពួកគណៈ ដោយហេតុនោះ ពុទ្ធាទិបណ្ឌិតទ្រង់ត្រេកអរក្នុងសេចក្តីស្ងប់ ទើបទ្រង់ប្រដៅឲ្យជនតាំងខ្លួននៅក្នុងខន្តិធម៌ ឲ្យបេះអត់ធន់ចំពោះហេតុនោះៗ ដែលនាំឲ្យកើតទោសៈ ដើម្បីរក្សាខ្លួន នឹងអ្នកដទៃទាំងពីរចំណែក ។

**ការបែងចែកវត្ថុឲ្យអ្នកដទៃ** ជាកិច្ចសំខាន់ប្រការមួយរបស់ជនអ្នកនៅក្នុងពួកគណៈ ៗ ក្នុងត្រកូលមួយ ស្វាមីនឹងភរិយា មាតាបិតា នឹងបុត្រធីតា ត្រូវសង្គ្រោះគ្នា ដោយការឲ្យរបស់ទ្រព្យ, ញាតិនឹងញាតិ មិត្តនឹងមិត្ត ត្រូវយកចិត្តទុកដាក់ទៅវិញទៅមក ឲ្យនូវវត្ថុដែលជាឧបាយចងមេត្រី, តែការឲ្យយ៉ាងនេះចាត់ថាសង្គ្រោះ ៗ អ្នកមានអធ្យាស្រ័យផ្សព្វផ្សាយមេត្តាដល់មនុស្សទាល់ក្រ លះទ្រព្យសម្បត្តិរបស់ខ្លួនឲ្យដើម្បីទំនុកបំរុងដោយឋានៈ ដើម្បីឧបត្ថម្ភផងគ្នា ដូច្នេះហៅថាទានៈ ៗ មនុស្សទាំង

ឡាយកើតមកក្នុងលោកនេះ អំពើកម្មតាក់តែងឲ្យជាអ្នកមានប្រភេទផ្សេងគ្នា ពួកខ្លះទាល់ក្រ សូម្បីគ្រាន់តែរកចិញ្ចឹមជីវិតក៏បានដោយលំបាក មនុស្សខ្លះមិនធ្លាក់ខ្លួនដល់ទៅម្ល៉េះទេ ប៉ុន្តែតាំងខ្លួនឲ្យមួនមាំមិនកើត មនុស្សខ្លះជាសេដ្ឋីបរិបូណ៌ដោយទ្រព្យសម្បត្តិ សូម្បីក្នុងផ្លូវដទៃក៏នៅផ្សេងៗគ្នាទៀត ដូចមនុស្សពិការ ឬ មានកំឡាំង តែមនុស្សអម្បាលណោះ មានសុខមានទុក្ខមិនច្រើនតិចជាងគ្នា បណ្ឌិតពិចារណាឃើញដូច្នេះហើយ ទើបប្រដៅឲ្យចេះមានចិត្តអាណិតអាសូរដល់គ្នាទៅវិញទៅមក ដោយការឲ្យដែលហៅថា ទាន ។

ប្រជាជនទាំងឡាយ ជាអ្នកគ្រប់គ្រងផ្ទះ ចូរញុំាងធម៌ ៤ ប្រការនេះ ឲ្យលូតលាស់គ្រប់ពេល គង់បានសេចក្ដីសុខ ចំរើន ក្នុងត្រកូលគ្រួសារ របស់អ្នកតរៀងទៅ ។

ចូរអ្នកសាងធម៌នេះ ឲ្យបានកើតឡើងដូចពោលខាងដើម គង់នឹងបានចៀសវាងអំពីសេចក្ដីក្ដៅក្រហាយ មានតែសេចក្ដីសុខកាយ សុខចិត្ត រហូតតាំងពីលោកនេះទៅលោកខាងមុខ ។

សំដែងអំពីធម៌ សម្រាប់ឃរាវាស ៤ ប្រការ គឺ: សច្ចៈ ១, ទម្មៈ ១, ខន្តី ១, ចាគៈ ១ ចប់ដោយសេចក្ដីសង្ខេបតែប៉ុណ្ណេះ ឯង ។

ចប់

# លទ្ធិពុទ្ធសាសនា និង លទ្ធិប្រជាធិបតេយ្យ

ផ្សាយចេញពី

## ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ
## ក្រុងភ្នំពេញ

តាមដែលបានសង្កេតហ្មត់ចត់ ឃើញថា លទ្ធិពុទ្ធសាសនា ហើយនឹងលទ្ធិប្រជាធិបតេយ្យ មានរបៀបស្រដៀងគ្នាជាច្រើនអន្លើ ដូចបរិយាយដោយសង្ខេបតទៅនេះ :

លទ្ធិ តាមវចនានុក្រមខ្មែរ ប្រែថា "បែបបទ" ថា "ការនិយម ..." ។

លទ្ធិពុទ្ធសាសនា ប្រែថា "បែបបទជាពាក្យប្រដៅរបស់ព្រះពុទ្ធ" យកពុទ្ធវចនៈជាបាវចនា ។

លទ្ធិប្រជាធិបតេយ្យ ប្រែថា "បែបបទគ្រប់គ្រងរដ្ឋដោយយកមតិប្រជាជនជាធំ" ។

បែបបទពុទ្ធសាសនា ជាបែបបទខាងផ្លូវធម៌ ។ បែបបទនេះប្រើរបៀបគ្រប់គ្រងពុទ្ធសាសនិកមណ្ឌលដោយមានព្រះពុទ្ធជាអ្នកតាំងនីតិបញ្ញត្តិគឺព្រះពុទ្ធជាអ្នកតែងតាំងច្បាប់គ្រប់យ៉ាងផ្ទាល់ព្រះអង្គ ហើយទ្រង់ប្រទានអំណាចនីតិប្បដិបត្តិដល់ពុទ្ធសាវក, ពុទ្ធសាវកជាអ្នកកាន់នីតិប្បដិបត្តិ គឺជាអ្នកប្រតិបត្តិតាមច្បាប់ដែលព្រះពុទ្ធទ្រង់តែងតាំងប្រទាន

ឲ្យមក តែព្រះពុទ្ធមិនទ្រង់ប្រើអំណាចផ្តាច់ការទេ ទ្រង់បើកឱកាសឲ្យពុទ្ធសាវ័កយកច្បាប់ដែលព្រះអង្គទ្រង់តែងតាំងឡើងនោះ ទៅពិនិត្យពិសោធចំពោះៗខ្លួន; កាលបើពិនិត្យពិសោធទៅឃើញថា មានហេតុផលគប់គ្រាន់ល្មមជឿកាន់តាមបានក៏ជឿកាន់តាមទៅ, បើមានហេតុផលមិនគប់គ្រាន់ទេក៏លះបង់ចោលទៅចុះ ទ្រង់មិនបង្ខិតបង្ខំឡើយ ។ ពុទ្ធសាសនាប្រើរបៀបគប់គ្រងពុទ្ធសាសនិកមណ្ឌលដោយយកមតិឯកច្ឆន្ទរបស់ការកសង្ឃជាធំ ។ ដំបូងឡើយព្រះពុទ្ធទ្រង់បំបួសកុលបុត្រផ្ទាល់ព្រះអង្គ, ក្រោយមកទ្រង់ប្រទានមុខងារនេះឲ្យការកសង្ឃចាត់ការបំបួសដោយសង្ឃកម្មដែលមានកម្មវាចាជាគម្រប់ ៤ ទាំងញត្តិគឺពាក្យសំនូររបស់ភិក្ខុ ១ រូបថ្លែងចំពោះការកសង្ឃជាមុន ហើយទើបធ្វើការបំបួសតទៅ ។ សង្ឃកម្មឯទៀតៗ មានកឋិនសីមាជាដើមក៏ប្រើរបៀបញត្តិជាដំបូងទាំងអស់ ។

បែបបទប្រជាធិបតេយ្យ ជាបែបបទខាងផ្លូវលោក ។ បែបបទនេះមានច្រើនយ៉ាង តែពោលចំពោះបែបបទប្រជាធិបតេយ្យនៅកម្ពុជរដ្ឋយើងហៅថា "រាជប្រជាធិបតេយ្យ" ប្រែថា "បែបបទគប់គ្រងរដ្ឋដោយយកមតិប្រជាជនជាធំ, តែមានព្រះរាជាជាប្រមុខរដ្ឋ" ។ ប្រទេសខ្មែរយើងតាំងពីព្រេងនាយមកកាន់លទ្ធិរាជាធិបតេយ្យ ប្រែថា "បែបបទគប់គ្រងរដ្ឋដោយមានព្រះមតិព្រះរាជាជាធំ" កិច្ចការតែងតាំងច្បាប់

នីមួយៗ ស្រេចទៅព្រះរាជា ៗ ដល់មករដ្ឋកាលបច្ចុប្បន្នតាំងពីថ្ងៃ ទី ៦ ឧសភា គ.ស ១៩៤៧ មក ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានរដ្ឋធម្មនុញ្ញ លទ្ធិប្រជាធិបតេយ្យដល់ប្រជារាស្ត្រវិញ ឲ្យប្រជារាស្ត្រមានសិទ្ធិនិងសេរីភាពបរិបូណ៌ឲ្យប្រើរបៀបគ្រប់គ្រងរដ្ឋដោយរដ្ឋសភា គឺទីប្រជុំអ្នកតំណាងរាស្ត្រដែលរាស្ត្របោះឆ្នោតទុកចិត្តឲ្យជាអ្នកស្តីការរដ្ឋជំនួស យកមតិតំណាងរាស្ត្រភាគច្រើនជាប្រមាណ តែមានព្រះមហាក្សត្រជាប្រមុខ, រដ្ឋសភាជាអ្នកតែងច្បាប់គ្រប់យ៉ាង វេលាធ្វើច្បាប់ឯណាទីមួយតែងមានញត្តិ ជាពាក្យសមាជិករដ្ឋសភា ១ រូបថ្លែងជំរាបសភាតំណាងរាស្ត្រឲ្យជ្រាបទូទៅ. បើរដ្ឋសភាមានមតិព្រមព្រៀងគ្នាជាឯកច្ឆន្ទ ឬភាគច្រើនទើបទុកជាបានការ ហើយធ្វើច្បាប់នោះតទៅ; ប្រហែលគ្នានឹងពុទ្ធសាសនាដែលមុនដំបូងព្រះពុទ្ធទ្រង់បំបួសកុលបុត្តផ្ទាល់ព្រះអង្គ ក្រោយមកទ្រង់ប្រទានឲ្យការកសង្ឃបំបួស ដោយយកមតិជុំនុំសង្ឃជាធំ ៗ

វៃបបទពុទ្ធសាសនា មានគោលគ្រប់គ្រងពុទ្ធសាសនិកមណ្ឌល ៣ យ៉ាង គឺ:

១ - សីលសិក្ខា = ការសិក្សាផ្លូវកាយវាចាឲ្យរៀបរយ

២ - សមាធិសិក្ខា = ការសិក្សាផ្លូវចិត្តឲ្យស្ងប់រម្ងាប់

៣ - បញ្ញាសិក្ខា = ការសិក្សាផ្លូវបញ្ញាឲ្យដឹងពិត

ព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាទាំង ៣ នេះ ប្រទានឲ្យពុទ្ធសាវក, ពុទ្ធសាវកជាអ្នកប្រតិបត្តិសិក្ខាទាំង ៣ នេះ តាមដែលព្រះពុទ្ធទ្រង់បញ្ញត្តទុកមក ។

បែបបទប្រជាធិបតេយ្យ ក៏មានគោលគ្រប់គ្រងរដ្ឋ ៣ យ៉ាង គឺ

១– នីតិបញ្ញត្តិ = ការធ្វើច្បាប់

២– នីតិប្បដិបត្តិ = ការប្រើច្បាប់

៣– នីតិតុលាការ = ការថ្លឹងច្បាប់ ។

រដ្ឋសភាជាអ្នកកាន់អំណាចនីតិបញ្ញត្តិ គឺអ្នកធ្វើច្បាប់ដោយមានសភាក្រុមប្រឹក្សាព្រះរាជអាណាចក្រជាអ្នកបំពេញជាគូពិគ្រោះ ។ រាជរដ្ឋាភិបាលជាអ្នកកាន់អំណាចនីតិប្បដិបត្តិ គឺជាអ្នកយកច្បាប់ដែលសភាទាំងពីរព្រមព្រៀងអនុម័តហើយនោះទៅប្រើប្រាស់ ។ តុលាការជាន់ខ្ពស់ជាអ្នកកាន់អំណាចនីតិតុលាការ គឺអ្នកសម្រេចក្តីជាន់ខ្ពស់បំផុត ។

ធម៌វិន័យពុទ្ធសាសនាបានបញ្ញត្តនាយកធម៌ ជាច្បាប់សម្រាប់ឲ្យអ្នកកាន់តំណែងគ្រប់គ្រងរដ្ឋ គ្រប់គ្រងបរិស័ទ - គ្រប់គ្រងសិស្ស - គ្រប់គ្រងបុត្រធីតា ... ប្រតិបត្តិ, អភិសមាចារិកធម៌ ជាច្បាប់ស្តីអំពីកិរិយាមារយាទ សម្រាប់ឲ្យអ្នកត្រូវការសុជីវធម៌ ... ប្រតិបត្តិ, សង្គហធម៌ជាច្បាប់សង្គ្រោះគ្នាទៅវិញទៅមក សម្រាប់ឲ្យអ្នកនៅក្នុងសង្គមប្រតិបត្តិ -- ; ប្រដៅឲ្យមេត្តាដល់គ្នានឹងគ្នា ឲ្យមានសេរីភាពគ្រប់គ្នា មានសមភាព

ស្មើគ្នា មានភាតរភាពរាប់អានគ្នាដូចបងប្អូន ។ ធម្មតាមនុស្សកាលនៅជាគ្រហស្ថតែងប្រកាន់ត្រកូលទាបខ្ពស់, តែដល់មកបួសទៅជាមានសិទ្ធិសេរីភាពនិងករណីយកិច្ចស្មើគ្នា ឥតមានប្រកាន់ទាបខ្ពស់តាមឋានៈត្រកូលដែលធ្លាប់មានមកនោះទេ ដូចទឹកទន្លេស្ទឹងបឹងអូរដែលហូរចូលដល់មហាសមុទ្រ ។ តែងធ្វើឲ្យមានរសប្រៃតែម្យ៉ាងស្មើគ្នា ។

រដ្ឋធម្មនុញ្ញបែបបទប្រជាធិបតេយ្យ ក៏បានបើកឲ្យពលរដ្ឋមានសេរីភាព - សមភាព - ភាតរភាព - ស្មើគ្នាទាំងអស់ដូចគ្នា មិនឲ្យពលរដ្ឋប្រើអំណាចរំលោភលើសិទ្ធិនិងសេរីភាពរបស់គ្នានិងគ្នា ឲ្យគោរពសិទ្ធិនិងសេរីភាពរបស់គ្នាទៅវិញទៅមក ។

លទ្ធផលដែលពុទ្ធសាវ័កត្រូវបាន អំពីការកាន់តាមបែបបទពុទ្ធសាសនាមាន ៣ យ៉ាង គឺ ១- ប្រយោជន៍លោកនេះ ២- ប្រយោជន៍លោកមុខ ៣- ប្រយោជន៍ផុតចាកលោកគឺព្រះនិព្វានជាទីរលត់ទុក្ខ ។

លទ្ធផលដែលពលរដ្ឋត្រូវបាន អំពីការកាន់តាមបែបបទប្រជាធិបតេយ្យ ក៏មាន ៣ យ៉ាង គឺ ១ សិទ្ធិ ២- សេរីភាព ៣- ករណីយកិច្ចស្មើគ្នា ។

បានសង្កេតឃើញពិតថា ប្រជាជនជាតិខ្មែរគ្រប់រូបក្នុងកម្ពុជរដ្ឋទាំងមូលសុទ្ធតែបានកាន់ពុទ្ធសាសនា ប្លែកគ្នាតែតឹងធូរប៉ុណ្ណោះ ។

ដោយហេតុប្រទេសខ្មែរធ្លាប់កាន់លទ្ធិពុទ្ធសាសនា ដ៏មានរបៀបស្រដៀងគ្នានឹងលទ្ធិប្រជាធិបតេយ្យ តាំងពីព្រេងនាយមកស្រាប់ហើយ បានជាដល់លទ្ធិប្រជាធិបតេយ្យមកប្រតិសន្ធិក្នុងកម្ពុជរដ្ឋនេះ អំពី គ.ស. ១៩៤៧ មក ប្រជាជនជាតិខ្មែរទូទៅទាំងប្រទេសស្នេហាស្មោះចំពោះលទ្ធិនេះយ៉ាងខ្ជាប់ខ្ជួន ឥតរើកើបប្រែប្រួលទេ វិស័យដូចសិលាចារឹកដ៏មាំ ដែលដាំចុះក្នុងផែនប្រថពីដ៏ជ្រៅ ឥតមានលទ្ធិណាមួយក្រៅពីលទ្ធិពុទ្ធសាសនានឹងលទ្ធិប្រជាធិបតេយ្យអាចបំបែរចិត្តរបស់ខ្មែរ ឲ្យបែរទៅជាដទៃបានឡើយ ។

ចាប ពិន

ពុទ្ធសាសនាមានគោលបី ឲ្យជនប្រុសស្រីសេរីភាព
នឹងសមភាពភារតភាព ឥតខ្ពស់ឥតទាបរាប់អានគ្នា ។
លទ្ធិប្រជាធិបតេយ្យ ក៏មានគោលត្រៃដ៏សោភា
គឺភាពទាំងបីប្រហែលគ្នា យើងកម្ពុជាគួររាប់អាន ។

ប. ព.

ការបណ្ដុះធំស្វ័យ

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ បឹង-ប៊ុម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

---

**នាយចៅហ្វាយនឹងខ្ញុំកំដរ.—** នាយចៅហ្វាយដែលល្អតែងចាត់ចែងការងារ ឲ្យខ្ញុំកំដរធ្វើតាមសមគួរដល់កម្លាំង តែងឲ្យអាហារនឹងរង្វាន់ មិនចេះតែសង្កត់សង្កិនទេ ។ បើឃើញធ្វើល្អក៏លើកដម្កើងតាមសេចក្ដីល្អដែលគេធ្វើ យកចិត្តទុកដាក់រក្សាព្យាបាលក្នុងវេលាឈឺចាប់ មិនយកទុកសេប្រើ តែក្នុងពេលដែលគេសប្បាយ លុះដល់គ្នាឈឺមិនមើលថែរក្សាគ្នា, ចែករបស់មានរសឆ្ងាញ់ឬរបស់ដែលប្លែកត្រកាលឲ្យគ្នាបរិភោគ ដើម្បីនឹងសំដែងអធ្យាស្រ័យទឹកចិត្តទូលំទូលាយ ឧបអរ សាទរ មេត្តា ករុណា ក៏បានអនុញ្ញាតឲ្យគ្នាឈប់សំរាកក្នុងសម័យដ៏គួរ ដូចជាក្នុងទេសៈកាលៈ នក្ខត្តឫក្ស មានបុណ្យចូលឆ្នាំជាដើម ។

បាវព្រាវដែលល្អ កាលបានទទួលការអនុគ្រោះអំពីនាយចៅហ្វាយដូច្នេះហើយ ត្រូវប្រតិបត្តិឲ្យត្រឹមត្រូវក្នុងនាយចៅហ្វាយ គឺត្រូវមានសេចក្ដីស្រឡាញ់ ដឹងគុណលោកដែលខ្លួនពឹងអាស្រ័យ តាំងចិត្តធ្វើការងារឲ្យជាកិច្ចគបស្នួន គឺក្រោកឡើងធ្វើការងារមុននាយចៅហ្វាយ

ប្រញាប់ប្រញាល់តាត់តែងធ្វើការងារឲ្យរៀបរយ ដោយមិនបាច់ដាស់តឿន មិនមែនជាមនុស្សខ្ជិលច្រអូសវៀចវេរគេចវេះ គឺត្រូវឈប់ធ្វើការងារនៅមុខនាយចៅហ្វាយ .មិនលបឈប់ក្នុងទីកំបាំងមុខ មិនធ្វើការងារយកមុខ ធ្វើការស្មោះស្មើទាំងចំពោះមុខ ទាំងកំបាំងមុខ កាន់យកតែរបស់ដែលនាយឲ្យ មិនជាមនុស្សខូចដៃ ចិត្តកិតកុក បិទបាំង លួចលាក់ក្បត់ករលួចយករបស់នាយចៅហ្វាយ ស្មោះត្រង់ចំពោះនាយពិតៗ ជាទីទុកចិត្តរបស់នាយបាន ខំធ្វើការងារឲ្យរឹតតែល្អឡើង មិនឲ្យនាយតិះដៀលបានៈព្រោះធ្វើមិនពិត ទឹង នាំសេចក្តីល្អរបស់នាយទៅសរសើរក្នុងទីនោះៗ ដែលជាហេតុធ្វើឲ្យនាយមានមុខមាត់ឡើង ។

អ្នកដែលជានាយចៅហ្វាយគេ គួរសំដែងកិរិយាពាចាទឹងទឹកចិត្តចំពោះអ្នកដទៃ ឲ្យដូចជាខ្លួនប្រាថ្នាឲ្យអ្នកដទៃធ្វើមកចំពោះខ្លួនក្នុងកាលដែលខ្លួនជាបាវព្រាវគេដូច្នោះ ។ គប្បីជ្រាបថា លោកអ្នកគ្រប់គ្រងបាវព្រាវដោយអំណាចជាធំ តទល់នឹងការគ្រប់គ្រងដោយអំណាចហេតុផលមិនបានឡើយ ។ ព្រោះការធ្វើឲ្យមនុស្សគោរពដោយអំណាច អ្នកដែលប្រតិបត្តិតាមមិនដែលធ្វើដោយចិត្តពិតៗទេ ។ លុះតែការគ្រប់គ្រងធ្វើឲ្យមនុស្សគោរពដោយគុណគឺសេចក្តីល្អ ទើបអ្នកដែលធ្វើតាមតបស្នងមកវិញដោយសេចក្តីជ្រះថ្លា ។ ហេតុនេះ នាយចៅហ្វាយ ទើបមិនត្រូវព្រងើយកន្តើយចំពោះការងារ ដែលបាវព្រាវធ្វើស្រេចហើយ

នោះឡើយ គួរធ្វើឲ្យគ្នារីករាយចិត្តដោយរង្វាន់ ដោយទឹកចិត្ត ដោយវាចា និងដោយការប្រើភ្នែកក្រឡេកមើលដោយក្រសែគួរឲ្យស្រឡាញ់កុំខាន ។ បុរាណពោលថា "ប្រើមិនមើលវេលា, កុហកក្លួតករទើង កំណាញ់រង្វាន់" អង្គទាំងនេះ មនុស្សមានគំនិត ល្មមចូលចិត្តបានថាជាលក្ខណៈនៃនាយដែលចិត្តអាក្រក់ ។ នាយដែលប្រកបដោយសេចក្ដីអត់ធន់ មានចិត្តឧបអារសាទរ មេត្តាករុណា និងស្គាល់គុណគឺសេចក្ដីល្អនេះជាដោគល្អនៃបាវពិតៗ ។ បាវអាចទទួលបំរើយ៉ាងស្មោះត្រង់ សូម្បីដល់ជីវិត ក៏អាចលះបង់ដើម្បីនាយបាន ។ នាយចៅហ្វាយបែបនេះ សូម្បីវាយដំឡៃខ្លួនខ្លាំងពេក ក៏គង់តែគេរាប់ថាត្រូវដែរ ។ "អ្នកនៅស្ងៀមគេថាល្ងង់, អ្នកនិយាយច្រើនគេថាញ៉ោះញ៉ង់បាក់រុក, អ្នកគោរពឧទលំទោនគេថាផ្គាប់ផ្គុន, អ្នកព្រងើយកន្តើយគេថារឹងត្អឹង, អ្នកនៅជិតគេថាបង្ខំ, អ្នកនៅឆ្ងាយតែបន្តិច គេថារកហៅប្រើមិនទាន់ចិត្ត ឱ! អនិច្ចាអើយ បើនាយប៉ះកទាបអាក្រក់ហើយ នាទីរបស់បាវព្រាវត្រូវតែយ៉ាងនេះជានិច្ច" ។

បើយើងបានប្រតិបត្តិត្រឹមត្រូវ ចំពោះគ្នានិងគ្នាដូចពោលមកហើយ ហៅថាជាអ្នកសុចរិតក្នុងបុគ្គល ។ គ្រួសារណា ពួកគណៈណា មិនប្រព្រឹត្តឲ្យត្រឹមត្រូវចំពោះគ្នានិងគ្នាដូច្នេះ គ្រួសារនោះ ពួកគណៈនោះ បាក់ជាមនុស្សទុច្ចរិតចំពោះគ្នា មិនស្រឡាញ់គ្នា មិនស្តាប់គ្នា មិនយក

ចិត្តគ្នា មិនថយរក្សាទឹកចិត្តគ្នា បង្កវិវាទទាស់ទែងប្រកួតប្រកាន់គ្នាដោយហេតុបន្តិចបន្តួច ដែលកឲ្យកើតសេចក្ដីក្ដៅក្រហាយអាក់អន់ទឹងការព្រងើយកន្តើយទ្រមឹងទ្រមើយ បំពោះគ្នានឹងគ្នា មិនជាទីតាំងនៃសុខសម្រាន្ត ។ ការចូលចិត្តខុសត្រឹមតែបន្តិចបន្តួច អាចជាធ្នួនកឲ្យកើតទៅជាពាក្យតាក់ដោតប្រមាថមើលងាយគ្នា រហូតដល់ទៅប្រើដៃប្រើជើងប្រើដំបងកាំយសំពងគ្នាយ៉ាងវឹកវរ រហូតដល់ទៅចាប់សស្ត្រាវុធចូលប្រហារគ្នាឲ្យបានក្ដៅក្រហាយទូទៅទាំងប្រទេស ៗ

សូមលោកអ្នកអញ្ជើញមកចុះ! មកគោរពរាប់អានសេចក្ដីស្មោះត្រង់បំពោះគ្នា មករួមគ្នា មកព្រមព្រៀងគ្នា មកធ្វើសេចក្ដីគោរពរកគ្នា មកជួយបន្ធូរបន្ថយរឿងក្រវល់ក្រវាយផ្សេងៗ មកឲ្យអភ័យដល់គ្នាកុំប្រកាន់តូចប្រកាន់ធំ នឹងមកជួយផ្សាយសាមគ្គីធម៌ កុំឲ្យបែកបាក់ចាកគ្នា ៗ បើយើងប្រតិបត្តិបានដូច្នេះហើយ ក៏នឹងឃើញច្បាស់ថា ស្រុកយើងរមែងជាទីសម្រាប់បំបាត់សេចក្ដីទុក្ខលំបាកវេទនា ឬ សេចក្ដីក្ដៅក្រហាយក្រវល់ក្រវាយចិត្តមកអំពីមុន នឹងរមែងជាទីរម្ងាប់អារម្មណ៍ក្នុងកាលដែលកំពុងធ្វើកិច្ចធុរៈនឿយហត់ ទាំងជាទីទំនុកបំរុងចិត្តឲ្យមានកម្លាំង តស៊ូបំពោះសេចក្ដីនឿយហត់ទៅខាងមុខទៀត ៗ

៣— សុបរិតក្នុងការអាជីវ.— ទុសថចំណានឯកសម្រាប់ចិញ្ចឹមជីវិតឲ្យជាសុខក្នុងលោកនេះ ដែលមាននៅពាសពេញទូទៅមិនលំបាករក

ហើយនៅជិតខាងយើង តែជាសរសៃសក់ប៉ុនក្តី មនុស្សយើងមើលមិនឃើញនោះ គឺការអាជីវៈត្រឹមត្រូវ ។ ការអាជីវៈត្រឹមត្រូវនេះជាថ្នាំត្រជាក់កែរោគក្តៅ ធ្វើឲ្យបានសេចក្តីសុខសប្បាយចិត្ត ទាំងក្នុងខណៈដែលប្រកប ទាំងក្នុងខណៈដែលបានមក ទាំងក្នុងខណៈដែលបរិភោគ ទាំងក្នុងខណៈដែលបរិភោគរួចហើយ ។ ការអាជីវៈត្រឹមត្រូវ រមែងសំដែងការប្រុងប្រៀបព្រមនៃសេចក្តីត្រជាក់ចិត្ត ។ ផលដែលអ្នកប្រកបត្រូវបានទទួល គឺសន្តិសុខ ។ ឯអាជីវៈខុស ជាដើមផ្លូវនាំមកនូវជីវិតសៅហ្មង ការប្រកបអាជីវៈខុស រមែងសំដែងសេចក្តីប្រុងប្រៀបព្រមនៃការបណ្តុះបន្ទា គឺសេចក្តីក្តៅក្រហាយឡើង ឲ្យមុតដួងចិត្តក្នុងខណៈជាមួយគ្នានឹងអ្នកប្រកប ឈ្មោះថាកាត់ខ្លួនឯងដោយដាវគឺទោស ។ ចិត្តដែលត្រូវដាវគឺទោសកាត់កំទេចហើយ ឥតមានឱសថអ្វីនឹងរក្សាបានឡើយ ។ បើលះបង់អាជីវៈខុសចេញហើយប្រកបអាជីវៈត្រឹមត្រូវវិញ អាជីវៈត្រឹមត្រូវនេះនឹងទៅជាមហាឱសថ កែការប្រហារនៃទោសនោះបាន ។

អ្នកវៀរចាកការចិញ្ចឹមជីវិតក្នុងផ្លូវទុច្ចរិត ប្រឹងប្រែងព្យាយាមរកចិញ្ចឹមជីវិតក្នុងផ្លូវសុចរិតត្រឹមត្រូវតាមសីលធម៌និងច្បាប់ទំលាប់ផែនដី មិនបៀតបៀនដណ្តើមសុខបង្ខូចដល់គេដើម្បីសេចក្តីសុខដល់ខ្លួន នេះចាត់ជាសុចរិតក្នុងការអាជីវៈ ។ ការងារដែលយើងធ្វើមិនដឹងច្បាស់ គឺការ

ងាររកទទួលបាន ។ បើការងាររកទទួលបានជាការងារត្រឹមត្រូវ អ្នកធ្វើៈឈ្មោះថាសន្សំរបស់ល្អទុក មិនជាអ្វី តែបើការរកទទួលបាន ជាការអាជីវៈខុស អ្នកធ្វើប៉ុនគ្នានឹងដាក់ថ្នាំពិសទុកក្នុងខ្លួន ប្រយ័ត្នតែដល់ពេលពន្លកពិស កើតឡើងឈ្មោះនឹងត្រូវស្អុយគគ្រុក ៗ មើលចុះ មនុស្សដែលបរិភោគអាហារកក្រក់ចូលទៅដូចម្តេច អ្នកដែលចិញ្ចឹមជីវិតខុសក៏ដូច្នោះដែរ ៗ អាជីវៈខុស រមែងនៅត្រង់ការបៀតបៀនទ្រព្យសម្បត្តិរបស់អ្នកដទៃដោយចោរកម្ម ចិញ្ចឹមជីវិតអនុលោមតាមចោរកម្មនឹងកិរិយាជាឆាយានៃចោរកម្ម ដែលអ្នកសុចរិតក្នុងអាជីវៈបានសំឡឹងឃើញហើយ គួរវៀរចេញយ៉ាងដាច់ខាត ៗ

ចោរកម្ម សំដៅយកការកាន់យកទ្រព្យសម្បត្តិ ដែលម្ចាស់របស់មិនបានឲ្យ ដោយអាការជាចោរគឺលាក់ឆក់បញ្ឆោត ប្លន់ បង្កាចបង្កិនបោកប្រាស លលួង ក្លែងក្លាយបន្លំ បិទបាំង ប្រវញ្ចន៍ លបលួចដណ្តើម ដោយធ្វើខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ; សូម្បីចូលដៃ រួមគំនិត រួមពួកទៅធ្វើជាមួយគ្នាក៏ឈ្មោះថាប្រព្រឹត្តជាចោរ ៗ

ការស្វែងរកទ្រព្យសម្បត្តិក្នុងផ្លូវមិនបរិសុទ្ធ ដូចជាសមគំនិតនឹងចោរដោយការទទួលទិញរបស់ចោរ ប្រាប់កន្លែងទ្រព្យឲ្យទីអាស្រ័យដល់ចោរសេពគប់គ្នាជាមិត្តសំឡាញ់ លាក់ចោរទុក ជួយការពារចោរមិនឲ្យរដ្ឋាភិបាលចាប់ភស្តុតាងបានជាដើមក្តី, ការមានមាយាសាថេយ្យ

ដូចជាលោកប៉ាំងបុរសស្ត្រីដែលប្រព្រឹត្តខុសប្រវេណី ដោយអាការមិនស្មោះត្រង់ ឃើញតែប្រយោជន៍ផ្ទាល់ខ្លួន បំណងតែក្នុងការបានសម្បត្តិរបស់គេ១ចំណែក ឲ្យគេតិចចង់បានច្រើនជាដើមក្តី, ការទទួលសំណូកមានទទួលទ្រព្យរបស់គេហើយជួយធ្វើធុរៈឲ្យគេក្នុងផ្លូវខុសជាដើមក្តី, ការសមគំនិតនឹងចោរ, ការមានមាយាថេយ្យនឹងការទទួលសំណូកទាំង ៣ យ៉ាងនេះឈ្មោះថាការចិញ្ចឹមជីវិតអនុលោមតាមចោរកម្ម ជាហេតុឲ្យកើតចោរអ្នកប្រទូសរ៉ាយកុះករឡើង ១ យ៉ាង ជាហេតុឲ្យខ្លួនធ្លាក់ទៅក្នុងសេចក្តីទុក្ខលំបាកតោកយ៉ាក ១ យ៉ាង ជាហេតុឲ្យពួកមនុស្សមិនតាំងនៅក្នុងទំនងនៃគន្លងធម៌១យ៉ាង ។ ការធ្វើទ្រព្យសម្បត្តិរបស់អ្នកដទៃឲ្យសូន្យ ឬឲ្យជារបស់ធ្លាក់មកនៅក្នុងកណ្តាប់ដៃខ្លួន ដូចជាបំផ្លាញមានលបដុតផ្ទះ សម្លាប់សត្វពាហនៈ កាប់ដើមឈើក្នុងចំការរបស់គេក្នុងកាលដែលខ្លួនខឹងនឹងគេ តែគ្មានឱកាសនឹងប្រទូសរ៉ាយខ្លួនគេបានជាដើមក្តី, ការកាន់យកៈ មានការកាន់យកទ្រព្យសម្បត្តិរបស់អ្នកដទៃដោយអាការៈមើលងាយដូចជាកូនចៅកាន់យកទ្រព្យសម្បត្តិរបស់ជីដូនជីតា ឪពុកម្តាយមាមីង ឬមិត្តយកទ្រព្យរបស់មិត្តទៅប្រើ ដោយមិនប្រាប់ឲ្យម្ចាស់របស់ដឹងជាដើមក្តី, ទាំងពីរបែបនេះឈ្មោះថាកិរិយាជាឆាយានៃចោរកម្ម ។

# រឿងសាមកុក

## កណ្ឌទី ១៤

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នករាជការធ្វើទាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្ដានស្នេហាជាតិ ។

ចាប់តាំងពីអ៊ួនសុតមិនព្រមឲ្យត្រាទៅស៊ុនសិក ហើយ ប៉ឹក្សារកហេតុរកទំនងនឹងទៅវាយស៊ុនសិក រហូតដល់ចួធ្ចូលើកទ័ពទៅច្បាំងនឹងតៀវស៊ីវ ៗ ទទួលចំណុះចុះចូលចាញ់ចួធ្ចូ ។

---

ឯអ៊ួនសុតនោះតាំងពីដើមពីបានត្រាផ្ទាក់មកទុក ក៏គិតនឹងតាំងខ្លួនជាស្ដេចជានិច្ច លុះឃើញបំរើស៊ុនសិកទៅទារត្រា ក៏ប្រកែកមិនព្រមឲ្យ ៗ ទាហានបំរើក៏លាត្រឡប់មកវិញ យកសេចក្ដីនោះជំរាបស៊ុនសិកគ្រប់ប្រការ ។

ខណៈនោះអ៊ួនសុតឲ្យហៅ អៀវកៃជៀង, តៀវហ៊ុន, គីឡេង, តៀវសេង, លុយប៉ុក, តាន់ឡាន់ នឹងទាហានទាំងពួងមកប្រឹក្សាគ្នាថាស៊ុនសិកនោះកាលពីដើមបាននៅធ្វើការនឹងយើង ៗ ក៏បានទំនុកបំរុងឲ្យធ្វើ

ជាអាហ៊ីន ហើយសុំអាហារយើងថានឹងជួយមាខ្លួនដើម្បីនឹងសងបិតា យើងក៏ព្រមឲ្យ ស៊ុនសិកបានប្រស័យពីកំឡាំងយើងជាមុន ទើបតាំងខ្លួនឡើងដល់ប៉ុណ្ណេះ ឥឡូវស៊ុនសិកបានធ្វើធំក្នុងត្រើយមាត់ទន្លេស្រុកកាំងតាំង ត្រឡប់រមិលគុណយើង ប្រើបំរើអាហារឲ្យមកទារយកត្រាធ្លាក់ អ្នកទាំងអស់នឹងយល់ដូចម្ដេច ឲ្យយើងបានខ្លួនស៊ុនសិកមកវិញ ? ។

អៀវតៃជៀងឆ្លើយថា ស៊ុនសិកបានគ្រប់គ្រងត្រើយទន្លេស្រុកកាំងតាំងហើយ បានអាហារដែលមានចូវដៃខាំងតូកែកក៏ច្រើន ឯដែនស្រុកកាំងតាំងនោះសោត ក៏ធំទូលាយជាងស្រុកយើងទៅទៀត បើយើងនឹងលើកទ័ពទៅតតាំងក៏មិនបាន សុំឲ្យលោកលើកទ័ពទៅវាយឡៅពីឲ្យបែកសិន បើបានឈ្នះឡៅពីហើយស៊ុនសិកក៏ត្រូវនៅក្នុងកណ្ដាប់ដៃយើង ។

អ៊ួនស៊ុតតបថា ឡៅពីតាំងទ័ពនៅតំបន់ស្រុកសៀវផាយ ជិតស្រុកឈីជីវដែលលីប៉ោនៅនោះ អ្នកទាំង ២ ក៏ត្រូវអធ្យាស្រ័យគ្នា ទោះបីយ៉ាងណា លីប៉ោក៏គង់លើកទ័ពមកជួយឡៅពី ឃើញថាកំឡាំងឡៅពីនឹងមាំឡើង យើងនឹងធ្វើការគង់មិនសម្រេច បើដូច្នេះត្រូវតែយើងរិះគិតឧបាយបញ្ចុះបញ្ចូលលីប៉ោឲ្យត្រូវជើងនឹងយើងសិន ។ និយាយហើយអ៊ួនស៊ុតក៏ចាត់សំបុត្រឲ្យហាន់អ៊ុនជាបំរើនាំយកស្រូវ ២០ ម៉ឺនថាំង ទៅឲ្យលីប៉ោ ។ សេចក្ដីសំបុត្រនោះថា ឡៅពីជាមនុស្សអាក្រក់គ្មានសេចក្ដីសត្យ យើងត្រូវកំចាត់ឡៅពីចេញ បើប្រសិនឡៅពីមកពឹងកំឡាំងអ្នកៗ ក៏កុំជួយជាធុរៈឡើយ ។

ឯលីប៉ោកាលបានទទួលសំបុត្រ នឹងរបស់គំនាប់ពីអ៊ុនស៊ុតបញ្ជូនទៅក៏ពេញចិត្តណាស់ ទទួលតាមពាក្យអ៊ុនសុតគ្រប់ប្រការ ។ ហានអ៊ុនក៏លាលីប៉ោត្រឡប់ទៅស្រុកឡាំយ៉ុងវិញ នាំយកសេចក្ដីនោះទៅជំរាបអ៊ុនស៊ុតគ្រប់ប្រការ អ៊ុនស៊ុតក៏ចាត់ប្រើគីឡេងជាមេទ័ពលើកទាហាន ៥ ម៉ឺនទៅជាមួយនឹងលុយប៉ុក, តាន់ឡាន់ ទៅស្រុកសៀវផាយ ។

ឡេពីជីងហើយក៏ប្រឹក្សានឹងគួនអ៊ូ, តៀវហ៊ុយ, ស៊ុនខៀនថា ឥឡូវអ៊ុនស៊ុតឲ្យគីឡេងលើកទ័ពមកច្បាំងនឹងយើង តើយើងនឹងគិតដូចម្ដេច? ។ ស៊ុនខៀនឆ្លើយថា ស្រុកសៀវផាយជាស្រុកតូចណាស់ ឃើញថានឹងតទល់នឹងគេមិនបានទេ សុំឲ្យលោកចេញសំបុត្រទៅនិយាយនឹងលីប៉ោឲ្យលើកទ័ពមកជួយ ។ តៀវហ៊ុយឆ្លើយថា លោកនឹងសង្ឃឹមយកលីប៉ោមកធ្វើជាគ្នាមិនបានទេ ទោះបីយ៉ាងណាក៏លីប៉ោមិនមកជួយយើងដែរ ។ ឡេពីតបថា "ដែលអ្នកថានេះគួរហើយ តែយើងត្រូវធ្វើតាមពាក្យស៊ុនខៀនល្បងចិត្តលីប៉ោមើលសិន" ហើយក៏ប្រើទាហានកាន់សំបុត្រទៅដល់លីប៉ោថា "ខ្ញុំឡេពីនឹងស្ម័គ្របក្សពួកទាំងអស់ បានមកតាំងនៅក្នុងស្រុកសៀវផាយនេះបានសេចក្ដីសុខសប្បាយ ក៏ព្រោះបុណ្យគុណរបស់អ្នកជួយឃុំគ្រងជាទីពឹង ឥឡូវអ៊ុនស៊ុតឲ្យទាហានលើកទ័ពមកច្បាំងនឹងខ្ញុំ ។ សំឡឹងមើលមិនឃើញអ្នកឯណានឹងជួយធុរៈខ្ញុំក្នុងរឿងនេះបាន ឃើញតែអ្នកនឹងជួយទុក្ខខ្ញុំបាន ហេតុនេះសុំឲ្យអ្នកលើកកងទ័ពទៅជួយខ្ញុំ" ។

លីប៉ោបានទទួលសំបុត្រហើយក៏ពិគ្រោះនឹងគាន់កុងថា ពីដើមអ៊ូនសុតឲ្យសំបុត្រនឹងស្បៀងមកដល់យើង ដើម្បីកុំឲ្យយើងលើកទ័ពទៅជួយឡៅពី យើងក៏បានទទួលពាក្យប្តេជ្ញាជាប្រាកដ ឥឡូវឡៅពីក៏មានសំបុត្រមកយើងដែរ ថាឲ្យលើកទ័ពទៅជួយ យើងគិតថា ឡៅពីនៅក្នុងស្រុកសៀវផាយជិតយើង បើទោះបីយ៉ាងណាក៏មិនធ្វើអន្តរាយដល់យើងទៅមុខទៀត ឯខាងអ៊ូនសុតវិញ ប្រសិនបើយើងជួយវាយបានស្រុកសៀវផាយហើយ យើងប្រះក្បាលដល់ខ្នើយដេកមិនបានជាប្រក្រតី គង់តែអ៊ូនសុតនឹងកំរើកចិត្តលើកទ័ពឆ្លងមកវាយស្រុកយើងទៀតមិនខាន បើដូច្នេះ គួរតែយើងចូលជួយខាងឡៅពីវិញស្រួលជាង ។ គាន់កុងស្តាប់យល់ត្រូវនឹងគំនិត ក៏រួមគ្នាកេណ្ឌកងទ័ពលើកទៅជួយឡៅពីក្នុងខណៈនោះ ។

លុះគីឡេងលើកទ័ពមកដល់ស្រុកសៀវផាយ ក៏តាំងបន្ទាយបោះទ័ពនៅខាងទិសឯត្បូង ។ ឡៅពីមានទាហានក្នុងស្រុកប្រហែល ៥ ពាន់ ដឹងថាគីឡេងលើកទ័ពមកដល់ទីកំពែងហើយ ក៏ប្រុងប្រៀបរៀបសេះទាហានមានគ្រឿងសស្ត្រាវុធព្រមប្រចាំការ ។ គីឡេងស៊ើបដំណឹងច្បាស់ថា លីប៉ោលើកទ័ពទៅជួយខាងឡៅពីវិញ ក៏ប្រើទាហានទៅសួរលីប៉ោថា ពីដើមអ្នកបានទទួលពាក្យប្តេជ្ញានឹងចៅហ្វាយយើងថា មិនជួយឡៅពីទេ ឥឡូវហេតុម្តេចអ្នកលើកទ័ពចូលទៅខាងណោះវិញ ។

លីប៉ោស្តាប់ដូច្នោះក៏ឯអន់ ហើយតបថា យើងនឹងគិតត្រិះរិះឲ្យអ្នកស្រុក នឹងឡៅពីធ្វើមេត្រីនឹងគ្នា លើកលែងអាឃាដព្យាបាទគ្នាតទៅ ត្រូវខ្លួនវិលទៅប្រាប់គីឡេងឲ្យចូលមកជួបនឹងយើងឥឡូវនេះ ៗ តាហានក៏លាលីប៉ោទៅប្រាប់គីឡេងតាមការ ៗ លីប៉ោក៏ប្រើតាហានទៅអញ្ជើញឡៅពីឲ្យចូលមកទៀត ៗ គួនអ៊ូ, តៀវហ៊ុយនិយាយនឹងឡៅពីថា លីប៉ោនឹងអ្នកស្រុកគប់គិតត្រូវគំនិតគ្នាមកពីដើម ក្រែងឲ្យហៅទៅធ្វើអន្តរាយយើងទេដឹង ៗ ឡៅពីតបថា "យើងមានគុណនឹងលីប៉ោច្រើនណាស់ បើយ៉ាងណាក៏លីប៉ោមិនមែនធ្វើបទអាក្រក់នឹងយើងទេ" ថាហើយក៏ឡើងសេះទៅរកលីប៉ោក្នុងខណៈនោះ ៗ គួនអ៊ូ, តៀវហ៊ុយក៏តាមជាប់ទៅជាមួយ ៗ លុះឡៅពីទៅដល់បន្ទាយ លីប៉ោក៏ចេញមកទទួលហើយនិយាយថា គ្រានេះខ្ញុំនឹងជួយអ្នកឲ្យផុតអំពីភ័យអន្តរាយ អំណើះតទៅអ្នកកុំត្រូវភ្លេចគុណយើងឡើយ ៗ ឡៅពីក៏ចាប់ដៃលីប៉ោចូលទៅក្នុងអង្គុយជាមួយគ្នា ៗ គួនអ៊ូ, តៀវហ៊ុយក៏កាន់ក្រប៊ីចូលតាមទៅឈរពីក្រោយខ្នងឡៅពី ទទួលគីឡេងទៅដល់ទៀត មានបំរើចូលទៅប្រាប់លីប៉ោ ៗ ឡៅពីឮដូច្នោះក៏ភ័យស្លុតគិតថាលីប៉ោនឹងធ្វើអន្តរាយ ៗ លីប៉ោដឹងអធ្យាស្រ័យក៏ស្រដីថា អ្នកកុំភ័យបារម្ភ ដែលខ្ញុំឲ្យអញ្ជើញមកនេះ ប្រាថ្នាឲ្យល្អនឹងគ្នាទាំងសងខាង ៗ ឡៅពីក៏នៅតែមិនអស់សង្ស័យ ៗ

គីឡេងក៏ដើរចូលទៅ ឃើញលីប៉ោនឹងឡៅតីអង្គុយជិតគ្នាក៏ភ័យស្លុតស្មារតី រំពៃថយក្រោយទៅរកទាហាន ។ លីប៉ោក៏ក្រោកទៅឃាត់ហើយចាប់ដឹកដៃឲ្យចូលទៅអង្គុយលើកៅអីជាមួយគ្នា ។ គីឡេងនិយាយថាអ្នកគិតការដូច្នេះ នឹងចង់សម្លាប់ខ្ញុំទេឬ ។ សម្លាប់អាឡៅតីត្រចៀកឃារ ។ លីប៉ោឆ្លើយថា ខ្ញុំមិនមែនគិតធ្វើអន្តរាយដល់អ្នកទាំង ២ ទេ ព្រោះឡៅតីនឹងខ្ញុំដូចជាបងប្អូនបង្កើត ឥឡូវអ្នកលើកទ័ពមកធ្វើអន្តរាយដល់ឡៅតីបានជាខ្ញុំលើកទ័ពមកជួយ ។ គីឡេងតបថា បើដូច្នោះអ្នកមិនចាំសម្លាប់ខ្ញុំទេឬ? បើចង់ឲ្យឡៅតីបានសេចក្ដីសុខ ។ លីប៉ោថា "ខ្ញុំគិតនឹងឲ្យអ្នកទាំង២បានជាមិត្រមេត្រីនឹងគ្នា ដើម្បីប្រយោជន៍នឹងមិនឲ្យរាស្ត្រប្រជាបានសេចក្ដីលំបាក" ថាហើយក៏ទាញដៃគីឡេងឲ្យអង្គុយជិតឡៅតី ។ លីប៉ោក៏ដែកអង្គុយកណ្ដាលបបួលគ្នាផឹកស្រា ហើយនិយាយលួងលោមថា អ្នកទាំង២បានមកឃើញមុខខ្ញុំវេលានេះ ខ្ញុំសុំកុំឲ្យមានចិត្តអាឃាតព្យាបាទគ្នាទៅទៀត ។ ឡៅតីក៏ស្ងៀម គីឡេងឆ្លើយថា ខ្ញុំជាបំរើអ៊ួនសុត ប្រើខ្ញុំឲ្យមកចាប់ខ្លួនឡៅតីយកទៅ បើខ្ញុំត្រឡប់ទៅវិញទទេ ខ្ញុំក៏មិនរួចពីកំហុស ។

តៀវហ៊ុយ ខឹងណាស់ ហូតក្រប៊ីឡើងកាន់ហើយស្រែកគំហក ថាអ្នកឯងមិនត្រូវមើលងាយយើងៗ មិនមែនកូនក្មេងទេ សូម្បីពួកចោរដួតក្បាលលឿងពីគ្រាជាន់មុន ម្ដេចក៏មិនអាចមើលងាយបងអញដែរ ។

គួនអ៊ូឃើញគៀវហើយឡូឡាខ្លាចក្រែងកើតវិការក៏និយាយឃាត់ថា ចាំ-ស្តាប់ទំនងលីប៉ោ"សិននឹងនិយាយបានការដូចម្តេច បើកាលណាមិនស្រុះស្រួលគ្នាសុំយើងធ្វើជាក្រោយ លីប៉ោ"ឃើញអាការដូច្នោះក៏និយាយថា " ខ្ញុំឲ្យអញ្ជើញអ្នកទាំងពីរមកជួបនិយាយសំរួសម្រួលឲ្យល្អ នឹងគ្នាទាំងសងខាង គ្រានេះគីឡេងគេនៅស្ងៀមហើយ ហេតុម្តេចគៀវហើយមកនិយាយទ្រគោះដូច្នេះ មិនទុកមុខឲ្យខ្ញុំដែលជាធំផង " ថាហើយក៏ធ្វើជាខឹងចាប់ទួនឡើងកាន់ឈរកណ្តាលទីជំនុំនោះ ។ គីឡេងនឹងឡេវពីឃើញដូច្នោះក៏គិតថា លីប៉ោ"នឹងធ្វើអន្តរាយ ។ លីប៉ោក៏ហៅទាហានឲ្យយកទួនទៅដោតបញ្ឈរទុកពីចម្ងាយ ប្រហែល ២ សិន (២០ម.) ហើយថា ខ្ញុំនឹងបួងឲ្យជាក់ច្បាស់ដល់ទេពតាទាំងឡាយលោកជួយគិតចុះ បើប្រសិនខ្ញុំបាញ់ធ្នូទៅមិនត្រូវចុងទួនទេ សុំឲ្យអ្នកទាំង ២ ធ្វើសង្គ្រាមនឹងគ្នាតាមការចុះ បើខ្ញុំបាញ់ត្រូវវិញ ឲ្យអ្នកទាំង ២ លើកទ័ពត្រឡប់ទៅតាមពាក្យខ្ញុំឥឡូវនេះ បើខាងណាមិនស្តាប់ខ្ញុំៗ នឹងធ្វើសង្គ្រាមតនឹងអ្នកនោះ ។

គីឡេងបានឮលីប៉ោ"ប្រកាសដូច្នោះមានសេចក្តីត្រេកអរណាស់ គិតក្នុងចិត្តថា កាលណាឡើយលីប៉ោ"នឹងបាញ់ទៅត្រូវចុងទួននោះ ឥឡូវអញទទួលពាក្យទុកតែតាមគួរទៅចុះ បើលីប៉ោ"បាញ់មិនត្រូវហើយ អញនឹងបានធ្វើការសង្គ្រាមនឹងឡេវពីដោយងាយ លីប៉ោ"ក៏ជួយឡេវពីមិន

កើត” គិតហើយក៏ព្រមទទួលពាក្យនឹងលីហ៊ៅគ្រប់ប្រការ ៗ លីហ៊ៅបបួលឡៅពីគៀងផឹកស្រាគំនាប់គ្នាទៅវិញទៅមក រួចក៏ចាប់ផ្ដុង ព្រួញយឹតឡើង ហើយស្រែកឲ្យទាហានទាំងពួងចាំមើល ក៏លែងព្រួញទៅត្រូវចុងទួនដែលដោតបញ្ឈរនោះ ចំគ្មានល្អៀងបន្តិចសោះ ទាហានទាំងឡាយស្រែកហ៊ោសរសើរថ្វីដៃលីហ៊ៅថា ចំណានស្ទាត់ក្នុងវិជ្ជាបាញ់ធ្នូឥតនរណាស្មើបាន ៗ លីហ៊ៅសើចហើយចាប់ដៃឡៅពីនឹងគៀងថា ខ្ញុំប្ដឹងដល់ទេពតាឃើញប្រាកដស្ដែងយ៉ាងនេះ រួចក៏រៀបតុះលៀងអាហារទាំងអស់គ្នា ៗ គៀងនិយាយថា ឥឡូវនេះខ្ញុំឃើញជាក់ច្បាស់ដល់ការដែលអ្នកប្ដឹងហើយ បើខ្ញុំនឹងលើកទ័ពត្រឡប់ទៅវិញ វេលានេះអួនសុតមុខជានឹងមិនជឿខ្ញុំទេ ៗ លីហ៊ៅថា “អ្នកកុំវិតក្កឡើយ” ហើយលីហ៊ៅតែងសំបុត្រ ១ ច្បាប់ប្រាប់ទៅអួនសុត ៗ គៀងទទួលសំបុត្រហើយក៏លាលើកទ័ពត្រឡប់ទៅស្រុកឡាំយ៉ុង ៗ

លីហ៊ៅនិយាយនឹងឡៅពីថា គ្រានេះបើខ្ញុំមិនបានមកជួយរំគិតដោយគំនិតដូច្នេះទេ ខ្លួនអ្នកគង់មានសេចក្ដីព្រួយលំបាកដោយគៀងជាប្រាកដ ៗ ឡៅពីទទួលគំនាប់លីហ៊ៅ ហើយក៏លាត្រឡប់ទៅស្រុកសៀវផាយ ៗ លីហ៊ៅក៏លើកទ័ពត្រឡប់ទៅស្រុកឈីជីវ ៗ

កាលគៀងទៅដល់ស្រុកឡាំយ៉ុងវេលាណា ក៏យកសំបុត្រទៅជូនអួនសុត ហើយពណ៌នារឿងជំរាបអួនសុតគ្រប់ប្រការ ៗ អួនសុត

មើលសំបុត្រហើយក៏ខឹងខ្លាំងណាស់ ថាលីប៉ោចរេតាមិនជាសត្យពិតត្រង់ ទើបប្រជុំសេនាទាហានថា យើងត្រូវលើកទ័ពទៅចាប់ខ្លួនឡៅពីឲ្យបាន ហើយនឹងទៅកយយកស្រុកឈើជីវទៀត ។ គីឡេងនិយាយឃាត់ថា លីប៉ោជាមនុស្សខ្លាំងពូកែណាស់ សេនាទាហានដែលមានថ្វីដៃក៏ច្រើន លេះគនឹងលើកទ័ពទៅគ្រានេះ លីប៉ោនឹងឡៅពីកំពុងត្រូវគ្នា គង់នឹងលើកទ័ពប្រសព្វគ្នាធ្វើយើងវិញឲ្យលំបាក ខ្ញុំឃើញថា យើងគង់នឹងបរាជ័យពុំខាន ការដែលយើងគិតបំរុងទុកនោះក៏នឹងមិនសំរេច បើដូច្នេះខ្ញុំសុំឲ្យលោកចាត់បំរើទៅសុំដណ្តឹងកូនក្រមុំលីប៉ោ ដែលគេគំនឹងនាងងៀមស៊ីនោះមកឲ្យកូនប្រុសលោក លីប៉ោនឹងលោកក៏នឹងបានស្និទ្ធជិតរាប់អានគ្នា ទោះនឹងប្រាថ្នាចាប់ខ្លួនឡៅពីក៏នឹងបានដោយងាយ ៗ អ៊ួនសុតគិតយល់ត្រូវ ក៏ចាត់ប្រើហាន់អ៊ុនជាបំរើនាំគ្រឿងបណ្ណាការដ៏មានដំឡៃទៅជូនលីប៉ោសុំដណ្តឹងបុត្រីតាមសំដីដែលគីឡេងថានោះ ។

ហាន់អ៊ុនទៅដល់ស្រុកឈើជីវក៏ចូលទៅគំនាប់លីប៉ោ លើកបណ្ណាការជូនហើយជំរាបថា អ៊ួនសុតជាចៅហ្វាយខ្ញុំបាទគិតមេត្រីដល់លោកជានិច្ច ទើបប្រើខ្ញុំបាទនាំយកវត្ថុទាំងអស់នេះមកជូនសុំផ្លូវលោកដែរ គឺសូមចងស្ពានមេត្រីដណ្តឹងបុត្រីលោកឲ្យជាភរិយាបុត្រអ៊ួនសុត ជាគូស្រករតាមប្រវេណីតទៅ ។

លីប៉ោបានស្តាប់ ក៏ចាប់ចិត្តត្រេកអរទទួលយកជំនូនបណ្ណាការ ហើយក៏ចូលទៅសារសព្វប្រាប់នាងងៀមស៊ីជាភរិយាពិគ្រោះគ្នា ៗ នាង

ធៀមស៊ីគិតថា អ៊ុនសុតជាមនុស្សមានសតិបញ្ញា ទាំងសេនាយោធា ក៏មានច្រើន ឯស្រុកឡាំយ៉ុងក៏ជាស្រុកធំ អំណោះតទៅមុខ អ៊ុនសុតក៏គង់បានជាម្ចាស់ កូនយើងក៏គង់បានធំដោយសារ ។ លុះគិតឃើញព្រមគ្នាហើយ លីប៉ោក៏ចេញមកនិយាយប្រាប់ហាន់អ៊ុនថា "យើងព្រមឲ្យកូនក្រមុំយើងតាមអ៊ុនសុតប្រាថ្នា" ហើយក៏អញ្ជើញហាន់អ៊ុនបរិភោគអាហារ រួចហាន់អ៊ុនក៏លាលីប៉ោត្រឡប់ទៅស្រុកឡាំយ៉ុងវិញ លុះទៅដល់ ក៏ចូលទៅជំរាបអ៊ុនសុតថា លីប៉ោព្រមឲ្យកូនក្រមុំមកលោកហើយៗ មានចិត្តមេត្រីនឹងលោកណាស់ ។

អ៊ុនសុតបានឮដូច្នោះ ក៏នឹកថាការដែលខ្លួនគិតនោះមុខជានឹងសម្រេចតាមប្រាថ្នា ហើយក៏តាក់តែងរៀបកស្តុភារបណ្ណាការ តាមទំនៀមដែលលើកស្លាដូនពេលា ឲ្យហាន់អ៊ុននាំទៅជូនលីប៉ោម្តងទៀត ដើម្បីនឹងនាំយកខ្លួនកូនក្រមុំលីប៉ោមកឯស្រុកឡាំយ៉ុង ហាន់អ៊ុនក៏នាំកស្តុភារចេញទៅ កាលទៅដល់ស្រុកឈីជីវហើយក៏នាំកស្តុភារចូលទៅជូនលីប៉ោហើយជំរាបថា អ៊ុនសុតមានសេចក្តីត្រេកអរណាស់ ឲ្យខ្ញុំបាទមកសុំយកខ្លួនកូនក្រមុំលោកនាំទៅ ។ លីប៉ោក៏ស្រោកស្រលទទួលជំនូនកស្តុភាររៀបភោជនាហារលៀងហាន់អ៊ុន ហើយរៀបចំកន្លែងទទួលភ្ញៀវឲ្យហាន់-អ៊ុនទទួលដំណេក ។ លុះពេលព្រឹកគាន់កុងទីប្រឹក្សាលីប៉ោ ក៏ចូលទៅជួបនឹងហាន់អ៊ុនៗ ឃើញក៏ក្រោកចេញមកទទួលហើយអញ្ជើញឲ្យ

អគ្គិយ ៗ តាន់កុងនិយាយថា ឡេវពីនៅក្នុងអំណាចលីប៉ោ នោះទីង ប្រាថ្នាក្បាលឡេវពីក៏គង់បានដោយងាយ ៗ

តាន់កុងតបថា អ្នកកុំគប្បីភ្ញើសចិត្តនឹងខ្ញុំៗ ឃើញថាការរបស់អ្នកដែលគិតនោះ ប្រសិនបើទីងលះបង់ចោលទុកយូរហួត ក៏ទីងមិនសម្រេចតាមប្រាថ្នា បានជាខ្ញុំមកជំរាបនេះដើម្បីទីងរំលឹកស្មារតីអ្នក ៗ ហាន់អ៊ុនយល់គំនិតតាន់កុងដែលនិយាយដោយពិតត្រង់ ក៏បណ្តោយថាសុំឲ្យអ្នកជួយជាធុរៈផងចុះ ៗ តាន់កុងថាអ្នកកុំព្រួយ បើប្រសិនលីប៉ោបានប្រែក្បាននឹងខ្ញុំ សុំខ្ញុំនិយាយឲ្យលីប៉ោបញ្ជូនកូនក្រមុំទៅឲ្យអ៊ួនសុតឲ្យបាន ៗ ហាន់អ៊ុនមានអំណរក្នុងចិត្តណាស់ថា ការនេះប្រសិនបើអ្នកជួយគិតសម្រេចបាន អ៊ួនសុតក៏គង់ដឹងគុណរបស់អ្នកមិនភ្លេចទេ ៗ តាន់កុងក៏លាហាន់អ៊ុនទៅជួបនឹងលីប៉ោហើយធ្វើជាសួរថា ខ្ញុំបាទបានឮថា លោកព្រមឲ្យកូនក្រមុំទៅអ៊ួនសុតមែនឬទេ ? ៗ លីប៉ោឆ្លើយទទួលថាមែន ៗ តាន់កុងថា លោកឃុះនធ្វើគន្លងនឹងអ៊ួនសុតគ្រានេះ ខ្ញុំមានសេចក្តីត្រេកអរណាស់ ចុះកាលណាទីងគិតរៀបមង្គលការ? ៗ

( មានត )

# រឿងអារក្សថ្លែងរឿងម្ភៃប្រាំ

## លោកវ៉ាយ-ប៊ុក ក្រមការ នៅក្រុមពុទ្ធសាសនបណ្ឌិត្យ

*ប្រែពីបារាំងមកជាខ្មែរ*

(តមក)

## រឿងទី ១២

*អារក្សក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ថា: "បពិត្រព្រះបាទពិក្រម៍[១], មាននគរមួយឈ្មោះចូរាបុរៈ (chûrâpur) ព្រះបាទចូរាម័ន (chûrâman) ជាព្រះមហាក្សត្រិយ៍ទ្រង់សោយរាជសម្បត្តិនៅនគរនោះ ។ គ្រូព្រះអគ្គ ឈ្មោះទេវស្វាមិ (Dévasvâmi) មានបុត្រម្នាក់ឈ្មោះហរិស្វាមិ (Harisvàmi) មានរូបឆោមស្អាតល្អប្រិមប្រិយដូចកាមទេព ឬទេវតាខាងកាម, មានចំណេះដូចព្រះព្រហស្បត៍ (Brihaspati)[២] មានភោគទ្រព្យដូចកុវេរៈ (Kuvéra)[៣] ។ ហរិស្វាមិមានភរិយាឈ្មោះនាងលាវណ្យាវតី (Lavanyavati) ជាបុត្រីព្រាហ្មណ៍ម្នាក់ ហើយអ្នកទាំងពីរស្រឡាញ់គ្នាពន់ពេក ។*

*ពេលយប់នៃវស្សានរដូវ អ្នកទាំងពីរកំពុងនិទ្រាលក់ស៊ប់នៅលើរានហាល, ស្រាប់តែខ្យល់ដែលត្រូវបកមុខនាងលាវណ្យាវតីរបើកចេញហើរ*

---

• ព្រះនាមនេះពីខាងដើមមកភ្ជាត់ដាក់ថា "ពិករ័ន" តែដែលត្រូវតាមច្បាប់ដើមគឺពិក្រម៍ ។
២ គ្រូទេវតា ។ ៣ ព្រះអាទិទេពនៃភោគទ្រព្យ ។

ទៅឆ្ងាយ ៗ វេលានោះ មានទេវតាក្នុងនៃស្ថានសួគ៌ម្នាក់ជិះទេវរថ ហោះមកឃើញនាង, ចុះមកដល់ដីហើយក៏យកនាងនោះកំពុងដេកលក់ ដាក់ទៅក្នុងទេវរថ យកទៅបាត់ ៗ លុះដល់ព្រាហ្មណ៍ជាស្វាមីភ្ញាក់ពីនិទ្រាមិនឃើញភរិយានៅទីនោះក៏ងឹកឆ្ងល់ពន់ពេក ៗ ព្រាហ្មណ៍នោះក្រោកដើររកពាសពេញគេហដ្ឋាន មិនឃើញនាង, ខំទៅតាមវិថីធំតូចក្នុងទីក្រុង, មិនឃើញទៀត ៗ ព្រាហ្មណ៍ក៏គិតក្នុងចិត្តថា: "តើអ្នកណាយកនាងទៅ? តើនាងទៅឯណា?" ៗ

ដល់អវសាន, ឃើញអស់សង្ឃឹមនឹងរកនាងពុំឃើញ, ព្រាហ្មណ៍កើតទុក្ខព្រួយជាខ្លាំងក៏ត្រឡប់មកកាន់គេហដ្ឋាន, ព្យាយាមរកម្តងទៀតមិនឃើញ ៗ បើគ្មាននាងទេ, គេហដ្ឋានដូចជាស្ងាត់សូន្យឈឹង ៗ ដល់ព្រួយខ្លាំងពេក, ព្រាហ្មណ៍ក៏ស្រែកហៅនាងថា: "ឱនាងជាទីស្រឡាញ់ពេញចិត្តរបស់ខ្ញុំ! ឱនាងជាទីស្រឡាញ់ពេញចិត្តរបស់ខ្ញុំ!" ៗ

ការដែលព្រាត់ប្រាស់ពីនាងធ្វើឲ្យចិត្តគាត់រំជួលខ្លាំង ៗ គាត់ក៏លះបង់ឋាន: ជាមេផ្ទះចោលស្រឡះ បោះបង់នូវលោកាមិស គ្រឿងបីពារ, លាបផេះ, លាមកគោញី, ពាក់នូវខោក្រជោតក្រាប់ ហើយក៏ចេញពីទីក្រុង ដើម្បីនឹងទៅកាន់បូជនីយដ្ឋាន ៗ ព្រាហ្មណ៍នោះត្រាច់ពីទីក្រុងមួយទៅទីក្រុងមួយ, ពីភូមិមួយទៅភូមិមួយ, ដល់ថ្ងៃត្រង់ ទៅដល់ទីកន្លែងមួយ, ឃ្លានបាយពន់ពេក, គាត់ក៏យកពែងមួយមកដងទឹក

ស៊ីកធាក (dhâk)[១] ចូលទៅក្នុងគេហដ្ឋាននៃព្រាហ្មណ៍ម្នាក់ហើយក៏សូមបាយម្ហូបអាហារបរិភោគ ។

បើកាលណាបុរសដែលលង់ទៅក្នុងកាមគុណហើយ លែងនឹកនាដល់ករណីយកិច្ច ឬ វណ្ណៈរបស់ខ្លួន, បុរសនោះបរិភោគអាហារនៅទីកន្លែងណាដែលមានអាហារ, ចិត្តជាឧបេក្ខាទទួលយកដោយគ្មានរបៀបនូវរបស់ដែលគេឲ្យ ។

ដល់អ្នកនោះសូមទាន, ព្រាហ្មណ៍ក៏យកពែងដាក់បាយនឹងទឹកដោះគោរួចប្រគល់ឲ្យ, អ្នកបួសនិយេសក៏ទទួលពែងពីព្រាហ្មណ៍, ដំរង់ទៅកាន់មាត់ត្រពាំងមួយ, ដាក់ពែងនឹងគល់ជ្រៃ, ក៏ចុះទៅក្នុងត្រពាំងដើម្បីនឹងលុបមុខលាងដៃ ។ ក្នុងពេលនោះ មានពស់វែកមួយចេញពីលើនោះក៏ខ្ទនក្បាលទៅក្នុងពែងខ្ជាក់នូវពិសពេញពែង ។

បុរសនោះ, ដល់លុបមុខលាងខ្លួនរួចហើយក៏វិលត្រឡប់មក, មិនដឹងនូវរឿងរ៉ាវខាងលើ ។

ដោយឃ្លានអាហារពន់ពេក បុរសនោះក៏អាស្រ័យបាយ ហើយក្នុងមួយរំពេច, ស្រាប់តែឧសថពុលផ្សាយសព្វសព៌ាង្គកាយ ។ អ្នកនោះក៏វិលមករកព្រាហ្មណ៍ហើយពោលថា: "អ្នកឯងឲ្យឧសថពុលមកខ្ញុំអាស្រ័យហើយ, ឥឡូវនេះខ្ញុំស្លាប់ហើយ" ។ ដល់ចេញវាចាដូចនោះ

---

១ Bntea frourosa

បុរសនោះក៏ដួលស្លាប់នៅទីនោះទៅ ។ លុះឃើញបុរសនោះអនិច្ចកម្ម, ព្រាហ្មណ៍ស្វាមីក៏ដេញភរិយាចេញពីគេហដ្ឋានហើយពោលថា: "ឯងធ្វើឃាតកម្មព្រាហ្មណ៍ ។ ទៅ, ឯងទៅចុះ ពេជ្ឈឃាតនៃព្រាហ្មណ៍ !" ។

លុះពោលរឿងនេះចប់ស្រេច អារក្សនោះក្រាបបង្គំទូលសួរព្រះមហាក្សត្រថា: "បពិត្រមហារាជ! តើអ្នកណាជាអ្នកទទួលការខុសត្រូវត្រង់ធ្វើឃាតកម្មនៃព្រាហ្មណ៍នោះ?" ។

ព្រះមហាក្សត្រិយ៍ មានព្រះបន្ទូលថា: "មាត់ពស់មានពិស គឺជាធម្មជាតិរបស់វា ។ ពស់នេះមិនមែនជាអ្នកមានទោសទេ ។ នាងជាភរិយាទទួលបង្គាប់ពីស្វាមី, នាងគ្មានទោសអ្វីឡើយ ។ ហរិស្វាមិបរិភោគបាយនោះដោយមិនដឹងខ្លួនសោះ, នេះក៏មិនមែនខុសពីគាត់ ។ ដោយហេតុដូចនេះ ក្នុងករណីយនេះ អ្នកមានទោសគឺអ្នកដែលគេចោទ" ។

អារក្សបានស្តាប់នូវព្រះបន្ទូលនៃព្រះមហាក្សត្រិយ៍ចប់សព្វគ្រប់ហើយ ក៏វិលត្រឡប់មកឡើងលើរុក្ខជាតិព្យួរខ្លួនសំយុងចុះមក ។ ព្រះមហាក្សត្រិយ៍ទ្រង់បានស្រោចស្រង់អារក្សនោះ ទ្រង់ក៏លីលើព្រះអង្សាហើយយាងទៅ ។

ចប់ រឿងទី ១២ មានរឿងទី ១៣ តទៅ ។

# រឿងស្លាប់ព្រោះជាតិ

## មាន ៣ ឈុត

លោក គង់ - លឹម និស្សិតសាលាគរុវិជ្ជាភ្នំពេញ តែង

---

## រាយតួ

| | |
|---|---|
| រាគា | អនុសេនិយទោ |
| រាគី | កូនប្រុសលោករាគា |
| វណ្ណនារី | កូនស្រីរបស់លោករាគា |
| តារា | ម្ដាយក្មេក |
| វិធ្នី | ម្ដាយរបស់លោករាគា |
| សារ៉ា | វិញ្ញាណកូនរបស់ប្រពន្ធលោករាគា |

រឿងហេតុនេះ កើតមានឡើងនៅខេត្តព្រៃវែង ។

### ឈុតទី ១ ឆាកទី ១

### តារា-រាគា

រាគា (មមើ)

ក្រាបៗ ! លូនចូល ! ចូល ! កុំខ្លាច បាញ់ ! កាប់ចាក់ទៅបើកនៅជិតដៃ ន៎ ! អាមួយនោះស្លាប់ហើយ លូនចូលទៅយកកាំភ្លើងមកៗ បាញ់ៗ !

គ្រាប់បែកដៃទុកធ្វើអ្វី ពេលសម្លាប់ពាក្យតំនែងដីទាំងអស់នោះទៅ ! ចូល ៗ បាញ់ ៗ គ្រាប លូនចូល កុំខ្លាចស្លាប់ ស្លាប់ក្រោមទង់ជាតិខ្មែរ ប្រសើរណាស់ ៗ

(រូបដេកទៅវិញ)

តារា (ស្ទុះចូលមក)

ឱកូនប្រុសមាសម្ដាយអើយ ! កូនវិលខ្លួនអស់ហើយ ៗ ក្នុងមួយខែ ៗ មិនសូវបាននៅផ្ទះទេ កូនចំរើនហាលថ្ងៃ ហាលខ្យល់ ហាលភ្លៀង ដេកក្នុងព្រៃ ៗ កូនចំណតតាំងជាមួយទឹងខ្មាំង ដើម្បីនឹងការពារសន្តិសុខក្នុងនគរ កូនបានបំរើមាតុភូមិដោយម៉ត់ចត់ ៗ ចិត្តកូននៅជាប់តែក្នុងសេចក្តីការពារនគរ ចិត្តនៅជាប់តែក្នុងការសឹកសង្គ្រាម ៗ ដេកក៏ចេះតែមមើយឃើញតែបាញ់ ឃើញតែគ្រាប ឃើញតែលូន គឺចិត្តនៅជាប់តែក្នុងការកសាងនឹងការពារនគរ ៗ

រាគា

មានការណ៍អ្វីអ្នកម្ដាយ ?

តារា

ទេឥតមានការណ៍អ្វីទេ កូន ! ប៉ុន្តែម្ដាយឮកូនខនិយាយស្រែកឡូឡា អម្បាញ់មិញនេះ បានជាម្ដាយមកមើលកូន ក្រែងកូនពុំស្រួលខ្លួន ៗ

រាគា

ខ្ញុំស្រែកឡូឡាខ្លាំងណាស់ទៅអ្នកម្តាយ ! ឱ : ខ្ញុំវិលខួរអស់ទៅហើយអ្នកម្តាយ ! ។

តារា

ចាំតែរក្សាចិត្តកូនឲ្យនៅនឹងនួនបន្តិច កុំឲ្យរវើរវល់ក្នុងការសោកសង្គ្រាមពេក ។

រាគា

កុំឲ្យខ្ញុំគិតដូចម្តេចបាន បើស្រុកសព្វថ្ងៃកើតកុលាហលពេញទាំងផែនដីដូច្នេះ នរណាក៏ដឹងគ្រប់ដែរ ថាប្រទេសយើងកើតវិបរិត ។

តារា

គិតតែល្មមៗបានហើយកូន ! ព្រោះឯងមានទុក្ខ ក្រៀមក្រំពន់ពេកណាស់ តែកូនគិតច្រើនពេក ក្រែងលោខូចស្មារតីរបស់កូនអស់ទៅ ។

ណ្ហើយកូនអើយ ! កុំកើតទុក្ខខ្លាំងពេក តែម្តាយឃើញមុខកូនក្រៀមក្រំរាល់ពេលវេលាយ៉ាងដូច្នេះ ម្តាយព្រួយចិត្តណាស់កូន ! ។

រាគា

ពិបាកណាស់អ្នកម្តាយ ! អ្នកម្តាយមានប្រសាសន៍ថាកុំឲ្យព្រួយយ៉ាងដូច្នេះបេះតែបាន ប៉ុន្តែខ្ញុំនឹងដកចិត្តចេញអំពីសេចក្តីព្រួយទាំងនេះមិនបានសោះ បេះតែគួរៗថែមឡើងមកទៀត ។ អ្នកម្តាយ ! កូនទៅធ្វើ

សើក បាយពុំបានទេ ផ្អែតក្នុងចិត្តជាធម្មតា តែទឹកឃើញផល់ក្តីកំសត់រាល់នាទីប្រពន្ធខ្ញុំនិងខ្ញុំកាលណា ទឹកភ្នែករបស់ខ្ញុំហូរមកមួយរំពេច ។

តារា

ណ្ហើយធ្វើម្តេចកូន! មនុស្សយើងតែកើតមកហើយ ក្នុងលោកសន្និវាសយើងនេះ តែងតែមានសេចក្តីវិនាសជាដរាប កុំថារូបណាជារូបណាឡើយ សេចក្តីស្លាប់នឹងសេចក្តីទុក្ខសោក តែងតែកើតមានឡើងរាល់ៗតែរូប ។

រាគា

ឲ្យខ្ញុំកាត់ម្តេចនឹងដាច់អ្នកម្តាយ! បើចេះតែចុកណែនក្នុងដើមទ្រូងជានិច្ចយ៉ាងដូច្នេះ ។

តារា

ខំកាត់ចិត្តបន្តិចទៅណាកូន! កុំគិតពេក ។

រាគា

បាទអ្នកម្តាយ ! ខ្ញុំទទួលសេចក្តីប្រដៅរបស់អ្នកម្តាយ ។

ឆាកទី ២

## រាគា-រាគី

រាគា

ឱព្រះអើយ ! ឲ្យខ្ញុំកាត់ចិត្តម្តេចនឹងដាច់ បើនាងតាំងតែពី

ប្រសប់ចាប់ដៃគ្នាកាលណា   នាងពុំដែលពោលពាក្យទ្រគោះប្រោះប៉ោក ឲ្យខ្ញុំមួយដងណាសោះ  សំដីរបស់នាងស្គាល់តែផ្អែម  ស្គាល់តែត្រជាក់ ដូចធម្មតា  ។

ឱគូសង្សារថ្មើមជីវិតបងអើយ !  មិនគួរឡើយអ្នកស្ដាប់ពោលខ្ញុំសោះ !  អ្នកគ្មានអាណិតដល់ប្អូនខ្ញុំទេ !  ខ្ញុំខំទៅធ្វើសិកសង្គ្រាម ! ធ្វើជាខ្ញុំរាជការ ដើម្បីនឹងយករង្វាន់មកចិញ្ចឹមនាង ! នៅនាងមិនសប្បាយចិត្តទៀត ។ មិនគួរទេប្អូន ! នាងស្ដាប់ពោលខ្ញុំ ឲ្យខ្ញុំរងទុក្ខ ! បងហូរតែទឹកភ្នែក រាល់ពេលរាល់វេលាយ៉ាងដូច្នេះ ។

ភាគី

លោកប៉ា ម្ដេចក៏មុខក្រៀមអ្វីដល់ម៉្លេះ? លោកប៉ាព្រួយចិត្តរឿងអ្វីឬ? លោកប៉ាខឹងនឹងខ្ញុំទេឬ? ។

ភាគា (ខឹង)

អញខឹងមិនខឹងក៏ដោយ !  អញព្រួយចិត្តអ្វីក៏ដោយ !  មិនបាច់ឯងមកនិយាយផ្ចុញផ្ចាល់ចំអកឲ្យអញទេ !  ឯងមិនមែនជាកូនរបស់ផងអញទេ ! បើឯងកូនអញ, ឯងមិនហ៊ានធ្វើដូច្នេះទេ ។

ភាគី

សូមអត់ទោសលោកប៉ា !  ខ្ញុំនឹងនាងប្អូនមិនដឹងគិតធ្វើដូចម្ដេចទេ ខ្ញុំខំសុំច្បាប់លោកតាំងហ្មានសាលាអស់ប៉ុណ្ណឹងហើយ ។ ដោយខ្ញុំជំរាប

លោកថា អ្នកម្ដាយរបស់ខ្ញុំមានជម្ងឺ សូមលោកអាណិតមេត្តាបើកច្បាប់ឲ្យខ្ញុំនឹងនាងវណ្ណនារី ដើម្បីនឹងទៅផ្ទះថែរក្សាអ្នកម្ដាយ! លោកពុំព្រមសោះ លោករឹតតែខឹងនឹងខ្ញុំកាន់តែខ្លាំងឡើង ។

រាគា

ក៏មិនដែលមាន! ម្ដាយគេឈឺ ហើយសុំច្បាប់មិនឲ្យ! ក្រែងឯងហ្នឹងឫកក់ធំផងទេដឹង? ។ ចិត្តឯងក៏ដាច់ពីឪពុកម្ដាយថែមទៀត! ឯងនេះគ្មានគិតដល់រូបឪពុកម្ដាយបន្តិចទេ! ឯងគិតតែសប្បាយ! ។

រាគី

មិនមែនយ៉ាងដូច្នោះទេលោកឪពុក! កូនទាំងពីរតែងតែជជែកជំនុំគ្នាជាធម្មតា នឹកមកដល់លោកឪពុកនឹងអ្នកម្ដាយ ព្រមទាំងលោកយាយ ។

រាគា

អាះ! ឯងអាងតែក្អកអញមិនឃើញ! ឯងចេះតែនិយាយៗទៅ! ស្រេចតែនឹងឯងចេះហៃហាទៅចុះ! ប៉ុន្តែសំដីឯងទាំងអស់នេះ អញគ្មានជឿបន្តិចទេ ។ ឯងនេះខូចណាស់! បានអញទិញរទេះកង់ឲ្យឯងមួយ ឯងគិតតែពីជិះដើរលេងជាមួយនឹងប្អូនឯង! ។ បានប្អូនស្រីមួយឯងគិតតែពីបញ្ជិះបណ្ដើរឲ្យពួកម៉ាកឯង ឃើញថាឯងនេះគ្រាន់បើណាស់ ។

ភាគី

ទេលោកឪពុក ! មិនមែនយ៉ាងដូច្នោះទេ ! មិនមែនដូចជាប្រសាស្ន៍លោកឪពុកដែលពោលនេះទេ ។ ខ្ញុំពុំដែលប្រព្រឹត្តទីងនាំប្អូនដើរលេងនោះទេ ។ បើលោកប៉ាពុំជឿសោត សូមលោកប៉ាអញ្ជើញផ្ញើសំបុត្រទៅសួរលោកគ្រូមើលចុះ ។

ភាគា

មិនបាច់ចាំទៅផ្ញើសំបុត្រនាំឲ្យអស់ថ្លៃតែមនោះទេ ! អញដឹងទាំងអស់ ! អំពីអំពើកិរិយាអាក្រក់របស់ឯង ។ អញដឹងគ្មានសល់ទេ, កុំចាំបាច់ថាឯងឲ្យអញផ្ញើសំបុត្រទៅសួរធ្វើអ្វីនោះ ។

ភាគី

លោកប៉ា ! ខ្ញុំគួបចិត្តណាស់ទឹងសេចក្តីដែលខ្ញុំពុំបានប្រព្រឹត្តសោះហើយស្រាប់តែមានកំហុសបានផលអាក្រក់ធ្លាក់មកលើខ្លួនយ៉ាងដូច្នេះ ។

ភាគា

ឯងចង់ធ្វើយ៉ាងដូចម្តេច ! ឯងចង់ឲ្យអញវាយឯងក្នុងពេលឥឡូវហ្នឹងឬ? ឯងដឹងឬទេ កិច្ចកំហុសរបស់ឯង? ។ ឯងនៅដល់ថ្នាក់ទី ៣ ក្នុងសាលាអនុវិទ្យាល័យហើយ ! ឯងនៅតែគិតមិនឃើញទៀត ។

ភាគី

បាទលោកឪពុកខ្ញុំគិតមិនឃើញទេ អំពីរឿងកំហុសរបស់ខ្ញុំនឹងប្អូននេះ ខ្ញុំបាទឥតមានសេចក្ដីកំហុសដ៏អាក្រក់ ដូចលោកប៉ាមានប្រសាស្ន៍នោះទេ ។ គឺដោយរាជការខាងខេត្តកំពង់ចាម លោកបានឃាត់រថយន្តទាំងឡាយ មិនឲ្យរត់ចេញចូលពីព្រោះមានអសន្តិសុខ បណ្ដាលឡើងជាមិនស្រួលនៅតាមផ្លូវ ហេតុនេះសូមលោកប៉ាជ្រាប ។

ភាគា

ឈប់និយាយ! មិនបាច់ឯងថ្លែងសេចក្ដីអធិប្បាយរបស់ឯង បែកជាអូរហូរជាស្ទឹងនោះទេ! អញដឹងអស់ហើយអំពើអប្បលក្ខណ៍របស់ឯង! ទៅទៅ! ចៀសចេញឲ្យឆាប់ពីមុខអញ កុំឲ្យអញឃើញមុខយូរមិនបានទេ អញខ្ញាញ់ណាស់ទៅ ។

ឆាកទី ៣

ភាគា

ត្រូវតែមានសេចក្ដីប្រកាន់ឲ្យរឹងបឹងបន្តិច តែខំបណ្ដោយតាមចិត្តវាមុខតែកើតទុក្ខហួសខ្ញុំទៅទៀត ពីព្រោះកូនខ្ញុំទាំងពីរនេះ វាស្រឡាញ់ម្ដាយវាណាស់សឹងតែថាបាត់មួយពេលមិនបាន ។ ប៉ុន្តែបើបណ្ដោយតាមចិត្តរបស់វាមិនកើតទេ សេចក្ដីរៀនសូត្រកំពុងតែបានចំរើន ឧបមា

បីដូចជាព្រះច័ន្ទពេញបូណ៌មី ដែលរះចេញពីព្រះធរណី ហើយអណ្តែតត្ពោះទៅកាន់អាកាសវេហាស៍ ។ ណាមួយកាន់តែជិតដល់ខែប្រឡងយកសញ្ញាប័ត្រទៅហើយ ប្អូនក៏ជិតដល់ខែនឹងប្រឡងយកសំបុត្រវិញ្ញាបណប័ត្រដែរ សុទ្ធតែកំពុងពេញដោយតម្រេះវិជ្ជា ។ ណ្ហើយចុះត្រូវតែកុំឲ្យវាដឹងពីរឿងមរណៈភាពរបស់ម្ដាយវា ។ ប៉ុន្តែមានសេចក្ដីទឹកអាណិតកូនពេកណាស់ ដោយគ្នាគ្មានខុសរឿងអ្វីសោះហើយ ចេះតែនិយាយបំពានលើយ៉ាងដូច្នេះ ។ ឱកូនសម្លាញ់មាសឪពុក! ចូរកូនកុំបង់ចិត្តខឹងនឹងឪពុកធ្វើអ្វី គឺឪពុកមិនចង់ឲ្យកូនឱបសេចក្តីល្ងង់ខ្លៅ ឪពុកចង់ឲ្យកូនចេះដឹង បានជាបុគ្គលិកមួយយ៉ាងធំនឹងគេទៅថ្ងៃក្រោយ ។
(ស្រក់ទឹកភ្នែក)

## ឆាកទី ៤

## វណ្ណ៍នារី ពតា សាព ពតី

### វណ្ណ៍នារី

លោកប៉ា! លោកប៉ាម្ដេចក៏អង្គុយស្រក់ទឹកភ្នែកលោកប៉ាយំ ឬ? ឬមួយលោកប៉ាព្រួយចិត្តរឿងអ្វី សូមប្រាប់កូនមក លោកប៉ាក៏លាក់ធ្វើអ្វី ។

# រឿងប៉ូល និងវីរ៉ស៊ីនី

## លោក ផេង-ជ្រីវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជាភ្នំពេញ

រៀបរៀង

(តមក)

---

ការធ្វើដំណើរទៅប្រទេសក្លិង្គ ទុកឲ្យខ្ញុំជាអ្នកធានាទៅសុំច្បាប់ពីលោកបូរដុណែ តែត្រូវឲ្យដំណឹងនេះដល់អាប៉ូលផង ៗ គេឆ្ងល់អីម្ល៉េះទេ អាប៉ូលចេះនិយាយជាមនុស្សចាស់ទៅទៀត ៗ វានិយាយនឹងខ្ញុំថា: ចុះហេតុអ្វីក៏ចង់ឲ្យខ្ញុំចេញពីផ្ទះខ្ញុំ ដើម្បីទៅស្វែងសម្បត្តិទ្រព្យដូច្នេះ? អីមានជំនួញឯណា ឲ្យផលជាងដំណាំដែលឲ្យផលក្នុងមួយជាហាសិបឬជាមួយរយគុណទៅទៀត? បើចង់ធ្វើជំនួញ ហេតុអ្វីក៏មិនឲ្យខ្ញុំយកវត្ថុសំណល់ប្រើប្រាស់មិនអស់ទៅលក់ឯផ្សារ សោះនឹងទៅធ្វើជំនួញឯប្រទេសក្លិង្គ ម្ដាយយើងទាំងពីរជាឬម៉ាំងចាស់ហើយ ៗ ទ្រុនទ្រាផង ចុះខ្ញុំ ៗ មិននៅក្មេងហើយក៏ឲ្យខ្ញុំចេះតែចំរើនកល់ថ្ងៃ? ខ្ញុំបារម្ភណាស់ ក្រែងលោមានគ្រោះថ្នាក់ដល់អ្នកទាំងឡាយ ក្នុងពេលដែលខ្ញុំមិននៅ ហើយជាប់ជាងគេបំផុត តែត្រង់វីរ៉ស៊ីនី ព្រោះរូបប្រាណនាងមិនសូវស្រួលស្រាប់ ៗ បើឯចឹង កុំ! កុំ! ខ្ញុំរកគិតឈានជើងចេញទៅមិនរួចទេ ៗ

សំដីអាប៉ូលឆ្លើយមក នាំឲ្យខ្ញុំពាល់គំនិតធំអីម្ល៉េះ ព្រោះនាងឡាតួរមិនមែនលាក់នឹងខ្ញុំទេ នូវសភាពនាងវីរ៉ស៊ីនី នឹងបំណងដែលនាងបាន

គិតទុកយូរមកហើយ គឺចង់ឲ្យក្មេងទាំងពីរនេះ  មានវ័យចាស់បន្តិចសិន បើដូច្នេះត្រូវបំបែកចេញពីគ្នាឲ្យឆ្ងាយ  គឺជាហេតុដែលនាំឲ្យខ្ញុំមិនហ៊ាន ទាំងធ្វើឲ្យអាប៉ូលសង្ស័យផង ។

កំពុងតែពិគ្រោះគ្នាអំពីទៅប្រទេសកុង្គ  ស្រាប់តែមានសំបុត្រមួយ ពីម្ដាយមីងនាងឡាទួរផ្ញើមកតាមកប៉ាល់ស្រុកបារាំង ។ កុំតែគិតខ្លាច ស្លាប់បន្តិច កុំអីចិត្តម្ដាយមីងនាងឡាទួរមិនមែនគិតនរណាទាំងអស់ ។ នាងនេះទើបនឹងងើបពីឈឺ អស់កំលាំងព្រមទាំងជរាគ្របសង្កត់ផង ។ នាងអង្វរឲ្យក្មួយត្រឡប់ទៅប្រទេសបារាំងវិញ៖ ឬបើមិនសូវជា ធ្វើដំណើរឆ្ងាយមិនបាន អាណិតឲ្យតែវីរស៊ីនីទៅ ដើម្បីនាងនឹងឲ្យគេបង្រៀនឲ្យ បានចេះដឹង ហើយនាងនឹងប្រគល់ទ្រព្យសម្បត្តិទាំងប៉ុន្មានឲ្យ ។

គ្រាន់តែមើលសំបុត្រហើយភ្លាម សេចក្ដីទោមនស្សកើតឡើងពាស ពេញត្រកូលទាំងមូល ។ ឌូម៉ាំងនឹងម៉ារី គិតតែពីយំ ។ អាប៉ូលឈរធ្វើ ទ្រមឹង បែបចង់ខឹង ។ វីរស៊ីនី ក្អែកម៉ក់ៗ សំឡឹងម្ដាយមិនហ៊ានហើបមាត់ មួយម៉ាត់ ។  នាងម៉ារីក៏រត់ស្ទុះទាំងយំទៅជិតនាងឡាទួររួចសួរថា៖ “អីសំឡាញ់អាចចេញចោលយើងឥឡូវហ្នឹង?” ។

នាងឡាទួរឆ្លើយថា៖ “ទេ! សំឡាញ់! កូន ខ្ញុំមិនចេញចោល អ្នកទាំងឡាយសោះឡើយ ។ ខ្ញុំស៊ូនៅស្លាប់រស់ជាមួយគ្នា ។ ខ្ញុំបាន ស្គាល់សេចក្ដីសន្តិសុខ គឺដោយសារសំឡាញ់ ។ សេចក្ដីសុខរបស់ម្ដាយ

មិនខ្ញុំមានអាការៈប្រែប្រួល គឺមកតែពីសេចក្ដីព្រួយរបស់គាត់យូរឆ្នាំមក ហើយជាហេតុទេតើ ។ ខ្ញុំដែលឈឺចិត្ត មកពីឪពុកម្ដាយខ្ញុំក្ដៅពេក ហើយនឹងកាត់បាត់បង់ទៅនៃប្ដីខ្ញុំ ។ គឺតាំងពីពេលនោះមក ដោយសារតែម្ដប់ខ្ទមផ្ទះផ្កាយនេះទេតើ ដែលខ្ញុំបានផ្ទួរចិត្តផ្ទួរគំនិតនឹងសុខស្រួល មិនមែនទ្រព្យពីវង្សត្រកូល ពីស្រុកកំណើត ជួយឲ្យខ្ញុំបានសុខស្រួលទេ" ។

គ្រាន់តែឮបិយភក់តាប៉ុណ្ណោះ អ្នកទាំងអស់គ្នាសប្បាយរីករាយវិញ រហូតដល់ហៀរហូរទឹកភ្នែក ។ អាប៉ូលឱបរឹតនាងឡាតួរហើយនិយាយថា: "ខ្លួនខ្ញុំក៏មិនស្ដីលះបង់លោកម្ដាយដែរ ខ្ញុំមិនទៅប្រទេសក្លិនទេ ។ យើងពល់គ្នាធ្វើការយកផលទុកសម្រាប់ចិញ្ចឹមលោកម្ដាយ យើងមិនឲ្យលោកម្ដាយខ្វះអ្វីឡើយ" ។

តែនៅបណ្ដាពួកក្រុមញាតិទាំងប៉ុន្មាន មនុស្សដែលមិនសូវសប្បាយនឹងជាអ្នកមានចិត្តព្រួយបារម្ភជាងគេ គឺនាងវីរ៍ស៊ីនី ។ នាងហាក់ដូចជាគិតថៃនេះ ជាពេលទីបំផុតនៃសេចក្ដីរីករាយដ៏ទទន់ល្អិត គឺនាងមានសេចក្ដីរីករាយប្លែក មនុស្សទាំងអស់មានសេចក្ដីពេញចិត្តរៀងខ្លួន ដោយបានឃើញនាងក្រមុំត្រឡប់មានការសុខស្រួលឡើងវិញ ។

ព្រឹកព្រលឹម មុនថ្ងៃរះ ឌូម៉ាំងចូលទៅឲ្យដំណឹងដល់ពួកក្រុមត្រកូល ដែលកំពុងអង្គុយថ្វាយបង្គំព្រះជាមួយគ្នា តាមទំលាប់មុនពេលបាយចា: មានមនុស្សម្នាក់ជិះសេះ មានទាសៈពីរនាក់ ដើរតាមក្រោយ

ដូចជាដើរសំដៅចំមកខ្ទមយើង ។ ឯមនុស្សនេះមិនគឺអ្នកណា គឺលោក បូរដុំណែ ។ លោកចូលមកខ្ទមក្នុងពេលដែលពួកគ្រួកំពុងស៊ីបាយ ។ នាងវីរស៊ីនី ទើបនឹងលើកកាហ្វេ ហើយនឹងបាយមកតាមទំនៀមស្រុក មានទាំងដំឡូងស្ងោរនឹងបេកទុំផង យករលាយឃោកធ្វើតាន យកស្លឹក ចេកធ្វើសំពត់ដំរង ។ លោកបូរដុំណែ ចូលមកឃើញទឹកនៀងគ្រអ៊ីម៉ូះទេ, រួចហើយក៏និយាយទៅកាន់នាងឡាតួរថា: "នាងមានម្ដាយមីងម្នាក់ជាអ្នក ទុគ្គតទុគ្គម ព្រមទាំងមានសម្បត្តិច្រើនផងនៅឯក្រុងបារីស៍ ម្ដាយមីង នោះប្រមូលសម្បត្តិទាំងប៉ុន្មាន ទុកសម្រាប់ឲ្យនាងឯង គាត់ចាំមើល តែផ្លូវនាង" ។

នាងឡាតួរឆ្លើយតបថា ខ្លួននាងមិនស្ទើរជា រកធ្វើដំណើរឆ្ងាយ ពុំបាន ។

លោកបូរដុំណែសួរទៀតថា: "ដោយហេតុអ្វី ចុះនាងក្រមុំវីរស៊ីនី នៅក្មេងនៅឡើយ មិនគួរនាងចិត្តអាក្រក់ ធ្វើឲ្យគ្នាខានបានដំណែលដ៏ធំ ឡើយ ។ ខ្ញុំមិនលាក់ទេនាង! ម្ដាយមីងនាងបើកអំណាចឲ្យខ្ញុំយកនាង ក្រមុំវីរស៊ីនីទៅនៅជិតគាត់" ។

គ្រាន់តែថាប៉ុណ្ណឹងហើយ លោកយកស្បោងប្រាក់ពីស្លាបព្រួញដែល កំពុងលើដាក់លើតុ ហើយប្រាប់ថា: "ហ្នឹងហើយជារបស់ដែលម្ដាយមីង នាងផ្ញើមក ដើម្បីឲ្យនាងក្រមុំ កូននាងរៀបចំដំណើរទៅស្រុកបារាំង" ។

តទៅទៀត លោកស្តីឲ្យនាងឡាគួរថា "បើចង់ត្រូវការអ្វី ហេតុដូចម្តេចក៏មិនផ្ញើសំបុត្រផ្ញើទៅប្រាប់លោកឲ្យដឹង" រួចលោកសរសើរកោតចិត្តប៊ុនអត់ទ្រាំ ។

អាប៉ូលលោចាប់ពាក្យនិយាយឡើងភ្លាមថា: "សូមលោកអត់ទោស! ម្តាយខ្ញុំបានផ្ញើសំបុត្រទៅជូនលោកដែរ តែក្រែងលោកមិនបានទទួល មើលទៅ" ។– អីនាងឯងមានកូនមួយទៀត? ។– ចាសទេលោក! ។ អាហ៊ឹងជាកូនសំឡាញ់ខ្ញុំទេ តែវាហ៊ឹង ហើយនឹងកូនខ្ញុំដូចជាពោះមួយ ខ្ញុំស្រឡាញ់វាទាំងពីរដូចគ្នា ។– នៃអ្នកកំឡោះ កាលណាអ្នកចេះច្បាប់លោកិយ ទើបអ្នកនឹងដឹងសេចក្តីទុក្ខនៃមនុស្សដែលមិនចេះដើរទៅណា អ្នកនឹងចេះនិយាយពន្យល់មនុស្សទាំងនោះបានដោយងាយ ហើយអ្នកដែលលាក់ខ្លួនពួនអាត្មានោះ នឹងអាចធ្វើការអាក្រក់បានដោយងាយពេក ។

នាងឡាគួរ អញ្ជើញលោកបួរដុំណៃឲ្យអង្គុយពិសាបាយជិតនាង ។ លោកក៏អង្គុយទទួលទានកាហ្វេលាយបាយ តាមរបៀបគេស៊ីនៅស្រុកអាយដែរ ។ លោកពេញចិត្តនឹងខ្ទមតូចមានរបៀបរៀបរយហើយស្អាតផង របស់ត្រកូលទាំងពីរនេះនឹងកំឡាំងការងារនៃទាសៈទាំងពីរ ។ លោកមានវាចាថា: គុះគាំងសុទ្ធតែឈើ តែមើលទៅចាំងផ្ទុះមុខ ។

អាប៉ូលពេញចិត្តនឹងការពេះពាយពក់ទាក់នៃលោកចៅហ្វាយ ទើបនិយាយទៀតថា: "ខ្ញុំចង់ធ្វើជាមិត្តភក្តិនឹងលោកពេក ព្រោះលោកជា

មនុស្សសុចរិត" ។ លោកបួរដុណ្ណៃព្រមទទួលសុន្ទរវាចានៃអាប៊ូល ដោយសេចក្ដីរីករាយដ៏ពេញលេញ ។ លោកលូកចាប់ដៃធ្វើឲ្យវាទុកចិត្តថា វាអាចរាប់រកថាលោកជាមិត្តភក្តិវាតាំងពីពេលនេះទៅ ។

បាយរួចហើយ លោកនាំនាងឡាគួរទៅតែឯងស្ងាត់ ហើយប្រាប់ថា ឧកាសក្រោយហ្នឹង កប៉ាល់ជិតចេញហើយត្រូវបញ្ជូនកូនស្រីទៅចាំយើងយកវាទៅផ្ញើនឹងនាងម្នាក់ ត្រូវជាសាច់ញាតិនឹងយើងដែលជិះកប៉ាល់ហ្នឹងដែរ ចូរកុំពេញចិត្តតែនឹងកន្ទេលដែលខ្លួនទើបមកនៅក្នុងវាង ប៉ុន្មានឆ្នាំនេះពេក ត្រូវស្ដាយសម្បត្តិទ្រព្យយ៉ាងធំឯណោះវិញ ។ លោកនិយាយបណ្ដើរដើរបណ្ដើរថា: "ម្ដាយមីងនាងគាត់រស់នៅយូរណាស់ពីរឆ្នាំទៀត ពួកមិត្តសំឡាញ់គាត់បាននិយាយប្រាប់យើង ។ ចូរនាងឯងគិតមើលចុះ ។ សម្បត្តិទ្រព្យមិនមែនហូរមករាល់ថ្ងៃទេ ។ ចូរគិតពិចារណាឲ្យសព្វ ។ បើពួកមនុស្សអ្នកឆ្លាត សុទ្ធតែយល់តាមយើងទាំងអស់" ។ នាងឡាគួរឆ្លើយតបវិញថា: បំណងរបស់នាងក្នុងលោកពីថ្ងៃនេះទៅគ្មានអ្វីធំជាងការចង់ឲ្យតែកូនស្រីរបស់នាង បានសេចក្ដីសុខការសម្រេចទៅប្រទេសបារាំង ស្រេចលើវាចុះ ។

ក្នុងឧកាសដែលអាប៊ូលទីនវីរ៍ស៊ុទី បែកចេញពីគ្នានេះ នាងឡាគួរមិនមែនជាទោមនស្សប៉ុន្មានឡើយ ព្រោះគង់មានថ្ងៃណាមួយនាងនឹងឲ្យសេចក្ដីសុខដល់វាទាំងពីរនាក់ជាមិនខាន ។ នាងហៅកូនមកខ្សឹបប្រាប់

ថា: "កូនអើយ ! កូនឈ្លលយើងទាំងពីរសឹងតែចាស់ជរាអស់ហើយ អាប៉ូលក៏នៅជំទង់ នាងម៉ារគ៏រីត ក៏កាន់តែចាស់ ខ្លួនអញក៏មិនសូវជា ចុះបើអញស្លាប់ទៅ តើធ្វើដូចម្តេច? កូនឯងគ្មានធនធាន នៅកណ្តាលព្រៃ ៗ កូនឯងមិននៅតែឯង គ្មានអ្នកណាជាទីពឹង? ហើយតោងតែធ្វើការកកាយព្រះធរណីដូចអ្នកទាំងពួង ដើម្បីចិញ្ចឹមជីវិតទៅហើយ? ម៉ែតែនឹកដល់រឿងហ្នឹងឡើង ព្រួយអីម៉្លេះទេ" ៗ នាងវីរស៊ុទី ឆ្លើយតបថា: ព្រះជាម្ចាស់បង្កើតយើងមកឲ្យធ្វើការអីចឹង ៗ ម៉ែបង្រៀនកូនឲ្យកូនធ្វើការនឹងឲ្យស្រឡាញ់ព្រះរាល់ថ្ងៃ ៗ ពីនោះមកដល់នេះ ព្រះអង្គមិនលះបង់ចោលយើងឯណា ព្រះថែរក្សាអ្នកក្រីក្រ ៗ ម៉ែមិនគឺធ្លាប់បាននិយាយប្រាប់ខ្ញុំច្រើនដងថា យ៉ាងនេះឬ? មើលទៅខ្ញុំរកគិតចេញពីម៉ែទៅមិនរួចឡើយ" ៗ នាងឡូត្សួរទ្រូងផ្អកៗ និយាយប្រាប់កូនទៀតថា: "ម៉ែគ្មានបំណងអ្វីក្រៅពីចង់ឲ្យចៅបានសេចក្តីសុខស្រួលឡើយ ហើយនឹងបានរៀបការជាមួយអាប៉ូលឲ្យក្នុងថ្ងៃណាមួយ ៗ ចូរកូនរំពឹងមើលចុះ អាប៉ូលគ្មានទេទ្រព្យ ស្រេចនៅលើកូនឯងទាំងអស់" ៗ

នាងវីរស៊ុទី រំភើបដោយសំដីម្តាយល្អពេក ក៏ធ្លាយរឿងប្រាប់ យ៉ាងដូចម្តេចសង្គ្រាមខាងក្នុងរបស់នាងពីមុនមក ហើយចម្បាំងនោះមានតែព្រះជាម្ចាស់មួយទេ ជាសាក្សី នាងក្រមុំឃើញមានតែជំនួយនៃព្រះដែលនៅក្នុងជំនួយនៃម្តាយដែលយល់ស្របតាមបំណងរបស់នាង ហើយគឺម្តាយ

ហ៊ីង ហើយជាអ្នកដឹកនាំនាងដោយវាចាប្រៀនប្រដៅទាំងឡាយ គឺម្ដាយជាទីពំនឹងដូចជាបង្គោល បានជានាងអាចស្ថិតនៅជិតគាត់បាន គ្មានការព្រួយក្នុងបច្ចុប្បន្ន នឹងបារម្ភទៅក្នុងអនាគត ។

នាងឡាត្រូវយល់ថា ការនិយាយស្ងាត់ៗ តែពីរនាក់ឲ្យផលផ្ទុយគ្នានឹងបំណងដែលនាងត្រូវរង់ចាំ ដូច្នេះនាងនិយាយប្រាប់ទៀតថា "ឱកូនស្រីមាសម្ដាយ! ម្ដាយមិនចង់រឹងទទឹងកូនទេ ចូរកូនរំពឹងពិចារណាតាមចិត្តចុះ តែចូរកូនកុំសំដែងសេចក្ដីដំរេកស្នេហាឲ្យអាប៉ូលដឹង ព្រោះថាកាលណាសង្សារបើដឹងចិត្តស្ត្រីក្រមុំជាក់ច្បាស់ហើយ វាមិនចាំបាច់ពិចារណាអ្វីទៀតឡើយ ។

ថ្ងៃល្ងាចត្រជាក់ ពេលដែលនាងនៅតែពីរនាក់នឹងកូន មានមនុស្សម្នាក់វាងដំបង ស្លៀកពាក់ពណ៌ខៀវដើរចូលមកផ្ទះនាង ។ គឺជាលោកសង្ឃមួយអង្គនៅនឹងកោះហ៊ីងដែលនាងឡាត្រូវនឹងវិរស៊ុទ តែងធ្លាប់គោរពប្រណិប័តន៍រៀងៗមក ។ គឺលោកបួរដៃណ្ណបញ្ជូនលោកអង្គនេះមក លោកសង្ឃមានវាចាថា: "ឱកូនទាំងឡាយ! លោកនិយាយបណ្ដើរដើរចូលបណ្ដើរ ចូរនាងទាំងឡាយគោរពព្រះជាម្ចាស់! ឥឡូវឃើញឬទេ នាងឯងនឹងជាអ្នកមានទ្រព្យហើយ ។ នាងឯងត្រូវស្ដាប់បង្គាប់តែចិត្តខ្លួនដែលល្អ ចូរធ្វើទានដល់អ្នកកំសត់ ។ យើងដឹងច្បាស់នូវសំដីដែលលោកបួរដៃណ្ណនិយាយនឹងនាង ហើយនឹងសំដីដែលនាងឆ្លើយមក

លោកវិញ នែនាង! ការប្រព្រឹត្តទៅនៃអត្តភាពរបស់នាង បង្ខំឲ្យនាងស្ថិតនៅក្នុងទីនេះ តែចំណែកនាងក្រមុំឯណោះ ព្រះមិនអត់ទោសឲ្យឡើយ ។ ត្រូវតែស្ដាប់បង្គាប់ព្រះជាម្ចាស់ នឹងបងប្អូនចាស់ៗ ទោះបីគាត់មិនសុខចិត្តក៏ដោយចុះ ។ រឿងហ្នឹងជាការព្រាត់ប្រាសក៏ពិតមែន តែគឺជាពាក្យបង្គាប់របស់ព្រះអង្គ ។ ស៊ូប្ដូរអាយុដើម្បីអ្នកទាំងឡាយ អ្នកទាំងឡាយតោងធ្វើតាមដំរាប់ព្រះអង្គ ត្រូវស៊ូបូជាជីវិតដើម្បីសង្គ្រោះសម្បត្តិទ្រព្យនៃត្រកូលរបស់ខ្លួន ។ ដំណើរទៅប្រទេសបារាំងនៃនាងនឹងមានលទ្ធផលខាងចុងដ៏សប្បាយ នែនាងក្រមុំ! ហេតុអីក៏មិនបង់ទៅនាង?" ។

នាងវីរស៊ីទី ដាក់មុខចុះ ឆ្លើយតបទៅលោកអង្គនោះវិញទាំងញ័រ ហើយយំផងថា: "បើជាសេចក្ដីបង្គាប់នៃព្រះជាម្ចាស់ ខ្ញុំមិនហ៊ានយល់ទាស់ទេ សូមបំណាងរបស់ព្រះអង្គសម្រេចចុះ" ។

លោកសង្ឃអង្គនេះ កាលណាចេញផុតពីខ្ទមនាងឡាតួរហើយ ក៏និមន្តទៅជំរាបលោកបួរដុណ្ណៃ អំពីកិច្ចដែលលោកឲ្យទៅ ឥឡូវសម្រេចហើយ ។ នាងឡាតួរ ប្រើខ្ញុំម៉ាំង ឲ្យហៅខ្ញុំ (តាចាស់) មកឯខ្ទមនាង នឹងសាកសួរពីធ្វើដំណើរចេញទៅនៃនាងក្រមុំវីរស៊ីទី ។ ខ្ញុំមិនព្រមយល់តាម បណ្ដោយឲ្យនាងវីរស៊ីទីចេញទៅឡើយ ។ ខ្ញុំទាញសុភាសិតខ្លះ ដែលថ្លែងពីសេចក្ដីសុខ យកមកតពន្យល់: យើងត្រូវតែចូលចិត្ត នឹងសុខ

ដែលកើតឡើងអំពីធម្មជាតិ ជាងសុខកើតពីធនធាន ហើយយើងមិនត្រូវស្វះស្វែងរកសុខនោះពីទីកន្លែងយើង ក្រៅពីរបស់ដែលយើងអាចរកបាននៅផ្ទះយើង ។ ខ្ញុំលើកយកសុភាសិតមកពន្យល់ប្រាប់គ្នាចន្លោះត្រង់កន្លែងណា ។ តែពាក្យដំបូន្មានរបស់ខ្ញុំធ្វើម៉េចនឹងឈ្នះ លោភចិត្តចំពោះទ្រព្យសម្បត្តិដ៏ធំ ការយល់របស់ខ្ញុំធ្វើម៉េចឈ្នះការយល់ដែលគេគិតទុករួចស្រេចហើយ ។ គឺជាច្បាប់សម្រាប់គោរពនាងឡាត្លូវផង ។ នាងនេះហៅខ្ញុំមកពិគ្រោះ ដើម្បីយកសេចក្តីគួរសមទេតើ! រឿងនេះគេសម្រេចតាំងពីលោកសង្ឃមួយអង្គនិមន្តមកឯណោះ ។ នាងម៉ារីតែនឹកក្នុងចិត្តថា មិនចង់ឲ្យវីស៊ីទីចេញទៅដែរ ចីដ្បិតជាប្រយោជន៍ដល់អាប៉ូលផង តែគង់មិនហ៊ានឃាត់គេ ។ ចំណែកអាប៉ូលដែលមិនដឹងការណ៍ដែលគេសម្រេចរួចហើយ ចេះតែឆ្ងល់នឹងម្តាយហើយកូនគេលួចខ្សឹបគ្នាដោយស្ងាត់ៗ វាក៏ស្រងូតស្រងាត់តែម្នាក់ឯង ។ វានិយាយថា: "មើលទៅប្រហែលគេគិតធ្វើអ្វីដ៏អាក្រក់ដល់អញហើយ បានជាគេចេះតែលាក់នឹងអញ" ។

ក្នុងពេលនោះ គេឮស្នូរល្បីល្បាញថាអ្នកដើងក្នុំ ឥឡូវមានទ្រព្យសម្បើមណាស់ គេឃើញឈ្មួញគ្រប់បែបនាំរបស់ទៅលក់នៅទីនោះ គេឃើញឈ្មួញលាតសំពត់គ្រប់បែបបង្ហាញ: មានព្រែពីស្រុកក្វិង សាំងហាយ ប៉េកាំង ណាងកាំង សំពត់សារូ ផាប៉ាន់ ផាមួង សំពត់ហូលផ្សេងៗ គ្រប់ពីប្រទេសដទៃទៀត ។ (មានត)

# ពិធីបុណ្យព្រះសារីរិកធាតុ

និង

# ព្រះអរហន្តធាតុនៃព្រះសារីបុត្តនិងព្រះមោគ្គល្លាន

---

ប្រជាជននៅកម្ពុជរដ្ឋ បានស្គាល់នូវពិធីបុណ្យមួយដ៏ឧឡារិកធំអស្ចារ្យជាបុណ្យដែលពុំធ្លាប់មានពីមុនៗ មកសោះ គឺពិធីបុណ្យដែលស្ថិតនៅក្នុងព្រះរាជធានីភ្នំពេញ ចំនួន ១ សប្តាហៈ គឺពីថ្ងៃអាទិត្យទី ៥ តុលាដល់ថ្ងៃសៅរ៍ទី ១១ តុលា ឆ្នាំ ១៩៥២ ។ ពិធីបុណ្យនោះ មានរបៀបដូចពោលតទៅនេះ :

ទី ១ កាលពីថ្ងៃអាទិត្យ ២ កើតខែអស្សុជ ឆ្នាំរោងចត្វាស័ក ព.ស. ២៤៩៥ ត្រូវនឹងថ្ងៃទី ៥ ខែតុលា គ.ស. ១៩៥២ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រមទាំងព្រះរាជវង្សានុវង្ស និងទីប្រឹក្សាឯកជនអមព្រះអង្គ, សម្តេចព្រះសង្ឃនាយកទាំង ២ គណៈ, សម្តេចឧត្តមប្រឹក្សា, សមាជិករដ្ឋាភិបាល, សមាជិករដ្ឋសភា, សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រ, លោកកុម្ម៉ៃស្សែរនិងលោកឧត្តមសេនី ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីគ្រប់ដំណែង បានស្តេចយាងអញ្ជើញទៅស្ថានីយ៍អាកាសយានពោធិចិនតុង ដែលវិចិត្រដោយទង់ជាតិនិងទង់សាសនា ដើម្បីនឹងទាំទទួលព្រះបរមសារីរិកធាតុនិងព្រះអរហន្តធាតុ ។ ចំណែក

ប្រជាជនទាំងគ្រហស្ថទាំងបព្វជិត ក្នុងក្រុងនិងខេត្តក្រៅ ក៏បានទៅជួបជុំកកកុញនៅពោធិចិនតុងដើម្បីដង្ហែព្រះសារីរិកធាតុនិងព្រះអរហន្តធាតុ ។ មានរថយន្តក្នុងក្រុងនិងមកពីខេត្តផ្សេងៗ ជាងពីរពាន់ ដែលប្រជាប់ដោយភ្លើងយ៉ាងក្រៃលែង បានទៅប្រច្រៀតគ្នា រង់ចាំសំដែងគារវកិច្ចតាំងពីម៉ោង ១ រសៀល ។

លុះដល់ម៉ោង ១៦ និង ៤៩ នាទី អាកាសយានដែលដង្ហែព្រះសារីរិកធាតុនិងព្រះអរហន្តធាតុ បានមកដល់ ហើយបានប្រទក្សិណាទីក្រុង ៣ ជុំ មុននឹងចុះមកកាន់ប្រថពី ។

ក្នុងពេលនោះ គេសង្កេតឃើញគណៈប្រតិភូ ដែលដង្ហែព្រះបរមធាតុមក ខាងផ្នែកឥណ្ឌា មាន ៩ រូបគឺ លោកដុកទ័រស្យាមៈប្រាសាទ ម៉ូកែរ្ជី (Syama Prasad moskerjè) ប្រធានមហាពោធិសមាគម, អតីតរដ្ឋមន្ត្រីនៃប្រទេសឥណ្ឌា ព្រះភិក្ខុ ន. ជិតរតនៈ (នាមដើម បៃល-ឡុង) ជាអតីតចៅហ្វាយស្រុកនៃប្រទេសកម្ពុជា ហើយបួសនៅប្រទេសឥណ្ឌា ជាយូរឆ្នាំហើយ. ព្រះភិក្ខុ ម. សង្ឃរតនៈ, សាមណេរ គ. សរណង្ករ, សាមណេរ សុលភទេវ, ដុកទ័រឌុត្តៈ, នាងកញ្ញា ម. ជុណ្ណារ, នាងកញ្ញា មុនថារ៉ូ នាងកញ្ញា សាស្ត្រី ។

ឯគណៈប្រតិភូថៃ ដែលបានឡើងយន្តហោះដង្ហែពីក្រុងបាងកកមក តាមសេចក្ដីអញ្ជើញនៃប្រទេសកម្ពុជា មានទាំងអស់ ៨ រូបគឺ